ទស្សនាវដ្ដីរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា

# ស្វែងរក ការពិត



- [illegible]
- [illegible]

# ស្វែងរកការពិត

ទស្សនាវដ្ដីនៃមជ្ឈមណ្ឌលឯកសារកម្ពុជា

លេខ៣៤ ខែតុលា ឆ្នាំ២០០២


## មាតិកា


◆ សំបុត្រៈ កំណត់ហេតុអង្គការលើ ........................................១

**ផ្នែកឯកសារ**

◆ អ្នកទុកឯកសារនៅស-២១ ក្លាយជាអ្នកទោស .......................២

◆ ដំណើរឆ្លងកាត់តំបន់ខ្មែរក្រហម ..........................................៥

◆ ការអប់រំកសាងកូនចៅរបស់បដិវត្តខ្មែរក្រហម .........................៩

◆ បញ្ជីឈ្មោះជនរងគ្រោះបរទេស ........................................១៥

◆ វណ្ណៈសង្គមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ .......................១៦

◆ បញ្ជីឈ្មោះជនរងគ្រោះដែលបានកម្ទេចនៅមន្ទីរស-២១ ........២០

**ផ្នែកប្រវត្តិសាស្ត្រនិងការស្រាវជ្រាវ**

◆ មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ ..................................២១

◆ នារីពេទ្យបដិវត្តស្រុកត្រាំកក់ ............................................២៩

◆ ការចាប់និងសម្លាប់អ្នកទោសជាខ្មែរសង្កាក់នៅមន្ទីរស-២១ .....៣៤

**ផ្នែកច្បាប់**

◆ករណីយកិច្ចក្នុងការចោទប្រកាន់អំពើរំលោភសិទ្ធិមនុស្ស ..........៣៧

◆គំរូអន្តរជាតិសម្រាប់ដាក់ឲ្យបុគ្គលរំលោភសិទ្ធិមនុស្ស ...............៣៩

**វេទិកាពិភាក្សាសាធារណៈ**

◆ បទសម្ភាសន៍ជាមួយសម្ដេចព្រះសុគន្ធាធិបតី បួរ គ្រី .............៤៥

◆ ឱកាសរកយុត្តិធម៌នៃឧក្រិដ្ឋកម្មខ្មែរក្រហមមិនពិបាកទេ ...........៥០

◆ សុន្ទរកថារបស់ឯកឧត្តម សុខ អាន ..................................៥៦

**ទំព័រស្រាវជ្រាវរកគ្រួសារ**

◆ ព្រាត់បងប្អូនម្ដៃប្រាំបីឆ្នាំហើយ ..........................................៥៩





## រក្សាសិទ្ធិ

មជ្ឈមណ្ឌលឯកសារកម្ពុជា



អនុញ្ញាតឲ្យបោះពុម្ពផ្សាយដោយ
ក្រសួងព័ត៌មាននៃរាជរដ្ឋាភិបាលកម្ពុជា
ប្រកាសទេសរដ្ឋមន្ត្រី និងរដ្ឋមន្ត្រីក្រសួងព័ត៌មាន
លេខ ០២៩១ពម.៩៩
ចុះថ្ងៃទី២ ខែសីហា ឆ្នាំ១៩៩៩

រូបថតឯកសារៈ មជ្ឈមណ្ឌលឯកសារកម្ពុជា
និងសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង



***ស្នេរលេខនេះ:*** *យិន នាន, លឿង អ៊ីង, អែម សុខឃីម, ហ៊ុយ វណ្ណៈ, អេលីហ្សាប៊ែត វ៉ាន់ស្កាក់, ប្រេង អាដាម, សុខ អាន, ជាំ សុផា* ***អ្នកនិពន្ធនិងស្រាវជ្រាវ:*** *លី សុផល, ដួង សុភារិទ្ធ* ***ជំនួយការនិពន្ធនាយក:*** *សាន់ កល្យាណ* ***និពន្ធនាយករងទី១:*** *សួ ប៊ុនស៊ូ* ***និពន្ធនាយករងទី២:*** *សឹម សុរិយ៉ា* ***អ្នកបកប្រែ:*** *អេង កុកថាយ* ***និពន្ធនាយកទូទៅ:*** *ឆាំង យុ* ***ក្រាហ្វិកកុំព្យូទ័រ:*** *ស៊ឹម សុភ័ក្ត្រ* ***គ្រប់គ្រងការចែកផ្សាយ:*** *សុខ វណ្ណៈ*

*សំបុត្រ៖*

# កំណត់ហេតុអគ្គការលើ

អៀង សារី បានធ្វើឲ្យសាធារណជនដឹងថាខ្លួនកំពុងសរសេរកំណត់ហេតុជីវិតនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ទាក់ទងនឹងអ្វីដែលខ្លួនគិតថាជាការពិតសម្រាប់ប្រវត្តិសាស្ត្រកម្ពុជា ។ អៀង សារី បានឲ្យដឹងទៀតថា លេខារបស់ខ្លួនគឺជាអ្នកសរសេរកំណត់ហេតុនេះ ។

នេះគឺមិនខុសពី ខៀវ សំផន ប៉ុន្មានទេ ។ ថ្មីៗនេះ អតីតកម្មាភិបាលជាន់ខ្ពស់នៃរបបកម្ពុជាប្រជាធិបតេយ្យម្នាក់ បានបញ្ចប់ការសរសេរកំណត់ហេតុរបស់ ខៀវ សំផន ។ កំណត់ហេតុនេះត្រូវបានសរសេរឡើងជាភាសាបារាំងដែលមានចំណងជើងថា “Khieu Samphan: Agrandi et réel.” ។ ក្រោយពីបញ្ចប់សំណេរនេះភ្លាម ខៀវ សំផន បានព្យាយាមរកការគាំទ្រពីសំណាក់ប្រវត្តិវិទូជាតិនិងអន្តរជាតិ ដើម្បីបោះពុម្ពផ្សាយ ។ ប្រវត្តិវិទូមួយក្រុមមកពីអឺរ៉ុបនិងសហរដ្ឋអាមេរិក បានវាយតម្លៃថា កំណត់ហេតុរបស់ ខៀវ សំផន នេះគឺជាការឃោសនារបស់ខ្មែរក្រហមពិតៗ ។

ការចងចាំខ្លះៗនៅក្នុងកំណត់ហេតុរបស់ ខៀវ សំផន រួមមាន៖

“នៅឆ្នាំ១៩៦៥ បន្ទាប់ពីមានព្រឹត្តិការណ៍នៅប្រទេសឥណ្ឌូនេស៊ី (ការកម្ចាត់ប្រធានាធិបតី ស៊ូកាណូ) ខ្ញុំ (ហ៊ូ នឹម) បានទទួលការបង្គាប់បញ្ជាពី ខៀវ សំផន ដើម្បីបញ្ចុះបញ្ចូល លោក សឺន សាន និងតាមរយៈគាត់ បញ្ចុះបញ្ចូលសម្តេច សីហនុ ថា «គ្រោះថ្នាក់គឺចេញមកពីក្រុមនិយមស្តាំដូចនៅឥណ្ឌូនេស៊ីអ៊ីចឹង» ។

ការចងចាំមួយទៀតរបស់ ខៀវ សំផន គឺ នួន ជា បាននិយាយថា៖

“ពិតហើយ អ្វីៗទាំងអស់ដែល ខៀវ សំផន ធ្វើ ពុំមែនជាគំនិតផ្តួចផ្តើមរបស់គាត់ទេ គឺគាត់ធ្វើទៅតាមបង្គាប់បញ្ជារបស់បក្ស និងដោយមានការជួយពីបក្សផង ដែលគាត់តែងតែមានចិត្តស្មោះត្រង់ សុចរិត និងភក្តីចំពោះបក្សជានិច្ច ។ ...បក្សជាអ្នកចង្អុលបង្ហាញគាត់ពីមាគ៌ាធំៗ ។ គាត់បានពង្រីកនិងផ្សព្វផ្សាយមាគ៌ាទាំងនេះក្នុងកាសែតរបស់គាត់និងក្នុងរដ្ឋសភា ហើយបានធ្វើឲ្យទៅដល់ហ្វូងមហាជនទៀត ។ ទន្ទឹមនឹងនោះ បក្សបានដកស្រង់សម្តីទាំងនោះមកបោះពុម្ពក្នុងសៀវភៅផ្សេងៗ និងផ្សព្វផ្សាយក្នុងចំណោមហ្វូងមហាជន នូវទស្សនៈរបស់គាត់ ដែលតាមអ្នកទាំងនោះយល់ គាត់គឺជាតំណាងអង្គការជាន់ខ្ពស់របស់ជាតិ ។ គឺហេតុដូច្នេះហើយ បានជាធ្វើឲ្យគេស្គាល់ចលនាមាគ៌ាដឹកនាំទាំងអស់របស់បក្សជ្រួតជ្រាបទៅដល់ប្រជាជនទូទាំងប្រទេស ហើយក្លាយទៅជាជាក់ស្តែងដោយការធ្វើសកម្មភាពផ្សេងៗ ។»

អៀង សារី និង ខៀវ សំផន កំពុងប្រើប្រាស់ការកត់ត្រាការចងចាំដោយជម្រើសនេះដើម្បីបន្តកំញើញដល់ការស្វែងរកយុត្តិធម៌ជូនដល់ជនរងគ្រោះរាប់លាននាក់ដែលស្លាប់នៅក្រោមការគ្រប់គ្រងដឹកនាំរបស់ខ្លួន ។ មកទល់នឹងពេលនេះ មិនទាន់មាននរណាម្នាក់រអើលនឹងកំណត់ហេតុរបៀបនេះទេ ។ ប្រជាជនកម្ពុជាទូទាំងប្រទេសដែលយ៉ាងហោចណាស់ក៏មានសមាជិកម្នាក់បានទទួលរងទារុណកម្មឬយកទៅសម្លាប់ចោលនោះ ស្គាល់ច្បាស់ណាស់ពីរបបវាលពិឃាតនេះ ។ កំណត់ហេតុរបស់ អៀង សារី និង ខៀវ សំផន មិនខុសពីកំណត់ហេតុរបស់អង្គការលើនៅក្នុងរបបខ្មែរក្រហមនោះឡើយ ។

**ឆាំង យុ**

# អ្នកទុកឯកសារនៅស-២១ ក្លាយជាអ្នកទោស


ពុយ តៃនី ហៅ នឿន

ពុយ តៃនី ជាអតីតគ្រូបង្រៀនម្នាក់នៅក្នុងសង្គមរាស្ត្រនិយម ។ ក្នុងរបបកម្ពុជាប្រជាធិបតេយ្យ តៃនី បានមកបម្រើការនៅក្នុងមន្ទីរស-២១ ក្នុងតួនាទីជាអ្នកទុកឯកសារ ។ គ្រាន់តែមួយរយៈពេលខ្លីប៉ុណ្ណោះ តៃនី បានក្លាយខ្លួនទៅជាអ្នកទោសរបស់មន្ទីរស-២១វិញ ។ តៃនី ត្រូវប្រធានគុក (ឌុច) ចាប់ខ្លួន ហើយក្រុមអ្នកធ្វើការជាមួយនៅក្នុងមន្ទីរ-២១ សួរចម្លើយពីបទជាប់ពាក់ព័ន្ធនឹង“សេ.អ៊ី.អា” ។ តៃនី ត្រូវបានសួរចម្លើយចំនួនបីលើកមុនពេលយកទៅសម្លាប់ ។

## ប្រវត្តិរូប

ពុយ តៃនី ហៅ នឿន ជនជាតិខ្មែរ ស្រុកកំណើតនៅជ្រោយតាកែវ ស្រុកកោះធំ ខេត្តកណ្តាល ។ ឪពុកឈ្មោះ ពុយ ផួនជី ម្តាយឈ្មោះ ហេង ញាន ។ ប្រពន្ធឈ្មោះ អេង គោយីង ហៅ គោ ។ តៃនី មានកូនប្រុស៤នាក់ និងកូនស្រីម្នាក់ ។ កូនទី១ ឈ្មោះ ពុយ រំពៃ កូនទី២ ពុយ រំពឹង កូនទី៣ ពុយ រំភឿន កូនទី៤ ពុយ រំពង់ និងកូនស្រីពៅឈ្មោះ ពុយ រំពូន ។ តៃនី ត្រូវបានឃាត់ខ្លួននៅថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧៧ ។

## ប្រវត្តិការងារនិងសកម្មភាព

តៃនី បានទទួលការអប់រំនៅអនុវិទ្យាល័យកោះធំ ស្រុក១៨ តំបន់២៥ និងបានទទួលសញ្ញាប័ត្របាក់ឌុបនៅឆ្នាំ១៩៦៥ នៅវិទ្យាល័យភ្នំដូនពេញ ។

នៅឆ្នាំ១៩៦៥-៦៦ តៃនី មកសិក្សានៅមហាវិទ្យាល័យគរុកោសល្យភ្នំពេញ ។ នៅក្នុងអំឡុងពេលសិក្សា តៃនី បានរាប់អាននិងទទួលឥទ្ធិពលនយោបាយខ្លះៗពី អ៊ុល ចន្ទ ហៅ ចុន ។

ក្រោយពីបញ្ចប់ការសិក្សានៅមហាវិទ្យាល័យគរុកោសល្យ តៃនី បានទៅបង្រៀននៅអនុវិទ្យាល័យចំបក់ ស្រុកបាទី ខេត្តតាកែវ ។ តៃនី បង្រៀនបណ្តើរ ឃោសនាពីនយោបាយដល់សិស្សបណ្តើរ ។

ឆ្នាំ១៩៦៨ តៃនី បានមកភ្នំពេញដើម្បីបន្តការសិក្សានៅសាលាគរុវិជ្ជាជាន់ខ្ពស់នៃមហាវិទ្យាល័យអក្សរសាស្ត្រ ដោយស្នាក់នៅផ្ទះឪពុកមាឈ្មោះ ម៉េងគ្រី ។ តៃនី បានទទួលការស្រលាញ់រាប់អានពី គ្រូយ៉ា ដែលជាមិត្តចាស់របស់ឪពុកខ្លួននិងជាគ្រូបង្រៀនគម្ពីរសាសនានៅតាខ្មៅ ។ ជារឿយៗ គ្រូយ៉ា នាំ តៃនី ចូលរួមក្នុងពិធីសង្គមជាមួយអ្នកកាន់សាសនាគ្រិស្តសញ្ជាតិអាមេរិកាំង ។ នៅឆ្នាំដដែលនេះ តៃនី បានរៀបការជាមួយនារីម្នាក់ឈ្មោះ អេង គោយីង (ឆ្នាំ១៩៧៤ ជាយុទ្ធនារីជាំស្លនៅរោងចក្រអគ្គិសនីទី២) ។

ដោយការសិក្សាមមាញឹកពេក តៃនី ពុំសូវមានពេលវេលាជួបលោកគ្រូយ៉ាទេ ។ ពេលបញ្ចប់ការសិក្សានៅសាលាគរុវិជ្ជាជាន់ខ្ពស់ តៃនី ត្រូវបានតម្រូវឲ្យទៅបម្រើការងារនៅវិទ្យាល័យព្រះអង្គឌួងក្នុងខេត្តព្រៃវែង ។ នៅខេត្តព្រៃវែង តៃនី បានស្គាល់លោកគ្រូម្នាក់ឈ្មោះ ហាក់ ស៊ុនឡាយ ហៅ ផុស ជាសាស្ត្រាចារ្យដែលមាននិន្នាការនយោបាយចម្រើននិយម ហើយចូលចិត្តអានសៀវភៅនិងទស្សនាវដ្តីចិនប្រជាមានិត ។ ក្រោយមក ការរាប់អានរបស់អ្នកទាំងពីរត្រូវបានកាត់ផ្តាច់ ។

ក្រោយរដ្ឋប្រហារបាន៣ខែ តៃនី, ហាក់ ស៊ុនឡាយ និងគ្រូយ៉ា ក៏បានជួបគ្នាវិញ ។ គ្រូយ៉ា បានណែនាំ តៃនី ជួបនឹងស្ត្រីអាមេរិកាំងម្នាក់នៅសាលាគម្ពីរតាខ្មៅ ដើម្បីស្ទាបស្ទង់មតិតៃនី ។ នៅខែកញ្ញា ឆ្នាំ១៩៧០ តៃនី សម្រេចចិត្តចូលជាសមាជិកសេ.អ៊ី.អា តាមការបញ្ចុះបញ្ចូលរបស់ គ្រូយ៉ា ។ តៃនី បានទទួលប្រាក់ខែ១៥០០រៀលក្នុងមួយខែពីស្ត្រីអាមេរិកាំងម្នាក់នោះ ដោយទទួលភារកិច្ចដើរស៊ើបរកពត៌មាននិងរកខ្សែបណ្តាញខ្មែរយៀកកុងនៅភ្នំពេញ ។

ពីមួយខែទៅមួយខែ តែនី បានចំណាយពេលវេលាក្រៅពីម៉ោងបង្រៀន យករបស់របរខ្លះៗទៅលក់នៅតំបន់រំដោះតាមផ្លូវជាតិលេខ១ លេខ៣ និងលេខ៤ ដើម្បីស៊ើបរកពត៌មានៗ ក្នុងការងារនេះ តែនី បានទាក់ទងអ្នកជួញការម្នាក់ឈ្មោះ ព្រំ សន្ធ ហៅ ជឹម ធ្វើការនៅក្រសួងឃោសនាការ ។

តែនី ដឹកនាំកម្លាំងចំនួន៦នាក់ធ្វើសកម្មភាពរហូតដល់ឆ្នាំ១៩៧៣ ។ ដោយសារតែគិញតាមរកចាប់ពេក តែនី ក៏ភៀសខ្លួនទៅទីជនបទរយៈពេល២ខែ ។ ដូច្នេះ តែនី ត្រូវប្រគល់កម្លាំងដែលខ្លួនបានគ្រប់គ្រងមួយផ្នែកទៅឲ្យ មិត្តហង់ និងមួយផ្នែកទៀតទៅឲ្យគ្រូយ៉ា ។

នៅឯជនបទ តែនី បានលត់ដំខ្លួនបំពេញការងារពលកម្មផ្សេងៗតាមអង្គការចាត់តាំង ដើម្បីឲ្យអង្គការបញ្ជូនខ្លួនមកភ្នំពេញវិញ ។ ២ខែក្រោយមក ទីក្រុងនិងជនបទត្រូវដាច់ទំនាក់ទំនង តែនី ក៏ត្រូវខកខានក្នុងការត្រឡប់មកភ្នំពេញ ។ នៅខែមិថុនា ឆ្នាំ១៩៧៤ អង្គការក៏បានបញ្ជូនគ្រួសាររបស់ តែនី មកជនបទ ។ តែនី បានរៀបរាប់អំពីជីវភាពនៅឯជនបទថា ការរស់នៅរបស់ខ្លួនមានការលំបាកណាស់ ខ្លួនគាត់ត្រូវស្ថិតនៅក្នុងតំនាបពីរ ម្ខាងជាសេ.អ៊ី.អា និងម្ខាងទៀតជាបដិវត្តន៍ ។ តែនី លាក់ខ្លួននៅក្នុងសេ.អ៊ី.អាផងនិងបដិវត្តផង ប៉ុន្តែការងារសំខាន់សម្រាប់ តែនី គឺរារាំងដំណើរការវាយចូលទីក្រុងរបស់អង្គការបដិវត្តន៍ ។ រាល់សកម្មភាពដែល តែនី បានធ្វើ គឺសុទ្ធតែបានរាយការណ៍ឲ្យ គ្រូយ៉ា ដឹងទាំងអស់ ។ នៅថ្ងៃទី ៧-៨ ខែមេសា គ្រូយ៉ា បានប្រាប់ តែនី ឲ្យដឹងថា ពួកអាមេរិកាំងនឹងត្រូវត្រឡប់ទៅប្រទេសវិញប្រសិនបើខាងលន់ណុលចាញ់ ប៉ុន្តែកិច្ចការសេ.អ៊ី.អា នៅតែបន្តធ្វើរហូតដល់ឱកាសមួយហុចឲ្យ ពួកអាមេរិកាំងនឹងត្រឡប់មកវិញ ។

បន្ទាប់ពីប្រទេសកម្ពុជាត្រូវរំដោះ ទំនាក់ទំនងរវាង គ្រូយ៉ា និង តែនី ត្រូវបានកាត់ផ្តាច់ ដោយហេតុថា គ្រូយ៉ា ត្រូវអង្គការជម្លៀសចេញឲ្យទៅរស់នៅកន្លែងផ្សេង ។ ពេលនោះ តែនី មានបំណងចង់ផ្លាស់ប្តូរជីវភាពរស់នៅរបស់ខ្លួន ឈប់ពាក់ព័ន្ធនឹងរឿងសេ.អ៊ី.អា ហើយងាកមកបម្រើការងារឲ្យបដិវត្តន៍ ធ្វើជាសមាជិកសហករណ៍នៅតាមជនបទវិញ ។ ប៉ុន្តែនៅខែវិច្ឆិកាឆ្នាំ១៩៧៥ តែនី បានបណ្តោយខ្លួនឲ្យ សុក អូសទាញបានម្តងទៀត ។ ការដែល សុក ចូលធ្វើជាសេ.អ៊ី.អាគឺដោយសារខឹងមិនបានឡើងបុណ្យស័ក្តិដូចគេ ។ ប្រាំថ្ងៃក្រោយមក តែនី ត្រូវបាន សុក នាំធ្វើពិធីសច្ចាប្រណិធានចូលជា សេ.អ៊ី.អា ។ លក្ខខណ្ឌនៃការចូលជាសេ.អ៊ី.អា គឺ ទី១) ស្មោះត្រង់នឹងអង្គការសេ.អ៊ី.អាជានិច្ច ទី២) គោរពតាមបទបញ្ជាអង្គការសេ.អ៊ី.អាគ្រប់កាលៈទេសៈ និង ទី៣) លាក់ការណ៍ដាច់ខាតអំពីអង្គការសេ.អ៊ី.អា ទោះគ្រាលំបាកយ៉ាងណាក៏ដោយ ។

នៅពេលដឹងថា តែនី ត្រូវផ្លាស់ទៅធ្វើការនៅមន្ទីរស-២១ សុក បានឲ្យ តែនី ទៅសហការជាមួយខ្សែរបស់ខ្លួនឈ្មោះ រិន ដែលកំពុងធ្វើការនៅមន្ទីរស-២១ដែរ ហើយថែមទាំងប្រាប់ តែនី ឲ្យខិតខំប្រមូលប្រជាជនមហាជនឲ្យបានច្រើនដើម្បីប្រកួតប្រជែងយកតំណែងតាំងពីថ្នាក់ក្រោមរហូតដល់លើ ។

នៅខែមីនា ឆ្នាំ១៩៧៦ តែនី, រិន និង សែង បានចាប់ផ្តើមពិភាក្សាការងារដែលត្រូវធ្វើ ។ ដំបូងរិះគន់ឥទ្ធិពលរបស់ ឌុច លើចំណុចអត្តនោម័តិក្នុងពេលបំពេញការងារ ដូចជាមកឃើតយ៉ាវ ប្រើប្រាស់ពាក្យមិនសមរម្យ ។ ឌុច មិនដែលឲ្យ តែនី, រិន និង សែង ដឹងពីកិច្ចការផ្ទៃក្នុងច្រើនទេ ចាំតែដាក់បញ្ជាឲ្យធ្វើប៉ុណ្ណោះ ។ ហេតុនេះហើយបានជា តែនី, រិន និង សែង ប្រជុំគ្នាលើកឡើងពីបញ្ហាកសាង ឌុច គឺ សុំឲ្យ ឌុច មានប្រជាធិបតេយ្យឲ្យខ្លួនបានដឹងកិច្ចការជាមុនផង ដើម្បីឈានទៅសម្រេចភារកិច្ច ។ សែង បានប្រាប់ តែនី ថា មុនពេល ឌុច មកគ្រប់គ្រងមន្ទីរសួរចម្លើយ ឌុច គឺជាខ្សែរបស់ សុក នៅតំបន់២៥ ។ ឌុច ស្ថិតនៅក្រោមការគ្រប់គ្រងរបស់ រិន ប៉ុន្តែក្រោយពេល ឌុច បានមកគ្រប់គ្រងមន្ទីរសួរចម្លើយ ឌុច ក៏ក្លាយជាអ្នកដឹកនាំ រិន វិញម្តង ។ ចំណែក ហ៊ា ជាខ្សែរបស់វៀតណាម ។

ខែឧសភា ឆ្នាំ១៩៧៦ តែនី, រិន និង សែង បានអង្គុយជជែកគ្នានៅមុខផ្ទះសួរចម្លើយ(ខាងកើតគុក) ។ រិន បាននិយាយថា "ឌុច នឹងឲ្យ តែនី ទៅធ្វើការជាមួយ ។ ដល់ពេលនោះ តែនី នឹងត្រូវផ្តាច់ចេញពីមហាជន មិនអាចធ្វើសកម្មភាពអ្វីឡើយ" ។ ក្រោយពេលស្តាប់ហើយ សែង និង តែនី បានរិះរកវិធីឲ្យ រិន បានដឹកនាំក្រុមពិសោធន៍ក្រុមសរុបឯកសារ ។ ក្នុងពេលប្រជុំ

ជីវភាពសាខា អ្នកទាំងបីបាន លើកយកបញ្ហាទាំងអស់នេះ សុំឲ្យ រិន បានដឹកនាំការសួរចម្លើយ ដើម្បីក្តាប់ចម្លើយអ្នកទោសជាខ្សែសង្វាក់ និងកែលម្អការសួរអ្នកទោស ប៉ុន្តែការទាមទារនេះត្រូវបរាជ័យ ។ រិន និង សែង ត្រូវអង្គការដកចេញពីមន្ទីរ ស-២១ ។ មុនពេលចាកចេញ រិន បានផ្តែផ្តាំ តែនី ឲ្យធ្វើតាមផែនការដោយប្រុងប្រយ័ត្ន កុំឲ្យធ្លោយមាត់ ក្រែងមានរឿង ។ រិន ក៏បាត់ខ្លួនតាំងពីពេលនោះមក ។

ខែធ្នូ ឆ្នាំ១៩៧៦ សុក បានចាត់តាំង តែនី, វុត, វៀង និង សែត ធ្វើសកម្មភាពតាមផែនការជាយុទ្ធសាស្ត្រយូរអង្វែង ។ ផែនការសំខាន់ៗគឺ "ប្រជែងយកតំណែងនាទីដឹកនាំ ក្តាប់មន្ទីរក្រសួងបុអង្គភាពដែលបានទៅធ្វើការ តាមយុទ្ធវិធីស្ងៀមស្ងាត់" ។ យុទ្ធវិធីមាន៥យ៉ាងគឺ ១) ប្រយុទ្ធបំពេញភារកិច្ចជាគំរូដល់មហាជន ២) សាមគ្គីភាពជាមួយថ្នាក់ដឹកនាំចាស់ឲ្យបានជារូបភាពតែមុខទំនាស់នៅដដែល (សម្ងាត់) ៣) ធ្វើការផាររមហាជនឲ្យបានល្អ ដើម្បីប្រមូលប្រជាជនឲ្យកាន់តែកុះករនៅជុំវិញយើង ធ្វើឲ្យមានឥទ្ធិពលគ្របដណ្តប់ទៅលើប្រជាជន ៤) បំផុសប្រជាជនឲ្យគាំទ្រឥទ្ធិពលយើង វាយបន្ទាបថ្នាក់ដឹកនាំចាស់ និង ៥) ពង្រីកកម្លាំងសេ.អ៊ី.អាដោយគ្មានបន្ធូ ដើម្បីចៀសវាងប៉ះពាល់លើសមាសភាពមិនល្អបណ្តាលឲ្យបែកការណ៍" ។

ក្រោយមក តែនី បានរាយការណ៍អំពីសភាពការណ៍ប្រាប់ សុក ថា "ពួកសេ.អ៊ី.អា ដែលមកពីប្រទេសអាមេរិក បារាំង កាណាដា (ជនជាតិខ្មែរ) គ្មាននរណាម្នាក់រួចខ្លួនទេ មកដល់ជាប់គ្មានសល់ អង្គការវាយបោលខ្ទេច" ។ "ពួកនេះមានគោលបំណងធំណាស់ ផែនការខ្លះវាយកម្ពុជាពីឆ្នាំ(១៩)៧៧-(១៩)៨០ ពីឆ្នាំ(១៩)៨០-៨៥ ហើយពួកខ្លះជាសម្ព័ន្ធសេ.អា.តូ មានចិន តៃវ៉ាន់ កូរ៉េខាងត្បូង ថៃ ហ្វីលីពីន ជាអ្នកជួយ ។ ក្រៅពីនេះមានអន្តរាគមន៍យន្តហោះបេ-៥២ អេហ្វសង់សែង ហ្វង់តូម រថក្រោះកាំភ្លើងធំ មានមុខសញ្ញាវាយឯកភាពគ្នា តាមច្រកពីរ តាមជើងគោកនិងតាមឆកសមុទ្រកំពង់សោម ។ ចំណែកនៅទីក្រុង អង្គការកំពុងវាយកម្ទេចពួកសេ.អ៊ី.អា សម្បើមណាស់ ដូចជា ចាន់ ចក្រី មេបញ្ជាការកងពល១៧០ ឈួន លីផែន ជាដើម ។ នៅពេលថ្មីៗនេះទៀត អង្គការបានវាយ ហែម សាភឿន ថ្នាក់វរសេនាធំកងពល១៧០ មិនដឹងថាឈ្មោះនេះបានឆ្លើយដាក់អ្នកណាខ្លះ ។ មានតែ ឌុច និងមិត្តម្នាក់ទៀតធ្វើការជាមួយ ឌុច ទើបអាចដឹងពីចម្លើយនេះ" ។

នៅក្នុងចម្លើយលើកទី៣ នឿន បានសារភាពថា គាត់ត្រូវបាន សុក ណែនាំឲ្យចេះពីរបៀបប្រើប្រាស់ពាក្យនិងលេខសម្ងាត់សម្រាប់ទំនាក់ទំនងចាំបាច់ក្នុងការរកនិរសាពីម្នាក់ទៅម្នាក់ដែលមិនស្គាល់ច្បាស់ ធ្វើសញ្ញាជាស្រែកភ្ញាត់មាត់ ។ ដោយលើកឧទាហរណ៍ថា "អង្គការកំណត់ឲ្យធ្វើស្រែឲ្យបានផល៣តោនមួយហិកតា ត្រូវភ្ញាត់មាត់ថា "បីតោនមួយហិកតា" ចំនួនពីរដង បើមានអ្នកនៅក្បែរនោះស្រែកបន្ទរដូចគ្នា ហើយសម្លឹងមុខអ្នកស្រែកនោះ គឺគ្នារបស់យើងហើយ" ។ ចំពោះការប្រើប្រាស់លេខវិញ គឺយកព្យញ្ជនៈមកតម្រៀប (ពីអក្សរកដល់អ) ។ "ក"លេខ១, "ខ" លេខ២, "គ"លេខ៣ តាមលំដាប់អក្សររហូតទៅ ។ ឧទាហរណ៍ ឈ្មោះ តែនី ហៅ នឿន (ន) លេខ២០ ហើយ (ន)មួយទៀតលេខ ២០ ដូចនេះដល់ពេលសរសេរ២០-២០ ដល់ពេលប្រែដឹងថាជាឈ្មោះ នឿន ។ ដោយឡែកក្នុងករណីមានការលំបាកបុទ័លច្រក គឺប្រើសញ្ញារូបគុបភ្លើងនៅក្នុងបាតដៃ ។ គុបភ្លើងនោះដូចរូបសំណាកសេរីភាពអាមេរិកាំងដែរ ។ ការរស់នៅនិងកិច្ចការប្រចាំថ្ងៃនៅមន្ទីរស-២១ បានធ្វើឲ្យ តែនី ឃើញច្បាស់ថាក្រុមសេ.អ៊ី.អាមិនអាចគេចផុតពីការកម្ទេចរបស់អង្គការឡើយ ។

ដូច្នេះ តែនី ក៏ខិតខំកែប្រែទស្សនៈរបស់ខ្លួនមួយកម្រិតទៀត ។ ប៉ុន្តែយឺតពេលទៅហើយ ពីព្រោះធាតុចាស់ដែលធ្លាប់ប្រឆាំងនឹងបដិវត្តន៍មិនបានរលុបបាត់ គឺវាពួនសម្ងំហើយស្តែងចេញជាបាតុភាពខុសឆ្គងជាបន្តបន្ទាប់ ។ ថ្ងៃទី២៣ ខែកុម្ភៈ ឆ្នាំ១៩៧៧ ពុយ តែនី ហៅ នឿន ត្រូវអង្គការចាប់ខ្លួនហើយយកទៅសម្លាប់ចោល ។

**លី សុផល**

◆ **លើកកម្ពស់ស្មារតីប្រុងប្រយ័ត្នបដិវត្តខ្ពស់ជានិច្ច ដើម្បីវាយកម្ចាត់គ្រប់ឧបាយកលខ្មាំង ការពារប្រទេស ការពារបដិវត្តន៍ ការពារប្រជាជន ការពារបក្ស ជាច់ខាត។** (ទង់បដិវត្ត ឆ្នាំ១៩៧៦)

# ដំណើរឆ្លងកាត់តំបន់ខ្មែរក្រហម

***(តពីលេខមុន)***

ផ្ទះថ្មជាច្រើនខ្នងនៅអមផ្លូវជាតិ ត្រូវបាក់បែកខ្ទេចអស់ នៅសល់តែគំនរឥដ្ឋរប៉ាត់រប៉ាយ ។ ផ្លូវជាតិត្រូវជីកគាស់រប៉ាត់រប៉ាយជាអន្លើ ។

យើងបានមកឈប់សំរាកនៅមុខវត្តមួយនៅខាងត្បូងផ្លូវជាតិចម្ងាយប្រមាណ២គ.ម ។ នៅទីនោះមានរទេះបងប្អូនអ្នកស្រុកជាច្រើនដែលរត់ភៀសខ្លួនបុព្វកខ្មែរក្រហមជម្លៀសមកដល់ទីនេះ ។ បន្តិចក្រោយមក មានឡានស៊ីបខ្មែរក្រហមមួយចងស្លឹកឈើ បើកមកឈប់នៅក្នុងវត្ត ។ នៅក្នុងសាលារៀននិងនៅក្រោមកុដិព្រះសង្ឃ យើងប្រទះឃើញកងទ័ពខ្មែរក្រហមឬខ្មែររណសិរ្ស ដេកលើអង្រឹងនីឡុងព្រោងព្រាតដូចហ្វូងប្រជៀវ ។

នៅម៉ោង១២ថ្ងៃត្រង់ យើងបានទៅដល់ទីរួមផ្សារបរសែត ។ តៀមចិនលក់ឥវ៉ាន់៥ឬ៦នៅបើកទ្វារស្វាគ់ជ្រងំ ។ មិត្តនីរសាបាននាំយើងទៅជួបប្រធានតំបន់ដែលជាអតីតគ្រូបង្រៀនធ្លាប់ធ្វើការនៅសាលាបឋមសិក្សាសន្ទរម៉ុក ហើយដែលបានចេញទៅនៅព្រៃតាំងពីឆ្នាំ១៩៦៦ ។ (យើងពុំអាចស្រាវជ្រាវរកឈ្មោះដើមឃើញទេ យើងគ្រាន់តែស្គាល់ឈ្មោះបដិវត្តន៍របស់គេប៉ុណ្ណោះ ឈ្មោះហំ) ។ មិត្ត ហំ ក្រោយពីបានអានលិខិតរបស់មិត្តស្នងការនយោបាយក្រុងភ្នំពេញហើយ ក៏ចាប់ផ្តើមសួរពត៌មានពីយើង ពីឈ្មោះពិតប្រាកដរបស់យើង ពីអាជីវកម្មនៅក្នុងសង្គមចាស់ (នេះជាសម្តីរបស់គេ) ពីស្រុកកំណើត ពីទីកន្លែងធ្វើការ ។ ក្រោយមក គេក៏ចាក់ទឹកតែហុចមកឲ្យយើង ព្រមទាំងនាំយើងទៅស្រស់ស្រូបបបរសនិងត្រីងៀត ។ គឺមិត្ត ហំ នេះហើយដែលជាអ្នកត្រួតត្រាតំបន់ដង្កោ ស្រុកកណ្តាលស្ទឹង មានឡានអ៊ី-ស៊ុយ-ស៊ុយមួយនិងម៉ូតូហុងដាជាច្រើនសម្រាប់ប្រើការ ។ គឺជាបុរសមាឌមាំ ទាប កំពស់ប្រមាណ១,៥៨ម មិនសូវនិយាយស្តី មានអាយុប្រមាណ៤០ឆ្នាំ ។

នៅម៉ោង២រសៀល មិត្តនីរសាដដែលបានជូនដំណើរយើងបន្តទៅមុខទៀត ។ មិត្ត ហំ បាន សរសេរកូនសំបុត្រមួយឲ្យយើងកាន់ ហើយប្រាប់ថា ឲ្យយកលិខិតនេះទៅប្រគល់ឲ្យមិត្ត ហង់ (ឈ្មោះបដិវត្តន៍) នៅមន្ទីរ៣០៥ ផ្ទាល់ដៃ ។ យើងធ្វើដំណើរកាត់តាមភូមិកាត់ភ្លុក-ក្រសាំង មកដល់ភូមិវាលល្មៀង ក្នុងសង្កាត់ផុងក្នុងខេត្តកំពង់ស្ពឺ ។ មិត្តនីរសាបានណែនាំយើងឲ្យប្រើឈ្មោះ “ហ្វូប” ជំនួសពាក្យបរិភោគបុញ្ញាំ ហើយឲ្យទំលាប់ប្រើពាក្យ “មិត្ត” ដូចគេដូចឯង ។ មកទល់នឹងថ្ងៃនេះ យើងបានជួបយៀកកុងតែ២នាក់ប៉ុណ្ណោះ ដែលកំពុងអង្គុយស៊ីគុយទាវនៅភូមិក្រសាំងកាត់ភ្លុក ។

មកដល់ភូមិវាលល្មៀង មិត្តនីរសាបន្ទាប់ពីបានប្រគល់យើងនិងលិខិតមិត្ត ហំ ឲ្យអនុប្រធាន “មិត្តនីរសា” នៃភូមិភាគពិសេស ហើយក៏វិលបកក្រោយវិញ ។ មិត្ត មាំង (ឈ្មោះបដិវត្តន៍) ជាអនុប្រធានមន្ទីរនីរសា នាំយើងទៅសំរាកនៅក្នុងផ្ទះអ្នកស្រុកមួយខ្នងដែលគេយកទៅធ្វើជាឃ្លាំងផ្ទុកឥវ៉ាន់ មានសំពត់ ប្រេងកាត អំបិល សំពត់កៅស៊ូ ជាដើម ។ មន្ទីរឬក្រុមនេះមានភារៈសំរាប់ចាត់ចែងដឹកជញ្ជូនឥវ៉ាន់ពីតំបន់ស្អាង-កោះធំ (តំបន់២៥) ឬពីស្អាន់-ទន្លេបាទី យកទៅភូមិភាគពិសេសដោយឆ្លងកាត់តាមផ្លូវលេខ៤ ។ មានឡានធំបីដែលសុទ្ធជាឡានរត់ឈ្នួល (ឡានរត់ឈ្នួលធំមួយមានដាក់យីហោ ហុក-ហេង) ម៉ូតូហុងដា៣គ្រឿង និងទោចក្រយាន៤ឬ៥ទៀត ព្រមទាំងដំរី៣ក្បាល ទុកសំរាប់ឲ្យក្រុមនីរសាប្រើប្រាស់ក្នុងការដឹកជញ្ជូនឥវ៉ាន់ ។

## ថ្ងៃ២០ មេសា ដល់ ថ្ងៃ១២ ឧសភា ១៩៧២

នៅថ្ងៃដំបូង ប្រជាកសិករនៅភូមិវាលល្មៀងទទួលអបអរសាទរនឹងយើងខ្លាំងណាស់ ។ គណៈកម្មាធិការរណសិរ្សភូមិបាននាំគ្នារៀបចំបាយទឹកម្ហូបចំណីទទួលយើង ព្រមទាំងរៀបចំរាត្រីសិល្បៈតូចមួយសំដែងដោយក្រុមកុមារា-កុមារីនៅក្នុងភូមិជូនជាកិត្តិយសដល់យើងទៀតផង ។ គឺជាថ្ងៃដំបូងដែលយើងបាន

ឃើញទិដ្ឋភាពនៃចំរៀងនិងរបាំរបស់អង្គការបដិវត្តន៍ខ្មែរក្រហម ។ យើងមានក្ដីរំភើបនិងសោមនស្សរជាខ្លាំងចំពោះមេត្រីភាពនិងការយកចិត្តទុកដាក់របស់បងប្អូនប្រជាកសិករ ហើយយើងក៏បានថ្លែងអំណរគុណសំដែងទឹកចិត្តស្មាមីភក្តិនិងមេត្រីភាពតបតទៅរកបងប្អូនទាំងអស់នោះវិញ ។ ការយកចិត្តទុកដាក់របស់បងប្អូនប្រជាកសិករមកលើរូបយើង ហាក់ធ្វើឲ្យមិត្ត មាំង និងសហការីរបស់គេ ប្រណែននិងយើងខ្លះៗដែរ ។

ប្រជាកសិករនៅភូមិវាលល្បៀងមានជីវភាពក្រខ្សត់ណាស់ ម្ហូបចំណីត្រីសាច់ពុំមានគ្រប់គ្រាន់ទេ ។ បងប្អូនទាំងនោះនៅជំពាក់ចិត្តទៅលើ “សម្ដេចឪ” យ៉ាងជ្រៅ ។ មានចាស់ទុំជាច្រើននិយាយសរសើរពី“សម្ដេចឪ” ហើយត្អូញត្អែរថា “សព្វថ្ងៃនេះរាស្ត្រគ្នារងាណាស់ រងាដូចកូនមាន់បាត់ម៉ែ” (បាត់សម្ដេចសីហនុ)...។ ប្រជាកសិករនៅតែសង្ឃឹមថា សម្ដេច សីហនុ នឹងវិលមកកាន់កាប់អំណាចវិញនៅពេលណាដែលកងទ័ពរំដោះវាយយកភ្នំពេញបាន ។

ចំណែកមិត្ត មាំង និងមិត្ត ចាន់ ប្រធានមន្ទីរនីរសានេះវិញ សុទ្ធតែជាក្របខ័ណ្ឌកុម្មុយនិស្ត ។ គេនាំគ្នាលាក់កំបាំងការពិតមិនទាន់ឲ្យប្រជាកសិករនៅក្នុងតំបន់នេះដឹងទេ ។ នេះជាយុទ្ធវិធីប្រមូលកម្លាំងមួយរបស់អង្គការខ្មែរក្រហម ។

ថ្ងៃបន្ទាប់មក ដូនចាស់ម្នាក់ឈ្មោះ យាយម៉ែន បាននាំយើងទៅនៅផ្ទះថ្មីមួយខ្នងទៀតដែលទើបនឹងសង់ហើយ ។ យើងបានទទួលការឧបត្ថម្ភយ៉ាងកក់ក្ដៅពីសំណាក់ដូនចាស់នេះនិងញាតិមិត្តចាស់ទុំជិតខាងផងទៀត ។ សឹងតែរាល់ថ្ងៃ ញាតិមិត្តជិតខាងយកនំចំណី ផ្លាំជក់ ដូងខ្ចី ស្លឹកសង្កែ មកឲ្យយើង ហើយនៅពេលល្ងាចៗ បងប្អូនទាំងនោះតែងនាំគ្នាមកសួរសុខទុក្ខសំណេះសំណាលកំសាន្តលេងជាមួយយើង បង្កើតជាចំណងមេត្រីភាពនិងការយល់ចិត្តគ្នាទៅវិញទៅមករឹតតែជិតស្និទ្ធថែមទៀត ។

មានពេលខ្លះ យើងនឹករឭកមកកូនប្រពន្ធ-គ្រួសារញាតិមិត្តយ៉ាងលន្លង់លន្លោច ជាហេតុធ្វើឲ្យយើងរឹតតែឈឺចាប់ពើតខ្លាំងឡើងទៀតនឹងសង្គ្រាមនិងអ្នកដែលបង្កឲ្យមានសង្គ្រាមនេះ សង្គ្រាមដែលធ្វើឲ្យយើងបែកបាក់គ្នា សង្គ្រាមដែលសាបព្រោះ




នូវទុក្ខវេទនាសព្វយ៉ាងដល់ប្រជារាស្ត្រស្លូតត្រង់ ។ ពេលជួបប្រទះយៀកកុងតាមផ្លូវម្ដងៗ យើងសឹងតែលោតទៅច្របាច់កកាប់ចិញ្ច្រាំឲ្យអស់ចិត្ត!!

ការស្នាក់អាស្រ័យនៅក្នុងភូមិវាលល្បៀងជាយូរថ្ងៃ កាន់តែធ្វើឲ្យយើងអផ្សុកតប់ប្រមល់ខ្លាំងឡើងៗ ។

នៅថ្ងៃ៦ ឧសភា មិត្ត ចាន់ (ឈ្មោះបដិវត្តន៍) បាននាំមិត្ត នង សួន ហៅ ចំរើនជ័យ ទៅសាកសួរសុខទុក្ខយើងដោយមាន



រូបថតឆ្នាំ១៩៧២ នៅតំបន់រំដោះ

នៅល្ងាចថ្ងៃដដែល បងប្អូននៅក្នុងភូមិបានរៀបចំម្ហូបចំណីជប់លៀង “សមមិត្ត” នង សួន ព្រមទាំងយើងទាំងអស់គ្នា ។ មិត្ត ចាន់ ប្រធានមន្ទីរដឹកនាំ បានប្រាប់យើងថា “ប្រហែល៤-៥ថ្ងៃទៀតមិត្តនឹងបានចេញដំណើរទៅ“អង្គការលើ” ។ ខ្ញុំបានវាយទូរលេខទៅជំរាបអង្គការលើពីរឿងមិត្តរួចហើយ” ។

ខ្ញុំភ្ញាក់ព្រើតកាលបើឮមិត្ត ចាន់ ប្រាប់ថា “មានវាយទូរលេខ” ព្រោះខ្ញុំមិនបានចាប់ភ្លឹកថា អង្គការខ្មែរក្រហមគេយកចិត្តទុកដាក់នឹងខ្ញុំដល់ថ្នាក់នេះ ។

នៅថ្ងៃបន្តបន្ទាប់មកទៀត យើងចាប់ផ្តើមជួបយៀកកុង-យៀកណាមខាងជើងឆ្លងកាត់ភូមិជាញឹកញាប់ មានដឹកអង្ករ បន្លែ មាន់ ទា និងដឹកគ្រាប់កាំភ្លើងត្បាល់តាមកង់ ។ ជួនកាលមានឃើញពួកវាសែងអ្នករបួសឆ្លងកាត់ភូមិ ។ អ្នកស្រុកផ្តល់ព័ត៌មានមកយើងថា ទ័ពធំរបស់ពួកវាមិនដែលដើរកាត់ភូមិទេ មានតែក្រុមសេដ្ឋកិច្ចទេជាអ្នកដើរចេញចូលរកទិញស្បៀងតាមភូមិ ។

យុទ្ធជនខ្មែរក្រហមចំនួន៩នាក់អមការពារសន្តិសុខផង ។ នង សួន ជាស្នងការនយោបាយតំបន់២៥ (ស្រុកស្អាង-កោះធំ) ឬគេហៅថា “លេខាតំបន់២៥” (លេខាធិការបក្សនៅក្នុងតំបន់) ។

នៅក្នុងការសន្ទនាជាមួយ នង សួន ខ្ញុំឆ្លៀតឱកាសបញ្ចោរសរសើរនូវវីរភាពនិងស្មារតីរឹងប៉ឹងរបស់ នង សួន ក្នុងការធ្វើបដិវត្តន៍ នូវសេចក្តីក្លាហានរបស់ នង សួន នាសមាជពិសេសនៅវាលមេរុ ដែលនាំឲ្យ នង សួន ជាប់គុករហូតមកដល់ឆ្នាំ១៩៧០ ។

ពេលឃើញជនបរទេសត្រូវឈ្លានពាន យើងក៏នឹកឃើញដល់វាសនាស្រុកទេស ដល់ឯករាជ្យរបស់ប្រជាជាតិ ដល់វិនាសកម្មរបស់ប្រជារាស្ត្រចំនួន៣ឆ្នាំកន្លងមកហើយ ។ល ។

ចុះខ្មែរក្រហម? នេះហើយជាចំណោទ!

ថ្ងៃទី៧ និង៨ ឧសភា មិត្ត ចាន់ បានជូនដំណើរ នង សួន ឡើងទៅលើ (អង្គការលើ) ។ ថ្ងៃ៨ និង៩ ឧសភា ភ្លៀងបង្អុរខ្លាំងលាយនិងខ្យល់ព្យុះធំ ទឹកដក់សស្វាចពាសពេញស្រែ ។ អារម្មណ៍

របស់យើងវិលវល់ នឹកដល់ការសប្បាយនិងសេចក្ដីសុខសាន្តនៅក្រោមដំបូលគ្រួសារដ៏កក់ក្ដៅដែលយើងធ្លាប់ជួបប្រទះពីដើមរៀងមក ។ ចំពោះយើង សេចក្ដីសុខលាយនឹងការភ្ញើតភ្ញើនរបស់យើងក្នុងមួយរយៈពេល ហាក់ដូចជាអំពើក្បត់មួយចំពោះប្រជាកសិករដែលកំពុងរងទុក្ខវេទនាដោយសារសង្គ្រាម ។ យើងគួរតែហ៊ានធ្វើអ្វីមួយជាវិភាគទានក្នុងការបំបាត់សង្គ្រាមនេះ ។

សេចក្ដីសំរេចរបស់យើងក្នុងការចូលទៅក្នុងជួរ "បក្សម្ខាង" អាចឲ្យមិត្តភក្ដិរបស់យើងបកស្រាយច្រើនបែបច្រើនយ៉ាងណាស់មកលើរូបយើង ។ ឬមួយគេចាត់ទុកយើងជាអ្នកផ្សងព្រេងនិយម ជាពួកឆ្កួតលីលា ជាក្រុមប្រលោមលោកនិយមព្រោះថាខ្លួនឯងអាច "ទូលផែនដី" ឬទេ? ឬមួយគេអាចចាត់ទុកយើងថាជាពួកសីហនុនិយម? ឬមួយគេចោទយើងថាជាជនកុម្មុយនិស្ត?

ចំពោះយើង យើងសុខចិត្តនៅស្ងៀមជាជាងស្រដី ។

នៅថ្ងៃ៩ ឧសភា យន្ដហោះ តេ-២៥ ពីរគ្រឿងមកទម្លាក់គ្រាប់បែកនៅខាងជើងវត្តកាត់ភ្លុក ។

ថ្ងៃ១០ ឧសភា ការអផ្សុកនិងរវើរវាយញាំញីយើងកាន់តែខ្លាំងឡើងៗ ។ យើងគ្មានសៀវភៅមើលកំសាន្ត គ្មានកាសែត ។ យើងដាច់ការទាក់ទងពីខាងក្រៅពីភ្នំពេញ ។ មួយថ្ងៃៗ យើងស្ដាប់ដំណឹងតែតាមវិទ្យុភ្នំពេញ ប៉េកាំង និងវ៉ាស៊ីនតោន ។

ដំណឹងថាក្រុងភ្នំពេញទទួលការវាយប្រហារដោយគ្រាប់កាំភ្លើងត្បាល់និងគ្រាប់រ៉ុក្កែត ១២២ម.ម ចំនួន ១៥៥គ្រាប់នៅដើមខែឧសភា ធ្វើឲ្យយើងរន្ធត់ញាប់ញ័រជាខ្លាំង ។

នៅល្ងាចថ្ងៃទី១០ ឧសភា មិត្ត "មាំង" ភូឈួយមិត្ត ចាន់ បានយកសំបុត្រមួយមកបង្ហាញយើង ។ ក្នុងលិខិតនោះ ស្នងការនយោបាយតំបន់៣៣ (មិត្ត សាំង រិន អតីតសាស្ត្រាចារ្យមធ្យមសិក្សា) បាន "ស្នើ" ឲ្យមិត្ត មាំង នាំយើងទៅជួបនិងគេនៅវេទិកាកិត្តិយស នៅវេលាម៉ោង៦ល្ងាច ។ នៅល្ងាចថ្ងៃ១០ ឧសភា នេះគណៈរណសិរ្សតំបន់៣៣បានចាត់ចែងរៀបចំមិទ្ទីងមួយយ៉ាងធំនៅក្បែរវត្តកាត់ភ្លុក ត្រង់សាលាបឋមសិក្សាចាស់ ។

យើងបានទៅរួមមិទ្ទីងនិងគេដែរ តែមិត្ត មាំង យើងមិនដឹងជាមានចេតនាបែបណា ពុំបាននាំយើងទៅជួបអ្នកដឹកនាំខ្មែរក្រហមនៅវេទិកាកិត្តិយសទេ ។

យើងមានការចាប់អារម្មណ៍ជាខ្លាំងទៅលើមិទ្ទីងនេះ ។ មនុស្សប្រមាណជាងមួយម៉ឺននាក់ រួមទាំង"ប្រជាជន" ទាំង"កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជា" ទាំងព្រះសង្ឃទាំងក្របខណ្ឌខ្មែរក្រហម (កម្មាភិបាល) ប្រដាប់ដោយសម្លៀកបំពាក់ខ្មៅ បានចេញមកពីគ្រប់ទិសទី ហែជាក្បួន កាន់ទង់ក្រហមនិងបដាក្រហម តម្រង់មកកាន់ទីធ្លាសាលារៀន ។ ក្រុមនារីឈរនៅជួរខាងមុខក្បែរវេទិកា ។ នៅមុខវេទិកាមានសង់តូបមីក្រូដាច់ឆ្ងាយពីគ្នា ។ ខាងក្នុងវេទិកា កៅអីប្រមាណ២០០តម្រៀបជាជួរ ។

ដំបូង អារម្មណ៍របស់យើងបាញ់ផ្ដោតទៅលើពាក្យស្លោកនៅលើបដាក្រហម ។ បណ្ដាបដាជាច្រើន យើងឃើញមានតែបដាក្រហមមួយទេដែលចែងថា "ជយោ! រណសិរ្សរួបរួមជាតិកម្ពុជាដែលមានសម្ដេច នរោត្តម សីហនុ ព្រះប្រមុខរដ្ឋ ជាប្រធាន" ក្រៅពីនេះគ្មានបដាក្រហមណាមួយនិយាយពីស្ដេចសីហនុ ឡើយ ។ ពាក្យស្លោកភាគច្រើនបញ្ចើចបញ្ចើពីវីរភាពរបស់ប្រជាជននិងកងកម្លាំងរបស់គេដូចជាៈ "ជយោ! កងកម្លាំងប្រដាប់អាវុធប្រជាជនរំដោះជាតិកម្ពុជាដ៏មានជ័យ!" ។ "ប្ដេជ្ញាគាំទ្រការតស៊ូដ៏អង់អាចក្លាហានរបស់ប្រជាជន" ។ "ជយោរដ្ឋអំណាចប្រជាជន" ។ "ប្ដេជ្ញាកំទេចចក្រពត្រអាមេរិកាំងនិងបរិវាររាឲ្យអស់ពីទឹកដីកម្ពុជា លាវ វៀតណាម" ។ "ជយោយុទ្ធសាមគ្គីនៃប្រជាជនខ្មែរ លាវ និង វៀតណាម" ។ល ។

ដោយឃើញបដាពីរសម្ដែងពរស្វាគមន៍ ចំពោះលោក ហ៊ូ យន់ ទើបយើងដឹងថាលោក ហ៊ូ យន់ ច្បាស់ជាមកជាអធិបតីក្នុងពិធីនេះ ។ យើងខិតខំផ្ទៀងរកមើលក្រែងមានយៀកកុង-យៀកណាមខាងជើងមកចូលរួមក្នុងបុណ្យមិទ្ទីងនេះ តែយើងរកមើលពុំឃើញមានម្នាក់សោះ ។ ភ្លើងអគ្គិសនីបានបំភ្លឺព្រោងព្រាតហាក់ដូចមិនមែនជាជនបទ ។ នៅក្បែរវេទិកា គេបានរៀបចំលេណដ្ឋានមានគម្របមួយយ៉ាងមាំសម្រាប់មេដឹកនាំខ្មែរក្រហម ។ នៅជុំវិញទីធ្លាសាលា មានគេជីកលេណដ្ឋានតូចៗយ៉ាងច្រើនសំរាប់ទស្សនិកជន ។ ក្រុមឲ្យសញ្ញាថាមានយន្ដហោះ បណ្ដាក់គ្នានៅជុំវិញបរិវេណសាលា ។ ពេលព្លុស្វូរកញ្ចែ ភ្លើងអគ្គិសនីត្រូវពន្លត់ បារីមិនត្រូវឲ្យជក់ ។ **(នៅមានត)** **អ៊ិត សារិន**

# ការអប់រំកសាងកូនចៅរបស់បដិវត្តខ្មែរក្រហម

សម័យបដិវត្តយើងឥឡូវជាសម័យវាយកំទេចនិងបោសសំអាតរបៀបរបបមនុស្សជិះជាន់មនុស្ស និងវាយកំចាត់នូវការទាក់ទងផលិតកម្មជិះជាន់តាមគ្រប់រូបភាពទាំងអស់ ។ ជាសម័យដែលជនគ្រប់រូបលើកតំកល់ផលប្រយោជន៍រួមរបស់ប្រទេសជាតិនិងប្រជាជនខ្ពស់ជាងផលប្រយោជន៍ស្ទួនតួផ្ទាល់ខ្លួនជានិច្ច ។ ពាក្យស្លោករបស់យើងសព្វថ្ងៃគឺ អ្វីៗទាំងអស់ដើម្បីរំដោះប្រទេសជាតិ និងរំដោះប្រជាជនឲ្យរួចចាកផុតពីនឹមជិះជាន់ឈ្លានពានរបស់ចក្រពត្តិអាមេរិកនិងចក្រពត្តិបរទេសទាំងអស់ និងឲ្យរួចចាកផុតពីការជិះជាន់សង្កត់សង្កិនមើលងាយមើលថោកសព្វបែបយ៉ាងរបស់បក្សពួកអាក្បត់ជាតិ លន់ណុល-សិរិមតៈ-សឺងង៉ុកថាញ់-អ៊ិនតាំ-ចេងហេង-ឡុងបូរ៉េត-សុស្តែន ។ អ្វីៗទាំងអស់ដើម្បីបដិវត្តឈ្នះ ។...

ដូច្នេះ បើស្រឡាញ់កូនចៅក៏ដើម្បីឲ្យវាធ្វើបដិវត្តបំរើប្រទេសជាតិនិងបំរើប្រជាជនបានល្អដែរ ។ ឯកសារអប់រំកសាងកូនចៅយើងក៏ដើម្បីឲ្យវាទៅជាអ្នកបដិវត្តល្អមួយរូបដែលស្នេហាជាតិ ចេះស្រឡាញ់គោរពស្មោះត្រង់ និងបំរើប្រជាជនដោយអស់ពីចិត្តពីថ្លើម នៅគ្រប់ទីកន្លែង ក្នុងគ្រប់កាលៈទេសៈលំបាកស្រួល ។ ដែលស្ចួតបូតសុភាពរាបសាចំពោះប្រជាជន-មហាជនជានិច្ច ធ្វើឲ្យប្រជាជន-មហាជនស្រឡាញ់រាប់អាន ពេញចិត្តពេញថ្លើមគ្រប់គ្នា ។ ដែលអង់អាចក្លាហាន មោះមុត ហ៊ានប្រយុទ្ធស្លាប់រស់ជាមួយខ្មាំងសត្រូវគ្រប់ប្រភេទ ហ៊ានទ្រាំទ្រការលំបាកវេទនាគ្រប់បែបយ៉ាងទាំងអស់ រហូតដល់ហ៊ានធ្វើពលិកម្មកម្រិតខ្ពស់ ដើម្បីសំរេចភារកិច្ចបដិវត្តជូនប្រទេសជាតិ-មាតុភូមិទាំងស្រុង ។

នេះហើយជាកិត្តិយសនិងជាមោទនភាពដ៏ខ្ពង់ខ្ពស់និងត្រឹមត្រូវរបស់ឪពុកម្តាយយើងក្នុងសម័យបដិវត្តឥឡូវ ។ គ្មានឪពុកម្តាយណាមួយដែលថាចង់ឲ្យកូនចៅទៅជាជនក្បត់ជាតិ ក្បត់ប្រជាជន និងក្បត់បដិវត្តឡើយ ។ គ្មានឪពុកម្តាយពលករណាមួយចង់ឲ្យកូនចៅទៅជាអ្នកព្រហើន កោងកាច ដើរជិះជាន់សង្កត់សង្កិនមើលងាយមើលថោកជិះជាន់គេឯងឡើយ ។

ដោយមានទស្សនៈគោលជំហរបដិវត្តត្រឹមត្រូវយ៉ាងនេះ ការស្រឡាញ់អប់រំកសាងកូនចៅក៏ត្រូវយោលទៅតាមនេះដែរ ។ ដូច្នេះយើងមិនអាចស្រឡាញ់អប់រំកសាងកូនចៅយើងទៅតាមបែបដែនសង្គមចក្រពត្តិ-អាណានិគមនិងសង្គមពួកអាក្បត់ជាតិបានឡើយ ។

យើងម្នាក់ៗសុទ្ធតែចង់ឲ្យកូនបានល្អ ចង់ឲ្យកូនចំរើន ចង់ឲ្យកូនធ្វើបដិវត្ត តែបើគ្មានទស្សនៈគោលជំហរបដិវត្តត្រឹមត្រូវចំពោះការស្រឡាញ់ ការអប់រំកសាងកូនចៅ ហើយគ្មានវិធីអប់រំកសាងកូនចៅឲ្យបានត្រឹមត្រូវទេ នោះក៏យើងពុំអាចកសាងវាឲ្យបានល្អសមស្របតាមគោលបំណងនិងសំណូមពររបស់យើងដែរ ។

ឪពុកម្តាយយើងខ្លះ ពេលឃើញកូនខូចខិលប្រឡេសប្រឡូសទៅ ក៏បន្ទោសថាមកពីកម្មផល ឬមកពីព្រេងសំណាងខ្លួនអាក្រក់ ។ ឪពុកម្តាយខ្លះទៀតបន្ទោសទៅលើកូនចៅថាវាមិនកើត វាមិនដើរតាមគន្លងឪពុកម្តាយ ។ល ។ ការបន្ទោសឬទំលាក់កំហុសបែបនេះសុទ្ធតែខុសទាំងអស់ ។ ក្នុងរឿងកូនចៅល្អឬខូចខិល កើតឬមិនកើតនេះ គឺឪពុកម្តាយជាអ្នកទទួលកំហុសទាំងអស់ ព្រោះយើងជាអ្នកអប់រំកសាងវាតាំងពីតូចៗមក ។ ឯកូនក្មេងវាមិនដឹងអ្វីទេ ។ វាប្រៀបបានទៅនឹងក្រដាសស១ផ្ទាំងអ៊ីចឹង បើយើងផាត់លាបពណ៌អីឲ្យវា វាក្លាយទៅជាពណ៌ហ្នឹងហើយ ។ បើយើងផាត់ពណ៌ខ្មៅ ក្រដាសហ្នឹងវាខ្មៅ ។ បើយើងផាត់ពណ៌ក្រហម វាក្រហម ។ ពោលគឺក្មេងវាចាំតែទទួលការអប់រំអំពីយើងប៉ុណ្ណោះ ។ បើយើងអប់រំកសាងវាបានត្រឹមត្រូវតាំងពីក្មេងខ្ចីមក វាក៏បានល្អត្រឹមត្រូវតាំងពីតូចរហូតដល់ធំ ។ តែបើយើងអប់រំវាទំរើសទំយើតាំងពីក្មេងមក វាក៏ឡើងចាងទៅតាមនោះដែរ ។

យើងធ្វើយ៉ាងនេះដើម្បីលើកកម្ពស់ស្មារតីទទួលខុសត្រូវ

ឲ្យខ្ពស់ក្នុងការស្រឡាញ់អប់រំកូនចៅ ។ វាមិនមែនដូចពាក្យខ្លះពោលថា "ដើមឈើបើវាបំរុងតែល្អហើយ មិនបាច់ស្រោចទឹកក៏ល្អដែរ!" នោះទេ ។ ព្រោះមនុស្សវាមិនមែនអត់វិចារណញ្ញាណដូចដើមឈើឯណា ។ វាមានវិចារណញ្ញាណ មានមនោសញ្ចេតនា មានទស្សនៈនិងគោលជំហរ ដែលជាទំលាប់ ជាអត្តចរិត និងជាផ្នត់គំនិតដែលជិតជាប់នៅក្នុងខ្លួនវាអស់មួយជីវិត មិនងាយនឹងកែប្រែវិញបានឡើយ ។ បើយើងជាឪពុកម្តាយអប់រំកសាងបណ្តុះបណ្តាលឲ្យវាមានទំលាប់ល្អឬអាក្រក់យ៉ាងណាហើយ វានឹងបានផ្នត់យ៉ាងនោះហើយមិនងាយកែប្រែវិញបានទេ ។

ដូច្នេះ ក្នុងការអប់រំកសាងកូនចៅនេះ បើយើងជាឪពុកម្តាយគ្រាន់តែមានចិត្តចង់ឲ្យវាល្អប៉ុណ្ណោះមិនគ្រប់គ្រាន់ទេ យើងត្រូវមានស្មារតីទទួលខុសត្រូវខ្ពស់ មានទស្សនៈគោលជំហរបដិវត្តឲ្យត្រឹមត្រូវ ព្រមទាំងមានទិសនិងមានវិធីអប់រំកសាងវាឲ្យច្បាស់លាស់និងត្រឹមត្រូវទៀត ។

### ១) ត្រូវកំណត់ទិសឲ្យច្បាស់

តើយើងចង់អប់រំកសាងកូនចៅយើងឲ្យទៅជាអ្វី ឲ្យធ្វើអ្វីទៅថ្ងៃក្រោយ?

ឪពុកម្តាយគ្រប់រូបសុទ្ធតែមានចិត្តចង់ឲ្យកូនចៅក្លាយទៅជាអ្នកបដិវត្តល្អមួយរូប ដើម្បីបន្តវេនធ្វើបដិវត្ត បំរើប្រទេសជាតិឲ្យសំបូរសប្បាយថ្កុំថ្កើងរុងរឿងទៅអនាគតទៀត ។

បន្តវេនបដិវត្តជាភារកិច្ចរុងរឿងឧត្តុង្គឧត្តម តែក៏ជាភារកិច្ចធ្ងន់ធ្ងរមួយដែរដែលទាមទារឲ្យមានគោលជំហរបដិវត្តរឹងប៉ឹងគ្រប់ផ្នែក ។ ដើម្បីកសាងគោលជំហរបដិវត្តឲ្យបានរឹងប៉ឹងគ្រប់ផ្នែក យើងពុំអាចធ្វើបានក្នុងរយៈ១ខែ-២ខែ ឬ១ឆ្នាំ-២ឆ្នាំនោះឡើយ តែយើងត្រូវលត់ដំហ្វឹកហ្វឺនកសាងវាជាបន្តបន្ទាប់ក្នុងចលនាបដិវត្តន៍ជាក់ស្តែង ទាំងក្តៅ ទាំងត្រជាក់ ទាំងលំបាកទាំងស្រួល ជារៀងរហូតទៅ ។ បើចំពោះក្មេងវិញ ក៏ត្រូវហ្វឹកហ្វឺនកសាងវាឲ្យមានទំលាប់ល្អ ឲ្យមានរបៀបរបបរស់នៅធ្វើការងារតាមបែបបដិវត្តតាំងពីតូចទៅដែរ ។ ទើបដល់ធំទៅវាបាក់ផ្នត់រត់ល្បត់ទៅខាងផ្លូវល្អ ដូច្នេះងាយកសាងខ្លួនឲ្យបានល្អ ឲ្យបានចំរើនជឿនលឿនយ៉ាងឆាប់រហ័ស ។

### ២) ត្រូវមានវិធីអប់រំកសាងកូនចៅឲ្យច្បាស់លាស់និងត្រឹមត្រូវ

ក្នុងសម័យបដិវត្តយើងឥឡូវ ទោះបីជារស់នៅក្នុងជួរបដិវត្តក្តី ទោះបីជារស់នៅតាមមូលដ្ឋានភូមិឃុំខ្លួនក្តី និយាយរួមគឺយើងសុទ្ធតែរស់នៅជាសមូហភាព ស៊ីចុក ស្លៀកពាក់ និយាយស្តី និងធ្វើការងារ ក៏ជាសមូហភាព ។ បើនៅក្នុងជួរបដិវត្តគឺយើងរស់នៅ ស៊ីចុក ស្លៀកពាក់ ដេកដើរ និងធ្វើការងារ នៅតាមមន្ទីរក្រសួង ការដ្ឋាន និងអង្គភាពបដិវត្តនានា មានអង្គការវិន័យនិងមានរបៀបរបបរស់នៅហ្មត់ចត់ត្រឹមត្រូវ ។

បើរស់នៅតាមមូលដ្ឋានភូមិ-ឃុំ ក៏យើងរស់នៅ ស៊ីចុក ស្លៀកពាក់ ធ្វើការងារ ជាសមូហភាពនៅក្នុងសហករណ៍ឬសហគមន៍នានាដែរ ។ បើទោះបីជាយើងមិនហូបបាយរួមដូចជានៅក្នុងជួរបដិវត្ត ក៏យើងធ្វើការងារជាសមូហភាព មានម៉ោងមានពេល និងទៅតាមការចាត់តាំងច្បាស់លាស់ត្រឹមត្រូវ ។ លុះបានផលមកក៏យើងមានរបៀបរបបចែកចាយគ្នាហូបសមស្របទៅតាមលក្ខការណ៍របស់អង្គការបដិវត្តកំណត់ឲ្យដែរ គ្មានអ្នកណាអាចកេងប្រវ័ញ្ចប្រមូលកើបយកធ្វើមានធ្វើបានតែម្នាក់ឯងនោះបានឡើយ ។ សរុបមក នៅក្នុងសម័យបដិវត្តយើងឥឡូវ គឺយើងសុទ្ធតែរស់នៅក្នុងសមូហភាពទាំងអស់ ដូច្នេះត្រូវតែគិតគូរដល់ផលប្រយោជន៍រួមរបស់សមូហភាពមុនគេបំផុត ក្នុងគ្រប់កាលៈទេសៈទាំងអស់ ។ ឯការអប់រំកូនចៅក៏ទិសដៅទៅបំរើផលប្រយោជន៍សមូហភាពនេះដែរ ។ យើងមិនមែនអប់រំវាសំរាប់ឲ្យយើងដែលជាឪពុកម្តាយវាស្រឡាញ់ពេញចិត្តពេញថ្លើមវាតែម្នាក់ឯងនោះទេ ។ ដូច្នេះ÷

ក) ត្រូវចេះអប់រំវាឲ្យចេះរស់នៅក្នុងសមូហភាព ។ ពោលគឺតាំងពីការស៊ីចុក ស្លៀកពាក់ លេងសើច ធ្វើការងារ សប្បាយរីករាយក្នុងសមូហភាព ។ ជៀសវាងដាច់ខាតកុំតុបតែងបញ្ចើចបញ្ចើ លើកដាក់វាឲ្យខុសប្លែកដាច់ឆ្ងាយពីកូនចៅប្រជាជន-មហាជនទូទៅ ។ ជៀសវាងដាច់ខាតកុំលបលួចបញ្ចុកបន្ស៊ីតែកូនចៅខ្លួនដោយឡែក ធ្វើយ៉ាងណាឲ្យតែបានឆ្ងាញ់ ឲ្យតែបានគ្រប់គ្រាន់ដល់កូនចៅខ្លួន ហើយគ្មានគិតគូរដល់កូនចៅប្រជាជន-មហាជនទូទៅផងសោះ ។ ជៀសវាងដាច់ខាតកុំថ្នាក់ថ្នមកូនចៅខ្លួនឲ្យខុសប្លែកឬលើសពីកូនចៅប្រជាជន-មហាជនទូទៅដោយរើសតែការងារស្រាលៗ ការងារណាងាយស្រួល ឲ្យតែ

កូនចៅខ្លួនធ្វើ ឬរហូតដល់ទំរើសវាមិនឲ្យធ្វើការអីទៀត ហើយទុកឲ្យតែកូនចៅប្រជាជន-មហាជនឯទៀតគេធ្វើជំនួសទាំងអស់វិញ ។ ពីព្រោះការអប់រំរបៀបនេះហើយដែលនឹងធ្វើឲ្យកូនយើងឡើងចាន ឃ្លាតដាច់ឆ្ងាយពីប្រជាជន-មហាជន និងមានទំលាប់សួនតួនិយម បុគ្គលនិយម អាត្មានិយម និងស័យឯកោនិយមផង ។ ពេលវានៅតូចក៏មិនចេះរស់នៅជាមួយសមូហភាព ។ លុះដល់ធំទៅក៏រឹតតែពិបាកនឹងរួមរស់នៅក្នុងសមូហភាពទៀត ពោលគឺទៅត្រង់ណាក៏ចូលនឹងគេមិនចុះដែរ ។ ដូច្នោះវានឹងទៅជាមនុស្សឈ្លើយ ព្រហើន កោងកាច កំបុតកំបុយ បុគ្គលនិយម សួនតួនិយម អំនួតអួតអាង ហើយដែលគ្មានប្រជាជន-មហាជនស្រឡាញ់រាប់អានឡើយ ។

ខ) ត្រូវទំលាប់វាឲ្យរស់នៅមានអន្តការវិន័យ និងគោរពអន្តការវិន័យដោយទៀងទាត់ត្រឹមត្រូវជានិច្ច ។ ក្នុងការដេកដើរក្តី ក្នុងការលេងសើចក្តី ក្នុងការស៊ីចុកក្តី ក្នុងការរៀនសូត្រ ឬធ្វើការងារក្តី ទោះវាធ្វើបានតិចបានច្រើនប៉ុនណាក៏ដោយ ត្រូវតែមានកំណត់ពេលវេលានិងរបៀបរបបឲ្យបានទៀងទាត់ជានិច្ច ។ ដាច់ខាតកុំបណ្តោយឲ្យវារស់នៅសេរីតាមតែទំនើងចិត្ត ចង់ដេកថ្មើរណាក៏ដេកទៅ ចង់ស៊ីអីថ្មើរណាក៏ស៊ីទៅ ចង់ធ្វើការងារក៏ធ្វើ មិនចង់ធ្វើទេក៏ហី ចង់រៀនថ្មើរណាក៏រៀន មិនចង់រៀនក៏រត់លេងបាត់ទៅ ហើយក៏ត្រូវទំលាប់កុំឲ្យវាទារអីបានតាមចិត្តដែរ ។

បើយើងទំលាប់វាឲ្យរស់នៅមានអន្តការវិន័យ *(ឯកសារបាត់១សន្លឹក)*... ជំហររឹងប៉ឹងល្អជាបន្តបន្ទាប់ ។

ម្យ៉ាងទៀត ការងារពលកម្មធ្វើឲ្យក្មេងមានសុខភាពមាំទាំល្អ និងមានកម្លាំងពលំខ្លាំងក្លាផង ។

ឃ) ក្នុងការអប់រំកូនចៅត្រូវជៀសវាងដាច់ខាតកុំបញ្ចោរកុំបញ្ចើចបញ្ចើ ឬក៏អួតសរសើរវានៅនឹងមុខ ពីព្រោះការអប់រំបែបនេះវាបណ្តុះតែបុគ្គលនិយមនិងអំនួតអួតអាងឲ្យដល់ក្មេងតែប៉ុណ្ណោះ ។ ដូច្នោះវានឹងទៅជាក្មេងក្រអឺតក្រទម បុគ្គលនិយម មិនសុភាពរាបសា ទាំងអាកប្បកិរិយា ទាំងគោលជំហរសតិអារម្មណ៍ ។ ដូច្នោះដល់ធំឡើងវាកសាងខ្លួនក៏មិនបានចំរើនដែរ ។

តែម្យ៉ាងទៀត ក្នុងការអប់រំកូនចៅក៏ត្រូវជៀសវាងកុំជេរស្តីបន្ទោស បន្ទាប់បន្ថុះ ត្មះតិះដៀលឬសម្លុតគំរាមកំហែងបន្ទាចបំភិតបំភ័យក្មេងឲ្យសោះ ។ ពីព្រោះការអប់រំរបៀបនេះនឹងធ្វើឲ្យក្មេងតុញតុះគំនិតប្រាជ្ញា ខ្លាចបាក់ស្បាត ចាញ់ប្រាបគេគ្មានគំនិតផ្តើម ព្រមទាំងកសាងនូវអត្តភាពក្មេងក៏មិនបាន ។ ដូច្នោះធំឡើងវានឹងទៅជាមនុស្សឆាប់សុញគំនិត មិនធុះធ្លាយ មិនឈ្លាសវៃ មិនអង់អាចក្លៀវក្លា មិនសកម្មប្រយុទ្ធ គ្មានគំនិតផ្តើម និងគ្មានអត្តភាពអ្វីទាំងអស់ ។ ដូច្នេះនៅក្នុងចលនាបដិវត្តគឺកសាងខ្លួនយឺតណាស់ ។ ដូច្នេះក្នុងការអប់រំកូនចៅ យើងត្រូវដើរផ្លូវកណ្តាល កុំបញ្ចើចបញ្ចើ តែក៏កុំបន្តុះបន្ទាប់ កុំថ្នាក់ថ្នមបញ្ចោរលើកដើង តែក៏កុំគំហកកំហែងគំរាមនាយអាយដែរ ។ បើក្មេងធ្វើខុស-ត្រូវយ៉ាងណា យើងត្រូវតែអប់រំវែកញែកពន្យល់ឲ្យវាយល់ ឲ្យវាឃើញច្បាស់ដោយខ្លួនវា តើធ្វើយ៉ាងម៉េចត្រូវ ធ្វើយ៉ាងម៉េចខុស យ៉ាងម៉េចល្អ យ៉ាងម៉េចអាក្រក់ ហើយប្រាប់វាកុំឲ្យធ្វើអ្វីដែលខុស ដែលអាក្រក់ ឲ្យធ្វើតែការងារណាដែលល្អត្រឹមត្រូវ ។ បើវាធ្វើខុស ត្រូវប្រាប់វាថា ធ្វើនេះខុសហើយ ហើយប្រាប់វាកុំឲ្យធ្វើទៀត ។ តែបើវាធ្វើត្រូវ ធ្វើល្អក៏ត្រូវលើកជាគុណសម្បត្តិ លើកទឹកចិត្តនិងជំរុញឲ្យក្មេងធ្វើកាន់តែល្អថែមទៀត ។ ធ្វើដូច្នេះទើបអប់រំកសាងក្មេងបានត្រឹមត្រូវល្អ និងកាន់តែចំរើនជឿនលឿនទៅមុខជានិច្ច ។

ង) ក្នុងការអប់រំកូនចៅ ត្រូវជៀសវាងដាច់ខាតកុំកាន់ជើងវានៅពេលដែលវាមានទំនាស់ជាមួយអ្នកណា ឬជាមួយក្មេងដទៃទៀត ហើយកុំទំលាប់ស្តាប់ការប្តឹងផ្តល់ឬសេចក្តីរាយការណ៍មិនល្អពីអ្នកនេះពីអ្នកនោះឲ្យសោះ ។ ពីព្រោះបើយើងធ្វើដូច្នេះម្យ៉ាងនឹងនាំឲ្យក្មេងមានអាង មានបង្អែក ហើយដើរទន្រ្ទានក្មេងដទៃ តែម្យ៉ាងទៀត ក៏ទំលាប់ក្មេងឲ្យនិយាយដើមវាយប្រហារគេឯងដែរ ។ បើវាមានទំលាប់បែបនេះតាំងពីក្មេងទៅហើយនោះដល់ធំឡើងវានឹងកាន់តែមានទំលាប់អាក្រក់ច្រើនថែមទៀតដែលនឹងនាំមកនូវការបែកបាក់សាមគ្គីផ្ទៃក្នុង និងនាំមកនូវការសោហ្មងដល់ខ្លួនវាទៀតផង ។

ដូច្នេះ បើកូនចៅមានការឈ្លោះប្រកែកទាស់ទែងនឹងអ្នកណា ត្រូវចេះនិយាយសំរបសំរួលឲ្យជានាស្រួលបួលនឹងគ្នាវិញ កុំកាន់ជើង ក៏កុំប្រកាន់ថាកូនយើងវាត្រូវ កូនគេវាខុសឲ្យសោះ ។

ទោះបីជាមានការលើសលោះគ្នាយ៉ាងណាក៏ត្រូវអប់រំពន្យល់កុំឲ្យវាឈ្លោះគ្នាទៀត ។ ហើយបើវាប្តឹងផ្តល់ឬរាយការណ៍មិនល្អពីអ្នកណា ម៉ែឪកុំចេះតែស្តាប់ហើយបន្ទោសតាមកូន ឬក៏ចេះតែលេងសើចជាមួយកូនឲ្យសោះ ។ យើងត្រូវទប់ទល់ហើយអប់រំកុំឲ្យវានិយាយដូច្នេះទៀត ។ ធ្វើយ៉ាងនេះទើបអប់រំកូនចៅក៏បានល្អ ហើយក៏មិននាំឲ្យមានការសៅហ្មងឬការបែកបាក់សាមគ្គីរវាងចាស់និងចាស់ទៀតផង ។

ទាំងនេះគ្រាន់តែជាវិធីអប់រំកូនចៅមួយចំនួនតែប៉ុណ្ណោះ ដែលយើងខ្ញុំសូមលើកឡើងគ្រាន់ជាការទាញអារម្មណ៍ដល់មាតាបិតាបដិវត្តយើងទាំងអស់ដែលចង់អប់រំកសាងកូនឲ្យបានល្អ ឲ្យទៅជាជនបដិវត្តល្អតរៀងទៅ ។

## បាតុភាពខុសឆ្គងមួយចំនួនក្នុងការអប់រំកសាងកូនចៅកន្លងមក

កន្លងមក មានឪពុកម្តាយខ្លះស្រឡាញ់កូនគ្រាន់តែដើម្បីស្រឡាញ់ប៉ុណ្ណោះ តែគ្មានទិសដៅច្បាស់លាស់ថាតើចង់កសាងកូនចៅយើងដល់ពេលវាធំឡើងឲ្យទៅជាអីឬឲ្យវាធ្វើអីនោះទេ ។ ដូច្នោះហើយ ក្នុងការអប់រំកូនចៅគឺមានត្រឹមតែថ្នាក់ថ្នម ទំរើសទំយើ មិនហ៊ានឲ្យកូនធ្វើការអីទេ ខ្លាចលំបាក ខ្លាចហត់នឿយ ។ ឯខាងសំភារៈក៏គិតតែពីថែបំប៉ន ធ្វើយ៉ាងណាឲ្យតែពីខាងឆ្ងាញ់ ឲ្យតែពីខាងសំបូរសប្បាយ និងឲ្យបានហ៊ឺហាឆើតឆាយដាច់គេ តែមិនសូវយកចិត្តទុកដាក់អប់រំកសាងកូនខាងសីលធម៌រស់នៅល្អ ខាងសីលធម៌ប្រយុទ្ធធ្វើការងារ ខាងការប្រយុទ្ធជាមួយធម្មជាតិក៏ដូចប្រយុទ្ធពុះពារឧបសគ្គតូចធំគ្រប់បែបយ៉ាងដែរ ។ មិនអប់រំកសាងកូនឲ្យស្គាល់ការលំបាក ការស្រួល ឲ្យស្គាល់សង្គមមនុស្ស ឬស្គាល់ល្អអាក្រក់ឡើយ ដោយភ័យខ្លាចកូនព្រួយចិត្ត ភ័យខ្លាចកូនលំបាកវេទនា ។ តែមិត្តយើងភ្លេចគិតថាជីវិតមនុស្សវាមានព្រំដែន យើងជាម៉ែឪមិនមែនចេះតែរស់នៅចិញ្ចឹមវាបំរើថ្នាក់ថ្នមវា និងទំនុកបំរុងផ្គត់ផ្គង់វា បានជារៀងរហូតទៅទេ ។ មិនដឹងជាថ្ងៃណាយើងនឹងស្លាប់បាត់បង់ជីវិតចោលវាបាត់ទៅហើយ ។ ហើយបើយើងអប់រំកសាងវារបៀបខាងលើនេះ នៅពេលដែលអត់ពីយើងទៅនោះហើយ ដែលកូនចៅយើង

កងកុមារីក្នុងរបបកម្ពុជាប្រជាធិបតេយ្យ



រឹតតែលំបាកវេទនាជាងពីកាលយើងអប់រំកសាងវាឲ្យស្គាល់ការលំបាកការស្រួលពីក្មេងទៅទៀត ។ ពីព្រោះវាគ្មានយល់ដឹងអ្វីទាំងអស់អំពីជីវិតមនុស្សនៅក្នុងសង្គម គ្មានចេះធ្វើការងាររកស៊ីអ្វីទាំងអស់ ។ល ។ ប្រៀបបីដូចជាដើមម្ទូដែលធ្លាប់តែវារឡើងលើជន្ទល់ ធ្លាប់តែអាស្រ័យពឹងពាក់លើជន្ទល់ដើម្បីរស់រានមានជីវិតនិងដុះលូតលាស់ទៅមុខទៀត ។ លុះដល់ជន្ទល់ពុកដួលរលំទៅ ដើមម្ទូក៏ត្រូវរលំដួលស្លាប់ដែរ ឬយ៉ាងហោចណាស់ក៏ត្រូវរួញស្វិតក្រញង់ពុំអាចដុះលូតលាស់ល្អតទៅទៀតបានឡើយ ។ យ៉ាងណាមិញ កូនចៅដែលយើងអប់រំតាមរបៀបខាងលើក៏ដូច្នោះដែរ ។

ម្យ៉ាងទៀត មានឪពុកម្តាយខ្លះស្រឡាញ់កូន ចង់ឲ្យកូនធ្វើបដិវត្ត ចង់ឲ្យកូនចេះដឹងចំរើនលូតលាស់ដែរ តែមិនបានត្រៀមរៀបចំអប់រំកសាងអនាគតឲ្យកូនឡើយ ។ ឪពុកម្តាយខ្លះស្រឡាញ់កូនហើយឱបក្រសោបកូនក្រុងកូនឲ្យតែនៅជិតខ្លួន មិនហ៊ានឲ្យកូនបែកទៅណាឆ្ងាយ ឬមិនហ៊ានឲ្យកូនទៅរស់នៅក្នុងសមូហភាពជាមួយមហាជនទេ ខ្លាចគេធ្វើបាបកូន ខ្លាចកូនអត់ឃ្លាន ខ្លាចកូនលំបាកវេទនា ខ្លាចគេប្រើកូនឲ្យធ្វើការហត់នឿយ ។ល ។

មានឪពុកម្តាយខ្លះទៀត សុខចិត្តឲ្យកូនទៅរស់នៅក្នុងសមូហភាពហើយ តែដល់ឃើញកូនចេះធ្វើការងារពលកម្មតូចធំធ្ងន់ស្រាលបានដូចគេឯង មិនសប្បាយរីករាយពេញចិត្តពេញថ្លើមនឹងកូនទេ បែរទៅជាអាណិតកូន ថាកូនលំបាកវេទនាណាស់ ថាគេធ្វើបាបកូនខ្លួនទៅវិញ ។

មានឪពុកម្តាយខ្លះទៀតឃើញកូនលត់ដំហ្វឹកហ្វឺនខ្លួនបានល្អ ចេះទ្រាំទ្រលំបាកវេទនា ស៊ីអត់ស៊ីឃ្លាន ស្លៀកពាក់កណ្ដុចកណ្ដាចដូចគេដូចឯងបាន បែរទៅជាស្រក់ទឹកភ្នែកអាណិតកូន ថាកូនខ្លួនលំបាកវេទនា តែមិនព្រមមើលឃើញកូនចៅប្រជាជន-មហាជនឯទៀតផង តើគេរស់នៅយ៉ាងម៉េចក្នុងចលនាបដិវត្តដែលកំពុងខ្វះខាតសព្វថ្ងៃ ។ល ។

ដោយមានទស្សនៈគោលជំហរខុសឆ្គងចំពោះការអប់រំកសាងកូនចៅយ៉ាងនេះ ឪពុកម្តាយទាំងនោះក៏អប់រំឬនិយមចិញ្ចឹមអប់រំកសាងកូនចៅឲ្យសំបូរបែបទៅតាមបែបផែននឹងរបៀបរបបខ្មាំង ដែលវារស់នៅសំបូរហូរហៀរដោយការរឹបជាន់ឆក់ប្លន់ប្រជាជនយើងដោយមិនដឹងខ្លួន ។

ឧទាហរណ៍ៈ នៅកន្លែងខ្លះក្នុងសម័យបដិវត្តយើងឥឡូវហើយ ក៏នៅមានម៉ែខ្លះយល់ខុសថា មិនហ៊ានឲ្យកូនបៅដោះម្ដាយទេ (និយាយចំពោះម្តាយដែលមានសុខភាពល្អ) ខ្លាចមិនធំធាត់ ហើយក៏គាំងឲ្យកូនបៅទឹកដោះគោវិញ ។ អ្នកខ្លះទៀតទឹកដោះគោកំប៉ុងហើយក៏មិនហ៊ានឲ្យបៅដែរ ទាល់តែទឹកដោះគោម្សៅទើបពេញចិត្ត ។ មិត្តយើងមើលមិនឃើញថាតើកូនចៅប្រជាជន-មហាជនដែលរស់ងរោកងងល់ ធ្វើបដិវត្តន៍វាយចក្រពត្តិអាមេរិកឈ្នះសព្វថ្ងៃ តើគេបៅអី?

ឧទាហរណ៍ៈ អ្នកខ្លះទៀត ពេលបំបៅកូនមិនហ៊ានធ្វើពលកម្មហាលថ្ងៃទេ ថាក្តៅទឹកដោះកូនបៅទៅរាកអាចម៍ ។ ចុះប្រជាជនកម្ពុជាយើងទូទាំងប្រទេសដែលធ្វើការងារពលកម្ម ហាលខ្យល់ ហាលថ្ងៃ ដើម្បីចិញ្ចឹមជីវិតរាល់ថ្ងៃ ម្តេចក៏គេបំបៅកូនគេចិញ្ចឹមកូនគេរស់ ។ ឯការរាកអាចម៍វាមានមូលហេតុផ្សេងទេ ។

ឧទាហរណ៍ៈ មិត្តយើងខ្លះទៀតចិញ្ចឹមកូនចៅសំបូរបែបមើលតែនៅក្នុងសង្គមចក្រពត្តិ-អាណានិគមនិងបនអាក្សត់នៅភ្នំពេញដូច្នោះដែរ គ្រាន់តែខោអាវក្រណាត់ហាលម្តងៗពីរ-បីស្ទួ ក្រៅពីនេះនៅមានសាប៊ូក្រអូប ម្សៅក្រអូប និងរបស់របរផ្សេងៗទៀតគ្រប់បែបយ៉ាង ហើយឲ្យតែខ្វះអីបន្តិចក៏ត្អូញត្អែរថាអាណិតកូន ។ មើលទៅហាក់ដូចជាមិនមែនឋិតក្នុងសម័យបដិវត្តដែលកំពុងធ្វើសង្គ្រាមតឹងតែងស្វិតស្វាញជាមួយចក្រពត្តិនិងបនអាក្សត់ជាបរិវារវាឡើយ ។ មិត្តយើងភ្លេចគិតដល់វីរភាពយុទ្ធជន-យុទ្ធនារីដែលរស់នៅខ្វះខាត លំបាកវេទនា ប្រយុទ្ធស្លាប់-រស់ បង្ហូរសាច់បង្ហូរឈាមជាមួយខ្មាំងនៅឯសមរភូមិមុខជារៀងរាល់ថ្ងៃ ភ្លេចគិតដល់ជីវភាពប្រជាជនដែលកំពុងលំបាកវេទនាឈឺចាប់ខ្លោចផ្សា ខ្វះគាំងពីអំបិល ក្រណាត់ ថ្នាំពេទ្យ និងស្បៀងអាហារផ្សេងៗ ។

ឧទាហរណ៍ៈ មិត្តយើងខ្លះទៀត ក្នុងការចិញ្ចឹមកូនតាំងពីកូនង៉ាឡើងទៅ ឲ្យតែឈឺអីបន្តិចបន្តួច ទំលាប់ប្រើប្រាស់ថ្នាំសង្កូវខ្ពស់ៗ ហូរហៀរសំបូរបែបគ្រប់មុខ គ្រប់សព្វ ដែលមិនមែនជាការចាំបាច់ ។

ឧទាហរណ៍ៈ ឪពុកម្តាយខ្លះទៀតទំលាប់ឬបណ្តោយឲ្យកូនតូចៗជេរឪពុកម្តាយលេង ឬជេរមនុស្សធំមនុស្សចាស់លេងតាមចិត្ត មិនទប់ទល់ មិនអប់រំតំរែតំរង់វាទេ ដោយសំអាងលេសថាវានៅតូច មិនទាន់ដឹងអី តែនេះក៏ជាទំលាប់អាក្រក់ ទំលាប់ឲ្យវាព្រហើនកោងកាចដែរ ។ល ។

ទស្សនៈគោលជំហរក្នុងការអប់រំកសាងកូនចៅនិងរបៀបរបបចិញ្ចឹមកូនចៅបែបខាងលើទាំងប៉ុន្មាននេះ ទោះចង់ឬមិនចង់ដឹងខ្លួនក្តី មិនដឹងខ្លួនក្តី គឺវាឈានទៅនិយមចូលចិត្តតាមទស្សនៈគោលជំហរនិងរបៀបរបបអប់រំនិងចិញ្ចឹមកូនចៅតាមបែបដែនសក្តិភូមិ[sic: printed as សង្គមបក្រពត្តិ]-អាណានិគមនិងបនក្បត់ហើយ ។ ទស្សនៈគោលជំហរនិងរបៀបចិញ្ចឹមកូនចៅទាំងនេះវាគ្មានលក្ខណៈបដិវត្តគ្មានលក្ខណៈមហាជនទេ ពីព្រោះវាមិនសមស្របនឹងសភាព-ការណ៍នៃចលនាបដិវត្តយើងសព្វថ្ងៃដែលក្រឌ្សត់ខ្លះមុខខ្លះក្រោយ ហើយកំពុងប្រយុទ្ធវាយកំទេចចក្រពត្តិអាមេរិកនិងបនអាក្បត់ដែលជាបរិវារជាច់ថ្លៃរបស់វាផង និងប្រយុទ្ធការពារឯករាជភាព អត្តភាព និងកិត្យានុភាពរបស់ប្រជាជាតិ និងចលនាបដិវត្តកម្ពុជាយើងផងដែរ ។

ដូច្នេះ បើមាតាបិតាបដិវត្តយើងមានទស្សនៈគោលជំហរចិញ្ចឹមបីបាច់និងអប់រំកសាងកូនចៅតាមរបៀបនេះ នោះគឺពុំអាចអប់រំកសាងកូនចៅយើងឲ្យបានល្អសមស្របតាមគោលបំណងនិងសំណូមពររបស់យើងឡើយ ។ យើងពុំអាចកសាងវាឲ្យទៅជាជនបដិវត្តល្អមួយរូបបានឡើយ ។ ដូច្នេះទៅថ្ងៃក្រោយ កូនយើងនឹងលំបាកវេទនា ឬយ៉ាងហោចណាស់ក៏គ្មានអនាគតភ្លឺស្វាងដែរ ។ ដូច្នេះមិនមែនបានសេចក្តីថាយើងចេះស្រឡាញ់កូនចៅទេ តែផ្ទុយទៅវិញ ទោះចង់ឬមិនចង់ បើយើងអប់រំកសាងនិងចិញ្ចឹមកូនចៅតាមរបៀបខុសឆ្គងខាងលើនេះ នោះបានសេចក្តីថាយើងធ្វើបាបកូនចៅយើងវិញទេទៅថ្ងៃក្រោយ ។

ឪពុកម្តាយគ្រប់រូប មិនថាជារស់នៅក្នុងមជ្ឈដ្ឋានណាឡើយ សុទ្ធតែមានមនោសញ្ចេតនាស្រឡាញ់ថ្នាក់ថ្នមកូនទាំងអស់គ្នា ។ បដិវត្តមិនមែនហាមប្រាមមិនឲ្យមាតាបិតាស្រឡាញ់បុត្រធីតារបស់ខ្លួនទេ តែវាខុសពីសង្គមចាស់ត្រង់ដែលថា មាតាបិតាបដិវត្តត្រូវចេះស្រឡាញ់កូន ត្រូវចេះអប់រំកសាងកូនឲ្យវាដើរផ្លូវល្អ ផ្លូវត្រឹមត្រូវ ពោលគឺត្រូវចេះកសាងអនាគតភ្លឺស្វាងឲ្យកូនយើងធ្វើយ៉ាងណាឲ្យប្រជាជន-មហាជនទូទៅគេស្រឡាញ់ពេញចិត្តពេញថ្លើមជាមួយយើងផងដែរ មិនមែនគ្រាន់តែស្រឡាញ់កូនដើម្បីស្រឡាញ់តែម្នាក់ឯងនោះទេ ។

តើអនាគតភ្លឺស្វាងរបស់កូនចៅយើងនៅក្នុងសម័យបដិវត្តឥឡូវនៅត្រង់ណា? គឺពិតជាពុំមែនឋិតនៅត្រង់រកទ្រព្យសម្បត្តិស្តុកស្តម្ភទុកឲ្យវា ឬទិញសញ្ញាប័ត្រទិញតំណែងនាទីធំៗទុកឲ្យវានោះទេ ហើយក៏រឹតតែពុំមែនឋិតនៅលើវិមានភូមិគ្រឹះស្កឹមស្កៃ ឡាន ម៉ូតូ នាឡិកាដៃ មាសពេជ្រ ឬខោអាវឆើតឆាយហ៊ឺហាជាច់គេនោះទេ ។ អនាគតភ្លឺស្វាងរបស់កូនចៅយើងក្នុងសម័យបដិវត្តយើងឥឡូវ ក៏ដូចតទៅអនាគតទៀត គឺឋិតនៅត្រង់ធ្វើយ៉ាងណាអប់រំកសាងគោលជំហរបដិវត្តឲ្យវាឲ្យបានរឹងប៉ឹងល្អ ពោលគឺឲ្យវាចេះរស់នៅក្នុងសមូហភាព គោរពអង្គការវិន័យហ្មត់ចត់ត្រឹមត្រង់ ឲ្យវាចេះទ្រាំទ្រការលំបាកវេទនាសព្វបែបយ៉ាងទាំងអស់ ឲ្យវាចេះធ្វើគ្រប់កិច្ចការតូចធំ ធ្ងន់ស្រាល ដើម្បីថ្ងៃក្រោយមានសមត្ថភាពនឹងបំរើប្រទេសជាតិ បំរើប្រជាជនឲ្យបានល្អនិងបានច្រើនជាអតិបរមា ឲ្យវាមានគោលជំហរនិងអាកប្បកិរិយាស្លូតបូតរាបសា ចេះស្រឡាញ់ គោរព ស្មោះត្រង់ចំពោះប្រជាជន-មហាជនជានិច្ច គួរជាទីស្រឡាញ់រាប់អាននិងជឿទុកចិត្តទុកថ្លើមរបស់ប្រជាជន-មហាជនគ្រប់គ្នា ។ បើកូនចៅយើងមានទំលាប់របៀបរបបរស់នៅ ធ្វើការងារ ស៊ីចុក ស្លៀកពាក់ ល្អត្រឹមត្រូវ និងមានគោលជំហរបដិវត្តរឹងប៉ឹងដូច្នេះហើយ ទោះបីជាយើងរស់នៅក្តី ឬស្លាប់ចោលវាក្តី ក៏ធានាថាកូនចៅយើងនឹងអាចរស់នៅដោយសុខដុមរមនាក្នុងសមូហភាព ជាមួយនឹងសមូហភាពបាន ប្រជាជន-មហាជនគេពិតជាស្រឡាញ់រាប់អានពេញចិត្តពេញថ្លើមនឹងវា ។ ដូច្នេះ កូនចៅយើងក៏ប្រាកដជានឹងមានអនាគតភ្លឺស្វាងត្រចះត្រចង់ពុំខានឡើយ ។

ដូច្នេះ មាតាបិតាបដិវត្តយើងត្រូវចេះស្រឡាញ់កូន ត្រូវមានទស្សនៈគោលជំហរបដិវត្តឲ្យត្រឹមត្រូវក្នុងការស្រឡាញ់កូននេះ ហើយមានទិសនិងវិធីចិញ្ចឹមបីបាច់និងអប់រំកសាងវាឲ្យបានត្រឹមត្រូវល្អតាំងពីតូចៗទៅ ទើបអប់រំកសាងកូនចៅយើងបានល្អ ។

**(ដកស្រង់ពីសៀវភៅកំណត់ហេតុលេខ ០០៨)**

# បញ្ជីឈ្មោះជនរងគ្រោះជនបរទេសដែលបានកម្ទេចនៅមន្ទីរស-២១

រៀបរៀងដោយៈ យិន នាន

(តពីលេខមុន)

| ល.រ | នាម-គោត្តនាម | សញ្ជាតិ | មុខងារ | ចាប់មកពី | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|---|
| ១៥៣ | តឹង ខាន់ស៊ុន | យួន | គិញយួន | ស្រុកយួន | ៣១-៥-៧៧ | ២០-១០-៧៧ |
| ១៥៤ | ង្វៀន វ៉ាងញឹម | យួន | សក្តិ២ | ស្រុកយួន | ៣១-៥-៧៧ | ២០-១០-៧៧ |
| ១៥៥ | ប្រាំ គាងយឿម | យួន | ? | ស្រុកយួន | ៣១-៥-៧៧ | ២០-១០-៧៧ |
| ១៥៦ | ង្វៀង យ៉ាងប៊ិន | យួន | ? | ស្រុកយួន | ៣១-៥-៧៧ | ២០-១០-៧៧ |
| ១៥៧ | ទឹង យ៉ាងទុង | យួន | ? | ស្រុកយួន | ៣១-៥-៧៧ | ២០-១០-៧៧ |
| ១៥៨ | ដាំ យ៉ាងជីង៉ុន | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៥៩ | ចាំង ថាន់ហឿង | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៦០ | ឡេ យ៉ាងម៉ាយ | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៦១ | ដឹម យ៉ាងគឹង | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៦២ | តាំង ង៉ុកហ៊ុង | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៦៣ | លេ ថាក់ឡឹយ | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៦៤ | ដាង យ៉ាងថា | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៦៥ | ង្វៀង ធូធឿង | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៦៦ | គឹម ង៉ុកទៀង | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៦៧ | ចាង យ៉ាងហេវ | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៦៨ | ង្វៀង ដិនអ៊ី | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៦៩ | ឡេ យ៉ាងម៉ាយ | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៧០ | ដាំង យ៉ាងថាន់ | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៧១ | យ៉ី យ៉ាងថាន់ | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៧២ | ង្វៀង ហូឡាង | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៧៣ | យ៉ី យ៉ាងដាង | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៧៤ | ចឹង យឹងកេុ | យួន | ? | កំពង់សោម | ៧-៥-៧៦ | ២៤-៥-៧៦ |
| ១៧៥ | លី យ៉ាភៀក | យួន | ? | កំពង់សោម | ៩-៥-៧៦ | ឈឺស្លាប់ |
| ១៧៦ | ង្វៀង យ៉ាវ | យួន | ? | កំពង់សោម | ១០-៥-៧៦ | ឈឺស្លាប់ |
| ១៧៧ | ទៀ យ៉ាងងៀ | យួន | ? | កំពង់សោម | ១០-៥-៧៦ | ឈឺស្លាប់ |
| ១៧៨ | ចាង ង្វៀងឡឹប | យួន | គិញយួន | កំពង់សោម | ១៤-៥-៧៦ | ឈឺស្លាប់ |
| ១៧៩ | ជឹង វ៉ាងយី | យួន | គិញយួន | កំពង់សោម | ១៤-៥-៧៦ | ឈឺស្លាប់ |

(នៅមានត)

# វណ្ណៈសង្គមនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ



នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ «វណ្ណៈ» គឺជាមូលដ្ឋាននៃការកសាងសង្គមបដិវត្ត ។ នៅក្នុងវចនានុក្រមខ្មែរ «វណ្ណៈ» សំដៅទៅលើពណ៌សម្បុរ ពន្លឺ ភេទ ថ្នាក់វង្ស ពូជពង្ស របស់មនុស្ស ។ ចំណែកឯនៅក្នុងសៀវភៅកំណត់ហេតុរបស់ខ្មែរក្រហមបានពន្យល់ថាៈ

«វណ្ណៈគឺ អ្នកមាន អ្នកក្រ អ្នកសុំទាន អ្នករកស៊ីលក់កម្លាំង ។ ដើម្បីកំណត់ថាអ្នកនេះវណ្ណៈអ្វី គឺត្រូវវិនិច្ឆ័យទៅលើលក្ខណៈសេដ្ឋកិច្ចនិងលក្ខណៈនយោបាយ» ។ បញ្ហាវណ្ណៈបានធ្វើឲ្យមានកំហឹងយ៉ាងស្រួចស្រាល់នៅក្នុងស្រទាប់វណ្ណៈកម្មករនិងកសិករ ។ ប្រជាជនដែលទទួលរងនូវការជិះជាន់ពីវណ្ណៈផ្សេងៗ និងបន្ថែមដោយការបញ្ឆេះកំហឹងផងនោះ ក៏បានប្រមូលផ្តុំគ្នាបង្កើតជាចលនាបដិវត្តន៍មួយ ។ នៅឆ្នាំ១៩៦៦ សម្តេចព្រះ នរោត្តម សីហនុ បានហៅក្រុមតស៊ូតូចមួយថា «ខ្មែរក្រហម» ។ ប្រាំបួនឆ្នាំក្រោយមក គឺនៅថ្ងៃទី១៧ មេសា ឆ្នាំ១៩៧៥ ខ្មែរក្រហមបានឈានដើរមកកាន់អំណាចនៅកម្ពុជាទាំងមូល ។

ខ្មែរក្រហមមានមោទកភាពយ៉ាងខ្លាំងចំពោះជ័យជម្នះជាប្រវត្តិសាស្ត្ររបស់ខ្លួន ដែលឈរនៅលើគំនិតថា «បានរំដោះប្រជាជន កម្មករ កសិករក្រ កណ្តាល ថ្នាក់ក្រោម និងពលករផ្សេងទៀត» ។ នៅក្នុងឯកសារប្រជុំសន្និបាតលើកទី១របស់សភាតំណាងប្រជាជនរបស់ខ្មែរក្រហមបានកត់ត្រាថា «មិនដែលមានទេនៅក្នុងប្រវត្តិសាស្ត្ររបស់ប្រជាជាតិនិងប្រជាជនកម្ពុជារាប់ពាន់ឆ្នាំមកហើយដែលវណ្ណៈកម្មករ កសិករ និងពលករកម្ពុជា ត្រូវបានជិះជាន់សង្កត់សង្កិន បន្ទុះបន្ទាប់ ប្រមាថមើលងាយ និងជាន់ឈ្លីទៅក្នុងភក់ជ្រាំ មិនមានពេលងើបមុខរួចសោះ ត្រូវបានឡើងកាន់អំណាចយ៉ាងដូច្នេះ» ។

ប៉ុល ពត គឺជាមេដឹកនាំរបបខ្មែរក្រហម ដែលមានឈ្មោះដើម សាឡុត ស កើតនៅថ្ងៃទី២៥ ខែមករា ឆ្នាំ១៩២៥ (ឆ្នាំឆ្លូវ) ក្នុងត្រកូលកសិករមួយនៃទីរួមខេត្តកំពង់ធំ ។ ប៉ុល ពត ធ្លាប់បាន

បួសជាសាមណេរអស់រយៈពេលមួយវស្សានៅវត្តបទុម ។ នៅឆ្នាំ១៩៤៤ ប៉ុល ពត បានបញ្ចប់ការសិក្សាថ្នាក់វិទ្យាល័យនៅខេត្តកំពង់ធំ ។ ឆ្នាំ១៩៤៩ ប៉ុល ពត បានទទួលអាហារូបករណ៍ទៅសិក្សាបច្ចេកទេសនៅប្រទេសបារាំង ហើយត្រឡប់មកប្រទេសវិញនៅថ្ងៃទី១៤ខែមករា ឆ្នាំ១៩៥៣ ដោយសារប្រឡងធ្លាក់ ។ ក្នុងឆ្នាំ១៩៦៣ ឬ១៩៦៤ ប៉ុល ពត បានធ្វើជាគ្រូបង្រៀននៅវិទ្យាល័យចំរើនវិជ្ជានៅភ្នំពេញ ។ ក្នុងខណៈពេលប៉ុល ពត នៅជាគ្រូបង្រៀន ប៉ុល ពត បានសួរកូនសិស្សថា “តើយើងត្រូវធ្វើដូចម្តេចដើម្បីឲ្យប្រជាជនស្រឡាញ់យើង?” ។ សិស្សម្នាក់ក្នុងចំណោមសិស្សទាំងអស់បានឆ្លើយថា “ទាល់តែដាក់ខ្លួនឲ្យទាបដូចអ្នកដែលក្រីក្របំផុត ពេលនោះប្រជាជននឹងមកចោមស្រឡាញ់មិនខាន” ។ ចម្លើយនេះបានធ្វើឲ្យ ប៉ុល ពត ពេញចិត្តយ៉ាងខ្លាំង ព្រោះថាត្រូវនឹងគោលគំនិតដែលខ្លួនចង់បាន ។ ប៉ុល ពត បានអនុវត្តទ្រឹស្តីនេះក្រោយពេលដែលខ្លួនបានឡើងកាន់អំណាចក្នុងអំឡុងឆ្នាំ១៩៧៥-៧៩ ។ ជាបណ្តើរៗ ប៉ុល ពត បានអនុវត្តនយោបាយកម្ទេចមនុស្សទាំងឡាយណាដែលខ្លួនចាត់ទុកថាជាវណ្ណៈចក្រពត្តិនិងវណ្ណៈសក្តិភូមិ ។

នៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យ ការបែងចែកវណ្ណៈនិងការយល់ដឹងអំពីវណ្ណៈ មានដូចខាងក្រោម÷

**១) វណ្ណៈសក្តិភូមិ**

វណ្ណៈសក្តិភូមិចែកជាពីរគឺ សក្តិភូមិអភិជន និង សក្តិភូមិម្ចាស់ដី ។ វណ្ណៈសក្តិភូមិអភិជនគឺសំដៅទៅលើ ស្តេច នាហ្មឺនដែលមានអំណាចក្នុងរបបសក្តិភូមិ ។ តាំងពីក្រោយសង្គ្រាមលោកលើកទី២មក សក្តិភូមិអភិជនកាន់តែចុះខ្សោយ ព្រោះតែពួកនាយទុនកាន់តែដណ្តើមតួនាទីច្រើនឡើងៗ ។ ឯពួកសក្តិភូមិម្ចាស់ដីឋិតនៅក្នុងភាពជាទូទៅនៅឡើយ ។ នៅតាមជនបទនៃប្រទេសកម្ពុជា ម្ចាស់ដីបានទទួលផលមកពីដី ដូចជាយកដីជួលឲ្យប្រជាជនដែលមានជីវភាពខ្វត់ខ្សោយ និងយកលុយចងការ ។ របបសក្តិភូមិនៅកម្ពុជា សង្គមម្ចាស់ដីគឺជាគ្រឹះតំណាងនៃរបបសេដ្ឋកិច្ច ។ ក្រោយមក សក្តិភូមិម្ចាស់ដីបានក្លាយទៅជានាយទុនបន្តិចម្តងៗតាមរយៈរកស៊ីចងការបណ្តាក់ ជួលដី និងរកស៊ីលក់ដូរផ្សេងៗ បើបានផលពីខាងណាច្រើន កំណត់វណ្ណៈភាពខាងនោះ ។ នាយទុនកសិកម្មកាន់កាប់ដីធ្វើចម្ការដំណាំធំៗ ហើយជួលពលករមកធ្វើការឲ្យប្រាក់ខែតាមម៉ោងតាមពេល ។ ចំពោះវិស័យសេដ្ឋកិច្ចនិងនយោបាយរបស់វណ្ណៈសក្តិភូមិនិងអភិជនវណ្ណៈទាំងពីរនេះជិះជាន់កម្លាំងពលកម្មគេទាំងស្រុង ដូចជាជួលដី ចងការ បញ្ចាំ បណ្តាក់ ។ លក្ខណៈនយោបាយប្រតិកិរិយាប្រឆាំងប្រជាជននិងបដិវត្តន៍ក្នុងឋានៈជាវណ្ណៈ ។ អភិជនជាស្តេចជានាហ្មឺនគ្រប់គ្រងរដ្ឋអំណាចតំណាងឲ្យម្ចាស់ដី ដូចជាចៅហ្វាយខេត្ត ចៅហ្វាយស្រុក ។ ទោះតិចឬច្រើន វាតំណាងឲ្យម្ចាស់ដីក្នុងរបបសក្តិភូមិ ។ ដូចជាលក្ខណៈនយោបាយរបស់គេ ក្នុងឋានៈជាវណ្ណៈគឺប្រតិកិរិយា ប្រឆាំងប្រជាជននិងបដិវត្តន៍ ។

**២) វណ្ណៈនាយទុន**

វណ្ណៈនាយទុនចែកជាពីរប្រភេទគឺ នាយទុនកុំប្រាដ័រនិងនាយទុនជាតិ ។

នាយទុនកុំប្រាដ័រគឺជានាយទុនតំណាងផលប្រយោជន៍ឲ្យនាយទុនអន្តរជាតិ ហៅថាស្ថានកណ្តាល តំណាងឲ្យចក្រពត្តិបារាំង ចក្រពត្តិអាមេរិក អាល្លឺម៉ង់ខាងលិច និងជប៉ុន ។

នាយទុនជាតិគឺនាយទុនមិនតំណាងឲ្យជនបរទេស ។ រកស៊ីខាងឧស្សាហកម្មខាងពាណិជ្ជកម្ម ខាងកសិកម្ម ក្នុងក្របខ័ណ្ឌប្រទេសជាតិ ដោយប្រើប្រាស់វត្ថុធាតុដើមនិងប្រើប្រាស់មធ្យោបាយកម្លាំងពលកម្មជារបស់ជាតិខ្លួន ហើយលក់ផលិតផលនៅក្នុងប្រទេសឬនាំផលិតផលបន្តិចបន្តួចទៅលក់នៅក្រៅប្រទេស ។ ពួកនេះជិះជាន់កម្លាំងពលកម្មរបស់កម្មករ ។ លក្ខណៈនយោបាយរបស់នាយទុនជាតិគឺមានលក្ខណៈជាតិច្រើនជាងសក្តិភូមិ ។ ដូចនេះនាយទុនជាតិបានកំណត់ថាជាកម្លាំងជំនួយយុទ្ធសាស្ត្រនៃបដិវត្តប្រជាជាតិប្រជាធិបតេយ្យ ។ គោលបំណងបដិវត្តប្រជាជាតិប្រជាធិបតេយ្យគឺ កម្ទេចចក្រពត្តិ សក្តិភូមិនាយទុនប្រតិកិរិយា ។

វណ្ណៈសក្តិភូមិនិងនាយទុនគឺជាសត្រូវធំបំផុតរបស់បដិវត្តន៍ដែលត្រូវតែបំបាត់ចោល ហើយឲ្យវណ្ណៈទាំងពីរនេះធ្វើពលកម្មដូចកសិករ និងធ្វើជារណបរដ្ឋអំណាចរបស់កម្មករ-កសិករវិញ

ដោយឲ្យប្រជាជនធ្វើជាម្ចាស់ការស្រុកភូមិស្រែចម្ការរបស់ខ្លួន មានសិទ្ធិសេរីភាពប្រជាធិបតេយ្យពិតប្រាកដ ។ ប្រជាជនជាអ្នកចាត់តាំងរដ្ឋអំណាចដឹកនាំទាំងផ្នែកនយោបាយ សេដ្ឋកិច្ច សង្គមកិច្ច វប្បធម៌ ។ល ។

### ៣) វណ្ណៈអនុធន

វណ្ណៈអធនគឺជាវណ្ណៈកណ្តាលត្រឹមរួចខ្លួន មិនជិះជាន់គេ ខ្លួនក៏មិនត្រូវបានគេជិះជាន់ដែរ ។ ផលប្រយោជន៍សេដ្ឋកិច្ចនិងនយោបាយយករួចខ្លួន សម្ញុំសុខ ។ វណ្ណៈអនុធនជាអ្នករកស៊ីលក់ដូរបន្តិចបន្តួចដោយខ្លួនឯង ។ បើអនុធន បញ្ញាជន សិស្ស អ្នករដ្ឋការ ចិញ្ចឹមជីវិតខាងកម្លាំងប្រាជ្ញាល្មមរួចខ្លួន ។ វណ្ណៈអនុធននេះត្រូវបានបែងចែកជាបីប្រភេទទៀតគឺៈ ទី១) អនុធនលើជាអ្នកជិះជាន់ពលកម្មបន្តិចបន្តួច ដើម្បីយកផលនេះមកថែមឲ្យលើសពីការគ្រប់គ្រាន់បន្តិច ។ អនុធនបញ្ញាជាន់លើ ជិះជាន់ពលកម្មខ្លះ ដូចជាជួលគេឲ្យមើលកូន ។ ទី២) អនុធនកណ្តាល គ្មានជិះជាន់ពលកម្មគេទេ ។ ទី៣) អនុធនក្រោម ហូបមិនបានគ្រប់គ្រាន់ ហើយយកកម្លាំងខ្លះទៅលក់ឲ្យគេទៀត ។ ចំណុចល្អរបស់ពួកអនុធនមានធាតុទាំងប្រជាជាតិ ទាំងប្រជាធិបតេយ្យ ប៉ុន្តែចំណុចខ្សោយ មិនមោះមុតដូចកម្មករ កសិករទេ ច្រើនយករួចខ្លួន សម្ញុំសុខ និងឃ្វេងឃ្វាង ជាសម្ព័ន្ធមិត្តនៃកម្មករនិងកសិករ ។

### ៤) វណ្ណៈកម្មករ

វណ្ណៈកម្មករគឺជាវណ្ណៈដែលលក់កម្លាំងពលកម្មទាំងអស់ឲ្យគេ ពិសេសលក់កម្លាំងឲ្យនាយទុន ។ វណ្ណៈកម្មករ គ្មានទ្រព្យធន មានតែកម្លាំង ហើយក៏គ្មានមធ្យោបាយផលិតកម្មដែរ ។ វណ្ណៈនេះតែងមានទំនាស់ និយាយរួមទំនាស់ជាមួយអ្នកជិះជាន់គេ ជាវណ្ណៈដែលមានធាតុបដិវត្តជាងគេ ជាវណ្ណៈដាច់ខាតជាងគេ បើប្រៀបធៀបទៅនឹងវណ្ណៈដទៃទៀត ។

### ៥) វណ្ណៈកសិករ

វណ្ណៈកសិករចែកជាបីៈ ទី១) កសិករមាន គឺកសិករធ្វើពលកម្មខ្លួននិងខ្លួន ហើយជិះជាន់កម្លាំងពលកម្មគេច្រើន ។ កសិករមានជិះជាន់គេប្រហែល៨០ភាគរយ ។ វណ្ណៈនេះមានធាតុទំនាស់និងទប់ទល់សក្តិភូមិនិងចក្រពត្តិ ហើយក៏មានចំណុចខ្សោយជិះជាន់គេដែរ ។ វណ្ណៈនេះមានលក្ខណៈប្រហែលនាយទុនជាតិដែរ ។ វណ្ណៈកសិករជាកម្លាំងធំមួយជាយុទ្ធសាស្ត្ររបស់បដិវត្តប្រជាជាតិប្រជាធិបតេយ្យ ។ ទី២) កសិករកណ្តាល ឬហៅថា អនុធនជនបទ មិនជិះជាន់គេ យករួចខ្លួន មិនចង់ឲ្យពួកបរទេសជិះជាន់ ស្អប់ពួកអ្នកជិះជាន់គេ ។ ពួកនេះមានលក្ខណៈប្រជាជាតិប្រជាធិបតេយ្យដែរ ។ កសិករកណ្តាលក្រោមមានជីវភាពខ្វះខាត ហើយលក់កម្លាំងរបស់ខ្លួនឲ្យគេខ្លះដើម្បីបំពេញជីវភាពរបស់ខ្លួន ។ ទី៣) កសិករក្រ ជាកសិករដែលខ្វះខាតខាងមធ្យោបាយផលិតកម្មនិងឧបករណ៍ផលិតកម្មច្រើន ។ កសិករក្រខិតខំបញ្ចេញកម្លាំងពលកម្មរបស់ខ្លួនទៅតាមមធ្យោបាយផលិតកម្មបន្តិចបន្តួច ដើម្បីដោះស្រាយជីវភាពរស់នៅ ប៉ុន្តែនៅតែមានការខ្វះខាតច្រើនក្នុងមួយឆ្នាំៗ ។ ដូច្នេះដើម្បីបំពេញកង្វះខាតក្នុងជីវភាព កសិករក្រត្រូវតែលក់កម្លាំងពលកម្មរបស់ខ្លួន ដូចជានៅតាមជនបទនិងនៅតាមទីក្រុង ធ្វើជាកម្មកសេរីជាដើម ។ កសិករក្រជាកម្លាំងបង្អែកនៃបដិវត្តន៍ ប្រជាជាតិប្រជា-ធិបតេយ្យនៅតាមជនបទ និងមានតួនាទីធំមហិមាណាស់ ក្នុងការរួមចំណែកជាមួយវណ្ណៈកម្មករក្នុងបដិវត្តន៍ ប្រជាជាតិប្រជាធិប-តេយ្យ ក៏ដូចជាបដិវត្តសង្គមនិយមនិងកុម្មុយនិស្តនិយមទៅអនាគត ។

ក្រៅពីវណ្ណៈខាងលើនេះ ក៏មានវណ្ណៈមួយចំនួនទៀតដែលខ្មែរក្រហមចាត់ទុកជាវណ្ណៈប្រតិកិរិយា ដែលមានការយល់ដឹងដូចខាងក្រោមនេះ÷

### ព្រះសង្ឃ

បក្សបានកំណត់វណ្ណៈភាពរបស់ព្រះសង្ឃថាជាវណ្ណៈពិសេសមានលក្ខណៈសេដ្ឋកិច្ចដូចតទៅៈ មិនធ្វើពលកម្មឬបង្កបង្កើនផលខ្លួនឯង ។ រស់នៅដោយសារប្រជាជនគ្រប់ប្រភេទ គឺជាវណ្ណៈពឹងផ្អែកសេដ្ឋកិច្ចរបស់ប្រជាជន ពិសេសពឹងផ្អែកលើសេដ្ឋកិច្ចរបស់កសិករក្នុងការចិញ្ចឹមជីវិត ។ ដូចជាព្រះសង្ឃមួយចំនួនដែលមានលក្ខណៈជាប់កសិករ ដូចកសិករ ហើយព្រះសង្ឃណាជាប់នឹងស្រទាប់លើគឺទទួលឥទ្ធិពលនយោបាយស្រទាប់លើ ។ ជារួមព្រះសង្ឃច្រើនជិតស្និទ្ធនឹងកសិករ ដូចនេះលក្ខណៈនយោបាយប្រហែល

កសិករដែរ ។ ចំពោះមន្ត្រីសង្ឃមានឋានន្តរស័ក្តិច្រើននៅស្រទាប់លើ ការទទួលឥទ្ធិពលនយោបាយក៏ពីស្រទាប់លើដែរ ។ ទន្ទឹមនឹងនេះ ព្រះសង្ឃក៏មានចំណុចល្អមួយចំនួនរបស់ព្រះអង្គដែរ គឺ "ព្រះសង្ឃមានចំណុចល្អខាងនយោបាយ គឺមានលក្ខណៈជាតិនិងស្រឡាញ់លទ្ធិប្រជាធិបតេយ្យ" ។ ចំណុចខ្សោយរបស់ព្រះសង្ឃគឺលក្ខណៈនយោបាយមិនច្បាស់លាស់ មកពីខ្លួនមិនសូវធ្វើពលកម្ម ការយល់ដឹងមិនជាក់ស្តែង ព្រំដែនវណ្ណៈមានភាពច្របូកច្របល់ មិនចេះបែងចែកការជិះជាន់ឲ្យដាច់ស្រឡះពីគ្នា ។ តាមចំណុចល្អរបស់សង្ឃបម្រើលក្ខណៈនយោបាយប្រឆាំងចក្រពត្តិនិងបរិវារច្រើន ។

**បញ្ញាជន**

បញ្ញាជនស្ថិតនៅក្នុងក្របខ័ណ្ឌវណ្ណៈអនុធន ដោយមានលក្ខណៈសេដ្ឋកិច្ចគ្រប់គ្រាន់ ហើយលក្ខណៈនយោបាយក៏កណ្តាលដែរ ។ ដោយឡែកបញ្ញាជនខ្លះស្ថិតនៅក្របខ័ណ្ឌស្រទាប់លើគឺវណ្ណៈប្រតិកិរិយា ដូចជា ពួកសក្តិភូមិ នាយទុន គេមានផលប្រយោជន៍ជាមួយពួកនេះ ។ ជាទូទៅបញ្ញាជនឋិតនៅក្របខ័ណ្ឌអនុធន ទោះលើទោះក្រោមក៏ដោយ ចំណុចពិសេសមួយគឺបញ្ញាជនឆាប់យល់ដឹងខាងកម្រិតទ្រឹស្តីវប្បធម៌ជាងពួកអនុធនធម្មតា ។

**ប៉ូលិស ទាហាន**

វណ្ណៈនេះគឺជាស្រទាប់វណ្ណៈពិសេសដែលកាន់អាវុធបម្រើរដ្ឋអំណាចផ្តាច់ការជិះជាន់ គឺជាកម្លាំងប្រដាប់អាវុធរបស់វណ្ណៈ ។ ប៉ូលិសនិងទាហានជាឧបករណ៍ផ្តាច់ការប្រដាប់អាវុធរបស់វណ្ណៈ ។ ចំពោះលក្ខណៈសេដ្ឋកិច្ច លក្ខណៈនយោបាយ នៅជាប់ជាមួយនឹងការជិះជាន់ គឺប្រតិកិរិយាដាច់ខាត ។

**បណ្តាជនជាតិ**

បណ្តាជនជាតិទាំងអស់នៅក្នុងសង្គមកម្ពុជាសុទ្ធតែមានការបែងចែកវណ្ណៈទាំងអស់ និយាយ រួមបណ្តាជនជាតិស្ថិតនៅក្នុងក្របខ័ណ្ឌវណ្ណៈកសិករ ។ ប៉ុន្តែជនជាតិន័យជារួមគឺការបែងចែកវណ្ណៈសម្បូរបែប ដូចជាជនជាតិខ្មែរដែរ តាមលក្ខណៈសេដ្ឋកិច្ចរបស់គេ ។ ពិសេសចំពោះបញ្ហាជនជាតិ ជាកសិករនៅព្រៃភ្នំតំបន់ដាច់ស្រយាល ខ្វះខាតលក្ខណៈសេដ្ឋកិច្ច ដូចលក្ខណៈនយោបាយប្រយុទ្ធខ្ពស់បំផុត ។ អ្នកទាំងអស់គឺជាកម្លាំងបដិវត្តន៍សំខាន់ណាស់ ។

ក្នុងចំណោមវណ្ណៈទាំងអស់ វណ្ណៈកម្មករនិងកសិករគឺជាវណ្ណៈដែលត្រូវបានយកចិត្តទុកដាក់ជាពិសេស ព្រោះថាវណ្ណៈទាំងពីរបានទទួលនូវការជិះជាន់តាំងពីយូរណាស់មកហើយ ។ ដូច្នេះជាពេលវេលាមួយដែលខ្មែរក្រហមគិតថាត្រូវតែផ្តល់តួនាទីដ៏សមរម្យមួយ ដើម្បីជាការឆ្លើយតបការខិតខំប្រឹងប្រែងរបស់អ្នកទាំងអស់នោះ ។ នៅក្នុងឯកសារកំណត់ហេតុរបស់ខ្មែរក្រហមបានកត់ត្រាថា "វណ្ណៈកម្មករមានតួនាទីជាអ្នកដឹកនាំ ឯវណ្ណៈកសិករជាកម្លាំងសម្ព័ន្ធមិត្តរបស់វណ្ណៈកម្មករ" "មានតែវណ្ណៈរបស់កម្មករតែមួយទេ ទើបដឹកនាំការបដិវត្តដាច់ខាតនឹងបានសម្រេចផល និងដឹកនាំទៅកាន់ជ័យជម្នះទីចុងបំផុត" ។ នៅក្នុងឯកសារប្រវត្តិរូប កម្មាភិបាលធំៗភាគច្រើនត្រូវបានជ្រើសចេញពីវណ្ណៈទាំងពីរនេះ ។ មិនតែប៉ុណ្ណោះ អ្នកគ្រប់គ្រងការងារនៅតាមមូលដ្ឋាន ភូមិ ឃុំ សហករណ៍ កងចល័តក្តី សុទ្ធសឹងជ្រើសរើសចេញពីវណ្ណៈកម្មករ-កសិករ ទោះអ្នកទាំងនោះមិនចេះអក្សរក៏ដោយ ។ នេះដោយសារតែអង្គការបានប្រកាន់យក "ជំហរវណ្ណៈមុនសមត្ថភាព" ម្យ៉ាងទៀតក្នុងគោលបំណងលើកស្ទួយវណ្ណៈកសិករដែល"ពុំបានរៀនសូត្រដូចវណ្ណៈជិះជាន់ដទៃទៀត រវល់តែលះបង់ពេលវេលាដ៏មានតម្លៃរបស់ខ្លួនការពារជាតិនិងចូលរួមបដិវត្តន៍" ។

ក្រៅពីវណ្ណៈទាំងពីរនេះគឺពុំបានទទួលនូវទំនុកចិត្តពីអ្នកដឹកនាំខ្មែរក្រហមឡើយ ហើយត្រូវស្ថិតនៅក្នុងការសង្ស័យរបស់ថ្នាក់លើជានិច្ច ទោះជាបុគ្គលនោះបានបម្រើផលប្រយោជន៍ឲ្យអង្គការក៏ដោយ ក៏ "អង្គការនៅតែមិនទុកចិត្ត" ។ ទីបំផុត បុគ្គលនោះបានទទួលការតបស្នងពីអង្គការវិញ ដោយជាប់គុក និងទទួលរងទារុណកម្មរហូតដល់ស្លាប់ ។ នៅក្នុងអំឡុងពេល៣ឆ្នាំ៨ខែ និង ២០ថ្ងៃ ខ្មែរក្រហមបានតាមដាននិងសើរើប្រវត្តិរូបអ្នកដែលមានចំណេះដឹងខ្ពង់ខ្ពស់ អតីតមន្ត្រីរដ្ឋការ នាយទាហាន ប៉ូលិសពីមុន យកទៅសម្លាប់ជាបន្តបន្ទាប់អស់រាប់លាននាក់ ។

**លី សុផល**

# បញ្ជីឈ្មោះជនរងគ្រោះដែលបានករម្ទេចនៅមន្ទីរ ស-២១ (គុកទួលស្លែង)

**រៀបចំនិងចងក្រងដោយៈ យិន នាន**

**(តពីលេខមុន)**

| ល.រ | ឈ្មោះ | តួនាទី | កន្លែងយក | ថ្ងៃចូល | ថ្ងៃកម្ទេច |
|---|---|---|---|---|---|
| ៥២៦ | ដួង់ សារឿន | ទាហាន | បាត់ដំបង | ២៥-៣-៧៦ | ២៧-៥-៧៦ |
| ៥២៧ | ប៊ូ ឈាន ហៅ ទូច | ទាហាន | តំបន់៣៣ | ២៨-៣-៧៦ | ២៧-៥-៧៦ |
| ៥២៨ | ប៊ូ អៀម | ទាហាន | តំបន់២៥ | ២៩-១-៧៦ | ២៧-៥-៧៦ |
| ៥២៩ | រិត រឿន | ទាហាន | បាត់ដំបង | ២១-៣-៧៦ | ២៧-៥-៧៦ |
| ៥៣០ | ទ្រី យុន | ទាហាន | តំបន់៣៣ | ១០-១០-៧៥ | ២៧-៥-៧៦ |
| ៥៣១ | លី គីម | គិញ | តំបន់៣៣ | ៣-៣-៧៦ | ២៧-៥-៧៦ |
| ៥៣២ | តាំង ម៉េងហ៊ | គិញ | តំបន់៣៣ | ៣-៣-៧៦ | ២៧-៥-៧៦ |
| ៥៣៣ | អេង មាស | គិញ | ព្រែកកុង | ២២-២-៧៦ | ២៧-៥-៧៦ |
| ៥៣៤ | ម៉ែន ហឿន | វិស្វករ | បាត់ដំបង | ២៧-៣-៧៦ | ២៧-៥-៧៦ |
| ៥៣៥ | គីម មាស | សុរិយោដី | បាត់ដំបង | ១៣-២-៧៦ | ២៧-៥-៧៦ |
| ៥៣៦ | លឹម គីមម៉ារី | ? | បាត់ដំបង | ១៣-២-៧៦ | ២៧-៥-៧៦ |
| ៥៣៧ | កៀង វ៉ានី | កូនសិស្ស | ដីឥដ្ឋ | ២២-២-៧៦ | ២៧-៥-៧៦ |
| ៥៣៨ | ត្រឹង យ៉ាងហ៊ | ប្រជាជន | តាខ្មៅ | ១២-១២-៧៥ | ២៧-៥-៧៦ |
| ៥៣៩ | ម៉ាន់ សុត ហៅ ឡេងយ៉ាងថាន់ | ប្រជាជន | តាខ្មៅ | ៥-១២-៧៥ | ២៧-៥-៧៦ |
| ៥៤០ | អ៊ឹម ពន្នី | ប្រជាជន | ភ្នំពេញ | ១០-១០-៧៥ | ២៧-៥-៧៦ |
| ៥៤១ | ឆោម ឆំ | ប្រជាជន | ដង្កោ | ១៧-១១-៧៥ | ២៧-៥-៧៦ |
| ៥៤២ | យ៉ែម យ៉ន | ប្រជាជន | ផ្សារកាប់គោ | ១២-១០-៧៥ | ២៧-៥-៧៦ |
| ៥៤៣ | ប្រាក់ អិន | ប្រជាជន | តំបន់២៥ | ៤-១-៧៦ | ២៧-៥-៧៦ |
| ៥៤៤ | ជា ចាន់ | ប្រជាជន | ព្រែកក្តាម | ២៩-១-៧៦ | ២៧-៥-៧៦ |
| ៥៤៥ | ហែម សន | ប្រជាជន | តាខ្មៅ | ១៩-៨-៧៥ | ២៧-៥-៧៦ |
| ៥៤៦ | នូ ឃីម ហៅ ភិន | ប្រជាជន | បាត់ដំបង | ១៩-២-៧៦ | ២៧-៥-៧៦ |
| ៥៤៧ | ប៉ាវ ប៉ន ហៅ ប៉ាន់ | ប្រជាជន | បាត់ដំបង | ១៨-២-៧៦ | ២៧-៥-៧៦ |
| ៥៤៨ | សូ អ៊ី | ប្រជាជន | តំបន់២២ | ២២-២-៧៦ | ២៧-៥-៧៦ |
| ៥៤៩ | មាស កេតកាន់យ៉ា | ប្រជាជន | តំបន់២២ | ២២-២-៧៦ | ២៧-៥-៧៦ |
| ៥៥០ | គេង សឹន | ប្រជាជន | តំបន់២៥ | ២២-២-៧៦ | ២៧-៥-៧៦ |
| ៥៥១ | ថានី ហ៊ាស | ប្រជាជន | គីឡូម៉ែត្រលេខ១០ | ២៧-៣-៧៦ | ២៧-៥-៧៦ |

(នៅមានត)



# មុនដំបូងខ្មែរក្រហមសម្លាប់ប៉ារបស់ខ្ញុំ

## ការចងចាំរបស់កុមារីកម្ពុជាម្នាក់

**លឿង អ៊ុង**

***(តពីលេខមុន)***

កាលខ្ញុំនៅតូចជាងសព្វថ្ងៃនេះ ប៉ាប្រាប់ខ្ញុំថា នៅក្នុងគ្រាមភាសាចិន ឈ្មោះរបស់ខ្ញុំ លឿង បកប្រែមកថា "នាគ" ។ ប៉ាមានប្រសាសន៍ថា នាគគឺសត្វរបស់ទេវតា ទោះបីខ្លួនវាមិនមែនជាទេវតាក៏ដោយ ។ សត្វនាគជាសត្វមានបុទ្ធានុភាព ហើយឆ្លាតវាងវៃ ។ ជារឿយៗ វាអាចមើលវែងឆ្ងាយទៅអនាគត ។ ប៉ាថែមទាំងពន្យល់ខ្ញុំទៀតថា ដូចជានៅក្នុងខ្សែភាពយន្តអ៊ីចឹង យូរៗម្តង សត្វនាគកំណាចមួយបុពីរបានចុះមកផែនដីដើម្បីបំផ្លិចបំផ្លាញប្រជាជន ប៉ុន្តែនាគភាគច្រើនមានតួនាទីជាអ្នកការពារមនុស្ស ។

កាលពីពីរបីយប់មុន ប៉ាប្រាប់ខ្ញុំថា "នៅថ្ងៃដែល បងគីម ចាប់កំណើត ប៉ាកំពុងតែដើរនៅខាងក្រៅផ្ទះ ។ មួយរំពេចនោះ ប៉ាមើលទៅលើហើយក៏ឃើញដុំពពកសយ៉ាងស្អាតហោះមករកប៉ា ។ ដុំពពកនោះហាក់ដូចជាហោះតាមប៉ាអ៊ីចឹង ។ បន្ទាប់មក ដុំពពកនោះក៏ចាប់ផ្តើមលេចចេញជារាងនាគដ៏ធំមួយដែលមើលទៅគួរឲ្យខ្លាច ។ នាគនោះមានប្រវែងពីប្រាំមួយទៅដប់ម៉ែត្រ មានជើងតូចៗបួន ហើយមានស្លាបត្រដាងឡើងត្រង់ពាក់កណ្តាលខ្លួន វាមានស្នែងរមួលខ្វង់ពីរដុះចេញពីក្បាល បែរចេញទៅជ្រុងម្ខាងមួយ ព្រុយរបស់វាមានប្រវែងមួយម៉ែត្រកន្លះ ហើយយោលយោកទៅមុខទៅក្រោយ ហាក់ដូចជាកំពុងរេរាំអបអរសាទរការចាប់កំណើតរបស់ បងគីម ដែរ ។ រំពេចនោះ វាក៏ហោះមកជិតប៉ា ហើយសម្លឹងមកប៉ាជាមួយភ្នែកទាំងគូដ៏ធំជិតប៉ុនកង់រថយន្ត ។ នាគនោះបានប្រាប់ប៉ាថា អ្នកនឹងមានកូនប្រុសម្នាក់ដ៏ខ្លាំងពូកែនិងមានសុខភាពមាំមួន នៅពេលធំឡើង កូនប្រុសនោះអាចធ្វើការងារដ៏អស្ចារ្យជាច្រើន ។ ប៉ាបានដឹងដំណឹងអំពីការចាប់កំណើតរបស់ បងគីម ពីសត្វនាគនោះឯង" ។ ប៉ាប្រាប់ខ្ញុំថា នាគបានចុះមកលេងនឹងគាត់ជាច្រើនសា នៅពេលវាចុះមកម្តងៗ វាតែងផ្តល់ពត៌មានអំពីការចាប់កំណើតថ្មីរបស់កូនគាត់ជានិច្ច ។ មូលហេតុនេះហើយដែលធ្វើឲ្យខ្ញុំនៅកន្លែងយ៉ផ្ទះនេះ សក់របស់ខ្ញុំរេរាំទៅក្រោយដូចព្រុយនាគ ហើយដៃទាំងគូរបស់ខ្ញុំនៅតែទទះឡើងលើដូចស្លាបនាគហោះហើររំលងលោក រហូតដល់ពេលប៉ាហៅខ្ញុំចូលទៅក្នុងផ្ទះវិញ ។

ម៉ានិយាយថាខ្ញុំសួរសំណួរច្រើនណាស់ ។ នៅពេលដែលខ្ញុំសួរគាត់ថា ប៉ាធ្វើអីនៅកន្លែងធ្វើការ គាត់ប្រាប់ខ្ញុំថា ប៉ាគឺជាប៉ូលិស ។

នៅលើឯកសណ្ឋានរបស់ប៉ា មានប៉ាន់ស័ក្តិមួយដែលមានបួនឆ្នូត ។ ប៉ាន់នេះមានន័យថាគាត់អាចរកចំណូលបានច្រើន ។ ម៉ាមានប្រសាសន៍ថា មានម្តងនោះ ពេលដែលខ្ញុំទើបមានអាយុប្រមាណមួយបុពីរឆ្នាំ មានមនុស្សបានព្យាយាមធ្វើឃាតប៉ាដោយដាក់គ្រាប់បែកនៅក្នុងធុងសំរាមរបស់យើង ។

"នៅពេលយន្តហោះចាប់ទម្លាក់គ្រាប់បែកនៅជនបទ ប្រជាជនជាច្រើនបានរត់មកនៅភ្នំពេញ ។ នៅភ្នំពេញ ប្រជាជនទាំងអស់នោះមិនអាចរកការងារធ្វើបាន ហើយក៏ស្តីបន្ទោសរដ្ឋាភិបាល ។ ប្រជាជនទាំងនោះមិនស្គាល់ប៉ាទេ ប៉ុន្តែគេគិតថា

មន្ត្រីរាជការទាំងអស់សុទ្ធតែពុករលួយ ហើយចិត្តអាក្រក់ ដូច្នេះ ហើយ អ្នកទាំងនោះក៏តម្រង់គោលដៅមកលើមន្ត្រីរាជការជាន់ខ្ពស់ទាំងអស់" ។

"អ្វីទៅគ្រាប់បែក? នរណាជាអ្នកទម្លាក់វា?" ។

ម៉ាមានប្រសាសន៍តបវិញថា "ឯងអាចសួរសំណួរនេះទៅប៉ាបាន" ។ ពេលរសៀលថ្ងៃដដែលនោះ ខ្ញុំអង្គុយនៅឯផ្ទះជាមួយប៉ា ហើយខ្ញុំក៏សួរប៉ាអំពីការទម្លាក់គ្រាប់បែកនៅជនបទ ។ ប៉ាប្រាប់ខ្ញុំថា ប្រទេសកម្ពុជាកំពុងមានសង្គ្រាមស៊ីវិល ប្រជាជនកម្ពុជាភាគច្រើនពុំមែនជាអ្នករស់នៅទីក្រុងទេ ប៉ុន្តែ អ្នកនៅទីជនបទដាច់ស្រយាលកំពុងធ្វើស្រែលើដីតូចៗរបស់គាត់ ។ ហើយគ្រាប់បែកគឺជាបាល់សំណដែលគេទម្លាក់ចុះពីលើយន្តហោះមក នៅពេលវាផ្ទុះ គ្រាប់បែកនោះនឹងបង្កើតជារណ្តៅនៅលើដីដែលមានទំហំមាត់លើប្រហែលប៉ុនកូនត្រពាំងតូចៗ ។ គ្រាប់បែកសម្លាប់គ្រួសារអ្នកស្រែចម្ការ បំផ្លាញដីធ្លីរបស់គាត់ ហើយធ្វើឲ្យគាត់រត់ចាកចេញពីផ្ទះ ។ ឥឡូវនេះ អ្នកក្រនិងអ្នកដែលគ្មានទីជម្រកបានមករស់នៅទីក្រុងភ្នំពេញ ដើម្បីស្វែងរកកន្លែងស្នាក់នៅនិងជំនួយឧបត្ថម្ភ ។

ដោយមិនអាចស្វែងរកទីជម្រកនិងការជួយឧបត្ថម្ភបាន អ្នកទាំងនោះបានបញ្ចេញកំហឹងក្រេវក្រោធ ហើយបានជះកំហឹងរបស់គាត់ទៅលើមន្ត្រីរាជការទាំងអស់នៅក្នុងជួររដ្ឋាភិបាល ។ ពាក្យសម្តីរបស់ប៉ាធ្វើឲ្យក្បាលរបស់ខ្ញុំវិល បេះដូងរបស់ខ្ញុំលោតញាប់ឡើងៗ ។

ខ្ញុំសួរប៉ាថា "ហេតុអ្វីបានជាគេទម្លាក់គ្រាប់បែក?" ។

ប៉ាឆ្លើយតបមកខ្ញុំវិញថា "ប្រទេសកម្ពុជាកំពុងតែប្រយុទ្ធប្រឆាំងនឹងសង្គ្រាម ដែលប៉ាក៏មិនយល់ដែរ ហើយចម្លើយនេះវាគ្រប់គ្រាន់ណាស់ទៅហើយសម្រាប់សំណួររបស់កូន" ។ រួចគាត់ក៏ឈប់និយាយតទៅទៀត ។

ការផ្ទុះគ្រាប់បែកក្នុងផុងសំរាមរបស់យើងបានធ្វើឲ្យរលំជញ្ជាំងចង្ក្រានបាយ ប៉ុន្តែជាសំណាងល្អ គ្មាននរណាម្នាក់ក្នុងគ្រួសារយើងរងរបួសទេ ។ ប៉ូលិសមិនដែលបានរកឃើញនរណាជាអ្នកដាក់គ្រាប់បែកនោះឡើយ ។ បេះដូងរបស់ខ្ញុំឈឺចុកចាប់នៅពេលដែលនឹកដល់ថានរណាជាអ្នកព្យាយាមចង់ធ្វើបាបប៉ារបស់ខ្ញុំពិតប្រាកដ ។ ប្រសិនបើប្រជាជនថ្មីទាំងអស់នៅក្នុងក្រុងភ្នំពេញដឹងថាប៉ាជាមនុស្សដ៏ល្អម្នាក់ ហើយតែងតែមានបំណងចង់ជួយយកអាសាអ្នកដទៃ អ្នកទាំងនោះនឹងមិនធ្វើបាបប៉ាទៀតទេមើលទៅ ។

ប៉ាកើតនៅឆ្នាំ១៩៣១ នៅភូមិតានន់ ឃុំព្រែកតានន់ ស្រុកកោះសូទិន ដែលជាភូមិដាច់ស្រយាលមួយនៅក្នុងខេត្តកំពង់ចាម ។ តាមជីវភាពអ្នកស្រែចម្ការ គ្រួសាររបស់ប៉ាជាអ្នកមានជីវភាពធូរធារ ។ ប៉ាត្រូវបានផ្តល់នូវអ្វីៗទាំងអស់តាមដែលគាត់ត្រូវការ ។ នៅពេលប៉ាមានអាយុដប់ពីរឆ្នាំ ឪពុករបស់គាត់បានទទួលអនិច្ចកម្ម ម្តាយរបស់គាត់បានរៀបការជាថ្មីទៀត ។ ឪពុកចុងរបស់ប៉ាជាមនុស្សស្រវឹងខ្ទប ហើយឧស្សាហ៍វាយដំប្រំធាក់ប៉ាណាស់ ។ ពេលប៉ាអាយុដប់ប្រាំបីឆ្នាំ ប៉ាបានចាកចេញពីផ្ទះទៅរស់នៅក្នុងវត្ត ដើម្បីចៀសចេញពីអំពើហិង្សានៅក្នុងផ្ទះ និងដើម្បីបន្តការសិក្សា ។ នៅទីបំផុត ប៉ាក៏បួសជាសង្ឃ ។ ប៉ាប្រាប់ខ្ញុំថា នៅពេលដែលគាត់មានជីវិតជាសង្ឃ ពេលគាត់និមន្តទៅណាមកណា គាត់តែងតែកាន់អំបោសនិងប្រដាប់ចូកសំរាមមួយ ដើម្បីបោសសម្អាតផ្លូវនៅខាងមុខគាត់ចេញ កុំឲ្យគាត់ដើរជាន់សត្វនិងរុក្ខជាតិមានជីវិតនានា ។

បន្ទាប់ពីលាចាកភាពជាបព្វជិតដើម្បីរៀបការជាមួយម៉ា ប៉ាបានចូលធ្វើការឲ្យកងកម្លាំងប៉ូលិស ។ គាត់ជាប៉ូលិសដ៏ល្អម្នាក់ ដូច្នេះហើយគាត់បានត្រូវគេតម្លើងឋានៈឲ្យចូលធ្វើការក្នុងសេវាភ្នាក់ងារសម្ងាត់កងខេមរភូមិន្ទ ក្រោមការដឹកនាំរបស់សម្តេច ព្រះនរោត្តម សីហនុ ។

ក្នុងតួនាទីជាភ្នាក់ងារ ប៉ាធ្វើការជាសម្ងាត់ ។ គាត់ត្រូវបានចាត់តាំងឲ្យបំពេញការងារដូចជនស៊ីវិល ដើម្បីប្រមូលព័ត៌មានជូនរដ្ឋាភិបាល ។ គាត់មិនដែលប្រាប់នរណាៗឲ្យដឹងពីការងារពិតប្រាកដរបស់គាត់ឡើយ ។ ដោយគិតថា គាត់អាចធ្វើការរកស៊ីបានប្រសើរជាងធ្វើការឲ្យរដ្ឋ ប៉ាក៏សម្រេចចិត្តលាឈប់ពីកងកម្លាំងប៉ូលិស ដើម្បីទៅធ្វើជំនួញជាមួយមិត្តភក្តិរបស់គាត់វិញ ។ ក្រោយការផ្តួលរំលំរដ្ឋាភិបាលរបស់សម្តេចព្រះ នរោត្តម សីហនុ

ក្នុងឆ្នាំ១៩៧០ ប៉ាបានត្រូវជ្រើសរើសឲ្យចូលធ្វើទាហានជាមួយរដ្ឋាភិបាលថ្មីរបស់ លន់ ណុល ម្តងទៀត ។ ទោះបីជារដ្ឋាភិបាលថ្មីតម្កើងឋានន្តរស័ក្តិប៉ាទៅដល់វរសេនីយ៍ត្រីក៏ដោយ ក៏ប៉ាមានប្រសាសន៍ថា ប៉ាមិនចង់ធ្វើការនេះទេ ប៉ុន្តែប៉ាត្រូវតែធ្វើ បើមិនដូច្នោះទេ គាត់អាចនឹងត្រូវគេធ្វើទុក្ខបុកម្នេញ ដោយចាត់ទុកថាគាត់ជាជនក្បត់ជាតិ ឬប្រហែលជានឹងត្រូវគេសម្លាប់ផងក៏មិនដឹង ។

ខ្ញុំសួរប៉ាថា "ហេតុអ្វីបានជាអ៊ីចឹង? តើនៅកន្លែងផ្សេងវាមានរឿងដូចអ៊ីចឹងដែរទេ?" ប៉ាយកដៃមកអង្អែលសក់ខ្ញុំបណ្តើរ ប៉ាឆ្លើយបណ្តើរថា "ទេ ។ កូនសួរច្រើនណាស់" ។

បន្ទាប់មក ប៉ាក៏ពេបមាត់ ហើយងាកភ្នែកចេញទៅឆ្ងាយពីខ្ញុំ ។ នៅពេលគាត់មានប្រសាសន៍ម្តងទៀត សំឡេងរបស់គាត់ពុកាន់តែខ្សាវទៅៗ ។

គាត់មានប្រសាសន៍ថា "នៅក្នុងប្រទេសជាច្រើន គេមិនដែលធ្វើដូច្នេះទេ ។ នៅក្នុងប្រទេសមួយដែលគេហៅប្រទេសអាមេរិក រដ្ឋាភិបាលរបស់ប្រទេសនោះមិនធ្វើរបៀបនេះទេ" ។

"តើប្រទេសអាមេរិកនៅកន្លែងណាទៅ?" ។

"វាជាប្រទេសមួយស្ថិតនៅឆ្ងាយពីទីនេះ ឆ្លងមហាសមុទ្រជាច្រើន" ។

"ហើយនៅក្នុងប្រទេសអាមេរិក ប៉ានឹងមិនត្រូវបង្ខំឲ្យចូលធ្វើទ័ពទេ មែនទេប៉ា?" ។

"អត់ទេកូន នៅប្រទេសអាមេរិកគេមានគណបក្សនយោបាយពីរដឹកនាំប្រទេស គណបក្សមួយមានឈ្មោះថា គណបក្សប្រជា-ធិបតេយ្យ ហើយគណបក្សមួយទៀតមានឈ្មោះថា គណបក្សសាធារណរដ្ឋ ។ នៅពេលដែលគេប្រជែងគ្នា គណបក្សមួយណាក៏ដោយឲ្យតែឈ្នះឆ្នោត គណបក្សមួយទៀតត្រូវតែស្វែងរកការងារផ្សេងៗធ្វើដោយខ្លួនឯង ។ ជាឧទាហរណ៍ ប្រសិនបើគណបក្សប្រជាធិបតេយ្យឈ្នះឆ្នោត គណបក្សសាធារណរដ្ឋនឹងបាត់បង់ការងាររបស់គេ ហើយជារឿយៗ សមាជិកគណបក្សនោះត្រូវរកការងារថ្មីធ្វើដោយខ្លួនឯងនៅគ្រប់ទីកន្លែងទាំងអស់ ។ វិធីនេះមិនត្រូវបានយកមកអនុវត្តនៅប្រទេសកម្ពុជាទេ ។ នៅប្រទេសកម្ពុជាយើង ប្រសិនបើគណបក្សសាធារណរដ្ឋចាញ់ សមាជិកគណបក្សសាធារណរដ្ឋទាំងអស់ត្រូវតែចូលខ្លួនមកធ្វើការឲ្យគណបក្សប្រជាធិបតេយ្យ បើមិនដូច្នោះទេ សមាជិកទាំងនោះមុខជាប្រឈមមុខនឹងការដាក់ទណ្ឌកម្មមិនខាន" ។

ការសន្ទនារបស់យើងត្រូវបានកាត់ផ្តាច់នៅពេលដែលបងប្រុសធំបង្អស់របស់ខ្ញុំដើរចូលមកអង្គុយជាមួយយើងទាំងពីរនៅយ៉ផ្ទះដែរ ។

បងម៉េង មានអាយុដប់ប្រាំបីឆ្នាំហើយ គាត់ស្រឡាញ់ប្អូនៗខ្លាំងណាស់ ។ ដូចជាប៉ាអ៊ីចឹងដែរ បងម៉េង មានសម្តីផ្អែមល្ហែមទន់ភ្លន់ ហើយចិត្តល្អ ។ បងម៉េង ជាបុរសដែលពោរពេញទៅដោយការទទួលខុសត្រូវ ។ គាត់ជាប្រភេទមនុស្សដែលអាចឲ្យជឿជាក់បាន ។ គាត់ជាសិស្សដែលត្រូវបានកោតសរសើរពីមិត្តភក្តិគ្រប់ៗគ្នា ។ ប៉ាទើបតែទិញរថយន្តតូចមួយឲ្យ បងម៉េង ។ រថយន្តនេះមើលទៅហាក់ដូចជា បងម៉េង ប្រើសម្រាប់តែដឹកជញ្ជូនសៀវភៅរបស់គាត់ប៉ុណ្ណោះ ជាជាងដឹកក្មេងស្រីៗ ។

ប៉ុន្តែសព្វថ្ងៃនេះ បងម៉េង មានមិត្តស្រីហើយ ។ គាត់ទាំងពីរនាក់នឹងរៀបការនៅពេលដែល បងម៉េង ទទួលបានសញ្ញាប័ត្រមកពីប្រទេសបារាំងវិញ ។ បងម៉េង ត្រៀមខ្លួនជាស្រេច ដើម្បីចេញទៅរៀននៅប្រទេសបារាំងនៅថ្ងៃទី១៨ ខែមេសា ។ ដោយសារថ្ងៃទី១៣ ជាថ្ងៃចូលឆ្នាំខ្មែរ ប៉ាបានអនុញ្ញាតឲ្យ បងម៉េង នៅលេងចូលឆ្នាំថ្មីសិន ។

បងម៉េង គឺជាបងប្រុសដែលគួរជាទីគោរពនិងជាទីសង្ឃឹម ។ បងឃួយ ជាបងប្រុសម្នាក់ទៀតដែលយើងគ្រប់ៗគ្នាខ្លាចជាងគេ ។ ក្នុងឆ្នាំនេះ បងឃួយ មានអាយុដប់ប្រាំមួយឆ្នាំ គាត់ចាប់អារម្មណ៍ទៅលើស្រីៗនិងក្បាច់ការ៉ាត់តេជាងសៀវភៅ ។ ម៉ូតូរបស់គាត់គឺជាយានជំនិះដែលអាចដឹកមនុស្សបានច្រើនជាងរថយន្តទៅទៀត ហើយម៉ូតូនោះជាមេដែកឆក់ទាញស្រីៗ ។ បងឃួយ គិតថា ខ្លួនគាត់មានសុជីវធម៌និងចិត្តស្ងប់មិនចេះច្រឡោតខឹង ប៉ុន្តែខ្ញុំដឹងថាគាត់កាច ។ នៅប្រទេសកម្ពុជា ប្រសិនបើឪពុកមមាញឹកនឹងការងារ ហើយម្តាយជាប់រវល់ជាមួយកូនតូចៗនិងទៅផ្សារ ការទទួលខុសត្រូវផ្នែកវិន័យនិងការដាក់ទណ្ឌកម្មនឹងត្រូវធ្លាក់ទៅលើកូនច្បង ។ នៅក្នុងគ្រួសារយើង ដោយសារគ្មាន

នរណាម្នាក់ខ្លាច បងម៉េង តួនាទីទាំងនេះក៏ធ្លាក់ទៅលើ បងឃួយ ។ គាត់មិនមែនជាមនុស្សងាយស្រួលបន្ទន់ចិត្តដោយសារតែភាពស្រស់ស្អាតនិងការរកលេសដោះសារបស់យើងទេ ។ ទោះបីជាគាត់មិនគំរាមកំហែងវាយដំលើយើងក៏ដោយ ក៏យើងទាំងអស់គ្នានៅតែខ្លាចគាត់ ហើយតែងតែធ្វើតាមអ្វីដែលគាត់ប្រាប់ជានិច្ច ។

ក្នុងវ័យដប់បួនឆ្នាំ បងស្រីច្បងរបស់ខ្ញុំកំពុងឡើងខ្លួនពេញរូបពេញរាងយ៉ាងស្អាត ។ ម៉ាមានប្រសាសន៍ថា បងគាវ នឹងមានបុរសជាច្រើនមកសុំរៀបការជាមួយ ហើយគាត់អាចរើសយកបុរសណាក៏បានតាមតែគាត់ពេញចិត្ត ។

ប៉ុន្តែម៉ាក៏និយាយដែរថា បងគាវ មានសំណាងមិនល្អដោយសារការចូលចិត្តនិយាយលេងច្រើន ហើយយកត្រូវជានិច្ច ។ លក្ខណៈទាំងនេះមិនត្រូវបានចាត់ទុកថាជាលក្ខណៈរបស់ស្ត្រីភេទទេ ។ ព្រមពេលដែលម៉ាចាប់ផ្តើមអប់រំ បងគាវ ឲ្យក្លាយជាស្ត្រីដ៏អស្ចារ្យម្នាក់ ប៉ាយកចិត្តទុកដាក់លើ បងគាវ កាន់តែខ្លាំងឡើងៗ ។ ប៉ាព្រួយបារម្ភលើសុវត្ថិភាពរបស់ បងគាវ ជាខ្លាំង ។ ប៉ាដឹងថាប្រជាជនជាច្រើនមិនសប្បាយចិត្តនឹងរដ្ឋាភិបាល ហើយអ្នកទាំងនោះកំពុងតែជះកំហឹងរបស់គាត់ទៅលើគ្រួសាររបស់មន្ត្រីរដ្ឋាភិបាល ។ កូនស្រីរបស់មន្ត្រីរាជការធ្វើការជាមួយប៉ាជាច្រើនត្រូវទទួលការរុកគួននៅតាមផ្លូវ ជួនកាលត្រូវចាប់ជម្រិតថែមទៀត ។

ប៉ាព្រួយបារម្ភខ្លាចក្រែងរឿងបែបនេះកើតទៅលើបងគាវ ដែរ ហេតុដូច្នេះហើយទើបប៉ាឲ្យភ្នាក់ងារអាវុធហត្ថពីរនាក់ដើរតាមការពារ បងគាវ គ្រប់ទីកន្លែងទាំងអស់ ។

បងគីម គឺជាបងប្រុសរបស់ខ្ញុំម្នាក់ទៀត ។ គាត់មានអាយុដប់ឆ្នាំ ឈ្មោះរបស់គាត់មានន័យជាភាសាចិនថា “មាស” ។ ម៉ាដាក់ឈ្មោះហៅក្រៅឲ្យគាត់ថា “ស្វាតូច” ពីព្រោះគាត់មានមាឌតូច វាងវៃ ហើយរត់លឿន ។ បងគីម ចូលចិត្តមើលកុនកាប់ចាក់របស់ចិន ។ ពួកយើងធុញណាស់នឹងការធ្វើត្រាប់របស់គាត់ តាមកាយវិការនៃក្បាច់គុនស្វានៅក្នុងរឿងកុន ។ ខ្ញុំធ្លាប់គិតថា បងគីម ជាមនុស្សចម្លែក ប៉ុន្តែពេលបានជួបបងប្រុសរបស់ក្មេងស្រីដទៃៗទៀត ខ្ញុំដឹងថាបងប្រុសទាំងអស់ភាគច្រើនគឺសុទ្ធតែដូចគ្នា ។ គោលបំណងធំរបស់គេគឺរិះគន់អ្នកនិងបង្ករឿងជាមួយអ្នក ។

ជូ គឺជាបងស្រីរបស់ខ្ញុំម្នាក់ទៀត គាត់មានអាយុច្រើនជាងខ្ញុំបីឆ្នាំ ។ អត្តចរិតរបស់ខ្ញុំនិងគាត់ខុសគ្នាស្រឡះ ។ ឈ្មោះរបស់គាត់ជាភាសាចិនមានន័យថា “ត្បូងថ្មៃ” ។ ក្នុងអាយុប្រាំបីឆ្នាំ បងជូ ជាមនុស្សស្ងៀមស្ងាត់ ខ្មាសអៀន និងស្តាប់បង្គាប់ ។ ម៉ាតែងតែប្រៀបធៀបខ្ញុំទៅនឹង បងជូ ហើយគាត់ឆ្ងល់ថាហេតុអ្វីបានជាខ្ញុំមិនមានចរិតល្អដូច បងជូ អ៊ីចឹង ។ ខុសពីបងប្អូនផ្សេងទៀត បងជូ ថែរក្សាប៉ា ។ បងជូ មានស្បែកខ្មៅខុសគេ ។ បងប្រុសធំៗរបស់ខ្ញុំចូលចិត្តនិយាយលេងសើចថា បងជូ មិនមែនជាបងប្អូនរបស់យើងពិតប្រាកដទេ ។

គាត់និយាយលេងថា ប៉ាឃើញ បងជូ ត្រូវគេបំបរបង់ចោលនៅជិតធុងសំរាមរបស់យើង ហើយប៉ាអាណិតក៏រើសយកមកចិញ្ចឹម ។

ខ្ញុំគឺជាកូនបន្ទាប់ពី បងជូ ។ ក្នុងអាយុប្រាំឆ្នាំ ខ្ញុំមានមាឌធំប៉ុន បងជូ ដែរ ។ បងប្អូនប្រុសស្រីរបស់ខ្ញុំស្ទើរទាំងអស់ ចាត់ទុកខ្ញុំជាក្មេងទម្រើសនិងជាក្មេងបង្កបញ្ហា ។ ប៉ុន្តែប៉ានិយាយថាខ្ញុំជាត្បូងពេជ្រដែលមិនទាន់ច្នៃពិតប្រាកដ ។ ក្នុងឋានៈជាពុទ្ធសាសនិក ប៉ាមានជំនឿលើចក្ខុវិញ្ញាណ ភាពស្វាហាប់ អាការៈរបស់មនុស្ស និងជឿលើចំណុចផ្សេងៗទៀតដែលមនុស្សយើងជឿថាជាជំនឿអរូបី ។ អាការៈគឺជាពណ៌ដែលខ្លួនប្រាណយើងបញ្ចេញវាមកក្រៅ ហើយវាអាចប្រាប់ដល់អ្នកសង្កេតមើលថាតើយើងជាមនុស្សប្រភេទណា ។ ពណ៌ខៀវមានន័យថាសប្បាយ ពណ៌ផ្កាឈូកតំណាងឲ្យសេចក្តីស្រឡាញ់ ពណ៌ខ្មៅតំណាងឲ្យចិត្តអាក្រក់ ។ គាត់និយាយថា ទោះបីជាមនុស្សភាគច្រើនមិនអាចឃើញអាការៈក៏ដោយ ក៏មនុស្សទាំងអស់សុទ្ធតែដើរជុំវិញពពុះខ្យល់ដែលបញ្ចេញពណ៌ស្មើៗគ្នាមកក្រៅយ៉ាងច្បាស់ក្រឡែត ។ ប៉ាប្រាប់ខ្ញុំថា នៅពេលដែលខ្ញុំកំពុងកើត គាត់ឃើញអាការៈក្រហមភ្លឺនៅព័ទ្ធជុំវិញខ្ញុំ ដែលនេះមានន័យថា ខ្ញុំជាមនុស្សដែលប្រកបដោយសេចក្តីត្រេកត្រអាល ។ ឆ្លើយតបនឹងចំណុចនេះ ម៉ាប្រាប់ប៉ាថា ទារកទាំងអស់ដែលកើតមកសុទ្ធតែក្រហមទាំងអស់ ។

ហ្គិច ជាប្អូនស្រីរបស់ខ្ញុំដែលទើបតែមានអាយុបីឆ្នាំ ។ នៅក្នុងភាសាចិន ហ្គិច មានន័យថា "ថ្មើមថ្ម" ។ ថ្មើមថ្មគឺជាត្បូងដ៏មានតម្លៃ ហើយគួរឲ្យស្រឡាញ់បំផុតសម្រាប់ជនជាតិអាស៊ី ។ ហ្គិច មានរូបរាងស្អាតណាស់ ។ អ្វីៗដែល ហ្គិច ធ្វើ សុទ្ធតែគួរឲ្យស្រឡាញ់ រួមទាំងរបៀបដែល ហ្គិច បង្ហៀរទឹកមាត់ផង ។ បងៗតែងតែច្បិចថ្ពាល់ដ៏កណ្តៀនៗរបស់ ហ្គិច ធ្វើឲ្យថ្ពាល់នោះឡើងពណ៌ផ្កាឈូកដែលគេច្រើននិយាយថានេះជាសញ្ញាថានាងមានសុខភាពល្អ ។ តែចំពោះខ្ញុំ ខ្ញុំគិតថានេះជាសញ្ញានៃការឈឺថ្ពាល់ទៅវិញទេ ។ ក្រៅពីនេះ ហ្គិច គឺជាកូនក្មេងតូចដ៏សប្បាយ ។ ខ្ញុំគឺជាអ្នករញ៉ាំរញ៉ូវជាងគេ ។

ពេលដែល បងម៉េង និងប៉ា កំពុងជជែកគ្នា ខ្ញុំក៏ជ្រៀតខ្លួនទៅរកបង្អួចដែកការពារ ហើយក្រឡេកមើលទៅរោងកុនដែលនៅម្ខាងផ្លូវនៃផ្ទះរបស់យើង ។ ខ្ញុំខស្បាហ៍ទៅមើលកុនណាស់ ព្រោះតែម្ចាស់រោងកុនដឹងថាប៉ាជានរណា ហើយគេក៏អនុញ្ញាតឲ្យកូនរបស់ប៉ាចូលមើលដោយមិនបាច់បង់ថ្លៃ ។ នៅពេលប៉ាទៅមើលកុនជាមួយយើង គាត់តែងតែទទួចបង់លុយថ្លៃសំបុត្រជានិច្ច ។ ពីយ៉ផ្ទះរបស់យើង ខ្ញុំអាចមើលឃើញផ្ទាំងផ្សាយពាណិជ្ជកម្មមួយយ៉ាងធំ ព្យួរនៅខាងមុខរោងកុននោះ ដែលមានគូររូបភាពក្នុងរឿងដែលត្រូវបញ្ចាំងក្នុងសប្តាហ៍នេះ ។ ផ្ទាំងផ្សាយពាណិជ្ជកម្មនោះមានរូបភាពស្រីក្មេងស្អាតម្នាក់ ដែលមានសក់សើុងកន្ទ្រើង ហើយមានទឹកភ្នែកស្រក់ចុះមកលើថ្ពាល់របស់នាង ។ ពេលទៅមើលជិតរូបភាព យើងនឹងឃើញសក់របស់នាងមានកូនពស់រមិករម៉ក់ជាច្រើននៅលើនោះ ។ ផ្ទៃខាងក្រោយនៃរូបភាពនេះពិពណ៌នាពីអ្នកស្រុកកំពុងចោលដុំថ្មទៅលើនាង ក្នុងខណៈដែលនាងកំពុងរត់ចេញពីអ្នកទាំងនោះ ដោយព្យាយាមគ្របក្បាលរបស់នាងជាមួយនឹងកន្សែងប្រពៃណីដែលខ្មែរហៅថា "ក្រមា" ។

ក្នុងពេលនេះ ផ្លូវនៅក្រោមផ្ទះរបស់យើងមានសភាពស្ងាត់ជ្រងំ លើកលែងតែសំឡេងអំបោសដែលគេបោសសំរាមដើម្បីដាក់គរវានៅតាមចិញ្ចើមផ្លូវប៉ុណ្ណោះ ។ បន្តិចក្រោយមក មានបុរសចំណាស់ម្នាក់និងក្មេងប្រុសម្នាក់ដើរចេញមកដោយមានរុញរទេះមកជាមួយផង ។ ក្នុងខណៈដែលបុរសចំណាស់នោះទទួលលុយរៀលពីរបីសន្លឹកពីអ្នកម្ចាស់តូប ក្មេងប្រុសដែលមកជាមួយគាត់ក៏លើកធុងសំរាមដាក់ទៅក្នុងរទេះ ។ បន្ទាប់ពីប្រមូលសំរាមដាក់រទេះហើយ អ្នកទាំងពីរក៏អូសរទេះទៅគំនរសំរាមខាងមុខទៀត ។

នៅក្នុងផ្ទះរបស់យើង បងគីម បងដូ ហ្គិច និងម៉ា កំពុងអង្គុយមើលទូរទស្សន៍ក្នុងបន្ទប់ទទួលភ្ញៀវ ចំណែកឯ បងឃួយ និង បងគាវ កំពុងធ្វើកិច្ចការសាលា ។ ក្នុងឋានៈជាគ្រួសារវណ្ណៈកណ្តាលមានន័យថា យើងមានលុយនិងរបស់របរប្រើប្រាស់ច្រើនជាងគ្រួសារមួយចំនួន ។ នៅពេលដែលមិត្តភក្តិខ្ញុំមកលេងផ្ទះយើង គេទាំងអស់គ្នាចូលចិត្តនាឡិការបស់យើងណាស់ ។ ក្នុងខណៈដែលមនុស្សជាច្រើននៅទីក្រុងភ្នំពេញមិនមានទូរស័ព្ទប្រើ ផ្ទះរបស់យើងមានទូរស័ព្ទដល់ទៅពីរ ទោះបីជាខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យប្រើមួយដាច់តែឯងក៏ដោយ ។ នៅក្នុងបន្ទប់ទទួលភ្ញៀវរបស់យើងមានទូតាំងធ្វើពីកញ្ចក់ខ្ពស់មួយ ដែលនៅក្នុងនោះម៉ាបានតម្រៀបចានសំប៉ែតជាច្រើន ជាមួយគ្រឿងតាំងផ្ទះតូចៗដទៃទៀត ។ មិនតែប៉ុណ្ណោះ ក្នុងទូនោះមានទុកស្ករគ្រាប់ដ៏គួរឲ្យចូលចិត្ត ហើយឆ្ងាញ់ទៀតផង ។ នៅពេលម៉ានៅក្នុងបន្ទប់ ខ្ញុំតែងទៅឈរនៅមុខទូតាំងនោះជារឿយៗ ហើយយកដៃទៅផ្ទឹបនឹងកញ្ចក់ទូដោយលេបទឹកមាត់ក្អឹកៗពេលឃើញស្ករគ្រាប់ ។ ខ្ញុំងាកមើលម៉ាដោយភ្នែកស្រទន់ ហើយសង្ឃឹមថាម៉ានឹងអាណិតខ្ញុំ ហើយយកស្ករឲ្យខ្ញុំខ្លះមិនខាន ។ ធ្វើរបៀបនេះ ជួនកាលខ្ញុំធ្វើបានសម្រេច ជួនកាលម៉ាយករំពាត់មកវាយកំប៉េះគូទខ្ញុំ ហើយដេញខ្ញុំឲ្យចេញឆ្ងាយពីទីនោះ ដោយសារស្នាមបាតដៃដ៏កខ្វក់របស់ខ្ញុំជិតជាប់នៅលើកញ្ចក់ទូរបស់គាត់ ។ ម៉ានិយាយទៀតថា ខ្ញុំមិនអាចញ៉ាំស្ករគ្រាប់នេះបានទេ ពីព្រោះស្ករនេះទុកសម្រាប់ភ្ញៀវ ។ តាមតែខ្ញុំមើលឃើញ ក្រៅពីប្រាក់កាសនិងរបស់របរដែលយើងមាន គ្រួសារឋានៈកណ្តាលទូទៅក៏មានពេលវេលាទំនេរច្រើនដែរ ។ ពេលដែលប៉ាចេញទៅធ្វើការ ហើយកូនៗទៅសាលារៀនរាល់ព្រឹក ម៉ាមិនមានការងារសម្រាប់ធ្វើច្រើនទេ ។ យើងមានអ្នកបម្រើម្នាក់ដែលមកផ្ទះរបស់យើងរាល់ថ្ងៃដើម្បីបោកគក់ខោអាវ ចម្អិនអាហារ និងសម្អាតផ្ទះ ។ មិនដូច

ក្មេងដទៃៗទៀត ខ្ញុំមិនចាំបាច់ធ្វើការកំប៉ិកកំប៉ុកក្នុងផ្ទះឡើយ ពីព្រោះអ្នកបម្រើរបស់យើងធ្វើជំនួសយើងអស់ហើយ ។ ទោះជាយ៉ាងនេះក៏ដោយ ខ្ញុំនៅតែមានការងារធ្វើច្រើន ពីព្រោះខ្ញុំទៅសាលារៀនរាល់ពេល ។ នៅវេលាព្រឹកៗ ពេលដែល បងជូ បងគីម និងខ្ញុំ ដើរទៅសាលាជាមួយគ្នា យើងឃើញក្មេងៗដែលអាយុមិនច្រើនជាងយើងប៉ុន្មាន កំពុងលក់ស្វាយ ផ្កាជ័រដែលធ្វើពីបំពង់បឺតទឹកគ្រប់ពណ៌ និងផ្កាស្លឹកលាតពណ៌ផ្កាឈូកដែលមានរូបតុក្កតា នៅតាមផ្លូវ ។ ដោយភក្តីភាពនឹងមិត្តសម្លាញ់តូចៗរបស់ខ្ញុំ ខ្ញុំតែងតែទិញអីវ៉ាន់ទាំងនេះពីក្មេងទាំងនោះ ។ ខ្ញុំមិនដែលទិញរបស់អស់នេះពីមនុស្សចំណាស់ៗទេ ។

ខ្ញុំចាប់ផ្តើមទៅរៀនថ្នាក់បារាំងនៅពេលព្រឹក ទៅរៀនភាសាចិននៅពេលរសៀល និងជាប់រវល់ជាមួយថ្នាក់ខ្មែរនៅពេលល្ងាច ។ ខ្ញុំទៅរៀនប្រាំមួយថ្ងៃក្នុងមួយសប្តាហ៍ ហើយនៅថ្ងៃអាទិត្យខ្ញុំត្រូវតែធ្វើកិច្ចការសាលារបស់ខ្ញុំ ។ ប៉ាប្រាប់យើងរាល់គ្នាថា ការងារចម្បងទីមួយរបស់យើងគឺទៅសាលា និងរៀននិយាយភាសាបរទេសឲ្យបានច្រើន ។ ប៉ាអាចនិយាយភាសាបរទេសយ៉ាងស្ទាត់ជំនាញ ។ គាត់ប្រាប់យើងថា ដោយសារភាសានេះហើយទើបធ្វើឲ្យគាត់ទទួលបានជោគជ័យនៅក្នុងជីវភាពរបស់គាត់ ។ ខ្ញុំចូលចិត្តឈរស្តាប់ប៉ានិយាយភាសាបារាំងជាមួយសហសេវិករបស់គាត់ណាស់ ហេតុដូច្នេះហើយ ទើបបានជាខ្ញុំចូលចិត្តរៀនភាសា ទោះបីគ្រូបង្រៀនកាច ហើយខ្ញុំមិនចូលចិត្តគាត់ក៏ដោយ ។ ជារៀងរាល់ព្រឹក គ្រូបង្រៀនភាសាបារាំងបានឲ្យសិស្សឈរជាជួរនៅចំពោះមុខគាត់ បន្ទាប់មកឲ្យយើងហុចដៃទាំងពីររបស់យើងចេញមកក្រៅ ដើម្បីឲ្យគាត់ពិនិត្យមើលក្រចកថាតើស្អាតឬក៏អត់ ។ បើមិនស្អាត គាត់នឹងវាយដៃយើងនឹងចុងរំពាត់របស់គាត់ ។ ជួនកាលគាត់មិនអនុញ្ញាតឲ្យខ្ញុំទៅបន្ទប់ទឹកទេ លុះត្រាតែខ្ញុំសូមអនុញ្ញាតជាភាសាបារាំងថា «ម៉ាដាម! ខ្ញុំសូមអនុញ្ញាតចេញទៅបន្ទប់ទឹកបន្តិច» ។

មានថ្ងៃមួយនោះ ដោយសារតែខ្ញុំដេកលក់ អ្នកគ្រូក៏គប់ដីសចំខ្ញុំ ធ្វើឲ្យមិត្តរួមថ្នាក់សើចចំអកដាក់ខ្ញុំគ្រប់គ្នា ។ ខ្ញុំសុំឲ្យគាត់បង្រៀនតែភាសាបរទេសមកយើងបានហើយ មិនមែនឲ្យគាត់មកបង្រៀនយើងអំពីភាពអាក្រក់នោះទេ ។

ខ្ញុំមិនចូលចិត្តទៅរៀនរៀងរាល់ពេលទេ ដូច្នេះ ជារឿយៗខ្ញុំតែងគេចសាលាទៅកន្លែងលេងពេញមួយថ្ងៃ ប៉ុន្តែខ្ញុំមិនដែលរាប់ប៉ាឲ្យដឹងពីរឿងនេះឡើយ ។ ចំណុចមួយដែលខ្ញុំចូលចិត្តទៅសាលាគឺការស្លៀកពាក់ឯកសណ្ឋានដែលខ្ញុំបានស្លៀកពាក់នៅឆ្នាំនេះ ។ ឯកសណ្ឋានរបស់ខ្ញុំគឺ អាវប៉ោងស្មាដៃខ្លីពណ៌ស និងសំពត់ក្លីស្សេខ្លីពណ៌ខៀវ ខ្ញុំគិតថាឯកសណ្ឋាននេះស្អាតណាស់ ទោះបីជួនកាលខ្ញុំខ្លាចថាសំពត់របស់ខ្ញុំវាខើចពេកក៏ដោយ ។ ប៉ុន្មានថ្ងៃមុននេះ នៅពេលដែលខ្ញុំកំពុងលេងមីកជាមួយមិត្តភក្តិរបស់ខ្ញុំ មានក្មេងប្រុសម្នាក់បានដើរមករកខ្ញុំ ហើយព្យាយាមលើកសំពត់ខ្ញុំឡើងធ្វើឲ្យខ្ញុំខឹងយ៉ាងខ្លាំងក៏ច្រានវាចេញមួយទំហឹង ។ ខ្ញុំរុញវាយ៉ាងខ្លាំង ខ្លាំងជាងដែលខ្ញុំគិតថាខ្ញុំអាចធ្វើបានទៅទៀត ។ វាដួលទៅដីហើយខ្ញុំក៏រត់ចេញទៅ ។ ខ្ញុំរត់រហូតដល់ខ្ញុំរោយជើង ។ ខ្ញុំគិតថាកូនក្មេងប្រុសនោះច្បាស់ជាខ្លាចខ្ញុំរហូតដល់ឥឡូវនេះ ។

ស្ទើរតែរៀងរាល់សប្តាហ៍ នៅពេលដែលយើងបញ្ចប់កិច្ចការសាលា ប៉ាតែងតែផ្តល់រង្វាន់ឲ្យយើងដោយនាំយើងទៅហែលទឹកលេង ។ ខ្ញុំចូលចិត្តហែលទឹក ប៉ុន្តែខ្ញុំមិនត្រូវបានអនុញ្ញាតឲ្យហែលទៅកន្លែងជ្រៅៗទេ ។ អាងហែលទឹកនៅក្លិបមានទំហំធំដូច្នេះហើយ សូម្បីតែនៅកន្លែងទឹករាក់ក៏មានកន្លែងជាច្រើនសម្រាប់ឲ្យខ្ញុំលេងបាចទឹកដាក់មុខ បងជូ ដែរ ។

បន្ទាប់ពីម៉ាជួយស្លៀកពាក់ខោអាវងូតទឹកពណ៌ផ្កាឈូកឲ្យខ្ញុំ ប៉ានិងម៉ាក៏ដើរចេញទៅញ៉ាំអាហារថ្ងៃត្រង់នៅជាន់ទីពីរ ហើយទុកឲ្យ បងការ មើលខ្ញុំ ។ ប៉ានិងម៉ាបក់ដៃជាសញ្ញាពីតុរបស់គាត់ដែលស្ថិតនៅពីក្រោយបង្អួចកញ្ចក់ ។ នេះជាលើកដំបូងហើយដែលខ្ញុំឃើញបារាំង ។

“បងជូ គាត់នោះធំណាស់ហើយសទៀតផង!” ខ្ញុំឈប់បាចទឹកដាក់ បងជូ ហើយខ្សឹបប្រាប់គាត់ពីបុរសនោះ ។

“គាត់ជាជនជាតិបារាំង ។ បារាំងមានន័យថា គាត់ជាមនុស្សស្បែកស» បងជូ និយាយទាំងមុខញញឹមមករកខ្ញុំ ដោយព្យាយាមអួតពីចំណេះចេះដឹងក្នុងអាយុរបស់គាត់ ។ ខ្ញុំតាមសម្លឹងមើលបារាំងពេលដែលកំពុងតែដើរទៅរកក្តារសម្រាប់លោតចុះ

ទឹក ។ គាត់មានកម្ពស់ខ្ពស់ជាងប៉ាបីតឹក មានរោមវែងៗពាសពេញដៃនិងជើង ។ គាត់មានមុខជ្រុងវែង ច្រមុះស្រួចដូចស្ទាំង មានមាឌធំខ្ពស់ ។ ស្បែកសរបស់គាត់គ្របទៅដោយរោមពណ៌ខ្មៅនិងពណ៌ត្នោត ថែមទាំងមានចំណុចអុចតូចៗពណ៌ក្រហមនៅលើខ្លួនផង ។ គាត់ស្លៀកតែខោខ្លីផ្លូតទឹក និងពាក់មួកកៅស៊ូនៅលើក្បាលប៉ុណ្ណោះ ដែលមួកនោះធ្វើឲ្យក្បាលគាត់មើលទៅហាក់ដូចជាតម្លែក ។ គាត់លោតចុះពីលើក្តារខ្ពស់មកក្រោម ដោយមិនបាច់ខំប្រឹង ហើយធ្វើឲ្យទឹកខ្ទាតឡើងតែបន្តិចប៉ុណ្ណោះ ។ នៅក្នុងខណៈដែលយើងកំពុងមើលបារាំងហែលបណ្តែតខ្លួនលើទឹក បងគាវ ស្តីបន្ទោសឲ្យ បងជូ ថាផ្តល់ពត៌មានខុសឲ្យខ្ញុំ ។ ដោយគ្រវីក្រចកដ៏ក្រហមរបស់គាត់ដែលទើបតែលាបថ្មីចុះឡើងនៅក្នុងទឹកបណ្តើរ បងគាវ ប្រាប់យើងបណ្តើរថា “បារាំង” មានន័យថាគាត់នោះជាជនជាតិបារាំង ។ ដោយហេតុថាបារាំងមករស់នៅក្នុងប្រទេសយើងអស់រយៈពេលយូរមកហើយ យើងក៏ហៅជនជាតិស្បែកសទាំងអស់ថា “បារាំង” ប៉ុន្តែជនជាតិស្បែកសទាំងនោះអាចមកពីប្រទេសផ្សេងៗទៀត រួមទាំងប្រទេសអាមេរិកផង ។

## ការកាន់កាប់របស់ខ្មែរក្រហម

**ថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥**

នៅវេលារសៀលថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ ខ្ញុំកំពុងលេងមីកនៅមុខផ្ទះជាមួយមិត្តភក្តិ ។ ជាទូទៅ នៅថ្ងៃព្រហស្បតិ៍ ខ្ញុំត្រូវទៅសាលារៀន ប៉ុន្តែនៅថ្ងៃនេះ ប៉ាឲ្យយើងទាំងអស់គ្នានៅផ្ទះ ។ ខ្ញុំឈប់លេងមីកភ្លាមពេលដែលខ្ញុំឮសន្ធឹកម៉ាស៊ីនរថយន្តពីចម្ងាយ ។ ដោយឮស្នូរម៉ាស៊ីនរថយន្តលាន់ដូចផ្គរ ភ្លាមៗនោះមនុស្សគ្រប់គ្នាក៏ឈប់ធ្វើកិច្ចការដែលគេកំពុងធ្វើ ដើម្បីសម្លឹងមើលរថយន្តដឹកទំនិញដែលកំពុងបើកចូលមកក្នុងទីក្រុងរបស់យើង ។ ប៉ុន្មាននាទីក្រោយមក រថយន្តដឹកទំនិញកញ្ចាស់ៗប្រឡាក់ភក់ស្រម៉ក បានបើកកាត់មុខផ្ទះយើងសន្សឹមៗ ។ រថយន្តដឹកទំនិញពណ៌បៃតង ពណ៌ប្រផេះ និង ពណ៌ខ្មៅ ទាំងនោះបើកចល័តចុះឡើងៗនៅលើកង់ដ៏រអិលរបស់វា ធ្វើឲ្យខ្ទាតដី និងបង្ហុយផ្សែងម៉ាស៊ីនចេញមកក្រៅខ្មៅទ្រុបពេញអាកាស ។ នៅលើកន្ទុយរថយន្តដឹកទំនិញនោះ យើងឃើញមនុស្សប្រុសជាច្រើនស្លៀកខោជើងវែងពណ៌ខ្មៅស្នេក និងពាក់អាវដៃវែងពណ៌ខ្មៅ ហើយក្រវាត់ក្រមាក្រហមយ៉ាងតឹងនៅនឹងចង្កេះ ព្រមទាំងរុំក្រមាពណ៌ក្រហមជុំវិញក្បាលរបស់គេផង ។ បុរសៗនៅលើរថយន្តទាំងនោះលើកកណ្តាប់ដៃរបស់គេឡើងទៅលើ ហើយស្រែកហ៊ោឡើង ។ ភាគច្រើន អ្នកទាំងនោះមើលទៅមានវ័យក្មេងៗ សក់វែងប្រះស្មា លាបប្រេងរលើប មាឌស្គម និងស្បែកពណ៌ខ្មៅដូចកម្មករធ្វើស្រែនៅចម្ការឲ្យអ៊ំរបស់យើង ។ សក់វែងហើយលាបប្រេងរលើបបែបនេះគឺជាសភាពដែលមិនអាចទទួលបានសម្រាប់ក្មេងស្រីៗនៅក្នុងប្រទេសកម្ពុជា ។ នេះជាសញ្ញាបញ្ជាក់ថាអ្នកនោះមិនចេះថែរក្សារូបសម្បត្តិរបស់ខ្លួនឯងទេ ។ ចំណែកឯបុរសដែលមានសក់វែងនឹងទទួលការមើលងាយ និងចាត់ទុកជាមនុស្សដែលគួរឲ្យសង្ស័យ ។ បុរសទុកសក់វែងត្រូវបានគេយល់ថាច្បាស់ជាមានអ្វីមួយលាក់បាំងហើយ ។ ថ្វីបើអ្នកទាំងនោះមានរូបរាងយ៉ាងនេះក៏ដោយ ក៏ហ្វូងមនុស្សបានស្វាគមន៍ការមកដល់របស់គេដោយទះដៃនិងស្រែកអបអរទ្រហឹងអឺងកង ។ ទោះបីជាប្រុសៗទាំងនោះមានភាពស្មោកគ្រោក ប៉ុន្តែទឹកមុខរបស់គេពោរពេញទៅដោយសេចក្តីរីករាយ ។ ជាមួយនឹងកាំភ្លើងវែងនៅក្នុងដៃ អ្នកខ្លះទៀតស្ពាយកាំភ្លើងពីក្រោយខ្នង ទាំងអស់គ្នាសើចញញឹម ហើយលើកដៃគ្រវីត្រឡប់មករកហ្វូងមនុស្សវិញ ដូចជាស្តេចបានធ្វើនៅពេលដែលទ្រង់យាងឆ្លងកាត់កន្លែងណាមួយ ។

មិត្តភក្តិរបស់ខ្ញុំសួរខ្ញុំថា “តើមានរឿងអ្វីកើតឡើង? តើមនុស្សទាំងនេះជានរណា?” ។

“ខ្ញុំមិនដឹងទេ ខ្ញុំទៅរកប៉ាខ្ញុំសិន គាត់ច្បាស់ជាដឹងរឿងនេះ” ។

ខ្ញុំរត់ឡើងទៅលើផ្ទះ ដើម្បីរកប៉ាដែលកំពុងអង្គុយនៅយ៉ផ្ទះរបស់យើង សម្លឹងមើលភាពរំជើបរំជួលនៅខាងក្រោម ។ ខ្ញុំឡើងអង្គុយលើភ្លៅរបស់ប៉ា ហើយសួរគាត់ថា “ប៉ា បុរសទាំងនោះជានរណា ហេតុអ្វីបានជាមនុស្សគ្រប់គ្នានាំគ្នាអបអរសាទរគេ?” ។

គាត់ឆ្លើយតបយ៉ាងស្ងៀមស្ងាត់ថា “អ្នកទាំងនោះជាកងទ័ព ប្រជាជននាំគ្នាអបអរសាទរគេ ពីព្រោះសង្គ្រាមត្រូវបានបញ្ចប់ហើយ” ។

"តើគេចង់បានអ្វី?" ។

លោកប៉ាមានប្រសាសន៍ថា "គេចង់បានយើង" ។

"សម្រាប់ធ្វើអ្វីទៅ?" ។

"គេទាំងនោះមិនមែនជាមនុស្សល្អទេ ក្រឡេកមើលស្បែកជើងរបស់គេមើល! គេពាក់ស្បែកជើងសង្រែកធ្វើពីកង់ឡាន" ។ នៅក្នុងអាយុប្រាំឆ្នាំ ខ្ញុំមិនដែលវវល់នឹងព្រឹត្តិការណ៍សង្គ្រាមអ្វីឡើយ ប៉ុន្តែខ្ញុំដឹងថាប៉ាជាមនុស្សឆ្លាត ហេតុដូច្នេះគាត់ច្បាស់ជានិយាយត្រូវ ។ ដោយភាពឆ្លាតវៃរបស់ប៉ា គាត់អាចប្រាប់ខ្ញុំថាកងទ័ពទាំងនេះជាមនុស្សរបៀបណាដោយគ្រាន់តែក្រឡេកមើលស្បែកជើងរបស់ពួកគេប៉ុណ្ណោះ ទោះបីជារឿងនេះវាហួសពីសមត្ថភាពនៃការយល់ដឹងទាំងអស់របស់គាត់ក៏ដោយ ។

"ប៉ា! ហេតុអ្វីបានជាមកពីស្បែកជើងហ្នឹងអ៊ីចឹង? ហេតុអ្វីបានជាពួកគេអាក្រក់?" ។

"ស្បែកជើងនេះបង្ហាញថា ពួកអ្នកទាំងនោះជាអ្នកបំផ្លាញអ្វីៗទាំងអស់" ខ្ញុំមិនសូវជាយល់អ្វីដែលប៉ាមានប្រសាសន៍ប៉ុន្មានទេ ។ ខ្ញុំគ្រាន់តែសង្ឃឹមថា ថ្ងៃណាមួយ ខ្ញុំនឹងឆ្លាតបានប្រហែលពាក់កណ្តាលប៉ាមិនខាន ។

"ខ្ញុំមិនយល់ទេ" ។

"មិនអីទេកូន ហេតុអីក៏កូនមិនទៅលេងតទៀតទៅ កុំទៅណាឆ្ងាយពេក ហើយនៅឲ្យឆ្ងាយពីផ្លូវរបស់មនុស្សទាំងនោះព្ទុទេ?" ។

ខ្ញុំមានអារម្មណ៍ធូរស្រាលបន្តិច បន្ទាប់ពីបាននិយាយជាមួយប៉ា ខ្ញុំលោតចុះពីលើភ្លៅរបស់គាត់ ហើយដើរចុះទៅក្រោមវិញ ។ ខ្ញុំតែងតែស្តាប់តាមប៉ាជានិច្ច ប៉ុន្តែការចង់ដឹងចង់ឮរបស់ខ្ញុំនៅពេលនេះបានមកគ្របដណ្តប់លើចិត្តខ្ញុំជាប់ នៅពេលដែលខ្ញុំឃើញមនុស្សច្រើនឡើងៗមកជួបជុំគ្នានៅតាមផ្លូវ ។ នៅគ្រប់ទីកន្លែង ប្រជាជនបានស្រែកអបអរចំពោះការមកដល់របស់ក្រុមមនុស្សចម្លែក ។

ជាងកាត់សក់ឈប់កាត់ ហើយឈរផ្ទឹងនៅខាងក្រៅហាងដោយដៃទាំងពីររបស់គាត់នៅកាន់កន្ត្រៃនៅឡើយ ម្ចាស់ភោជ-នីយដ្ឋាននិងភ្ញៀវចេញមកក្រៅហាងដើម្បីមើលមនុស្សចម្លែកហើយអបអរដាក់ពួកគេ ។ នៅសងខាងផ្លូវ មានក្មេងប្រុស-ស្រីជាច្រើនក្រុម អ្នកខ្លះអង្គុយលើទោចក្រយានយន្ត ស្រែកនិងប្រឡាច់ស៊ីប្លេម៉ូតូរបស់គេលាន់ទ្រហឹង នៅក្នុងពេលដែលអ្នកខ្លះទៀតរត់ឡើងទៅលើរថយន្តដឹកទំនិញដើម្បីប៉ះឬចាប់ដៃកងទ័ពទាំងនោះ ។

នៅមុខផ្ទះរបស់យើង ក្មេងៗនៅតែលោតចុះលោតឡើងគ្រវីដៃទៅលើវេហាស៍ដើម្បីស្វាគមន៍មនុស្សចម្លែកទាំងអស់នោះ ។ ដោយក្តីរំភើប ខ្ញុំក៏គ្រវីដៃអបអរសាទរទៅកងទ័ពទាំងអស់នោះដែរ ទោះបីជាខ្ញុំមិនដឹងថាហេតុអ្វីបានជាខ្ញុំត្រូវគ្រវីដៃក៏ដោយ ។

បន្ទាប់ពីរថយន្តដឹកទំនិញបើកទៅផុត សំឡេងមនុស្សម្នាក៏ស្ងប់ស្ងាត់ ហើយខ្ញុំក៏ត្រឡប់មកផ្ទះវិញ ។ នៅពេលមកដល់ផ្ទះខ្ញុំភ្ញាក់ផ្អើលស្រឡាំងកាំងចំពោះទិដ្ឋភាពដែលខ្ញុំបានឃើញ ។ អ្នកផ្ទះរបស់ខ្ញុំកំពុងវេចខ្ចប់អីវ៉ាន់គ្រប់ៗគ្នា ។

"មានរឿងអីកើតឡើង? តើអ្នកទាំងអស់គ្នាចង់ទៅណា?" ។

"តើឯងបាត់ទៅណា? ប្រញាប់ទៅញ៉ាំបាយឲ្យលឿនទៅ យើងត្រូវតែចាកចេញពីផ្ទះក្នុងពេលឆាប់ៗនេះ" ។ ម៉ាកំពុងរត់ចុះរត់ឡើងគ្រប់ទីកន្លែងទាំងអស់ដើម្បីវេចខ្ចប់របស់របរនៅក្នុងផ្ទះយើង គាត់រត់លឿនខ្មីតពីកាច់ជ្រុងបន្ទប់ទៅកាន់បន្ទប់ទទួលភ្ញៀវដើម្បីដកយករូបថតរបស់គ្រួសារយើងហើយនិងរូបព្រះពុទ្ធចេញពីជញ្ជាំង ។

"ខ្ញុំអត់ឃ្លានទេម៉ា" ។

"កុំប្រកែកជាមួយម៉ា! ទៅញ៉ាំបាយទៅ! ដំណើរនេះនឹងជាដំណើរផ្លូវឆ្ងាយ" ។

អារម្មណ៍របស់ខ្ញុំប្រាប់ខ្ញុំថា ថ្ងៃនេះម៉ាមិនសូវមានភាពអត់ធ្មត់ទេ ដូច្នេះខ្ញុំសម្រេចចិត្តមិនតវ៉ានឹងគាត់ទៀតឡើយ ។ ខ្ញុំដើរលបៗទៅជិតចង្ក្រានបាយដោយត្រៀមស្រេចហើយថាខ្ញុំនឹងមិនញ៉ាំអ្វីទាំងអស់ ព្រោះខ្ញុំតែងតែញ៉ាំចំណីចំណុកនៅខាងក្រៅ ហើយសល់យកវាមកលាក់នៅកន្លែងណាមួយនៅក្នុងផ្ទះរហូតដល់ជួនកាលខ្ញុំរកមិនឃើញហើយពឹងអ្នកផ្សេងឲ្យជួយរកថែមទៀតផង ។

**(នៅមានត)**

# នារីពេទ្យបដិវត្តស្រុកត្រាំកក់

របបកម្ពុជាប្រជាធិបតេយ្យបានលើកស្ទួយនារីកសិករអ្នកមូលដ្ឋានដែលមិនចេះអក្សរនៅតាមជនបទដាច់ស្រយាល ឲ្យទទួលតួនាទីសំខាន់ៗក្នុងកិច្ចការរបស់បក្ស ។ នារីស្រុកត្រាំកក់ត្រូវបានអង្គការផ្តល់តួនាទីក្នុងការគ្រប់គ្រងនារីនៅតាមភូមិភាគនានា ។ កម្មាភិបាលស្ទើរតែគ្រប់មន្ទីរពេទ្យនៅក្រុងភ្នំពេញ សុទ្ធតែនារីមកពីស្រុកត្រាំកក់និងស្រុកដទៃទៀតនៅក្នុងខេត្តតាកែវ ។ នៅឆ្នាំ១៩៧៧ នារីស្រុកត្រាំកក់មួយភាគធំត្រូវអង្គការបញ្ជូនទៅទូទាំងខេត្តតាកែវ ដើម្បីតាមដាននិងគ្រប់គ្រងប្រជាជនក្នុងភូមិភាគទាំងអស់នៃខេត្តតាកែវ ។ មូលហេតុដែលអង្គការផ្តល់អាទិភាពព្រោះថា នារីស្រុកត្រាំកក់បានទទួលការអប់រំពីគោលនយោបាយរបស់បក្សមុនបង្អស់ ។ ស្រុកត្រាំកក់ជាស្រុកមួយដែលលេចធ្លោជាងគេខាងវិស័យយោធានិងសេដ្ឋកិច្ច និងជាស្រុកមួយដែលខ្មែរក្រហមយកធ្វើជាបន្ទែកមូលដ្ឋានសម្រាប់តស៊ូប្រដាប់អាវុធ ។ ស្រុកត្រាំកក់បានក្លាយជាស្រុកគំរូនិងជាដៃស្តាំរបស់បក្សក្នុងចំណោមស្រុកចំនួន២០នៅក្នុងភូមិភាគនិរតី ។

តាមឯកសារស្តីពីគោលការណ៍របស់នារីបានឲ្យដឹងថា គោលនយោបាយរបស់អង្គការយកនារីធ្វើជាមុខព្រួញយ៉ាងសំខាន់ក្នុងការធ្វើបដិវត្តន៍កម្ទាត់រដ្ឋអំណាចសត្រូវ កម្ទាត់ទាំងសេដ្ឋកិច្ច វប្បធម៌ ព្រោះនារីមានចំនួន៥០ភាគរយក្នុងចំណោមប្រជាជនកម្ពុជាទាំងអស់ ។

នៅក្នុងឯកសាររបស់តុលាការប្រជាជនបដិវត្តឆ្នាំ១៩៧៩ គ្រីយ៍ បេងហុង បានរាយការណ៍ឲ្យដឹងថា នៅក្នុងអំឡុងឆ្នាំ១៩៧៧-៧៨ អង្គការបានបញ្ជូននារីពីភូមិភាគនិរតីជាច្រើនឲ្យមកគ្រប់គ្រងនៅភូមិភាគបូព៌ា ។ នៅស្រុកកងមាស នារី ធី ត្រូវបានអង្គការប្រគល់តួនាទីកាន់កាប់និងតាមដានប្រជាជន ។ បេងហុង បាននិយាយថា អ្នកមកពីភូមិភាគនិរតីមានឥទ្ធិពលខ្លាំងណាស់ ។ ធី ត្រូវបានអង្គការផ្តល់សិទ្ធិក្នុងការគ្រប់គ្រងនិងសម្លាប់ប្រជាជននៅស្រុកកងមាស ។

មុខវិជ្ជាពេទ្យជាមុខជំនាញមួយដែលនារីនៅក្នុងរបបកម្ពុជាប្រជាធិបតេយ្យប្រាថ្នាចង់បាន ព្រោះថាជាមុខវិជ្ជាដែលបានទទួលការគោរពកោតខ្លាចពីស្រទាប់មហាជនក្នុងរបបនោះ ។ ការគោរពកោតខ្លាចពីមហាជន ធ្វើឲ្យនារីពេទ្យមួយចំនួនធំមានចរិតមានះនិងឆ្មើងឆ្មៃ ។ អង្គការបានហៅការងារពេទ្យថា “ការងារសង្គមកិច្ច” ។ វិស័យសុខាភិបាលត្រូវបានអង្គការលើកសរសើរយ៉ាងខ្លាំងបន្ទាប់ពីវិស័យយោធា ។ ពាក្យស្លោករបស់ខ្មែរក្រហមគឺ “កូនស្រីត្រូវធ្វើជាពេទ្យ ឯកូនប្រុសត្រូវធ្វើជាកងទ័ព” ។ អង្គការបានយកភាសិតនេះមកឃោសនាក្នុងបណ្តាស្រទាប់កម្មាភិបាលនិងមហាជននៅទូទាំងប្រទេសកម្ពុជា ។ នារីក្មេងៗខ្លះអាយុប្រមាណ១២-១៣ឆ្នាំ បានចាកចេញពីឪពុកម្តាយ ស្ម័គ្រចិត្តចូលធ្វើពេទ្យ ។ នារីមួយចំនួនស្ម័គ្រចិត្តចូលធ្វើពេទ្យព្រោះតែចង់គេចឲ្យផុតពីការគាបសង្កត់របស់រដ្ឋអំណាចនៅមូលដ្ឋាន ។ នារីមួយចំនួនបានចូលធ្វើជាពេទ្យព្រោះឈឺចិត្តនឹងអង្គការ និងឈឺចិត្តនឹងនារីដូចគ្នាដែលជៀលត្មះថាជាជនកំសាកមិនហ៊ានទៅសមរភូមិមុខ ។ ក្នុងចំណោមនារីពេទ្យទាំងអស់ក៏មាននារីជាកូនកម្មាភិបាលដែរ ។ នារី ជិន, សុំ និងនារីក្មេងៗជាច្រើនទៀតនៅភូមិមឿងចារ ឃុំជាងទង ស្រុកត្រាំកក់ បានរត់ទៅបម្រើបដិវត្តន៍ព្រោះតែចង់ធ្វើពេទ្យ ។ នារី សុំ ត្រូវអង្គការបញ្ជូនទៅធ្វើជាបុគ្គលិកពេទ្យនៅភ្នំពេញ ។ សុំ បានចូលរៀនខាងផ្នែកពេទ្យក្រោមការបណ្តុះបណ្តាលពីបុគ្គលិកពេទ្យដូចគ្នា ។ នារី លីន ហៅ អាគ្រូ និងកូនស្រីបីនាក់ទៀត ជាកូនរបស់ តាម៉ុក បានធ្វើពេទ្យនៅភូមិភាគនិរតី ។ សមមិត្ត ជា លេខាតំបន់២៥ បានយកកូនស្រីទៅផ្ញើសមមិត្ត ភា (អៀង ធីរិទ្ធ) នៅពេទ្យ ព-១ ជាមន្ទីរពេទ្យកុមារ ។ កែ ពក បានយកកូនស្រីទៅផ្ញើសមមិត្តប្រធានពេទ្យនៅមន្ទីរពេទ្យកុមារពេទ្យព-១ ។ សែម ជន បានចូលធ្វើពេទ្យព្រោះតែនារី បឿន និយាយថា “យើងកូនខ្មែរ ត្រូវចេញទៅរៀនពេទ្យអីខ្លះ យើងអង្គុយពឹងគេអ្នកចេះ បានអ្នកណាស្គង

ត្រកូលតស៊ូអ្នកបដិវត្តន៍» ។ កូនរបស់ អៀង ធិរិទ្ធ ចំនួនបីនាក់ សុទ្ធតែមានតួនាទីជាកម្មាភិបាលសង្គកិច្ចនៅក្រុងភ្នំពេញ ។ នារី មិញ បានក្លាយជាប្រធានមន្ទីរពេទ្យ ៣-១ ព្រោះតែមាន អៀង ធិរិទ្ធ រដ្ឋមន្ត្រីក្រសួងសង្គមកិច្ច និង អៀង សារី ឧបនាយករដ្ឋមន្ត្រីនិងរដ្ឋមន្ត្រីក្រសួងការបរទេស ជាឪពុកម្តាយ ។

នៅស្រុកត្រាំកក់ អង្គការមានការប្រយ័ត្នប្រយែងយ៉ាងខ្លាំង ក្នុងការជ្រើសរើសសមាជិកឲ្យចូលបម្រើក្នុងមន្ទីរក្រសួងនីមួយៗ ។ អង្គការអង្កេតនិងចំរាញ់យកប្រវត្តិរូបយ៉ាងល្អិតល្អន់មុននឹងឲ្យនារីណាម្នាក់ទទួលតំណែងជាពេទ្យ ។ ទម្រាំក្លាយខ្លួនជានារីពេទ្យរបស់អង្គការ នារីត្រូវឆ្លងកាត់ការលំបាកជាច្រើនក្នុងការដែលធ្វើឲ្យអង្គការមានទំនុកចិត្ត ព្រោះ «នៅគ្រប់ស្ថាប័នក្រសួងមន្ទីររបស់អង្គការបដិវត្តន៍ត្រូវតែអនុវត្តន៍នូវគោលការណ៍មួយ គឺសមាជិកម្នាក់ៗត្រូវឆ្លងកាត់ការជ្រើសរើសប្រវត្តិរូបច្រើនដំណាក់កាលលើកលែងតែលំដាប់មជ្ឈិម» ។ «បើអ្នកណាប្រឆាំងនឹងអ្នកកសាងប្រវត្តិរូបថ្មី គឺប្រឆាំងនឹងមាគ៌ាបក្សប្រឆាំងនឹងការប្រមូលកម្លាំងរបស់បក្ស» ។ ក្នុងសំបុត្ររបស់មន្ទីរ៨៧០ និងចំណាររបស់សមមិត្ត សុន សេន ហៅ ខៀវ បានបញ្ជាក់អំពីការ «ជ្រើសរើសនារីពេទ្យត្រូវមាននយោបាយនិងវណ្ណៈភាពល្អ» ។ សុន សេន បានផ្ញើទៅគ្រប់កងពល វរសេនាធំ ៣-៩៨ និងភ័ស្តុភារ ឲ្យអនុវត្តតាមគោលការណ៍នេះ ដើម្បីឲ្យសង្គមកិច្ចបើកវគ្គកសាងពេទ្យ ។ នៅដំណាក់កាលដំបូងនៃសម័យតស៊ូក្នុងព្រៃ អង្គការហាក់ដូចជាពុំសូវតឹងតែងក្នុងការជ្រើសរើសប្រវត្តិរូបទេ ឲ្យតែនារីស្ម័គ្រចិត្តចូលបំរើក្នុងបដិវត្តន៍ អង្គការទទួលយកទាំងអស់ ។ ក្រោយពីទទួលបានជ័យជម្នះ អង្គការបានអនុវត្តន៍នូវគោលការណ៍តែមួយប៉ុណ្ណោះ ក្នុងការជ្រើសរើសឲ្យធ្វើជាពេទ្យ÷ «ពេទ្យបដិវត្តន៍ត្រូវប្រសូត្រចេញពីកូនចៅវណ្ណៈកសិករធ្វើស្រែ



ចិញ្ច្រាំដើមរុក្ខជាតិធ្វើថ្នាំ

ចម្ការ» ព្រោះ «វណ្ណៈកសិករជាវណ្ណៈធំជាងគេ...» ។ នារីពេទ្យភាគច្រើននៅស្រុកត្រាំកក់ មានប្រភពចេញពីវណ្ណៈកសិករ កូនអ្នកមូលដ្ឋានដែលមិនសូវចេះអក្សរ ។

អង្គការអនុវត្តតាមទ្រឹស្តីនេះដោយមិនយកអ្នកមានចំណេះវិជ្ជាពីសង្គមចាស់មកប្រើប្រាស់ ព្រោះតែអង្គការគិតថាជាផ្នែកមួយនៃអាណានិគមជិះជាន់របស់សក្តិភូមិ នាយទុន បំពុលស្មារតីយុវនារីទៅតាមទស្សនៈនិងផលប្រយោជន៍វណ្ណៈ ។ ក្នុងបទសម្ភាសន៍របស់ ប៉ុល ពត ជាមួយគណៈប្រតិភូប៊ែលហ្ស៊ិក នៅថ្ងៃទី៥ ខែសីហា ឆ្នាំ១៩៧៨ បាននិយាយថា «វប្បធម៌កម្ពុជាប្រជាធិបតេយ្យមានលក្ខណៈជាវប្បធម៌ថ្មី...លុបបំបាត់ចំណុចណាដែលប្រតិកិរិយា» ។ អង្គការមិនជឿនិងមិនទុកចិត្តទាល់តែសោះចំពោះអ្នកដែលបានទទួលការសិក្សាជ្រៅជ្រះចេញពីសាលារបស់វណ្ណៈជិះជាន់ ។ អង្គការបានលើកស្ទួយនារីវណ្ណៈកសិករដោយផ្តល់សិទ្ធិអំណាចគ្រប់យ៉ាងដល់កូនកសិករ ដោយសារតែ «នារីកសិករពុំបានរៀនសូត្រដូចវណ្ណៈជិះជាន់ដទៃ រវល់តែលះបង់ពេលវេលាដ៏មានតម្លៃរបស់ខ្លួនដើម្បីបម្រើបដិវត្តន៍» ។

ឆ្នាំ១៩៧៨ ប៉ុល ពត បាននិយាយថា «ការថែបំប៉នសុខភាព» គឺមិនធ្វើតាមសន្ទាក់ការងារនាយទុនឡើយ ។ បើតាមបទសម្ភាសន៍ជាមួយនារីពេទ្យនៅស្រុកត្រាំកក់ គ្មាននារី ១៧ មេសា ណាម្នាក់មានវាសនាបានចូលធ្វើពេទ្យបដិវត្តន៍ខ្មែរក្រហមឡើយ ។

រោងចក្រផលិតថ្នាំចំនួន៤នៅទីក្រុងភ្នំពេញត្រូវគាំងដំណើរ ព្រោះតែអង្គការយកនារីកូនកសិករដែលមិនចេះអក្សរឲ្យមកផលិតថ្នាំ ធ្វើឲ្យលទ្ធផលមានកម្រិតតិចជាងផែនការ ។ ឃើញដូច្នេះ ប៉ុល ពត បានបញ្ជាឲ្យរកអ្នកមានចំណេះពីសង្គមមកបម្រើការនៅក្នុងរោងចក្រផលិតថ្នាំវិញ ។

មន្ទីរពេទ្យមួយស្ថិតនៅក្នុងឃុំត្រពាំងធំខាងជើង ស្រុកត្រាំកក់ ខេត្តតាកែវ ចាប់បង្កើតឡើងនៅឆ្នាំ១៩៧៥ ដំណើរការរហូតដល់ឆ្នាំ១៩៧៩ ដែលមានប្រធានឈ្មោះ រៀល សន និងបុគ្គលិកពេទ្យចំនួន៩៦នាក់ ។ តាមបទសម្ភាសន៍ជាមួយអតីតនារីពេទ្យជាច្រើនបាននិយាយថា សមាសភាពកម្មាភិបាលនៅពេទ្យស្រុកមានមិនទៀងទាត់ទេ ។ អង្គការតែងតែផ្លាស់ប្តូរកម្មាភិបាលពេទ្យជាញឹកញាប់ ។ កម្មាភិបាលពេទ្យមួយចំនួនបានបាត់ខ្លួនដោយសម្ងាត់ ។ នារីនៅពេទ្យស្រុកខ្លះត្រូវអង្គការបញ្ជូនទៅធ្វើការនៅពេទ្យតំបន់និងភូមិភាគនានា ព្រោះតែអ្នកទាំងនោះធ្វើការងារសកម្មនិងមានប្រវត្តិល្អ ។ នៅក្នុងមន្ទីរពេទ្យ អង្គការបានបែងចែកជា៥ផ្នែក គឺ ផ្នែកជំងឺទូទៅ ផ្នែកឆ្មប ផ្នែកស្លថ្នាំ ផ្នែកដាំបាយ និងផ្នែកបង្កបង្កើនផល ។ ផ្នែកស្លថ្នាំចែកចេញជាពីរទៀតគឺ ស្លថ្នាំបុរាណនិងថ្នាំសម័យ ។ ប៉ុន្តែនារីពេទ្យណាដែលទំនេរពីការងារ ត្រូវចែកវេនគ្នាទៅតាមមុខសញ្ញាប្រចាំសប្តាហ៍និងប្រចាំថ្ងៃដែលអង្គការបានកំណត់ ។ អង្គការមិនអនុញ្ញាតឲ្យនារីពេទ្យនៅទំនេរឬខ្ជះខ្ជាយពេលវេលាដោយឥតប្រយោជន៍ និងមិនទម្លាប់ឲ្យបុគ្គលិកពេទ្យចេះធ្វើការតែមួយមុខៗនោះទេ ។ រាល់កិច្ចការក្នុងមន្ទីរពេទ្យ កម្មាភិបាលពេទ្យទាំងអស់ត្រូវតែចេះនិងអាចជំនួសគ្នាបាននៅពេលអ្នកណាម្នាក់អវត្តមាន ។

នៅក្នុងមន្ទីរពេទ្យស្រុកត្រាំកក់អង្គការបានបែងចែកអ្នកជំងឺជាពីរប្រភេទ គឺអ្នកជំងឺជាប្រជាជនមូលដ្ឋាននិងអ្នកជំងឺ ១៧មេសា ។ អ្នកជំងឺបានទទួលត្រឹមតែថ្នាំលេបដែលផលិតដោយអង្គការប៉ុណ្ណោះ ។ នៅក្នុងមន្ទីរពេទ្យស្រុកក៏ដូចជាមន្ទីរពេទ្យនៅឃុំដទៃទៀតដែរ អ្នកជំងឺភាគច្រើនសុទ្ធតែជាប្រជាជន ១៧មេសា ជាប្រជាជនដែលអង្គការចាត់ទុកថាជាជនបញ្ញើក្អែក ឬប្រជាជនប្រភេទទីបីនិងជាជនដែលត្រូវអង្គការកម្ចាត់ចេញពីសង្គមកម្ពុជាប្រធិបតេយ្យ ។

សេចក្តីស្រេកឃ្លានធ្វើឲ្យប្រជាជនភ្លេចគិតពីសុខភាពអនាម័យ ។ អ្នកទាំងនោះចេះតែបរិភោគផ្តេសផ្តាស ផឹកទឹកនៅក្នុងស្រែ ចំណីអាហារគ្មានអនាម័យ បូករួមទាំងអាកាសធាតុក្តៅនិងសើម ធ្វើការហួសកម្លាំង បណ្តាលឲ្យសរីរាង្គកាយចុះខ្សោយឆាប់ទទួលរងនូវជំងឺរាតត្បាតផ្សេងៗ ។ ក្នុងបទសម្ភាសន៍ជាមួយ រៀល សន អ្នកកាន់បញ្ជី និងអតីតនារីពេទ្យជាច្រើនរូបទៀតនៅស្រុកត្រាំកក់បាននិយាយថា ប្រជាជន១៧មេសា ភាគច្រើនកើតជំងឺហើមខ្វះជីវជាតិ ។ អង្គការបានផ្សព្វផ្សាយថា ជំងឺហើមទាំងនោះបណ្តាលមកពី«ចក្រពត្តិអាមេរិកបាចមេរោគមីពុល» ពាសវាលពាសកាល ធ្វើឲ្យមនុស្សសត្វពុល

ខូចសុខភាពរហូតដល់ស្លាប់ ។ រៀល សន និយាយថា ក្នុងមួយថ្ងៃៗមានអ្នកជំងឺ១៧មេសាស្លាប់ពី៥ ទៅ២០នាក់ ។ អត្រានៃការស្លាប់នេះ មិនគិតពីចំនួនអ្នកជំងឺស្លាប់នៅតាមពេទ្យឃុំ តាមការដ្ឋាន និងតាមផ្ទះទេ ។ គាត់ដឹងចំនួនត្រឹមតែក្នុងមន្ទីរពេទ្យរបស់គាត់តែប៉ុណ្ណោះ ។ អ្នកជំងឺជាប្រជាជន១៧មេសា អនុញ្ញាតឲ្យមកសម្រាកនៅមន្ទីរពេទ្យបានលុះត្រាតែមានលិខិតធានាបញ្ជាក់ពីគ្រូពេទ្យនៅតាមការដ្ឋាន ពីប្រធានក្រុម និងប្រធានការដ្ឋានជាមុនសិន ។ ជួនកាលអ្នកជំងឺនោះត្រូវអង្គការចោទថា «គ្មានទន្សាយ ឬគ្មានញាក់គ្មានញ័រ គ្មានគ្រាក់ទ័រ គ្មានឡានគ្មានសតិអារម្មណ៍» ។ អ្នកជំងឺនៅតាមកងបានផ្ញើជីវិតទៅលើពេទ្យប្រចាំការដ្ឋាន ឬពេទ្យឃុំទាំងស្រុង «បើពេទ្យថាឲ្យរស់គឺរស់ បើពេទ្យថាឲ្យស្លាប់គឺស្លាប់» ។

បងស្រី អ៊ិន និយាយថា តាមពិតនៅក្នុងមន្ទីរពេទ្យពុំមានអ្នកជំងឺសតិអារម្មណ៍ទេ អង្គការចេះតែចោទ អ្នកឈឺគ្រប់គ្នាឃ្លានណាស់ ចេះតែលួចនេះលួចនោះ ខ្លួនគាត់ក៏ធ្លាប់បានលួចអង្ករដាំបាយហូបដែរ ។

ការកំណត់របបអាហារនិងបង្ខំឲ្យធ្វើការហួសកម្លាំងបណ្តាលឲ្យស្ត្រីដែលទើបសម្រាលកូនរួច ងាយទទួលរងគ្រោះនូវជំងឺគ្រប់ប្រភេទ ដូចជាជំងឺខ្វះទឹកដោះ ជាដើម ។

នៅមន្ទីរពេទ្យផ្សេងៗក៏មិនខុសពីមន្ទីរពេទ្យស្រុកត្រាំកក់ដែរ អង្គការថ្នាក់លើបានដឹងយ៉ាងច្បាស់ពីបញ្ហាខ្វះខាតថ្នាំសង្កូវ ខ្វះស្បៀងអាហារនាំឲ្យប្រជាជនកើតជំងឺឈឺថ្កាត់ស្គមស្គាំងនេះដែរ ។ ប្រជាជន ១៧ មេសា ត្រូវបាត់បង់ជីវិតអស់ជាច្រើន ។ អង្គការបានផ្សព្វផ្សាយតាមវិទ្យុទស្សនាវដ្តីថា «ក្រសួងសង្គមកិច្ចសុខាភិបាលមានការរីកចំរើនខ្លាំង សុខភាពប្រជាជនកាន់តែរឹងប៉ឹងល្អ បានកម្ចាត់ជំងឺគ្រុនចាញ់និងជំងឺសង្គមគ្រប់បែបយ៉ាងនៅពាក់កណ្តាលឆ្នាំ១៩៧៧ និង ១៩៧៨ ចំនួនទារកកើត ៣៩២.០០០នាក់ ក្នុងចំនួនមនុស្ស ៧៨០០.០០០នាក់ គឺស្មើនឹង៥០ភាគរយ ។ ឯចំនួនដែលស្លាប់មិនដល់១៣ភាគពាន់ទេ ។ សំណូមពររបស់បក្សបង្កើនប្រជាជនពី១៥ ទៅ២០លាននាក់ ក្នុងរយៈពេលពី១៥ ទៅ២០ឆ្នាំ ដោយយកចិត្តទុកដាក់លើកស្ទួយថែបំប៉នជីវភាពនិងសុខភាពប្រជាជន» ។

ប្រជាជនមូលដ្ឋានឬប្រជាជនចាស់ពុំសូវទទួលរងនូវជំងឺដូចប្រជាជន១៧មេសាទេ ដោយហេតុថាអ្នកមូលដ្ឋានធ្លាប់មានប្រវត្តិតស៊ូកាលពីសង្គ្រាមជាមួយគ្នា អង្គការតែងតែអនុគ្រោះឲ្យប្រជាជនមូលដ្ឋានច្រើនជាងប្រជាជន១៧មេសា ។ អ្នកជំងឺមូលដ្ឋានត្រូវបានទទួលការថែទាំយ៉ាងដិតដល់ពីកម្មាភិបាលពេទ្យដែលជាអ្នកមូលដ្ឋានដូចគ្នា ។

នៅក្នុងមន្ទីរពេទ្យ អ្នកជំងឺមិនបានត្រូវអនុញ្ញាតឲ្យដើររហេតរហូតឬទៅណាតាមចិត្តចង់នោះទេ ។ បុគ្គលិកពេទ្យនឹងឲ្យអ្នកជំងឺត្រឡប់ទៅការដ្ឋានវិញភ្លាម ប្រសិនបើមិនគោរពវិន័យរបស់មន្ទីរពេទ្យ ម្យ៉ាងទៀតនារីពេទ្យយល់ថាអ្នកជំងឺនោះជាសះស្បើយអាចដើរបាន ។ អ្នកជំងឺគ្មានសិទ្ធិតវ៉ាជាមួយបុគ្គលិកពេទ្យទេ ។

មូលហេតុដែលបណ្តាលឲ្យអ្នកជំងឺស្លាប់ច្រើន មកពីបុគ្គលិកពេទ្យបានទទួលការបណ្តុះបណ្តាលផ្នែកវិជ្ជាពេទ្យត្រឹមតែរយៈពេលបីខែ រួចអនុវត្តផ្ទាល់តែម្តង ។ នារីពេទ្យមួយចំនួនធំសុទ្ធតែមិនចេះអក្សរពុំអាចយល់នូវខ្លឹមសារនៃមុខវិជ្ជាពេទ្យដែលសរសេរភាសាបារាំង ជាពិសេសថ្នាំដែលមានឈ្មោះជាភាសាបរទេស ។ ការមិនយល់នូវភាសាពេទ្យធ្វើឲ្យនារីពេទ្យទាំងនោះមានការភ័ន្តច្រឡំជាញឹកញាប់ក្នុងការប្រើថ្នាំព្យាបាលអ្នកជំងឺ ។ ប្រធានពេទ្យឈ្មោះ ស៊ុម លាងហាក់ ហៅ សី ក៏បានធ្វើរបាយការណ៍នៅក្នុងកិច្ចប្រជុំគណៈអចិន្ត្រៃយ៍ ដូន ប៉ុល ពត នួន ជា ខៀវ សំផន និង អៀង ធីរិទ្ធ ថា នៅក្នុងមន្ទីរពេទ្យ១៧មេសា មានការប្រើថ្នាំច្រឡំជាច្រើនដងទៅលើអ្នកជំងឺ ។ ការភ័ន្តច្រឡំបណ្តាលមកពីនារីពេទ្យទាំងនោះមិនចេះអក្សរ ។ ក្នុងកិច្ចប្រជុំនោះ អៀង ធីរិទ្ធ ក៏ទទួលស្គាល់អំពីការលំបាករបស់នារីពេទ្យដែលមិនចេះអក្សរហើយទៅរៀនវិជ្ជាពេទ្យពីគ្រូពេទ្យជាជនជាតិចិនដែរ ។

អ៊ុម និយាយថា នារីពេទ្យម្នាក់ឈ្មោះ ខន អនុប្រធានពេទ្យបានយកថ្នាំទៅចាក់យុវជន១៧មេសា ឈ្មោះ កុក គ្រោង គ្រាន់តែដកម្ជុលប្រហែលមួយសន្ទុះ អ្នកជំងឺនោះស្រែកអូយៗ ហើយក៏ដាច់ខ្យល់ស្លាប់ទៅ ។ សន និយាយថា នារីពេទ្យម្នាក់បានយកថ្នាំទៅចាក់ឲ្យអ្នកជំងឺ១៧មេសា គ្រាន់តែដកម្ជុលចេញ

ក្លាម អ្នកជំងឺប្រកាច់ស្លាប់មួយរំពេច ។ សន និយាយទៀតថា នារីនោះមិនចេះអក្សរមិនដឹងថាថ្នាំនោះជាថ្នាំអ្វីទេ ចេះតែចាក់ស្នានៗ ។

ការបង្រៀនខាងវេជ្ជសាស្ត្រនៅមន្ទីរពេទ្យស្រុកត្រាំកក់ ក៏មិនខុសពីមន្ទីរពេទ្យដទៃទៀតដែរ វិធីសាស្ត្រមានតែមួយគត់ គឺការចំណាំ ទាំងការចាក់ថ្នាំឲ្យអ្នកជំងឺ និងអាការរោគរបស់អ្នកជំងឺ ។ នៅពេលអ្នកជំងឺមានអាការធ្ងន់ធ្ងរមកព្យាបាលនៅក្នុងមន្ទីរពេទ្យ ទាំងប្រធាននិងបុគ្គលិក ពុំអាចមានលទ្ធភាពព្យាបាលបាន ក៏បណ្តោយឲ្យអ្នកជំងឺស្លាប់តាមយថាកម្ម ។

ក្រៅពីបង្ហាត់បង្រៀនអ្វីដែលហៅថា ក្បួនវេជ្ជសាស្ត្រថ្មី អង្គការបានប្រឹងប្រែងបណ្តុះបណ្តាលនារីពេទ្យឲ្យចេះប្រើប្រាស់និងផលិតថ្នាំថ្មីៗតាមក្បួនវេជ្ជសាស្ត្របុរាណថែមទៀត ដើម្បីបំពេញតាមផែនការ "មហាលោតផ្លោះមហាអស្ចារ្យ និងផ្សារភ្ជាប់ខ្លួនទៅនឹងមហាចលនាសម្រេច៣តោន១ហិកតា" ដើម្បីកសាងវប្បធម៌សង្គមកិច្ចថ្មី ។ នៅក្នុងទស្សនាវដ្តីទង់បដិវត្តបានសរសេរថា "នៅផ្នែកសង្គមកិច្ចនិងសុខាភិបាលមានការរីកចម្រើនខ្លាំងណាស់ ព្រោះរោងចក្រផលិតថ្នាំនៅក្រុងភ្នំពេញកំពុងវាយសម្រុកផលិតថ្នាំសម័យនិងថ្នាំជាតិដែលប្រើប្រាស់វត្ថុធាតុដើមនៅក្នុងប្រទេស បម្រើសេចក្តីត្រូវការរបស់ប្រជាជនបានជោគជ័យ ។ ក្រៅពីនេះនៅតាមភូមិភាគ តំបន់ ស្រុក រហូតដល់សហករណ៍ សុទ្ធតែមានមន្ទីរពេទ្យសម្រាប់ព្យាបាលអ្នកជំងឺនិងមន្ទីរផ្សំថ្នាំជាអតិបរមាឯករាជ្យម្ចាស់ការ" ។ ប៉ុល ពត បានដាក់ផែនការទៅមន្ទីរពេទ្យឲ្យខិតខំស្រាវជ្រាវរកដើមឈើនិង "យកគ្រូថ្នាំបុរាណឲ្យប្រាប់រូបមន្តផលិតថ្នាំ" ។ នៅស្រុកត្រាំកក់មានមន្ទីរពេទ្យធំចំនួនពីរនិងមន្ទីរពេទ្យតាមឃុំចំនួន១២ ។ មន្ទីរពេទ្យឃុំនីមួយៗមានកន្លែងផលិតឱសថ ។ គ្រប់មន្ទីរពេទ្យត្រូវឯករាជ្យម្ចាស់ការលើបញ្ហាថ្នាំព្យាបាលអ្នកជំងឺ ។ នៅក្នុងកិច្ចប្រជុំអចិន្ត្រៃយ៍ ឌីជុន ហៅ ធុក គណៈបច្ចេកទេសពេទ្យធ្មេញនិងកម្ចាត់ជំងឺគ្រុនចាញ់ បានរាយការណ៍អំពីបញ្ហាថ្នាំបុរាណដែលគាត់បានប្រមែប្រមូលរូបមន្តថ្នាំចម្រុះទូទាំងប្រទេស មកបោះពុម្ពជាសៀវភៅឲ្យអង្គការអនុម័ត ។ ជុន បានប្រាប់អង្គការថាគាត់មានរូបមន្តនិងដើមឈើសំបូរបែប សូម្បីតែប្រទេសថៃក៏យករូបមន្តពីគាត់ទៅផលិតថ្នាំដែរ ។

ថាន នារីផលិតថ្នាំបូរាណនៅមន្ទីរពេទ្យស្រុកត្រាំកក់ បាននិយាយថា តាពូន ប្រធានផ្នែកផលិតថ្នាំបុរាណ បានបញ្ជាឲ្យលាយប្រមាត់មនុស្សជាមួយម្សៅមីនិងដើមឈើច្រើនមុខទៀតដើម្បីស្ងូនជាថ្នាំគ្រាប់ ហៅថា "ថ្នាំអាចម៍ទន្សាយ" ។ ដើមរុក្ខជាតិថ្នាំត្រូវបាន តាពូន និងនារីពេទ្យទៅស្វែងរកនៅតំបន់ភ្នំឆ្ងាយៗ រីឯប្រមាត់មនុស្សបានមកពីខាងសន្តិសុខផ្ញើមកឲ្យ ។

ក្រៅពីផលិតថ្នាំបូរាណ មន្ទីរពេទ្យស្រុកត្រាំកក់ក៏ផលិតថ្នាំសម័យដែរ ។ វិធីផលិតថ្នាំទឹកគឺយកទឹកធម្មតាទៅបិតបន្ថូរដូចបិតស្រា ។ បន្ទាប់មក យកទឹកដែលបានបន្សុទ្ធរួចទៅលាយជាមួយមេថ្នាំតាមកម្រិត ។ លាយរួចទុកថ្នាំនោះឲ្យត្រជាក់ទើបច្រកដាក់ដបប៉ិបស៊ី ឬដបទឹកក្រូចកូកាកូឡា ។

នៅឯទីក្រុងភ្នំពេញ អង្គការបានបង្កើតរោងចក្រចំនួន៤សម្រាប់ផលិតថ្នាំសម័យ ។

ក្រៅពីភារកិច្ចដ៏មមាញឹកនិងគ្មានពេលវេលាសម្រាកនារីពេទ្យនៅស្រុកត្រាំកក់ត្រូវគោរពអង្គការវិន័យនិងសីលធម៌ឲ្យបានហ្មត់ចត់ ។ អ្វីដែលអង្គការចង់ឲ្យគោរពប្រតិបត្តិនោះគឺសីលធម៌១២ប្រការ ។ **(នៅមានត)**

**វ៉ែម សុខឃីម**

## ពន្យល់ពាក្យខ្មែរក្រហម

◆ **ធាតុពិតជាប់ជិតស្និទ្ធនឹងមហាជនៈ** មានមហាជននៅជាមួយបក្ស ។ គណៈកម្មាធិការបក្សមួយនៅក្នុងអង្គភាពមួយ បើគ្មានមហាជននៅជាមួយមិនខ្លាំងទេ ។ នៅជាមួយក្នុងន័យសតិអារម្មណ៍នៅជាមួយ នយោបាយនៅជាមួយ ចាត់តាំងនៅជាមួយ ។ *(ទង់បដិវត្តលេខ៧ ខែកក្កដា ឆ្នាំ១៩៧៦)*

◆ ***យោធាបដិវត្តល្អៈ*** យោធាដែលបំពេញភារកិច្ចគ្រប់មុខបានល្អដោយគ្មានលក្ខខណ្ឌ ពេលមាន ពេលអត់ ពេលស្រួល ពេលលំបាក ពេលឈ្នះ ពេលចាញ់ជាបណ្តោះអាសន្ន ពេលឈ្នះទាំងស្រុង ចូលទីក្រុង ក៏គ្មានលក្ខខណ្ឌ ។

*(កំណត់ហេតុលេខ១០៨)*

# ការចាប់និងសម្លាប់អ្នកទោសជាខ្មែរសខ្មៅក់នៅមន្ទីរស-២១

រយៈពេលប្រមាណពីរខែបន្ទាប់ពីទទួលបានជ័យជម្នះនៅថ្ងៃទី១៧ ខែមេសា ឆ្នាំ១៩៧៥ របបកម្ពុជាប្រជាធិបតេយ្យបានបង្កើតឡើងនូវមន្ទីរស-២១ (គុកទួលស្លែង) ដើម្បីឃុំឃាំង សួរចម្លើយ និងធ្វើទារុណកម្ម ជនណាដែលត្រូវបានសង្ស័យឬរកឃើញថាបានប្រព្រឹត្តផ្ទុយពីមាគ៌ាបដិវត្តន៍ ។ អ្នកទាំងនេះត្រូវបានចាត់ទុកជា "ខ្មាំងអន្តការ" ។ មន្ទីរស-២១មានការផ្លាស់ប្តូរប្រធាននិងទីតាំងចំនួនពីរលើក ។

នៅក្នុងចម្លើយសារភាពរបស់ យូ ប៉េងគ្រី ហៅ ម៉ុន អនុប្រធានមន្ទីរ ស-២១យ ដែលជាសាខាមួយរបស់មន្ទីរ ស-២១ បានកត់ត្រាថា នៅក្នុងរយៈពេលប្រាំបីខែដំបូង មន្ទីរ ស-២១ ស្ថិតនៅក្រោមការគ្រប់គ្រងរបស់សមមិត្ត អ៊ិន លន ហៅសមមិត្ត ណាត ជាលេខាកងពលលេខ៧០៣ ។ សួស ធី អតីតអ្នកកាន់បញ្ជីអ្នកទោសនៅមន្ទីរស-២១ បានសន្និដ្ឋានថា ពេលនោះសមមិត្ត ឌុច មានតួនាទីជាប្រធានផ្នែកសួរចម្លើយអ្នកទោស ។

ដំណើការបោសសម្អាតខ្មាំងនៅក្រោយថ្ងៃទី១៧ ខែមេសា បានផ្តោតសំខាន់លើអ្នករដ្ឋការនៃរបបសាធារណរដ្ឋខ្មែរ ។ នៅថ្ងៃទី២៧ ខែវិច្ឆិកា ឆ្នាំ១៩៧៥ ឌុច បានផ្ញើលិខិតមួយច្បាប់ជូនសមមិត្ត ណាត ហៅ "បង០៣" ដើម្បីពិនិត្យលើអតីតភាពរបស់អ្នករដ្ឋការលន់ណុលចំនួនបីនាក់គឺ ១) គាម ទត អតីតនិស្សិតសាស្ត្រាចារ្យឆ្នាំទី២ ២) ង៉ូវ វ៉ា ជាមនុស្សដែលធ្លាប់ចេញចូលផ្ទះរបស់ លន់ ណុល បូរ៉េត និង ប៉ាន់ សុធី និង ៣) តាប់ ប៊ុនឌីន ជាបុគ្គលិកអភិវឌ្ឍន៍សហគមន៍ ។ ចំពោះមនុស្សទាំងបីនាក់ខាងលើនេះ ឌុច បានស្នើយោបល់ទៅសមមិត្ត ណាត ថា "ចាប់ឬមិនចាប់ស្រេចលើបងវិភាគចុះ" ។

នៅក្នុងចម្លើយសារភាពរបស់ ម៉ុន បញ្ជាក់ថា នៅខែមករា ឆ្នាំ១៩៧៦ សមមិត្ត ណាត បានប្តូរការគ្រប់គ្រងពីមន្ទីរស-២១ ទៅជាជំនួយការសេនាធិការកងទ័ពវិញ ។ នៅអំឡុងខែមករានិងខែកុម្ភៈ ឆ្នាំ១៩៧៦ មន្ទីរស-២១បានស្ថិតនៅក្រោមការគ្រប់គ្រងរបស់សមមិត្ត សែម អតីតប្រធានមន្ទីរស-៥០ ។ មកទល់ថ្ងៃនេះ ពុំមានឯកសារណាមួយដែលបញ្ជាក់អំពីការតែងតាំងប្រធានមន្ទីរ ស-២១ ជាផ្លូវការទេ ។ នៅថ្ងៃទី៤ ខែមករា ឆ្នាំ១៩៧៦ សែម បានចូលរួមប្រជុំលេខាកងពលនិងលេខាកងវរសេនាធំ ស្តីអំពីគម្រោងចំណាយស្រូវនៅឆ្នាំ១៩៧៦ ។

បន្ទាប់ពី សែម គ្រប់គ្រងមន្ទីរស-២១មួយរយៈពេលខ្លី នៅខែកុម្ភៈឬខែមីនា ឆ្នាំ១៩៧៦ ឌុច ដែលមានបទពិសោធន៍ខាងសន្តិសុខជាច្រើនឆ្នាំនៅមន្ទីរ១៣ ឬគុកអមលាំង នៅក្នុងខេត្តកំពង់ស្ពឺ និងធ្លាប់ជាប្រធានផ្នែកសួរចម្លើយអ្នកទោសស្រាប់ផងនោះ ត្រូវបានជ្រើសរើសជាប្រធានមន្ទីរស-២១រហូតដល់ថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។

អតីតយុទ្ធជនភាគច្រើននៅក្នុងកងពលលេខ៧០៣ បានដឹងថានៅក្នុងរបបខ្មែរក្រហមមានការចាប់មនុស្សជាខ្មែរសខ្មៅក់នៅក្នុងអង្គភាពនីមួយៗ ទោះបីជានៅក្នុងពេលនោះ យុទ្ធជនខ្លះមិនបានដឹងថាមិត្តរួមអាវុធរបស់ខ្លួនត្រូវបានចាប់ខ្លួនបញ្ជូនទៅមន្ទីរស-២១យ៉ាងណាក៏ដោយ ។

ចក់ ផល្លា នីរសាកងវរសេនាតូចកងពល៧០៣ នៅចាំបានថា ព្រឹកមួយនាដើមឆ្នាំ១៩៧៨ គាត់បានឃើញកងសន្តិសុខចំនួន៦នាក់បានចុះមកចាប់ អ៊ឹង ជាប្រធានកងវរសេនាតូចនៅលើកោះចម្រើនដែលស្ថិតនៅជិតកំពង់ចម្លងអ្នកលឿង ។ ផល្លា មិនបានស្គាល់អត្តសញ្ញាណរបស់កងសន្តិសុខទាំង៦នាក់នោះទេ ។ ផល្លា គិតថាជាកងពិសេសនៃក្រុមណាមួយរបស់មជ្ឈិម ។

ផល្លា បានពិពណ៌នាថា សន្តិសុខទាំង៦នាក់នោះមានមាឌធំ

និងមានកាំភ្លើងគ្រប់ដៃ ។ សន្តិសុខពីរនាក់បានដើរសំដៅគាត់ ដើម្បីសួររក អ៊ីង ។ ផល្លា មិនទាន់បានឆ្លើយតបផង កងសន្តិសុខទាំងនោះបានដើរចូលទៅចាប់ អ៊ីង តែម្តង បន្ទាប់ពីក្រឡេកឃើញ អ៊ីង កំពុងអង្គុយនៅក្នុងរោង ។ អ៊ីង មិនបានដឹងថានឹងមានការចាប់ខ្លួនគាត់ទេ ។ កងសន្តិសុខម្នាក់បានហុចបារីមួយដើមឲ្យទៅ អ៊ីង ។ ក្នុងខណៈដែល អ៊ីង ឈោងដៃទទួលយកបារី កងសន្តិសុខនោះបានចាប់មួលដៃរបស់ អ៊ីង បន្ទាប់មកដកយកកាំភ្លើងខ្លីចេញពីចង្កេះរបស់ អ៊ីង ។ ជាមួយគ្នានោះ ផល្លា ក៏ត្រូវចាប់ខ្លួនដែរ ពេលដែលព្យាយាមដើរទៅយកកាំភ្លើងវែងមួយដើមដែលព្យួរនៅលើជញ្ជាំង ។ អ៊ីង បានសួរសន្តិសុខថា «ហេតុអ្វីបានជាចាប់ខ្ញុំ?» ។ សន្តិសុខម្នាក់បានឆ្លើយតបវិញថា «មិត្តឯងមិនបាច់និយាយអីទេ» ។ ជាមួយគ្នានឹងការឆ្លើយតប កងសន្តិសុខនោះបានធាក់ អ៊ីង មួយជើងចំផ្ទៃមុខ បណ្តាលឲ្យហូរឈាមស្រោក់តាមមាត់ ។ អ៊ីង ត្រូវកងសន្តិសុខលើកបោះដាក់លើឡានបើកចេញទៅ ។

ផល្លា មិនបានដឹងថាកងសន្តិសុខបញ្ជូន អ៊ីង ទៅទីណាឡើយ ។ ប៉ុន្តែគាត់ប្រាកដក្នុងចិត្តថា អ៊ីង ពិតជាត្រូវសម្លាប់ចោល ។ ផល្លា ត្រូវបានបញ្ជូនទៅកន្លែងលត់ដំមួយរយៈ ហើយក្រោយមកបានទទួលការចាត់តាំងឲ្យទៅជញ្ជូនស្បៀងឲ្យកងទ័ពនៅសមរភូមិមុខ ។

គង់ សាន នីរសាប្រចាំមន្ទីរកងពល៧០៣ បានរំឭកថា នៅពាក់កណ្តាលឆ្នាំ១៩៧៧ កម្មាភិបាលចាប់ពីប្រធានកងអនុសេនាធំឡើងទៅ ត្រូវបានចាប់ខ្លួនជាបន្តបន្ទាប់ ។ នៅក្នុងពេលនោះ សាន គ្រាន់តែសង្ស័យថាអ្នកទាំងនោះត្រូវបានបញ្ជូនទៅមជ្ឈិម ។ សាន អះអាងថា ក្រោយឆ្នាំ១៩៧៩ គាត់បានដឹងច្បាស់ថា អ្នកដែលបានចាប់ខ្លួនត្រូវបញ្ជូនមកមន្ទីរស-២១ រួចហើយយកទៅសម្លាប់នៅបឹងជើងឯក ។

យុទ្ធជនទាំងអស់នៃមន្ទីរ ស-២១ សុទ្ធតែបានដឹងអំពីយន្តការចាប់អ្នកទោសជាខ្សែសង្វាក់ ។ ញ៉ែប ហូ អតីតយុទ្ធជនកងការពារអ្នកទោសនៅមន្ទីរស-២១ បានពិពណ៌នាថា ទោះបីជាគាត់បានដឹងថា ប៉េង ដែលត្រូវជាប្អូនប្រុសរបស់គាត់ មានតួនាទីជាប្រធានកងវរៈផ្នែកការពារអ្នកទោសក៏ដោយ ក៏គាត់មិនហ៊ានទាក់ទងជិតស្និទ្ធជាមួយ ប៉េង ដែរ ។ ញ៉ែប ហូ មិនបានដឹងថា ប៉េង មកបម្រើការនៅមន្ទីរ ស-២១ តាំងពីពេលណាទេ រហូតដល់ពេលគាត់ត្រូវបានចាត់តាំងឲ្យមកបម្រើការជាកងការពារនៅទីនេះ ។

នៅគ្រាដំបូង ហូ និង ប៉េង បាននិយាយប្រាប់គ្នាអំពីសុខទុក្ខរបស់ក្រុមគ្រួសារ ប៉ុន្តែក្រោយមក ហូ មិនហ៊ាននិយាយជាមួយ ប៉េង ទៀតទេ ព្រោះបារម្ភខ្លាចក្រែងមានការចាប់ខ្លួនម្នាក់នឹងអាចប៉ះពាល់ដល់ម្នាក់ទៀត ។ ហូ បានដឹងអំពីវិធីការពារអាយុជីវិតរបស់ខ្លួនតាមរយៈបទពិសោធន៍ដែលគាត់ធ្លាប់បានឃើញនៅមន្ទីរស-២១ ។


ញ៉ែប ហូ ឆ្នាំ១៩៧៧

ទោះបីយ៉ាងណាក៏ដោយ ការព្យាយាមលាក់បាំងពីការស្រាវជ្រាវប្រវត្តិនិងការតាមចាប់ខ្លួន មិនមែនជាការងាយស្រួលឡើយ ។ នៅលើផ្នែកខាងមុខនៃឯកសារប្រវត្តិរូបសង្ខេបរបស់ ញ៉ែប ហូ ដែលធ្វើដោយមន្ទីរស-២១ មានចំណារទឹកខ្មៅនៅទំព័រខាងមុខថា «បងអាប៉េង» ។

នៅពាក់កណ្តាលឆ្នាំ១៩៧៨ សោម ម៉េត អតីតយុទ្ធជនកងការពារអ្នកទោសនៅមន្ទីរស-២១ ត្រូវបានបញ្ជូនទៅលត់ដំនៅមន្ទីរស-២១យ ដោយសារតែបងប្រុសរបស់គាត់ម្នាក់ឈ្មោះ សោម ម៉េង ត្រូវបានចាប់ខ្លួនបញ្ជូនមកមន្ទីរស-២១ ។ ម៉េត មិនបានដឹងអំពីមូលហេតុនៃការចាប់ខ្លួនបងប្រុសរបស់គាត់ទាល់តែសោះ ។ ម៉េត អះអាងថា បងប្រុសរបស់គាត់ត្រូវ

ឃុំឃាំងនិងសួរចម្លើយនៅមន្ទីរ ស-២១ ប្រមាណពីរសប្តាហ៍ មុនពេលនាំយកទៅសម្លាប់ចោលនៅជើងឯក ។

ហ៊ីម ហ៊ុយ ដែលមានតួនាទីជាអនុប្រធានកងការពារអ្នកទោស ក៏មានការប្រុងប្រយ័ត្នជានិច្ចដើម្បីការរស់រានមានជីវិត ។ ហ៊ុយ និយាយថា «អ្វីដែលខ្ញុំព្រួយបារម្ភបំផុតគឺខ្លាចក្រែងអ្នកទោសឆ្លើយដាក់ខ្ញុំ» ។ ហ៊ុយ បញ្ជាក់ថា ពុំធ្លាប់មានអ្នកទោសណាម្នាក់ឆ្លើយដាក់ថាគាត់បានចូលរួមធ្វើសកម្មភាពក្បត់បដិវត្តន៍នោះទេ ។

ចម្លើយរបស់អ្នកទោសចំពោះបុគ្គលណាម្នាក់អាចជាមូលហេតុមួយដែលនាំទៅដល់ការចាប់ខ្លួនអ្នកនោះ ។ ហ៊ុយ បានរំឭកថា នៅពាក់កណ្តាលឆ្នាំ១៩៧៧ ប៉ាំង មេបញ្ជាការកងវរសេនាធំកងពលលេខ៧០៣ ត្រូវបាន ចាប់ខ្លួនបញ្ជូនមកមន្ទីរ ស-២១ ។ ហ៊ុយ ដឹងថា ប៉ាំង បានសរសេរនៅក្នុងចម្លើយសារភាពថា ហ៊ី អនុប្រធានមន្ទីរ ស-២១ បានរួមធ្វើសកម្មភាពក្បត់បដិវត្តន៍ជាមួយខ្លួន ។ ហ៊ុយ បាននាំដំណឹងនេះទៅប្រាប់ ហ៊ី ។

ហ៊ុយ និយាយថា គាត់មិនបានដឹងទេថា ហ៊ី ចាត់វិធានការដូចម្តេចចំពោះ ប៉ាំង ប៉ុន្តែនៅមុនពេលដែលចម្លើយសារភាពរបស់ ប៉ាំង ត្រូវបានបញ្ជូនទៅដល់ដៃ ឌុច ឈ្មោះរបស់ «ហ៊ី» ត្រូវបានលុបចេញពីចម្លើយសារភាពនេះរួចទៅហើយ ។ ហ៊ី បានរក្សាជីវិតរហូតដល់ថ្ងៃដួលរលំនៃរបបកម្ពុជាប្រជាធិបតេយ្យ ។ ហ៊ុយ បានអះអាងថា នៅក្នុងខែកុម្ភៈ ឆ្នាំ១៩៧៩ ឌុច បានបាញ់សម្លាប់ ហ៊ី នៅតំបន់ពាយ័ព្យ ដោយសារតែមានជម្លោះក្នុងការរៀបចំទ័ពដើម្បីវាយបកកងទ័ពវៀតណាម ។

នៅចុងខែធ្នូ ឆ្នាំ១៩៧៨ សមមិត្ត ណាត ត្រូវបានចាប់ខ្លួនបញ្ជូនមកកាន់មន្ទីរស-២១ ដែលមន្ទីរនេះ សមមិត្ត ណាត ធ្លាប់បានគ្រប់គ្រងអស់រយៈពេលជិតមួយឆ្នាំ ។ មុនពេលត្រូវចាប់ខ្លួន សមមិត្ត ណាត មានតួនាទីជាជំនួយការសេនាធិការ និងបន្ទាប់មកបម្រើការនៅក្រសួងការបរទេសដែលមានសមមិត្ត អៀង សារី ជារដ្ឋមន្ត្រី ។

ណាត បានបន្សល់ទុកឯកសារចម្លើយសារភាពវាយដោយម៉ាស៊ីនអង្គុលីលេខចំនួនពីរដុំ ដែលដុំទីមួយមានចំនួន៨ទំព័រ និងដុំទីពីរមានចំនួន៥ទំព័រ ។ ចម្លើយសារភាពនេះបានបាត់បង់ផ្នែកខាងដើមមួយចំនួន ។ នៅក្នុងចម្លើយសារភាពដុំទីមួយ ដែលស្ថិតក្នុងលក្ខណៈជាការសរសេរបន្តពីផ្នែកខាងដើម បានចុះកាលបរិច្ឆេទនៅទំព័រខាងចុង «ថ្ងៃទី២៥ ខែធ្នូ ឆ្នាំ១៩៧៨» ហើយចម្លើយសារភាពដុំទីពីរបានចុះកាលបរិច្ឆេទ «ថ្ងៃទី៣១» ខែនិងឆ្នាំដដែល ។

ណាត ត្រូវបានចាប់ខ្លួនបន្ទាប់ពី ស៊ុន ទី ហៅ ទាញ ប្រធានភ័ស្តុភារសេនាធិការ បានសរសេរនៅក្នុងចម្លើយសារភាពថា «ណាត បានចូលរួមក្នុងសកម្មភាពក្បត់បដិវត្តន៍ជាមួយខ្លួន» ។ ទាញ ត្រូវបានចាប់ខ្លួននៅថ្ងៃទី១០ ខែសីហា ឆ្នាំ១៩៧៨ ។ នៅថ្ងៃទី១៥ ខែធ្នូ ឆ្នាំ១៩៧៨ ទាញ បានសរសេរលិខិតចុងក្រោយរបស់ខ្លួនផ្ញើតាមសមមិត្ត ឌុច ប្រធានមន្ទីរស-២១ ដើម្បីបញ្ជាក់ជូន«បងលេខាបក្ស» អំពីគោលជំហររបស់ខ្លួន ។

លិខិតរបស់ ទាញ មានខ្លឹមសារថា «សូមគោរពបក្សជាទីគោរពលើសជីវិត ។ សូមគោរពសមមិត្ត មិត្ត ខ្ញុំខុសហើយ ។ ខ្ញុំអត់ក្បត់បក្សទេ ។ មុនខ្ញុំមិនឆ្លើយ ក្រោយត្រូវដំបងធ្ងន់ ខ្ញុំឆ្លើយប្រឌិតទេ ។ សូមបូជាជីវិតជូនបក្ស ។ សូមបក្សកុំចាប់ឈ្មោះដែលខ្ញុំរាយការណ៍ ខុសហើយ ។ មិត្តយើងគេល្អទេ ។ ខ្ញុំអត់សេ.អ៊ី.អា ឬខ្មែរសេរីទេ ។ ខ្ញុំសូមសម្រេចចិត្តចុងក្រោយបង្អស់ដែលខ្ញុំត្រូវស្លាប់ ។ សូមបក្សនិងសមមិត្តអនុគ្រោះដល់អាយុជីវិត ។ ខ្ញុំជាជនកុម្មុយនិស្ត សូមបូជាជីវិតជូនបក្ស ។ ដោយអាវ៉ន អាខេត្ត អាគង់សុផល ឆ្លើយដាក់ថា ខ្ញុំសេ.អ៊ី.អា ខ្មែរសេរី ។ ខ្ញុំអត់ចូលជាមួយវាទេ ។ ប្រពន្ធខ្ញុំ ប្រពន្ធសមមិត្ត ណាត អត់ដឹងអីទេបង! ។ ភ្នំពេញថ្ងៃ ១៥-១២-៧៨ ស៊ុន ទី ហៅ ទាញ» ។

នៅខាងឆ្វេងផ្នែកខាងក្រោមនៃលិខិត ទាញ បានសរសេរបញ្ជាក់បន្ថែមជូនចំពោះ ឌុច ថា «ស្នើសុំសមមិត្តកុំហែកចោល នេះជាសំឡេងចុងក្រោយបំផុតរបស់ខ្ញុំ ។ ជយោ! បក្សកុម្មុយនិស្តកម្ពុជាដ៏រុងរឿងមហាអស្ចារ្យ! ។ ជយោ! បក្សប្រជាជនបដិវត្តន៍កម្ពុជាដ៏មហិមាមហាអស្ចារ្យ! ។ ជយោ! ប្រជាជនកម្ពុជាដ៏ខ្លាំងក្លាមហាអស្ចារ្យ! ។ ជយោ! កងទ័ពប្រជាជនបដិវត្តន៍កម្ពុជាដ៏ខ្លាំងពូកែមហាអស្ចារ្យ!» ។

**ហ៊ុយ វណ្ណៈ**

# ករណីយកិច្ចក្នុងការចោទប្រកាន់អំពីរំលោភសិទ្ធិមនុស្ស

**(តពីលេខមុន)**

សន្ធិសញ្ញាសិទ្ធិមនុស្សខ្លះមានផ្លូវជាច្រើនសម្រាប់ឲ្យជនរងគ្រោះអំពីការរំលោភសិទ្ធិមនុស្ស ទទួលបាននូវដំណោះស្រាយ ។ ឧទាហរណ៍ៈ កតិកាសញ្ញាអន្តរជាតិក៏ផ្តល់នូវយន្តការមួយសម្រាប់បុគ្គលប្តឹងដោយផ្ទាល់ប្រឆាំងនឹងរដ្ឋ ប្រសិនបើរដ្ឋនោះបានចុះហត្ថលេខាលើពិធីសារសិទ្ធិជ្រើសរើសពិសេសនៃកតិកាសញ្ញានេះ ។ មិនតែប៉ុណ្ណោះ អង្គការសហប្រជាជាតិធ្វើឲ្យអង្គភាពបីដែលមានអំណាចប្រហាក់ប្រហែលនឹងតុលាការ មានលក្ខណៈដូចគ្នា ដែលអាចពិនិត្យរាល់បណ្តឹងទាមទារពីបុគ្គលដែលអះអាងថាខ្លួនជាជនរងគ្រោះដោយសារការរំលោភសិទ្ធិមនុស្ស ។ អង្គភាពនីមួយៗត្រូវបានបង្កើតឡើងដើម្បីត្រួតពិនិត្យមើលការអនុវត្តរបស់រដ្ឋទៅតាមកាតព្វកិច្ចរបស់ខ្លួននៅក្នុងសន្ធិសញ្ញា ។ ក៏ដូចជាកតិកាសញ្ញាដែរ គ្រាន់តែការឲ្យសច្ចាប័នទៅលើសន្ធិ-សញ្ញាជាមូលដ្ឋានតែម្យ៉ាង មិនអាចផ្តល់អង្គភាពទាំងនេះនូវអំណាចក្នុងការទទួលយកនូវបណ្តឹងទាមទារឡើយ ។ ប៉ុន្តែរដ្ឋត្រូវតែប្រកាសឲ្យបានច្បាស់លាស់ថា ខ្លួនទទួលស្គាល់ចំពោះសមត្ថ-កិច្ចរបស់អង្គភាពណាមួយឲ្យទទួលនិងពិចារណានូវរាល់សំណុំពាក្យសុំនានា ។ អង្គភាពគំរូមួយចំនួននៃសន្ធិសញ្ញាទាំងនេះមានដូចខាងក្រោមនេះ÷

១) គណៈកម្មាធិការសិទ្ធិមនុស្សដែលបង្កើតឡើងដោយកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ។

២) គណៈកម្មាធិការលុបបំបាត់ការរើសអើងជាតិសាសន៍ដែលបង្កើតឡើងដោយអនុសញ្ញាប្រឆាំងនឹងគ្រប់ទម្រង់នៃការរើសអើងជាតិសាសន៍ ។

៣) គណៈកម្មាធិការប្រឆាំងនឹងទារុណកម្មដែលបង្កើតឡើងដោយអនុសញ្ញាប្រឆាំងនឹងទារុណកម្មនិងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយណាដែលឃោរឃៅអមនុស្សធម៌ ឬដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស ។

ជាច្រើនលើកមកហើយ គណៈកម្មាធិការទាំងនេះបានទទួលស្គាល់និងការពារករណីយកិច្ចរបស់រដ្ឋក្នុងការស៊ើបអង្កេតនិងចោទប្រកាន់ការរំលោភសិទ្ធិមនុស្សនៅក្នុងដែនដីរបស់ខ្លួន ។ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបញ្ជាក់ថា "បណ្តឹងអំពីការធ្វើទុក្ខទោស ចាំបាច់ត្រូវតែស៊ើបអង្កេតប្រកបដោយប្រសិទ្ធភាពពីសំណាក់អាជ្ញាធរមានសមត្ថកិច្ច ។ អ្នកដែលគេរកឃើញកំហុស ត្រូវតែទទួលខុសត្រូវ...ហើយជនរងគ្រោះខ្លួនឯងចាំបាច់ត្រូវតែមានដំណោះស្រាយកែតម្រូវដ៏មានប្រសិទ្ធភាពតាមដែលខ្លួនមាន រួមទាំងសិទ្ធិក្នុងការទទួលបាននូវសំណងការខូចខាតផង" ។ ឧទាហរណ៍ៈ នៅក្នុងរឿងក្តីរវាងមុតតេបា និងប្រទេសហ្សាអៀ គណៈកម្មាធិការសិទ្ធិមនុស្សរកឃើញថា ភ្នាក់ងាររបស់រដ្ឋហ្សាអៀបានប្រព្រឹត្តទារុណកម្មដែលទង្វើនេះបង្ខំឲ្យរដ្ឋាភិបាលហ្សាអៀ "មានកាតព្វកិច្ច... ស៊ើបអង្កេតទៅលើស្ថានការណ៍នៃទារុណកម្មនោះ ដើម្បីផ្តន្ទាទោសអ្នកដែលត្រូវបានរកឃើញថាមានកំហុសក្នុងការធ្វើទារុណកម្ម និងចាត់វិធានការដើម្បីធានាឲ្យប្រាកដថា ការរំលោភដែលមានលក្ខណៈប្រហាក់ប្រហែលគ្នានេះពិតជាមិនឲ្យកើតឡើងសាជាថ្មីឡើយ" ។ ដូចគ្នានេះដែរ នៅក្នុងរឿងក្តីរវាង ប្លេអី និង អ៊ីនតឺរ៉ូសជាមួយប្រទេសអ៊ូរ៉ាហ្គាយ គណៈកម្មាធិការសិទ្ធិមនុស្សអង្គការសហប្រជាជាតិបានកំណត់ថា តាមសេចក្តីថ្លែងការណ៍អាមេរិកាំងស្តីពីសិទ្ធិនិងករណីយកិច្ចរបស់យុទ្ធជន រដ្ឋាភិបាលអ៊ូរ៉ាហ្គាយមានករណីយកិច្ចស៊ើបអង្កេតការបាត់ខ្លួន កាត់ទោសអ្នកដែលទទួលខុសត្រូវ សងជំងឺចិត្តដល់ជនរងគ្រោះ និងធានាមិនឲ្យអំពើរំលោភបែបនេះកើតឡើងសាជាថ្មីម្តងទៀត ។ តុលាការសិទ្ធិមនុស្សអន្តរ-អាមេរិកាំងបានរកឃើញនូវកាតព្វកិច្ចប្រហាក់ប្រហែលគ្នានេះក្រោមអនុសញ្ញាអាមេរិកាំងស្តីពីសិទ្ធិមនុស្ស ។

អ្នកអត្ថាធិប្បាយមួយចំនួនបានអះអាងថា ករណីយកិច្ចនេះកើតឡើង បើទោះជារដ្ឋនោះមិនបានចុះហត្ថលេខាទៅលើលិខិតុបករណ៍ដែលពាក់ព័ន្ធនៅពេលមានការរំលោភនោះក៏ដោយ ។ កាតព្វកិច្ចបច្ចុប្បន្ននេះក្នុងការស៊ើបអង្កេតនិងចោទប្រកាន់ទៅលើការរំលោភសិទ្ធិមនុស្សកាលពីអតីតកាល ប្រហែលជាមានចែងក្នុងបញ្ញត្តិនៅក្នុងសិទ្ធិសញ្ញាទាំងនេះ ដែលតម្រូវឲ្យមានដំណោះស្រាយកែតម្រូវតាមផ្លូវតុលាការ ។

### ឃ) ច្បាប់ទម្លាប់អន្តរជាតិ

តួយ៉ាង សន្ធិសញ្ញា (ទីបី) ស្តីពីច្បាប់ទំនាក់ទំនងបរទេសរបស់សហរដ្ឋអាមេរិកបញ្ជាក់ថា រដ្ឋមួយរំលោភទៅលើច្បាប់អន្តរជាតិ (ប្រសិនបើរដ្ឋនោះផ្អែកតាមនយោបាយរបស់ខ្លួន) អនុវត្ត ជំរុញ ឬបណ្តោយឲ្យមានអំពើដូចតទៅនេះកើតឡើងៈ អំពើប្រល័យពូជសាសន៍ អំពើទាសភាព ឬការជួញដូរទាសករ ឃាតកម្មឬការបាត់ខ្លួន ទារុណកម្ម និងការផ្តន្ទាទោស ឬការប្រព្រឹត្តទាំងឡាយដែលឃោរឃៅអមនុស្សធម៌ ឬដែលនាំឲ្យបាត់បង់តម្លៃជាមនុស្ស ការឃុំខ្លួនក្នុងរយៈពេលយូរស្រេចតែអំពើចិត្ត ការរើសអើងជាតិសាសន៍ជាលក្ខណៈប្រព័ន្ធ ឬទម្រង់នៃការរំលោភទ្រង់ទ្រាយធំមានលក្ខណៈដូចៗគ្នា ទៅលើសិទ្ធិមនុស្សដែលត្រូវបានទទួលស្គាល់ជាលក្ខណៈអន្តរជាតិ ។ មិនតែប៉ុណ្ណោះ ប្រសិនបើគ្មានវិធានការទប់ស្កាត់អំពើទាំងនេះកុំឲ្យកើតឡើងសាជាថ្មី ឬកាត់ទោសអ្នកដែលប្រព្រឹត្តបទល្មើស រដ្ឋនេះនឹងត្រូវបានសន្មតថាបានជំរុញឬបណ្តោយឲ្យអំពើទាំងនេះកើតឡើងជាមិនខាន ។ មានអ្នកខ្លះទាញជាអំណះអំណាងថា ដោយសារអំពើទារុណកម្មបង្ហាញពីបទដ្ឋានដាច់ខាតនិងឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ ។ ដូចនេះរដ្ឋនានាមានកាតព្វកិច្ចវិនិច្ឆ័យក្តីទៅលើការរំលោភទៅតាមច្បាប់ទម្លាប់ ចំណែកឯអនុសញ្ញាប្រឆាំងនឹងទារុណកម្មត្រឹមតែពង្រឹងកាតព្វកិច្ចដែលមានតាំងពីមុនតែប៉ុណ្ណោះ ។ ទឡ្ហីករណ៍ដូចគ្នានេះក៏អាចលើកឡើងចំពោះអំពើប្រល័យពូជសាសន៍និងអនុសញ្ញាប្រល័យពូជសាសន៍ដែរ ។

### ង) ការគេចអំពីកាតព្វកិច្ចច្បាប់អន្តរជាតិ

ដូចដែលបានលើកឡើងខាងដើមមកហើយថា អំណះអំណាងដ៏រឹងមាំគឺថា រដ្ឋទាំងឡាយមិនអាចមិនអនុវត្តកាតព្វកិច្ច ហើយបែរមកប្រកាន់នូវបទដ្ឋានដាច់ខាតឡើយ ។ ប៉ុន្តែទោះជាយ៉ាងណាក៏មានតម្រុយបង្ហាញថា រដ្ឋនានាអាចសម្រាលករណីយកិច្ចរបស់ខ្លួនមួយចំនួនដែលចងដោយបទដ្ឋានច្បាប់ទម្លាប់អន្តរជាតិមិនដាច់ខាតទៅតាមស្ថានការណ៍ចាំបាច់ជាក់ស្តែងដែរ ។ អញ្ញត្រកម្ម (ករណីលើកលែង) ទាំងនេះ ទាក់ទងទៅនឹងការបង្ហាញនូវភាពចាំបាច់ ហើយរួមបញ្ចូលនូវអ្វីដែលគេស្គាល់ថាអញ្ញត្រកម្មនៅពេលមានអាសន្នជាសាធារណៈ ដែលតម្រូវឲ្យមានការបង្ហាញដ៏គួរឲ្យជឿជាក់អំពីស្ថានភាពជាក់ស្តែងនិងធ្ងន់ធ្ងរ ។ នេះគឺជាបទដ្ឋានមួយដ៏លំបាកសម្រាប់រដ្ឋមួយធ្វើតាម ពីព្រោះរដ្ឋនោះត្រូវតែស្តែងឲ្យឃើញថា ការងាកចេញពីករណីយកិច្ចគឺជាមធ្យោបាយមួយក្នុងការបញ្ចៀសអាសន្នជាសាធារណៈ ។ មិនតែប៉ុណ្ណោះ វានៅតែមិនច្បាស់នៅឡើយថាតើរដ្ឋមួយអាចមិនសូវយកចិត្តទុកដាក់លើកាតព្វកិច្ចរបស់ខ្លួនក្នុងការស៊ើបអង្កេតនិងកាត់ទោសឬក៏ផ្តល់នូវដំណោះស្រាយកែតម្រូវដ៏មានប្រសិទ្ធភាពសម្រាប់ការរំលោភទៅលើបទដ្ឋានដាច់ខាតទាំងនេះយ៉ាងណានោះ ។ តម្លៃតបស្នងដ៏សមហេតុសមផលទៅតាមពេលវេលា ប្រាក់កាស និងធនធាន អាចធ្វើឲ្យការសម្រាលកាតព្វកិច្ចក្នុងការប្តឹងផ្តល់មានលក្ខណៈធ្ងន់ធ្ងរតិចជាងការរំលោភសិទ្ធិមនុស្ស ។

**អេលីហ្សាប៊ែត វ៉ាន់ស្កាក់**

## សេចក្តីកែតម្រូវ

នៅទំព័រទី៥៣នៃទស្សនាវដ្តី «ស្វែងរកការពិត» លេខ៣៣ ខែកញ្ញា ឆ្នាំ២០០២ អត្ថបទដែលមានចំណងជើងថា «ហេតុអ្វីនៅតែពុំមានការកាត់ទោសមេដឹកនាំខ្មែរក្រហម?» ក្នុងកូឡោនទី១ បន្ទាត់ទី១៣ ដែលសរសេរថា «...ចេញពីលិខិតស្នើសុំរបស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ**១៩៧៩**...» សូមអានថា «...ចេញពីលិខិតស្នើសុំរបស់រាជរដ្ឋាភិបាលកម្ពុជា ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ**១៩៩៧**...» ។

សូមអរគុណ

# គំរូអន្តរជាតិសម្រាប់ដាក់បុគ្គលរំលោភសិទ្ធិមនុស្ស ឱ្យទទួលខុសត្រូវចំពោះមុខច្បាប់

## ក) ករណីប្រទេសអាហ្សង់ទីន

ប្រទេសអាហ្សង់ទីនជាប្រទេសមួយដែលត្រូវបានចាត់ទុកថាជាប្រទេសដែលទទួលបានជោគជ័យបំផុតក្នុងទ្វីបអាមេរិកឡាទីន (នៃសតវត្សរ៍ទី២០) ហើយប្រហែលជាក្នុងពិភពលោកផងក៏មិនដឹង ក្នុងកិច្ចខិតខំប្រឹងប្រែងនាំយកបុគ្គលដែលរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរឲ្យទទួលខុសត្រូវចំពោះមុខច្បាប់ ។ នៅឆ្នាំ ១៩៨៣ លោកប្រធានាធិបតីជាប់ឆ្នោតតាមលក្ខណៈប្រជាធិ-បតេយ្យ រ៉ាអ៊ូល អាលហ្វុងស៊ីន បានប្រកាសថា លោកនឹងកាត់ទោសមន្ត្រីយោធាដែលបានរំលោភសិទ្ធិមនុស្សនៅក្នុងរបបដែលគ្រប់គ្រងដោយភាពផ្តាច់ការយោធា (ឆ្នាំ១៩៧៦-១៩៨៣) ។ នៅពេលទន្ទឹមគ្នានេះដែរ លោកបានបង្ហាញនូវវិធានការមួយចំនួនក្នុងគោលបំណងជំរឿនសិទ្ធិមនុស្ស ពោលគឺ លោកបានបង្កើតនូវវិន័យម៉ឺងម៉ាត់មួយប្រឆាំងនឹងការប្រព្រឹត្តទារុណកម្ម និងមនុស្សឃាត លោកផ្តល់សច្ចាប័នលើគ្រប់កតិកាសញ្ញាអន្តរ-ជាតិសំខាន់ៗស្តីពីសិទ្ធិមនុស្ស និងធ្វើឲ្យក្រុមព្រហ្មទណ្ឌជាលក្ខណៈផ្តាច់ការក្លាយជានិរាករណ៍ទាំងអស់ ។ លោកប្រធានាធិបតី អាលហ្វុងស៊ីន ក៏បានបង្កើតនិងផ្តល់នូវអំណាចក្នុងការស៊ើបអង្កេតដល់គណៈកម្មការដែលមានឈ្មោះថា *Commission Nacional Para la Desaparicion de Personas* ។ គណៈកម្មការនេះស៊ើបអង្កេតយ៉ាងល្អិតល្អន់ដូចជា ការសម្ភាសន៍ជាលក្ខណៈបុគ្គលជាច្រើន ត្រួតពិនិត្យមន្ទីរឃុំឃាំង កន្លែងបញ្ចុះសាកសពសម្ងាត់ ព្រមទាំងពិនិត្យឯកសារមកពីអង្គការក្រៅរដ្ឋាភិបាលដែលធ្វើការខាងសិទ្ធិមនុស្ស ។ គណៈកម្មការនេះបានបោះពុម្ពផ្សាយនូវលទ្ធផលនៃការស្រាវជ្រាវ នៅក្នុងសៀវភៅមានចំណងជើងថា "នុនកា ម៉ាស" ដែលមានន័យថា "លែងកើតទៀតហើយ" ។ សៀវភៅនេះជាសៀវភៅក្នុងស្រុកដែលលក់ដាច់ជាងគេបំផុត ។

បន្ទាប់មកទៀត លោកប្រធានាធិបតី អាលហ្វុងស៊ីន និងសភាជាតិ ក៏បានបង្កើតនូវអង្គជំនុំជម្រះកាត់ទោសបុគ្គលដែលបានរំលោភសិទ្ធិមនុស្ស ។ ក្នុងដំណើរការនេះ លោកហ្វុងស៊ីន ជួបប្រទះនូវឧបសគ្គផ្នែកច្បាប់ជាច្រើន ។ ទីមួយច្បាប់លើកលែងទោសដែលបង្កើតឡើងដោយរបបផ្តាច់ការយោធាហើយនៅតែមានសុពលភាពនៅឡើយ ។ ការធ្វើឲ្យច្បាប់ទៅជានិរាករណ៍មិនអាចទៅរួចទេនៅពេលនោះ ពីព្រោះច្បាប់របស់ប្រទេសអាហ្សង់ទីនបង្គាប់ឲ្យចៅក្រមបកស្រាយច្បាប់នោះសម្រាប់បម្រើផលប្រយោជន៍ដល់ចុងចោទនៅក្នុងចន្លោះពេលនៃការប្រព្រឹត្តបទល្មើសនិងពេលដាក់ទណ្ឌកម្ម ។ តុលាការមិនជួបប្រទះបញ្ហានេះទេ ដោយសារតែសភាជាតិអាហ្សង់ទីនប្រកាសថា ច្បាប់លើកលែងទោសមានលក្ខណៈផ្ទុយនឹងរដ្ឋធម្មនុញ្ញ ។ ទីពីរការកាត់ទោសយោធាពីបទឧក្រិដ្ឋដែលប្រព្រឹត្តឡើងជាលក្ខណៈសឹក (ដូចជាបទល្មើសដទៃៗទៀតនៅប្រទេសអាហ្សង់ទីនដែរ) គឺស្ថិតនៅក្នុងខេត្តដែលមានតុលាការយោធា ហើយតុលាការយោធានេះទៀតសោត គ្មានសុឆន្ទៈច្បាស់លាស់ចង់កាត់ទោសបក្ខពួករបស់គេដែរ ។ ដើម្បីចៀសវាងការផ្លាស់ប្តូរយុត្តាធិការក្រោយអង្គហេតុ (ច្បាប់ប្រតិសកម្ម) ដែលហាមប្រាមដោយរដ្ឋធម្មនុញ្ញរបស់ជាតិ ក៏មានសេចក្តីសម្រេចជាចុងក្រោយថា ការជំនុំជម្រះនៅសាលាដំបូងនឹងធ្វើឡើងនៅចំពោះមុខតុលាការយោធាដែលមានសិទ្ធិប្តឹងឧទ្ធរណ៍ទៅតុលាការស៊ីវិលរបស់រដ្ឋសហព័ន្ធ ។ ចំណុចចុងក្រោយមួយទៀតគឺថា របបថ្មីត្រូវតែដោះស្រាយទៅលើបញ្ហាការពារខ្លួនក្នុងករណីកូនចៅធ្វើតាមបញ្ជារបស់ថ្នាក់លើដែលចែងនៅក្នុងច្បាប់យោធារបស់ប្រទេសអាហ្សង់ទីន ។ ដំណោះស្រាយគឺត្រូវអនុញ្ញាតឲ្យតែកូនចៅដែលគ្មានអំណាចធ្វើការសម្រេចចិត្តសោះ មានសិទ្ធិការពារខ្លួន ។ ក៏ប៉ុន្តែអ្នកដែលផ្តល់បទបញ្ជាមានឆន្ទានុសិទ្ធិទៅលើរាល់ទង្វើរបស់ខ្លួនឬបានប្រព្រឹត្តបទល្មើសរំលោភសិទ្ធិមនុស្សធ្ងន់ធ្ងរមិនមានសិទ្ធិ

ការពារខ្លួនក្នុងករណីពិសេសនេះឡើយ ។

ដោយសារតែតុលាការយោធាពន្យារពេលដំណើរការជំនុំជម្រះសាលាឧទ្ធរណ៍ ប៊ូណូស អៃរ៉េស នៃរដ្ឋសហព័ន្ធក៏សន្មតយកដែនសមត្ថកិច្ចទៅលើរឿងក្តីនេះ ហើយបានជំនុំជម្រះដាក់ស្តែងជាច្រើនលើក ។ ការពន្យារពេលនៅតុលាការសហព័ន្ធមួយចំនួនទៀត ធ្វើឲ្យមានការរំដើបរំជួលកាន់តែខ្លាំងទៅៗ នៅក្នុងចំណោមសមាជិកយោធាដែលគម្រាមថានឹងមិនធ្វើតាមដីកាកោះនិងដីកាឲ្យចូលខ្លួនរបស់តុលាការឡើយ ។ ទោះបីជាចាញ់ឆ្នោតនៅឆ្នាំ១៩៨៣ក៏ដោយ ក៏យោធានៅតែមានស្វ័យភាពយ៉ាងច្រើនពីការគ្រប់គ្រងជាលក្ខណៈស៊ីវិល ហើយគ្រាប់រំសេវក៏កាន់កាប់ផ្តាច់មុខទៀត ។ ដូច្នេះយោធាមានលទ្ធភាពគាបសង្កត់មកលើរដ្ឋាភិបាលថ្មីៗ លោក អាលហ្វុងស៊ីន មានប្រតិកម្មតបដោយប៉ុនប៉ងបញ្ចប់ដំណើរការជំនុំជម្រះក្តីឲ្យបានឆាប់រហ័ស ពោលគឺមានពេលកំណត់ច្បាស់លាស់ ។ នៅពេលដែលភាពតានតឹងចេះតែបន្ត លោកបានបោះបង់ការសម្របសម្រួលទៅលើបញ្ហាធ្វើតាមបទបញ្ជាថ្នាក់លើ និងប្រកាសថា ថ្នាក់ណាមានសមត្ថភាពចេញសេចក្តីសម្រេចចិត្ត ព្រមទាំងបោះបង់ចោលនូវអញ្ញត្រកម្មចំពោះបទល្មើសឃោរឃៅនៅគ្រប់ឋានៈទៀតផង ។

ប៉ុន្តែចុងបញ្ចប់ ការជំនុំជម្រះក្តីភាគច្រើនមិនបានបញ្ចប់ត្រឹមត្រូវឡើយ ដោយសារគណបក្សរបស់លោក អាល់ហ្វុងស៊ីន ចាញ់ឆ្នោតនៅឆ្នាំ១៩៨៩ ។ តំណែងប្រធានាធិបតីក៏បានទៅលើលោក ម៉េនិម ដែលទើបជាប់ឆ្នោតថ្មីៗ ប្រធានាធិបតីថ្មីឡើងកាន់អំណាចទន្ទឹមពេលដែលប្រជាពលរដ្ឋមានទោមនស្សនឹងអតិផរណាហួសកម្រិតរបស់ប្រទេស ។ ប្រធានាធិបតី ម៉េនិម បានលើកលែងទោសដល់ជនដែលត្រូវបានចោទប្រកាន់រួចហើយ ព្រមទាំងអ្នកដែលកំពុងតែទទួលការជំនុំជម្រះក្តីនៅតុលាការអំពីកំហុសនៅក្នុងពេលមានសង្គ្រាម រួមទាំងអ្នកដែលនាំអាទិ៍ធ្វើភេរវកម្មផង ។

### ខ) ប្រទេសបូលីវី

លោកប្រធានាធិបតីដែលជ្រើសតាំងជាលក្ខណៈប្រជាធិបតេយ្យ ហឺណាន ស៊ីឡេស ហ្សួហ្សូ បានបង្កើតគណៈកម្មការស្វែងរកការពិតមុនដំបូងបង្អស់នៅទ្វីបអាមេរិកឡាទីន ។ លោកប្រធានាធិបតីបានជ្រើសរើសស្នងការចំនួន៨រូបឲ្យធ្វើជាតំណាងរបស់សង្គមទាំងមូល (ក្នុងចំណោមស្នងការទាំងនោះ មានតំណាងមកពីសហព័ន្ធប្រជាកសិករ អង្គការសិទ្ធិមនុស្ស និងយោធា) ។ គណៈកម្មការនេះបានរលាយរូបរាងដោយគ្មានផលិតបាននូវរបាយការណ៍ជាសាច់ការអ្វីឡើយ ។ មូលហេតុមួយផ្នែកគឺបណ្តាលមកពីកង្វះការឧបត្ថម្ភផ្នែកហិរញ្ញវត្ថុពីសំណាក់រដ្ឋតែម្តង ។ ការស៊ើបអង្កេតធ្វើតែទៅលើករណីបុគ្គលដែលបាត់ខ្លួនក្នុងអំឡុងពេលណាមួយតែប៉ុណ្ណោះ ចំណែកឯការរំលោភសិទ្ធិមនុស្សដទៃៗទៀតគ្មានអ្នកណាយកចិត្តទុកដាក់ឡើយ ។

### គ) ប្រទេសឆាដ

គណៈកម្មការស្វែងរកការពិតរបស់ប្រទេសឆាដមានការខ្វះខាតសម្ភារៈបំពាក់ច្រើនណាស់ ដែលធ្វើឲ្យគណៈកម្មការនេះមិនមានលទ្ធភាពស៊ើបអង្កេតឲ្យមានប្រសិទ្ធភាពលើករណីរំលោភសិទ្ធិមនុស្សដែលប្រព្រឹត្តដោយអតីតប្រធានាធិបតី ហាប្រេ ។



មិនតែប៉ុណ្ណោះសោត គណៈកម្មការនេះស្ថិតនៅទីតាំងអតីតមន្ទីរឃុំឃាំង ដែលធ្វើឲ្យសាក្សីឬអ្នកដឹងពត៌មាន ញញើតញញើម មិនហ៊ានចេញមុខមកធ្វើជាកសិណស្រាយបំភ្លឺនូវដំណើរដើមទង។ ឧបសគ្គមួយទៀតគឺថា រថយន្តដ៏តិចតួចរបស់គណៈកម្មការក៏ត្រូវចោរលួចអស់ទៅទៀត ធ្វើឲ្យអ្នកស៊ើបអង្កេតគ្មានលទ្ធភាពចុះទៅដល់ទីតាំង។ មិនតែប៉ុណ្ណោះ សមាជិកមួយចំនួនរបស់គណៈកម្មការបានទទួលមរណភាព និងអ្នកខ្លះរត់ចោលការងារដោយសារយល់ថាការងាររបស់ខ្លួនប្រកបដោយគ្រោះថ្នាក់បំផុត។ ទោះជាមានឧបសគ្គយ៉ាងនេះក្តី គណៈកម្មការនៅតែផលិតបាននូវរបាយការណ៍លម្អិតមួយ បើទោះជាអង្គការសិទ្ធិមនុស្សមួយចំនួនមានមន្ទិលទៅលើភាពគួរឲ្យទុកចិត្តបានរបស់របាយការណ៍នេះក៏ដោយ។

### ឃ) ប្រទេសឈីលី

នៅឆ្នាំ១៩៧៣ របបផ្តាច់ការយោធាដែលដឹកនាំដោយលោកឧត្តមសេនីយ៍ អូហ្គីសតូ ពីណូជេ បានផ្តួលរំលំរដ្ឋាភិបាលដែលជ្រើសតាំងដោយការបោះឆ្នោតតាមលក្ខណៈប្រជាធិបតេយ្យរបស់លោក សាលវ៉ាឌ័រ អាឡិនឌី។ របបដឹកនាំរបស់លោក ពីណូជេ ដែលជាឧត្តមសេនីយ៍ ហើយក្រោយមកឡើងធ្វើជាប្រធានាធិបតី បានរំលោភសិទ្ធិមនុស្សយ៉ាងយង់ឃ្នង ក្នុងនោះមានអំពើទារុណកម្ម ការសម្លាប់ដោយគ្មានការជំនុំជម្រះ ការឃុំឃាំងស្រេចតែចិត្ត និងការបាត់ខ្លួន។ នៅឆ្នាំ១៩៧៨ ប្រធានាធិបតី ពីណូជេ បានចេញនូវក្រឹត្យលើកលែងទោសមួយក្តោបក្រសោបនូវភ្នាក់ងារទាំងឡាយដែលទទួលខុសត្រូវចំពោះការរំលោភពីអតីតកាល។ គោលបំណងនៃក្រឹត្យនោះគឺ ដើម្បីផ្តល់នូវការលើកលែងទោសចំពោះបុគ្គលគ្រប់រូបដែលបានប្រព្រឹត្តដោយផ្ទាល់ ជួយជ្រោមជ្រែងឬបិទបាំងបទល្មើសព្រហ្មទណ្ឌនៅអំឡុងពេលដែលរដ្ឋនេះស្ថិតនៅក្រោមការឡោមព័ទ្ធ (ឆ្នាំ១៩៧៣-១៩៧៨) វៀរលែងតែចារីទាំងនោះកំពុងឡើងតុលាការឬ


កម្មាភិបាលខ្មែរក្រហមនិងទីប្រឹក្សាចិន

ក្លាយជាទណ្ឌិតរួចទៅហើយ ។ ក្រឹត្យនោះក៏បានដកចេញពីករណីលើកលែងទោស ចំពោះបទល្មើសទូទៅមួយចំនួន (ដូចជាឃាតកឃាត ចោរកម្ម ការបង្កអគ្គីភ័យ រំលោភ ការស្រវឹងស្រាក្នុងពេលបើកបរ និងការចាប់ជម្រិត) ប៉ុន្តែ មនុស្សឃាត ការចាប់ពង្រត់ និងការបំពារបំពាន មិនឃើញមានចែងថាមិនមានការលើកលែងទោសឡើយ ។ ក្រឹត្យបានសង្កត់ធ្ងន់នូវតម្លៃគបស្នួងបីចំណុចគឺៈ ១) ធ្វើឲ្យមានភាពស្ងប់ស្ងាត់ ២) បំភ្លេចចោលនូវកំហឹងគុំគួនកាលពីអតីតកាលដែល "គ្មានន័យ" និង ៣) ភាពចាំបាច់ក្នុងការជំរុញនូវឯកភាពជាតិនិងកសាងសង្គមថ្មី ។ ដោយសារក្រឹត្យនេះមានចេតនានិងគោលបំណងបម្រើផលប្រយោជន៍អ្នករៀបចំអង្គការចាត់តាំងនិងសមាជិកនៃរបបផ្តាច់ការយោធាកំពុងកាន់អំណាច មានអ្នកខ្លះយល់ថា វាជា "ការលើកលែងទោសដោយខ្លួនឯង" ។ តុលាការកំពូលបានធ្វើតាមក្រឹត្យនេះ ទោះបីជាសង្ស័យថាក្រឹត្យនេះគ្មានសុពលភាពយ៉ាងណាក៏ដោយ ។

រដ្ឋធម្មនុញ្ញរបស់រដ្ឋាភិបាលយោធានេះតម្រូវឲ្យមានសេចក្តីសម្រេចរបស់ប្រជាពលរដ្ឋ ហើយនៅឆ្នាំ១៩៨៨ ប្រជាសិទ្ធិនេះក៏លែងទទួលស្គាល់លោក ពីណូជេ ។ នៅឆ្នាំ១៩៩០ លោក ប៉ាទ្រីស៊ីអូ អាយវីន ត្រូវបានជ្រើសតាំងជាប្រធានាធិបតីថ្មី ហើយរក្សាទុកលោក ពីណូជេ នៅធ្វើជាអគ្គមេបញ្ជាការកងទ័ពទៅតាមស្មារតីនៃរដ្ឋធម្មនុញ្ញ ។ រដ្ឋាភិបាលថ្មីបានបង្ខំចិត្តចរចាអំពីដំណើរការផ្លាស់ប្តូររបស់ប្រទេសឈីលីឈានទៅរកលទ្ធិប្រជាធិបតេយ្យ ដោយមានកងទ័ពឯកភាពគ្នាមួយដែលមានការគាំទ្រនយោបាយពីសំណាក់ប្រជាជនទូទៅ ។ លោកប្រធានាធិបតី អាយវីន បដិសេធការរំលាយចោលនូវក្រឹត្យលើកលែងទោស និងបដិសេធនូវរាល់យោបល់នានាឲ្យមានការកាត់ទោសជាបន្ទាន់តាមរយៈតុលាការពិសេសទៅតាមបណ្តឹងទាមទារដែលធ្វើឡើងតាមនីតិវិធីតុលាការធម្មតា ។ មិនតែប៉ុណ្ណោះ លោកបានបង្កើតនូវគណៈកម្មការជាតិស្វែងរកការពិតនិងបង្រួបបង្រួមជាតិ ដែលជាអង្គការមានសមាជិកស៊ើបអង្កេតឯករាជ្យ៨នាក់ ទទួលបន្ទុកផលិតនូវឯកសារផ្លូវការស្តីអំពីការរំលោភពីអតីតកាល ទទួលស្គាល់ការទទួលខុសត្រូវរបស់រដ្ឋ និងពន្យល់អំពីអង្គហេតុនៃការបាត់ខ្លួនប្រសិនបើមានលទ្ធភាព ។ គណៈកម្មការ រ៉េតធីង (ដែលដាក់ឈ្មោះតាមប្រធានគណៈកម្មការ "រ៉ាអ៊ូល រ៉េតធីង") បានពិនិត្យទៅលើបណ្តឹងប្រមាណ ៣៤០០ ហើយទទួលនូវសក្ខីកម្មពីសមាជិកគ្រួសារនគរបាល យោធា និងអតីតភ្នាក់ងារសម្ងាត់ ។ គួរឲ្យសរសើរដែរ គណៈកម្មការនេះបានចេញសេចក្តីសន្និដ្ឋានទៅលើ៦៤១ករណី ។ ជាងនេះទៅទៀត គណៈកម្មការផលិតនូវឯកសារ១៨០០សន្លឹក ដោយនិយាយលម្អិតអំពីលទ្ធផលនៃការស៊ើបអង្កេត និងអនុសាសន៍នានាឲ្យទាមទារសំណងដូចជារបបសោធននិវត្តន៍សម្រាប់គ្រួសារដែលមានសមាជិកគ្រួសារស្លាប់ឬបាត់ខ្លួន និងអនុសាសន៍ផ្សេងៗទៀតដូចជា កំណែទម្រង់ផ្នែកច្បាប់និងស្ថាប័នជាដើម ។ ដោយមានអនុសាសន៍ទាំងនេះ លោកប្រធានាធិបតី អាយវីន បានបង្កើតនូវសាជីវកម្មជាតិសម្រាប់សំណងនិងការផ្សះផ្សា ដើម្បីរៀបចំការស្វែងរកអដ្ឋិធាតុរបស់ជនដែលបាត់ខ្លួន និងផ្តល់នូវសំណងចំពោះសមាជិកគ្រួសារដែលនៅរស់ ។ ក្នុងចំណោមសំណងដែលផ្តល់ដោយរដ្ឋនេះ ក៏មានប្រាក់ធានាសង្គមដែលមានទម្រង់ដូចជានិរភ័យសង្គម ថែទាំសុខភាព ប្រាក់បំណាច់សម្រាប់ការអប់រំនិងផ្ទះសម្បែង ។

គណៈកម្មការនេះត្រូវបានរិះគន់ថាមិនដំណើរការឲ្យបានយូរគ្រប់គ្រាន់ មិនចេញផ្សាយនូវឈ្មោះរបស់ជនដៃដល់ និងស៊ើបអង្កេតតែករណីទាំងឡាយដែលបណ្តាលឲ្យជនរងគ្រោះស្លាប់ (ដោយមិនបញ្ចូលករណីទារុណកម្មឡើយ) ហើយមិនយល់ព្រមទៅលើវិសោធនកម្មរដ្ឋធម្មនុញ្ញដែលប្រហែលជាអាចធ្វើឲ្យប្រធានាធិបតីបណ្តេញមន្ត្រីយោធាប្រសិនបើគណៈកម្មការនេះយល់ព្រម ។ អ្នកគាំទ្រតបថា គណៈកម្មការនេះមិនអាចចុចឈ្មោះអ្នកដែលអវត្តមានពីដំណើរកាត់ក្តីឡើយ ពីព្រោះបើធ្វើដូច្នេះវាមានន័យថាជាការថ្កោលទោសដោយគ្មាននីតិវិធីត្រឹមត្រូវទេ ។ នៅពេញអំឡុងពេលធ្វើការងាររបស់ខ្លួន គណៈកម្មការនេះត្រូវបានយោធាប្រកាសបដិសេធថាជាយុត្តិធម៌សម្រាប់តែអ្នកឈ្នះប៉ុណ្ណោះ ។

វិធីដោះស្រាយរបស់លោកប្រធានាធិបតី អាយវីន ចំពោះបម្លាស់ប្តូរនេះគឺផ្អែកទៅលើទ្រឹស្តីដែលថា ការទប់ស្កាត់និងសំណងគឺជាគោលដៅសំខាន់បំផុតនៃនយោបាយសិទ្ធិមនុស្សដែល

ប្រឈមមុខដោះស្រាយការរំលោភកាលពីអតីតកាល ។ ជាលទ្ធផលចុងក្រោយ គេឲ្យអាទិភាពក្នុងការបង្ហាញនូវការពិត ។ នៅឆ្នាំ១៩៩៣ អេឌូអាដូ ហ្វ្រេ ត្រូវបានបោះឆ្នោតជ្រើសតាំងជាប្រធានាធិបតី ។ នយោបាយទៅថ្ងៃអនាគតរបស់គាត់នៅក្នុងវិស័យនេះនៅតែមិនរីកចម្រើនទៅមុខតែដដែល ។

### ៥) ករណីឆ្មាំព្រំដែនរបស់អាល្លឺម៉ង់

នៅឆ្នាំ១៩៨៩ នៅពេលឈានដល់ដំណាក់កាលសង្គ្រាមត្រជាក់ អតីតសម្ព័ន្ធមិត្តក្នុងសង្គ្រាមលោកលើកទី២ បានបំបែកទឹកដីអាល្លឺម៉ង់ជាពីរចំណែកៈ អាល្លឺម៉ង់ខាងកើត និង អាល្លឺម៉ង់ខាងលិច ។ សហភាពសូវៀតប្រកាសថា អាល្លឺម៉ង់ខាងកើតស្ថិតនៅក្នុងប្លុកសូវៀត ។ បក្សកុម្មុយនិស្តអាល្លឺម៉ង់ខាងកើតបានកាន់កាប់អំណាចភ្លាមក្រោយពីខ្លួនអនុវត្តនយោបាយអំណាចមជ្ឈការបែបស្តាលីន បង្ក្រាបសាសនានិងវប្បធម៌ មិនទទួលស្គាល់សេរីភាពពលរដ្ឋ ការកម្ចាត់សារព័ត៌មាន និងការដាក់ទណ្ឌកម្មទៅលើអំពើវិទ្ធង្សនា ។

ចាប់ពីពេលនោះរហូតដល់សតវត្សរ៍ក្រោយៗទៀត មេដឹកនាំរឹងទទឹងនឹងសម្ពាធកែទម្រង់នានា ដែលមិនខុសគ្នាប៉ុន្មាននឹងអតីតសហភាពសូវៀតដែលធ្លាប់ពិសោធន៍ទៅលើនយោបាយក្លោះ «glasnost» (ដែលមានន័យថា "ការបើកចំហ") និង «perestroika» (ដែលមានន័យថា "ស្ថាបនាឡើងវិញ") ។ នៅឆ្នាំ១៩៦១ សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់បានសាងសង់របងទីក្រុងប៊ែរឡាំង ដើម្បីទប់ការហូរចូលនៃជនភៀសខ្លួនពីទីក្រុងប៊ែរឡាំងខាងកើតចូលមកខាងលិច ។ ឆ្មាំព្រំដែនបានទទួលបញ្ជាឲ្យបាញ់សម្លាប់ជនទាំងឡាយណាដែលប៉ុនប៉ងរត់ឆ្លងតាមព្រំដែន ។ ទង្វើនេះធ្វើឲ្យមនុស្សស្លាប់ប្រមាណ ២០០នាក់ ។ នៅឆ្នាំ១៩៨៩ ប្រជាពលរដ្ឋនៅសងខាងជញ្ជាំងទីក្រុងប៊ែរឡាំងចាប់ផ្តើមធ្វើបាតុកម្មឲ្យមានការរួបរួមគ្នាឡើងវិញ និងឲ្យធ្វើកំណែទម្រង់ ។ នៅថ្ងៃទី៩ ខែវិច្ឆិកា ឆ្នាំ១៩៨៩ ក្លោងទ្វារប្រ៊ែនឌឺប៊ឺកត្រូវបានបើកចំហ ហើយអាល្លឺម៉ង់ត្រូវបានរួបរួមគ្នានៅឆ្នាំបន្ទាប់ ។

នៅឆ្នាំ១៩៩១ សមាជិកបួននាក់នៃឆ្មាំព្រំដែនអាល្លឺម៉ង់ខាងកើតត្រូវបានយកមកកាត់ទោសនៅមុខតុលាការអាល្លឺម៉ង់ក្នុងករណីបាញ់សម្លាប់មនុស្សនៅឆ្នាំ១៩៨៩ ទៅលើជនជាតិអាល្លឺម៉ង់ខាងកើតឈ្មោះ គ្រីស្សៀន ហ្គូឡៀន និង គ្រីស ដូហ្វ្រយ ដែលរត់កាត់តាមព្រំដែនពីសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ទៅសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ ។ ដូហ្វ្រយ ត្រូវបានសម្លាប់ ។ ហ្គូឡៀន ត្រូវរងរបួស ហើយក្រោយមកត្រូវចាប់ខ្លួន ។ ឆ្មាំព្រំដែនឈ្មោះ អ៊ីងហ្គូ ហេនរីច, អង់ដ្រេ គូនដាស់, ម៉ៃ ស្មីត និង ភីតធ័រ ស្មេត ត្រូវបានចោទប្រកាន់ពីបទមនុស្សឃាត និងប៉ុនប៉ងធ្វើមនុស្សឃាត ។ ហេនរីច ត្រូវបានកាត់ឲ្យជាប់គុក ៣ឆ្នាំពីបទមនុស្សឃាត ។ គូន ដាស់ ត្រូវបានកាត់ឲ្យជាប់ទោសពីបទប៉ុនប៉ងធ្វើមនុស្សឃាត និងទទួលសាលក្រមព្យួរទោសពីរឆ្នាំ ។ ស្មីត និង ស្មេត ត្រូវបានតុលាការសម្រេចឲ្យរួចខ្លួន ។

តុលាការព្រហ្មទណ្ឌទី២៣ដែលជាតុលាការទទួលបន្ទុកទាំងរឿងក្តីរដ្ឋប្បវេណីនិងព្រហ្មទណ្ឌនៃតុលាការរដ្ឋទីក្រុងប៊ែរឡាំងបានប្រកាសខ្លួនថា កំពុងតែវាយតម្លៃទៅលើការទទួលខុសត្រូវរបស់ចុងចោទ ដោយយោលទៅតាមច្បាប់របស់អតីតសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ដោយសារច្បាប់នេះមានសុពលភាពនៅកន្លែងនិងពេលវេលានៃការបាញ់ ។ តុលាការក៏បានពិចារណាទៅលើច្បាប់ព្រហ្មទណ្ឌរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ដែលត្រូវបានជំនួសដោយច្បាប់របស់សាធារណរដ្ឋប្រជាធិតេយ្យអាល្លឺម៉ង់ តាំងពីពេលប្រកាសសាលក្រមសម្រេចទោសឆ្មាំព្រំដែនមកម្ល៉េះ ។ នៅទីបញ្ចប់ លទ្ធផលចុងក្រោយនៃករណីនេះគឺសម្រេចទៅតាមការបកស្រាយច្បាប់សីលធម៌ ។

តុលាការកត់សម្គាល់ថា តាមច្បាប់របស់សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ "ការប្រើកាំភ្លើងនៅពេលយាមតាមព្រំដែនមានលក្ខណៈស្របច្បាប់ ប្រសិនបើការប្រើនោះបម្រើឲ្យផលប្រយោជន៍ក្នុងការទប់ស្កាត់មិនឲ្យមានការសម្លាប់ដែលជិតមកដល់ ឬការបន្តប្រព្រឹត្តបទល្មើសព្រហ្មទណ្ឌដែល (បើតាមកាលៈទេសៈជាក់ស្តែង) មើលទៅហាក់ដូចជាបទឧក្រិដ្ឋឬសម្រាប់ការដេញចាប់មនុស្សដែលមានការសង្ស័យខ្លាំងមែនទែនថាពិតជាបានប្រព្រឹត្តបទល្មើស" ។ ផ្ទុយមកវិញ បញ្ញត្តិច្បាប់នៅក្នុងរដ្ឋធម្មនុញ្ញរបស់សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ស្តីពីការការពារជីវិត បូរណភាពខាងរាងកាយនិងសុខភាព ធ្វើឲ្យតុលាការ

សម្រេចថា ការប្រើកាំភ្លើងអាចអនុញ្ញាតបានទៅតាមការណែនាំយ៉ាងហ្មត់ចត់ពីសំណាក់គោលការណ៍សមាមាត្រភាព ។ ដោយផ្អែកទៅតាមគោលការណ៍នេះ និង"ស្មារតីនៃសាធារណជនទូទៅ" តុលាការសម្រេចក្នុងលក្ខណៈជាច្បាប់ជាតិមិនលាយលក្ខណ៍អក្សរថា សកម្មភាពរបស់ឆ្មាំទាំងនោះគឺអាចផ្ដន្ទាទោសព្រហ្មទណ្ឌបាន ។ នៅត្រង់ចំណុចនេះ តុលាការរដ្ឋទីក្រុងប៊ែរឡាំងបានស្រង់យកច្បាប់របស់តុលាការសហព័ន្ធអាល្លឺម៉ង់ដែលចែងថាៈ

*"តាមស្មារតីរបស់ប្រជាជាតិដែលមានអរិយធម៌ខ្ពង់ខ្ពស់ដែលមានគំនិតផ្សេងៗគ្នាដូចដែលបានឃើញស្រាប់ តាមរយៈស្ថាប័នច្បាប់នានា គឺមានច្បាប់គោលរួមមួយដែលផ្អែកតាមទស្សនាទានទូទៅ ដែលមានធាតុនីត្យានុកូលដែលមិនអាចរំលោភបំពានដោយច្បាប់ណាមួយ (sic) និងដោយចំណាត់ការរបស់រដ្ឋអធិបតេយ្យណាមួយឡើយ ។ ច្បាប់នេះផ្ទុកនូវរាល់គោលការណ៍... ដែលត្រូវបានចាត់ទុកថាមានលក្ខណៈបន្ទាប់ឲ្យគោរពតាម ដោយមិនគិតថាបញ្ញត្តិនៅក្នុងរដ្ឋនីមួយៗចាត់ទុកថាវាមិនសំខាន់ឬយ៉ាងណានោះទេ"* ។

តុលាការសហព័ន្ធបានប្រកាសមោឃភាពទៅលើច្បាប់ដែលបង្អាក់ដល់គោលការណ៍ទាំងនេះ ។

ដោយប្រើច្បាប់ឥតសរសេរជាជាងច្បាប់វិជ្ជមាន តុលាការនោះបានឲ្យតម្លៃទៅលើគោលការណ៍ជាមូលដ្ឋានយុត្តិធម៌ ដែលមានខ្លឹមសារច្រើនជាងទៅលើយុត្តិធម៌តាមលក្ខណៈច្បាប់ ។ តុលាការទទូចថា សេចក្ដីសម្រេចរបស់ខ្លួនគឺធ្វើទៅតាមវិធាននៃច្បាប់ ដែល "មិនត្រឹមតែមានភាពប្រាកដប្រជានិងសុវត្ថិភាពក្រោមច្បាប់តែប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងមានយុត្តិធម៌ដែលមានខ្លឹមសារពិតប្រាកដថែមទៀតផង" ។

តុលាការបានបដិសេធនូវការការពារក្ដីដែលថាឆ្មាំទាំងនោះគ្រាន់តែធ្វើតាមបញ្ជាពីថ្នាក់លើ ពីព្រោះថា គ្មានឃើញ (លិខិត) បញ្ជាឲ្យសម្លាប់ច្បាស់លាស់ទេ ។ បើទោះជាមានបទបញ្ជាឲ្យបាញ់សម្លាប់ក៏ដោយចុះ វាក៏មានលក្ខណៈអនីត្យានុកូលដែរ (មានន័យថា វាជាអំពើអយុត្តិធម៌) ហើយមិនគួរឲ្យធ្វើតាមបញ្ជាបែបនេះទេ ។ ក្រោយពីបានសម្រេចថា ការបាញ់បោះទៅលើជនរងគ្រោះ ហ្គាឌៀន និង ដូហ្វ្រយ ជាបទល្មើសព្រហ្មទណ្ឌដែលអាចផ្ដន្ទាទោស ដែលជាអំពើគ្មានមនសិការរបស់ឆ្មាំព្រំដែនមកនៅក្នុងការសម្រេចចេញសាលក្រមផ្សេងៗ តុលាការបានចាត់ទុកថា ការអប់រំឆ្មាំទាំងនោះអំពី "ប្រព័ន្ធអនុវត្តអំពើអមនុស្សធម៌ដោយបន្ទុំដែលមានពាសពេញសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់" គឺជាកត្តាសម្រាលទោសមួយ ។

យ៉ាងហោចណាស់មានអ្នកអត្ថាធិប្បាយម្នាក់បានកត់សម្គាល់ទៅលើការលំបាកចំពោះធម្មាធិបតេយ្យ ដែលបន្តដោយការជំនុំជម្រះក្ដីនៅក្នុងសម័យអន្តរកាល ដូចករណីឆ្មាំការពារព្រំដែនជាឧទាហរណ៍ស្រាប់ៈ

*"នៅពេលរៀបចំប្រព័ន្ធច្បាប់ត្រឹមត្រូវ ច្បាប់ធម្មជាតិជួយបំពេញចន្លោះច្បាប់វិជ្ជមាន ។ ចាំបាច់ត្រូវតែមានការប៉ះទង្គិចគ្នារវាងតម្រូវការវិធាននៃច្បាប់ និងតម្រូវការនៃច្បាប់ធម្មជាតិ ។ ក៏ប៉ុន្តែ នៅពេលដែលសង្គមមួយស្ថិតក្នុងការផ្លាស់ប្ដូរ ដូចជាប្រទេសអាល្លឺម៉ង់ ដែលមានប្រព័ន្ធច្បាប់និងប្រព័ន្ធសីលធម៌ខុសគ្នាខ្លាំងហើយលាយបញ្ចូលគ្នានោះ ការប៉ះទង្គិចរវាងច្បាប់ធម្មជាតិនិងវិធាននៃច្បាប់គឺពិតជាមានសភាពធ្ងរស្រាលច្រើន"* ។

សេចក្ដីសម្រេចរបស់តុលាការរដ្ឋទីក្រុងប៊ែរឡាំងបានធ្វើលោបកម្មទៅលើការប្រទាំងប្រទើសនេះ នៅពេលដែលខ្លួនរំសង្កត់ធ្ងន់ទៅលើធាតុផ្សំសីលធម៌នៅក្នុងច្បាប់វិជ្ជមាន ទោះបីជាប្រឆាំងនឹងសាវតាជាតិរបស់សង្គមនោះដែលប្រហែលជាគ្មាន "ស្មារតីនីត្យានុកូល" ក៏ដោយ ។

ក្រុមព្រហ្មទណ្ឌរបស់សាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់គួរតែត្រូវអនុញ្ញាតឲ្យតុលាការរដ្ឋទីក្រុងប៊ែរឡាំងសម្រេចដោយយោងទៅតាមច្បាប់វិជ្ជមានរបស់សាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ដែលមានអានុភាពគតិយុត្តិនៅពេលដែលមានអំពើរបស់ឆ្មាំការពារព្រំដែនកើតឡើង ។ ផ្ទុយទៅវិញ តុលាការប្រហែលជាផ្អែកទៅលើសេចក្ដីសម្រេចរបស់ខ្លួនពីមុន ទៅលើការរំលោភកិច្ចព្រមព្រៀង ហេលស៊ីនគី និងអនុសញ្ញាទីក្រុងហ្សឺណែវ ដែលលិខិតូបករណ៍ទាំងពីរនេះសុទ្ធតែបានទទួលស្គាល់ដោយសាធារណរដ្ឋប្រជាធិបតេយ្យអាល្លឺម៉ង់ ប៉ុន្តែ តុលាការមិនបានប្រឈមមុខដោះស្រាយបញ្ហារំលោភទៅលើនីតិអន្តរជាតិវិជ្ជមានដោយផ្ទាល់ឡើយ ។ ***(នៅមានត)*** **អេលីហ្សាប៊ែត វ៉ាន់ស្លាក់**

# បទសម្ភាសន៍ជាមួយសម្តេចព្រះសុគន្ធាធិបតី ប៊ួរ គ្រី ព្រះសង្ឃរាជគណៈធម្មយុត្តិកនិកាយនៃព្រះរាជាណាចក្រកម្ពុជា

***សួរៈ*** *ខ្ញុំព្រះករុណាសូមក្រាបបង្គំសួរសម្តេចព្រះសង្ឃរាជអំពីបញ្ហាតុលាការខ្មែរក្រហមដែលបច្ចុប្បន្ននេះកំពុងតែមានភាពពុះកញ្ជ្រោល តើសម្តេចព្រះសង្ឃរាជទ្រង់មានព្រះតម្រិះយ៉ាងណាដែរ?*

***សម្តេចព្រះសុគន្ធាធិបតីៈ*** *រឿងតុលាការ រឿងកាត់ទោសខ្មែរក្រហមអីទាំងអស់ហ្នឹង អាត្មាក្នុងឋានៈជាអ្នកបួស អ្នកបួស បើយោងទៅតាមព្រះពុទ្ធដីកាសម្តេចព្រះសម្មាសម្ពុទ្ធ ស្តេចទ្រង់មានព្រះទ័យមេត្តា (សេចក្តីរាប់រក សេចក្តីប្រណី) ករុណា (សេចក្តីអាណិតអាសូរ) មុទិតា (ការមិនច្រណែនឈ្នានីស) ឧបេក្ខា (ការតាំងចិត្តជាកណ្តាល) ។ មិនចំពោះថាអ្នកហ្នឹងជាស្អីទេ គឺទ្រង់មានព្រះទ័យអីចឹង សូម្បីតែទេវទត្តដែលតាមធ្វើគុតព្រះពុទ្ធអង្គ ព្រះពុទ្ធអង្គក៏ស្តេចទ្រង់ព្រះពុទ្ធានុញ្ញាតឲ្យចូលគាល់ដែរ ។ បើយើងគិតទៅតាមរបៀបខ្មែរយើងតាំងពីបរមបុរាណមក លោកថា “កាត់ទឹកមិនដាច់ កាត់សាច់វាឈឺ” ។ មួយទៀតគេថា “យល់ញាតិឃ្លាតច្បាប់” ។ សង្គមខ្មែរយើងយកមកប្រើទាំងអស់ ច្បាប់ក៏ប្រើ សាច់ញាតិក៏ប្រើ ប្រើទាំងពីរ ។ ទាំងពីរហ្នឹងយើងយកមកថ្លឹងមើល យើងក៏មិនថាឲ្យខាងណាមួយដាច់ខាតដែរ ទាល់តែថ្លឹងថ្លែងមើលទាំងអស់ មិនគួរឬគួរ អាហ្នឹងវាជារឿងត្រឡប់ទៅត្រឡប់មក មិននិយាយដាច់មួយម៉ាត់បាន ។ រឿងខ្មែរក្រហមមិនអាចនិយាយដាច់មួយម៉ាត់ថាកាត់ឬទុក ព្រោះយើងមើលទៅតើមានប្រយោជន៍ឬអត់ប្រយោជន៍? កាត់ចេញទៅវាមានប្រយោជន៍កើតប៉ុនណា បើយើងទុកប្រយោជន៍វាកើតប៉ុនណា យើងថ្លឹងមើលប្រយោជន៍ហ្នឹង ។ ពិសេសគឺយើងអ្នកទទួលមុន ពួកយើងហ្នឹង ខ្មែរហ្នឹង ដែលទទួលមុនគេបង្អស់ហើយ ។ អីចឹងខ្មែរថ្លឹងថ្លែងមើល តើវាមានបានទទួលផលប្រយោជន៍ប៉ុនណា ខូចផលប្រយោជន៍ប៉ុនណា ។*

***សួរៈ*** *តើទ្រង់ព្រះតម្រិះថាគួរតែមានការផ្សះផ្សាឡើងវិញរវាងអតីតខ្មែរក្រហមជាមួយនឹងប្រជាជនខ្មែរទាំងអស់ឬយ៉ាងណា?*


*សម្តេចព្រះសុគន្ធាធិបតី ប៊ួរ គ្រី*

***សម្តេចព្រះសុគន្ធាធិបតីៈ*** *អាត្មាជម្រាបរួចហើយ ពាក្យខ្មែរថា កាត់ទឹកវាមិនដាច់ កាត់សាច់វាឈឺ ។ មួយទៀតថា យល់ញាតិឃ្លាតច្បាប់ ។ ប៉ុន្តែឥឡូវយើងគិតពីប្រយោជន៍វិញ ថាខ្មែរត្រូវការប្រយោជន៍ ខ្មែរចង់បានប្រយោជន៍ ។ ចុះបើថា ឥឡូវយើងកាត់ បានទទួលប្រយោជន៍ប៉ុនណាដល់ខ្មែរ ឥឡូវបើមិនកាត់ តើយើងខូចប្រយោជន៍ប៉ុនណា ។*

***សួរៈ*** *តើការកាត់ទោសខ្មែរក្រហមជាមួយធម៌ព្រះ ឃ្លាតខុសគ្នាប៉ុនណា? គម្លាតនៃពេលវេលា គម្លាតច្បាប់និងសាសនា ។*

***សម្តេចព្រះសុគន្ធាធិបតីៈ*** *នៅក្នុងព្រះពុទ្ធសាសនា លោកនិយាយពីរឿងកម្មផល គឺទទួលខ្លួនឯងទាំងអស់ អត់មានអ្នកណាកាត់ឲ្យទេ គឺថាអ្នកណាធ្វើអំពើហ្នឹងចាត់ចែងឲ្យទៅ ។ អីចឹងបានជាព្រះពុទ្ធដីកាលោកថា សត្តេ កម្មំ វិភជ្ជតិ (សត្វទាំងឡាយទទួលនូវកម្មដែលខ្លួនបានសាង) ។ កម្មបែងចែកចំណែកសត្វហ្នឹងផ្សេងៗគ្នា បានន័យថា កម្មហ្នឹងហើយកាត់សេចក្តីហ្នឹងឲ្យផ្សេងគ្នាទៅទាប ទៅខ្ពស់ អាស្រ័យអំពើដែលខ្លួនធ្វើ ។ អំពើដែលធ្វើហ្នឹងអ្នកកាត់សេចក្តីឲ្យ អ្នកចាត់ចែងឲ្យ អំពើរបស់យើងហ្នឹង អត់មានអ្នកណាទេ យើងម្ចាស់ខ្លួនយើង យើងធ្វើយើងទទួលខ្លួនយើង ។ នៅក្នុងព្រះពុទ្ធសាសនាលោកបន្ទូលអីចឹង ព្រះពុទ្ធលោកប្រដៅពុទ្ធបរិស័ទ ។ លោកថា បើអ្នកឯងមិនចង់បានទទួលសេចក្តីទុក្ខទេ អ្នកឯងកុំធ្វើអំពើអាក្រក់ អ្នកឯងឈប់ធ្វើទៅ បើអ្នកឯងចង់បានសេចក្តីសុខ អ្នកឯងខំប្រឹងធ្វើអំពើល្អច្រើនឡើង អំពើល្អហ្នឹងឧបត្ថម្ភអ្នកឯងឲ្យបានសុខ អំពើអាក្រក់ឧបត្ថម្ភអ្នកឯងឲ្យបានទុក្ខ ។ ប៉ុន្តែទុក្ខហ្នឹងអត់មានអ្នកណាឲ្យទេ ខ្លួនឯងធ្វើខ្លួនឯង ។*

សុខក៏អត់មានអ្នកណាឲ្យ ខ្លួនឯងធ្វើខ្លួនឯង ។ ព្រះពុទ្ធអង្គលោកគ្រាន់តែប្រដៅយើងទេ ។ លោកក៏មិនឲ្យយើងបាប តែលោកក៏មិនឲ្យយើងបុណ្យ ខ្លួនយើងធ្វើខ្លួនយើង លោកគ្រាន់តែបង្រៀនយើងថា ធ្វើអីចេះបុណ្យ ធ្វើអីចេះបាប អីចេះសុខ អីចេះទុក្ខ ។

**ស្នួរៈ** តើសម្តេចព្រះសង្ឃរាជទ្រង់ព្រះតម្រិះថា បច្ចុប្បន្ននេះមេដឹកនាំខ្មែរក្រហមបានទទួលកម្មដែលគេបានប្រព្រឹត្តហើយឬនៅ?

**សម្តេចព្រះសុគន្ធាធិបតីៈ** លោកស្រីអញ្ជើញមើល គាត់បានទទួលតាំងពីបច្ចុប្បន្នហ្នឹងហើយ ។ ទទួលយ៉ាងម៉េច? ពិភពលោកគេស្អប់គាត់ គេដាក់ទោសគាត់ ទាំងអស់ហ្នឹងជាបាបកម្មរបស់គាត់ហើយ អាហ្នឹងគាត់បានទទួលរបស់គាត់ហើយ ។ សព្វថ្ងៃពិភពលោកមានអង្គការសហប្រជាជាតិជាដើម គេចេះតែទទូចដើម្បីនឹងកាត់ទោសដាក់ទោសគាត់ អាហ្នឹងសុទ្ធតែបាបកម្មរបស់គាត់ហើយ ។ បើមនុស្សល្អអ្នកណាគេនឹងទៅទទូចកាត់ទោសអីចឹង? ហើយគាត់ដែលបានទទួលការសរសើរពីគេទេ? អាហ្នឹងបាបកម្មរបស់គាត់ហើយ ។ ពួកគាត់ក៏ចេះតែបានទទួលបន្តៗអីចឹងមកហួរហែអីចឹងយើងដឹងហើយ ។ យើងមើលជីវិតរបស់គាត់ ទីបំផុតដុតនឹងកង់ឡាន ខ្លះស្លាប់ ស្អីស្អុកទៀត យើងអត់ដឹងទេ ប៉ុន្តែគាត់ទទួលហើយ បើគិតទៅតាមធម៌ព្រះថាគាត់ទទួលហើយ គាត់អត់គេចរួចខ្លួន ។

**ស្នួរៈ** សម្តេចព្រះសង្ឃរាជមានព្រះរាជបន្ទូលថា “មានកម្ម-ផល” ចុះកាលពីជំនាន់ខ្មែរក្រហម៧៥-៧៩ហ្នឹង តើប្រជាជនទាំងអស់សុទ្ធតែមានកម្ម-ផលមែនទេដែលទទួលរងទុក្ខវេទនា?

**សម្តេចព្រះសុគន្ធាធិបតីៈ** រឿងកម្ម-ផលនេះ អ្នកដែលកាន់ព្រះពុទ្ធសាសនាដាក់ច្បាស់គឺជឿមួយរយភាគរយ ។ ស្អីក៏ដោយ ការដែលធ្វើទាំងអម្បាលម៉ាននេះ មិនមែនធ្វើឡើងដោយគ្មានហេតុគ្មានផលទេ សុទ្ធតែប្រកបដោយហេតុបច្ច័យទាំងអស់ ។ ព្រះពុទ្ធអង្គលោកថា ហេតុឃើញហើយរកមុខបច្ច័យ ។ “ហេតុបច្ចយោ” គឺថា មានបច្ច័យកើតឡើងព្រោះហេតុអី? ខ្មែរក្រហមកើតឡើងព្រោះហេតុអី? តៗស្រាវៗអីចឹងណា៎ អាហ្នឹងសុទ្ធតែធម៌ព្រះហើយហ្នឹង ។

**ស្នួរៈ** តើរឿងខ្មែរក្រហមគឺជារឿងចេតនារបស់មេដឹកនាំខ្មែរក្រហមដែលផ្តួចផ្តើមឡើងឬមួយយ៉ាងណា?

**សម្តេចព្រះសុគន្ធាធិបតីៈ** អាត្មាក៏មិនបានដឹងថាគាត់មានចេតនាឬអចេតនាក៏មិនដឹងរឿងគេដែរ ។ រឿងខ្មែរក្រហម អាត្មានិយាយទៅតាមផ្លូវព្រះពុទ្ធសាសនា អ្វីទាំងអស់គឺវាមានចិត្តមកអីចឹង ។ ចេតនាហ្នឹងហើយជាតួកម្ម ។ “ចេតនាហំ កម្មំ ភិក្ខវេ” ម្នាលភិក្ខុទាំងឡាយ ចេតនាជាតួកម្ម ។ តួកម្មធំវានៅនឹងចិត្តអាហ្នឹងហើយចេតនា ។

**ស្នួរៈ** តើការដែលខ្មែរក្រហមមានចេតនាសម្លាប់មនុស្សគឺជាកម្មដែលបណ្តាលចិត្តគាត់ឲ្យធ្វើដូច្នេះ?

**សម្តេចព្រះសុគន្ធាធិបតីៈ** អ្វីៗទាំងអស់គឺវានៅលើអំពើដែលយើងធ្វើ ។ កម្មហ្នឹងហើយចាត់ចែងវា ។ យើងម្នាក់ៗមានកម្មជារបស់ខ្លួន ។ ព្រះពុទ្ធជាម្ចាស់លោកថា យើងមានកម្មជារបស់ខ្លួន កើតមកមានកម្មមកជាមួយហើយ ។

**ស្នួរៈ** តើមេដឹកនាំខ្មែរក្រហមហ្នឹងក៏មានកម្មដែលបណ្តាលឲ្យប្រព្រឹត្ត ហើយជនរងគ្រោះក៏មានកម្មដែលបណ្តាលឲ្យរងគ្រោះ?

**សម្តេចព្រះសុគន្ធាធិបតីៈ** នេះគេហៅថា កម្មពន្ធុ កម្មជាផៅពង្ស កម្មជាសម្ពូហភាព ។ យើងទៅរកគ្រូ យើងទៅរកទាំងអស់ទៅ ទាំងរទេះរាប់រយអីចឹងទៅ ។ យើងទៅធ្វើបុណ្យកឋិនឡានយើង ២០ ដង្ហែអីចឹងទៅ ។ អាហ្នឹងហើយហៅថាកម្មពន្ធុ កម្មជាផៅពង្ស កម្មជាបងប្អូន យើងធ្វើកម្មរួមគ្នា កម្មជាសម្ពូហភាព អាហ្នឹងយើងមានដែរ ។ ក្នុងពុទ្ធសាសនាអត់ប្រើពាក្យចៃដន្យទេ ។ ចៃដន្យគ្មានទេ ។ ក្នុងព្រះពុទ្ធសាសនាមិនប្រើពាក្យចៃដន្យដាច់ខាត គឺសុទ្ធតែកម្មទាំងអស់ កម្មហ្នឹងនាំឲ្យទៅអីចឹង អំពើដែលយើងធ្វើហ្នឹងនាំយើងទៅអីចឹង ។ ប៉ុន្តែមនុស្សយើង បើយើងមិនជឿកម្មយើងរកការស្ងប់អត់ឃើញទេក្នុងជីវិត ។ រស់ក្នុងគ្រួសារក៏អីចឹងរស់នៅក្នុងសង្គមក៏អីចឹង បើយើងមិនជឿរឿងកម្មទេ យើងរស់អត់កើត ។ ព្រោះយើងមិនអាចដោះស្រាយដោយចិត្តយើងបានទេ ។ អីចឹងហើយត្រូវមានការអត់ធ្មត់ ខន្តី ។ ព្រះពុទ្ធអង្គថា ខន្តីអត់ធ្មត់ ស្អីក៏ដោយ មានកាលពេលទាំងអស់ ។ ទឹកពេលវាជន់បាន វាស្រកបាន ជោរបាន នាចបាន ។ មានយប់មានថ្ងៃមានត្រជាក់ មានក្តៅ វាមិនមែនត្រជាក់រហូត មិនមែនក្តៅរហូតរដូវវាផ្លាស់ប្តូរអីចឹង ។ ជីវិតរស់នៅរបស់មនុស្សអីចឹង កើតចាស់ ឈឺ ស្លាប់ ។ អ្នកណាចង់ស្លាប់? ថាអត់ទេ ។ ហើយម៉េចក៏

ស្លាប់? ពេទ្យគេពូកែសឹងអី មើលមនុស្សមិនជា? ថាអ្នកឯងដល់ពេលហើយ អ្នកឯងបានតែប៉ុណ្ណឹងទេ សម្លាយអ្នកឯងបានតែប៉ុណ្ណឹងមកទេ ទោះបីពេទ្យទេវតាក៏មើលអ្នកឯងមិនជាដែរ ព្រោះអ្នកឯងអស់ហើយ គឺថាកម្មអ្នកឯងបានត្រឹមប៉ុណ្ណឹងមកទេ រស់បានប៉ុណ្ណឹងទេ ។ ព្រះពុទ្ធអង្គលោកប្រដៅមកអ៊ីចឹង ។ ព្រះពុទ្ធអង្គលោកអភ័យឲ្យច្រើនណាស់ លោកអភ័យឲ្យអ្នកដែលមកព្យាបាទលោក លោកអភ័យរហូតក្នុងឋានៈលោកជាអ្នកបួសក្នុងឋានៈលោកជាព្រះពុទ្ធ លោកចេះតែមេត្តា ។

**សួរៈ** តើសម្តេចទ្រង់ជឿពាក្យដែលថា «ពៀររំងាប់ដោយការមិនចងពៀរ»?

**សម្តេចព្រះសុគន្ធាធិបតីៈ** អាត្មាជឿ ព្រោះព្រះលោកថាហើយ អាត្មាជឿហើយ ។ ស្អីក៏ដោយ តែយើងរំងាប់ហើយ យើងអភ័យឲ្យគ្នាហើយ ព្រោះមនុស្សវាមានពេលខុស វាមានពេលវង្វេង វាចេះតែមានអ៊ីចឹង ។ ចុះបើយើងចេះតែមិនទទួលស្គាល់ថ្ងៃក្រោយយើងអស់គ្រួសារហើយ ។ ព្រះពុទ្ធអង្គលោកមេត្តារហូត ប្រទានអភ័យឲ្យរហូត ។

**សួរៈ** ប្រសិនបើអភ័យពេកទៅ តើមនុស្សហ្នឹងអាចដឹងកំហុសខ្លួនដែរឬទេ? ឬលុះត្រាតែយើងដាក់ពិន័យ ដូចខ្មែរក្រហមអ៊ីចឹងលុះត្រាតែកាត់ទោស ។

**សម្តេចព្រះសុគន្ធាធិបតីៈ** បំរើនពរ! អ៊ីចេះ ចំពោះព្រះពុទ្ធអង្គលោកអភ័យឲ្យហើយ យកមកអប់រំ មិនមែនអភ័យចោលទទេអ៊ីចឹងទេ ។ ពាក្យថា «អភ័យ» បានន័យថាយកមកអប់រំឲ្យកែចិត្តកែគំនិតប្រព្រឹត្តទៅតាមផ្លូវល្អវិញ ។ ដូចជាអង្គុលីមារអ៊ីចឹងដែរ ព្រះពុទ្ធអង្គទៅបញ្ឈប់កុំឲ្យ អង្គុលីមារ ហ្នឹងធ្វើការអាក្រក់ តែលោកយកមកអប់រំឲ្យបួស ហ្នឹងអប់រំមួយហើយ ។ តែយើងមិនមែនថាឲ្យមកបួសអ៊ីចឹងទេ យើងអាចថាមកចូលអប់រំទៅតាមផ្លូវសង្គមដែលយើងត្រូវការ ដែលយើងនាំគ្នាជួយកសាងជាតិ ទៅតាមផ្លូវណាដែលល្អអ៊ីចឹងទៅ ។ មិនមែនថាអភ័យហើយឲ្យនៅឯកោ មិនមែនអ៊ីចឹងទេ គឺថាអភ័យគេឲ្យចូលក្នុងសង្គម អប់រំគ្នាឲ្យដើរតាមផ្លូវជាមួយគ្នាឡើងវិញណា៎ ។

**សួរៈ** មុននេះសម្តេចព្រះសង្ឃរាជមានព្រះបន្ទូលថា មេដឹកនាំខ្មែរក្រហមបានទទួលកម្មរបស់គេហើយ ដោយបានទទួលការស្អប់ខ្ពើមអីជាដើម ។ ប៉ុន្តែ ខ្ញុំព្រះករុណាយល់ថាដូចជាមានគម្លាតគ្នាខ្លាំងពេក ព្រោះជនរងគ្រោះនៅតែរស់ក្នុងសភាពលំបាកវេទនាដោយសារការរងគ្រោះតាំងពីរបបខ្មែរក្រហមមក ហើយមេដឹកនាំខ្មែរក្រហមរស់ដោយសេចក្តីសុខសប្បាយរស់ដោយមានទ្រព្យបរិបូណ៌និងមានសេរីភាព ។

**សម្តេចព្រះសុគន្ធាធិបតីៈ** អាត្មានិយាយរឿងផ្លូវចិត្ត ។ សំបកយើងអត់ដឹងទេ ។ សំបកយើងមើលវាមួយ ប៉ុន្តែខាងក្នុង សាច់ខាងក្នុងនេះវាយ៉ាងម៉េចយើងអត់ដឹង ។ ថាឥឡូវបើសម្លាប់ខ្មែរក្រហមទាំងអស់ហ្នឹង ហើយរាស្ត្រហ្នឹងបានធូរស្រាលឡើងវិញស្រួល អាហ្នឹងប្រយោជន៍ហើយ បើថាធ្វើអ៊ីចឹងបានទទួលប្រយោជន៍ អាហ្នឹងខ្មែរទាំងអស់គ្នាគិតទៅ ។ បើថា ឥឡូវនែ៎ រាស្ត្រក្រមកពីអ្នកឯងប៉ុន្មាននាក់ហ្នឹង អ្នកឯងសុខចិត្តឲ្យគេកាត់ទោសទៅ ដើម្បីឲ្យរាស្ត្រគេប៉ុន្មានលានហ្នឹងគេសុខសប្បាយឡើងវិញ ។ ប្រសិនបើចាប់ពួកអស់ហ្នឹងយកទៅធ្វើទោសអស់ទៅ ហើយរាស្ត្រខ្មែរប៉ុន្មានលានហ្នឹងបានសុខសប្បាយ អាហ្នឹងវាជាប្រយោជន៍ហើយ ។

**សួរៈ** តើសម្តេចព្រះសង្ឃរាជមានព្រះតម្រិះថាការផ្សះផ្សាជាតិមានសារសំខាន់ប៉ុនណា?

**សម្តេចព្រះសុគន្ធាធិបតីៈ** អាត្មាមិនដឹងថាយ៉ាងម៉េចទេ ។ ឥឡូវមិនដឹងថាចោលគ្នាទៅឯណា មិនដឹងថាយកទៅទុកឯណា ដាក់កន្លែងណា ឥឡូវហ្នឹងយកទៅដាក់កន្លែងណា យកទៅទុកឯណា អាត្មាមិនដឹងឆ្លើយថាយ៉ាងម៉េចទេ ។ គួរឬមិនគួរយ៉ាងម៉េចក៏ទាល់តែយើងទាំងអស់គ្នាព្រមព្រៀងគ្នា ម្នាក់ឯងឆ្លើយមិនបាន ។ នេះវាមិនមែនរឿងឯកជន មិនមែនរឿងផ្ទាល់ខ្លួន វាជារឿងជាតិយើងទាំងមូលផង អន្តរជាតិផង ។

**សួរៈ** តើសម្តេចព្រះសង្ឃរាជទ្រង់ព្រះតម្រិះថា ប្រវត្តិសាស្ត្រអំពីរឿងខ្មែរក្រហមគួរតែត្រូវនិយាយតទៅទៀត ឬគួរតែបំភ្លេចចោល?

**សម្តេចព្រះសុគន្ធាធិបតីៈ** ប្រវត្តិសាស្ត្រហ្នឹងវាអ៊ីចឹងទៅហើយ អ្នកណាគេនិយាយក៏និយាយទៅ អ្នកណាគេមិននិយាយក៏មិននិយាយ អាហ្នឹងយើងហាមឃាត់ក៏មិនបាន ។ គេចង់និយាយក៏និយាយ ។ នេះជារឿងជាប្រវត្តិសាស្ត្រទៅហើយ ចេះតែ

និយាយហួរហែអីចឹងទៅ ។

**សួរៈ** តើគួរចងក្រងទុកឬក៏មិនបាច់ចងក្រងប្រវត្តិសាស្ត្រអំពីរបបខ្មែរក្រហម?

**សម្តេចព្រះសុគន្ធាធិបតីៈ** អាហ្នឹងវាប្រវត្តិសាស្ត្រ ព្រះពុទ្ធអង្គលោកសម្តែងធម៌មក លោកទៅប្រោសអ្នកណាៗ សរសេរមក បើមិនអីចឹងព្រះអង្គទៅទេសនាឲ្យអ្នកណាស្តាប់ បានធម៌ឯណាយកមកនិយាយ យើងបានអីមករៀន លោកទៅប្រដៅថាម៉េច ហើយអ្នកនោះធ្វើម៉េច អ្នកនោះធ្វើអាក្រក់ម៉េច ព្រះពុទ្ធអង្គលោកទប់ស្កាត់យ៉ាងម៉េច ព្រះពុទ្ធអង្គលោកទប់ស្កាត់អ្នកហ្នឹងកុំឲ្យធ្វើអំពើអាក្រក់ ឲ្យអ្នកហ្នឹងចូលមកធ្វើអំពើល្អ ។ សៀវភៅទាំងអស់ដែលយើងសិក្សាមកហ្នឹងវាជាប្រវត្តិទាំងអស់ហើយ ។

**សួរៈ** តើទ្រង់មានព្រះតម្រិះថាការសិក្សាអំពីប្រវត្តិសាស្ត្រខ្មែរក្រហមជាការឆ្កឹះកកាយរឿងឈឺចាប់យកមករំពុកវិញទេ?

**សម្តេចព្រះសុគន្ធាធិបតីៈ** យើងថាឈឺក៏បាន ថាមិនឈឺក៏បាន ។ ព្រះពុទ្ធអង្គលោកមានបន្ទូលថា អតីតកាលកន្លងផុតទៅហើយកុំយកមកគិតជាអារម្មណ៍ បច្ចុប្បន្នត្រូវខំប្រឹងធ្វើ អនាគតមិនទាន់ដល់កុំឲ្យដេកសង្ឃឹម ។ ព្រោះម៉េច? ព្រោះអតីតកាលដូចខ្មោចស្លាប់អីចឹង ។ ខ្មោច បើយើងមិនកប់ យើងចេះតែកាន់ពរហូតអីចឹងទៅ វាស្អុយអសោចដល់ខ្លួនយើងទៀត អត់អ្នកណានៅជិតបានទេ ។ អីចឹងយកទៅកប់ទៅអតីតហ្នឹង ។ បើអនាគតមិនទាន់មកដល់ យើងកុំសង្ឃឹមថាមកជាអីៗ វាមិនបានដូចចិត្តយើងទៅជាទុក្ខទៀត ។ ព្រះពុទ្ធអង្គលោកថា បច្ចុប្បន្នខំប្រឹង ដង្ហើមដកចេញចូល ពេលនេះធ្វើអី គិតអី ពិចារណាអី ពេលហ្នឹង ។ កុំចាំស្អែក ស្អែកក៏អនាគតដែរ ហើយកុំគិតពីម្សិលមិញ អាហ្នឹងអតីតដែរ ។ ឥឡូវហ្នឹងធ្វើអី កំពុងធ្វើអី គិតធ្វើអីធ្វើឥឡូវហ្នឹងទៅ ក្រែងលោវាស្លាប់មុននឹងបានធ្វើការហ្នឹងទៅ ។ ព្រះពុទ្ធអង្គលោកថាអីចឹង ។

**សួរៈ** ប៉ុន្តែខ្ញុំព្រះករុណាយល់ថា ការដែលយើងបំភ្លេចអតីតកាលមួយ មិនយូរមិនឆាប់ទេ អតីតកាលនោះនឹងត្រឡប់មកកប់ខ្លួនយើងម្តងទៀត ។

**សម្តេចព្រះសុគន្ធាធិបតីៈ** លោកស្រីយល់អីចឹង តែព្រះពុទ្ធអង្គលោកអត់យល់អីចឹង ។ ស្អីក៏ដោយ បើចប់ហើយគឺវាចប់ហើយ ។ ស្អីក៏ដោយ វាមិនដែលកើតពីរដង ស្លាប់ទៅវាមិនអាចកើតមកវិញទេ ។ អាត្មាមិនមានជំនឿ ព្រោះអាត្មាមិនជឿថាខ្មោចរស់ មិនជឿថាខ្មោចដែលគេយកទៅដុតហើយវាមកផ្ទុំរស់ មកធ្វើយើងវិញ មិនមានទេ ។ ពេលវេលាវាផុត វាខុស វាអាចមានឈ្មោះហ្នឹងអីហ្នឹងមែន ប៉ុន្តែការផាវវាខុសគ្នាទាំងអស់ ។ នេះអាត្មាមិនជឿទេ អាត្មាសូមបដិសេធ មិនជឿទេ ដែលយើងចង់ឲ្យម៉ែឪ ចង់ឲ្យជីដូនជីតាយើងរស់មកនៅជុំយើងវិញ គាត់អត់មកបានសោះ ។

**សួរៈ** ប៉ុន្តែខ្ញុំព្រះករុណាជឿពាក្យថា “វកាសាដាន” ។

**សម្តេចព្រះសុគន្ធាធិបតីៈ** អាហ្នឹងពាក្យដែលយើងនិយាយអីចឹងឥឡូវសាមិនសាវានៅលើយើងទេ ។ តើពៀររំងាប់ដោយការមិនចងពៀរ បើគេចង់ចងពៀរចេះតែសាទៅ បើគេឈប់ចងពៀរបានអីសាមកទៀត ។

**សួរៈ** ខ្ញុំព្រះករុណាចង់និយាយពាក់ព័ន្ធទៅលើរឿងផ្លូវច្បាប់ ។ ខ្ញុំព្រះករុណាឧទាហរណ៍ថា មនុស្សម្នាក់ទៅសម្លាប់គេ ហើយជននោះមិនបានទទួលការផ្តន្ទាទោសទេ អ្នកដទៃឃើញដូច្នោះក៏ធ្វើដែរ ។ អីចឹងអំពើឃោរឃៅហ្នឹងវាចេះតែកើតហើយកើតទៀត ។ បុគ្គលម្នាក់ហ្នឹងមិនប្រព្រឹត្តដដែលទេ ប៉ុន្តែបុគ្គលក្រោយៗទៀតប្រព្រឹត្តអំពើហ្នឹង ។

**សម្តេចព្រះសុគន្ធាធិបតីៈ** អាត្មាយល់ ។ ចុះដែលយើងយកទៅដាក់ធ្វើទុក្ខធ្វើទោសអី មនុស្សរាងចាលទេ?

**សួរៈ** ខ្ញុំព្រះករុណាយល់ថា ជាគំរូឲ្យអ្នកជំនាន់ក្រោយបានឃើញ ។

**សម្តេចព្រះសុគន្ធាធិបតីៈ** គំរូហ្នឹងបានធ្វើប៉ុន្មានពាន់ឆ្នាំមក តាំងពីកើតទឹកកើតដីមកដល់ឥឡូវ មនុស្សអស់ខូចទេ? អស់ចោរទេ? អស់ការប្រព្រឹត្តផ្តេសផ្តាសទេ? សម្លាប់ក៏សម្លាប់ចោលហើយ ដាក់គុកអស់ជីវិតក៏ដាក់ហើយ ធ្វើអីហើយ តើវាអស់ទេ? អត់អស់ ។

**សួរៈ** ប៉ុន្តែខ្ញុំព្រះករុណាយល់ថា ប្រសិនបើអត់មានច្បាប់ ប្រហែលជាមនុស្សអាក្រក់កើតរឹតតែច្រើន ដល់មានច្បាប់ទៅអាចទប់បានខ្លះ ។

**សម្តេចព្រះសុគន្ធាធិបតីៈ** ព្រះពុទ្ធអង្គលោកបង្រៀនហ្នឹងគឺច្បាប់ហើយ ទេសនាពន្យល់ហ្នឹងគឺជាច្បាប់ហើយ ។ អីចឹងបានថា កុំ

ក្លែងពាក្យខាងដើមថា "យល់ញាតិវាឃាតច្បាប់" អាហ្នឹងក៏ខ្មែរយើងយកមកប្រើ ហើយមួយទៀត ខ្មែរយើងគាត់ថា "កាត់ទឹកមិនដាច់ កាត់សាច់វាឈឺ" អាហ្នឹងក៏ខ្មែរយកមកប្រើ ។ ឥឡូវយើងថ្លឹងមើលទៅ យើងក៏មិនអាចចោលមួយណាបានទេ ។

**សួរៈ** តើសម្តេចទ្រង់មានព្រះតម្រិះថា ប្រវត្តិសាស្ត្រខ្មែរក្រហមគួរតែយកទៅបង្រៀនដល់ក្មេងជំនាន់ក្រោយៗទៀតឲ្យបានដឹងដែរឬយ៉ាងណា?

**សម្តេចព្រះសុគន្ធាធិបតីៈ** រឿងទាំងអស់នេះមិនមានបញ្ហាអីចំពោះអាត្មាទេ ព្រោះអាហ្នឹងវាអីចឹងហើយ ។ ស្អីដែលវាកើតមានហើយវាកើតទៅ យើងចេះតែដឹងតៗគ្នា ។ ទោះបីជាយើងមិនសរសេរ ក៏ម៉ែឪគេទៅនិយាយប្រាប់កូនគេ និយាយប្រាប់ចៅគេ ហូរហែអីចឹងទៅ ។ ដូច្នេះទោះយើងមិនសរសេរ ក៏គង់តែគ្រួសារហ្នឹងគេនិយាយប្រាប់កូនគេ ។

**សួរៈ** តើព្រះពុទ្ធសាសនាអាចជួយអ្វីខ្លះដល់ការផ្សះផ្សាសង្គមជាតិខ្មែរ?

**សម្តេចព្រះសុគន្ធាធិបតីៈ** ទេសន៍រាល់ថ្ងៃហ្នឹង ទេសនាអប់រំឲ្យកាន់សីល ឲ្យធ្វើបុណ្យ ឲ្យលះអំពើអាក្រក់ ឲ្យធ្វើអំពើល្អ ហ្នឹងព្រះពុទ្ធសាសនាហើយ ។ ប្រើងធ្វើតែតាមតួនាទីជាអ្នកបួសអីចឹង ។ ធ្វើអាក្រក់បានទុក្ខ ធ្វើល្អបានសុខ ពុទ្ធសាសនាលោកធ្វើអីចឹង លោកដើរទេសនាអីចឹង ។

**សួរៈ** សូមសម្តេចព្រះសង្ឃរាជទ្រង់ព្រះមេត្តាពន្យល់ពាក្យ "យុត្តិធម៌" បើតាមផ្លូវសាសនា យុត្តិធម៌ មានន័យថាម៉េច?

**សម្តេចព្រះសុគន្ធាធិបតីៈ** ក្នុងព្រះពុទ្ធសាសនា លោកនិយាយពីរឿង "អគតិ" ហើយនិង "គតិ" ។ ក្នុងពុទ្ធសាសនានិយាយពីរឿងអគតិមានបួនៈ ឆន្ទាគតិ (លម្អៀងព្រោះស្រលាញ់) ទោសាគតិ (លម្អៀងព្រោះខឹង ព្រោះស្អប់) ភយាគតិ (លម្អៀងព្រោះភ័យ) មោហាគតិ (លម្អៀងព្រោះវង្វេង) ។ អាហ្នឹងហើយការលម្អៀង ។ បើកាលណាយើងលម្អៀងអីចឹង ព្រះពុទ្ធលោកថា តែលម្អៀងវៀចផ្លូវហើយ ។ អាហ្នឹងបើចង់សួររឿងយុត្តិធម៌ ។ ទីមួយព្រោះអី? ព្រោះស្រលាញ់ ទីពីរព្រោះស្អប់ ទីបីព្រោះភ័យខ្លាច ទីបួនព្រោះមោហៈ វង្វេង ។ ឥឡូវបើយើងចង់បានគតិយុត្តិធម៌ ទាល់តែធ្វើម៉េចឲ្យផុតអាបួនហ្នឹង ។

**សាន់ កល្យាណ និង អែម សុខឃីម**



បង្សុកូលឧទ្ទិសដល់វិញ្ញាណក្ខ័ន្ធជនរងគ្រោះនៅក្នុងល្អាងគិរីរម្យ ខេត្តបាត់ដំបង

# ឱកាសរកយុត្តិធម៌នៃឧក្រិដ្ឋកម្មខ្មែរក្រហមមិនពិបាកទេ

នៅថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៩៨ សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានទៅបំពេញទស្សនកិច្ចនៅប្រទេសថៃ ដោយបានជួបសន្ទនាជាមួយនាយករដ្ឋមន្ត្រីថៃ ឈួន លីកផៃ ។

របៀបវារៈនៃកិច្ចប្រជុំរួមមាន កិច្ចពិភាក្សាទៅលើបញ្ហាព្រំដែន ការកម្រិតព្រំដែន ជនភៀសខ្លួន ទិដ្ឋាការ និងស្ថានីយ៍វារីអគ្គិសនីស្ទឹងណាម ។ បញ្ហាទាំងនេះត្រូវបានពិភាក្សានៅក្នុងឯកសារដែលរដ្ឋាភិបាលថៃហៅថា "ការពិគ្រោះពិភាក្សាពេញអង្គ" ដែលចាប់ផ្តើមនៅម៉ោង៦ៈ១០នាទីល្ងាច នៅ"វិមានរដ្ឋាភិបាល" ទីក្រុងបាងកក ។

ប៉ុន្តែមិនខុសពីកិច្ចប្រជុំរវាងមេដឹកនាំនយោបាយនានាទេ ការពិភាក្សាដ៏សំខាន់បំផុតនៅទីក្រុងបាងកកនេះគឺធ្វើឡើងសម្ងាត់ដាច់ដោយឡែក ។ មុនពេលចាប់ផ្តើមបើកសម័យប្រជុំពេញអង្គ ដែលរួមមានគណៈប្រតិភូជាច្រើនរូបនៃភាគីទាំងសងខាង សម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន បានជួបប្រជុំដាច់ដោយឡែកជាមួយលោក ឈួន លីកផៃ ។ ភាគីទាំងពីរជួបពិភាក្សាគ្នាអស់រយៈពេល ២៥នាទីនៅក្នុង "អង្គប្រជុំជាលក្ខណៈបុគ្គល" នៅក្នុងបន្ទប់ "លូវរ៉ូម" ។

ផ្អែកតាមរបាយការណ៍ "សម្ងាត់" ពីរសន្ទឹកនៃអង្គប្រជុំរបស់រដ្ឋាភិបាលថៃ "នាយករដ្ឋមន្ត្រីថៃបានជម្រាបជូនសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថា កិច្ចប្រជុំសម្ងាត់ដាច់ដោយឡែកនឹងត្រូវការពេលវេលាប្រមាណ១០-២០នាទី ដើម្បីឲ្យសម្តេចលើកឡើងនូវបញ្ហានានាដែលលោក ឈួន លីកផៃ មិនចង់ឲ្យបញ្ចេញនៅក្នុងការពិគ្រោះពិភាក្សាពេញអង្គ" ។

បញ្ហាដែលសម្តេច ហ៊ុន សែន ចង់និយាយ គឺបញ្ហាខ្មែរក្រហម ។

ប្រទេសថៃបានគាំទ្រខ្មែរក្រហមចាប់តាំងពីខ្មែរក្រហមត្រូវបានវៀតណាមបណ្តេញចេញពីអំណាចឲ្យទៅនៅតាមព្រំដែនថៃនៅដើមឆ្នាំ១៩៧៩មកម្ល៉េះ ។ ទោះបីជានៅចំពេលប្រជុំនេះខ្មែរក្រហមបានដួលរលំស្ទើរតែទាំងស្រុងទៅហើយ (ពោលគឺ អៀង សារី បានចុះចូលនៅឆ្នាំ១៩៩៦ ប៉ុល ពត ត្រូវបានចាប់ខ្លួនដោយ តាម៉ុក នៅខែមិថុនា ឆ្នាំ១៩៩៧ ហើយស្លាប់នៅខែមេសា ឆ្នាំ១៩៩៨) ក៏ដោយ ក៏កងទ័ពថៃនៅតែបន្តផ្តល់នូវការឧបត្ថម្ភគាំទ្រដល់មេដឹកនាំខ្មែរក្រហមដែលនៅសេសសល់ ។ ប្រសិនបើសម្តេច ហ៊ុន សែន ចង់ចាប់ខ្លួនមេដឹកនាំខ្មែរក្រហមដែលនៅសល់យកទៅកាត់ទោសដូចដែលសម្តេចបានស្នើឡើងស្ទើរតែមួយឆ្នាំកន្លងមក សម្តេចចាំបាច់ត្រូវតែនិយាយជាមួយថៃទើបបាន ។

អ្វីដែលសម្តេច ហ៊ុន សែន ស្នើនៅក្នុងកិច្ចប្រជុំនោះ ធ្វើឲ្យមន្ត្រីថៃមានការតក់ស្លុតយ៉ាងខ្លាំង ។

យោងតាមឯកសារនៃកិច្ចប្រជុំនោះ សម្តេច ហ៊ុន សែន បានមានប្រសាសន៍ទៅកាន់សមភាគីរបស់សម្តេចថា ការជំនុំជម្រះក្តីមេខ្មែរក្រហមនៅតែជាបញ្ហាក្តៅគគុកនិងជាបញ្ហានយោបាយនៅឡើយ ។ សម្តេចមានការព្រួយបារម្ភថា បញ្ហានេះអាចនឹងលែងធ្វើឲ្យមានការចាប់អារម្មណ៍មកលើការបោះឆ្នោតដែលខិតជិតមកដល់ហើយនោះ ។ បញ្ហាតុលាការអន្តរជាតិមើលទៅហាក់ដូចជាស្មុគ្រស្មាញណាស់ ។ វាអាចក្លាយជាបញ្ហាចម្រូងចម្រាសមួយរវាងមហាអំណាចនានា ពីព្រោះថាចិននៅតែបន្តប្រឆាំងជំទាស់ទៅនឹងគំនិតបង្កើតតុលាការអន្តរជាតិនៅឡើយ ។ ដូច្នេះប្រសិនបើ តាម៉ុក, នួន ជា និង ខៀវ សំផន អាចបាត់ខ្លួន បញ្ហានឹងកាន់តែប្រសើរជាងនេះ ។ សហរដ្ឋអាមេរិកចង់បានខ្លួនអ្នកទាំងនេះ ប៉ុន្តែខ្ញុំមានអារម្មណ៍ថា មេដឹកនាំទាំងបីនាក់នេះនឹងមិនប្រគល់ខ្លួនឲ្យទេ ទោះជាស្ថិតក្នុងលក្ខខណ្ឌណាក៏ដោយ ។ ប្រសិនបើអ្នកទាំងបីអាចត្រូវបានលាក់បំពួនកន្លែងណាដែលគេមិនអាចរកឃើញ នោះវានឹងក្លាយជាដំណោះស្រាយមួយដ៏

ប្រពៃបំផុត» ។

សម្តេច ហ៊ុន សែន បន្តសួរអំពីបញ្ហាវិទ្យុផ្សាយសំឡេងរបស់ខ្មែរក្រហម ។ សម្តេចបានបញ្ចប់ដោយសួរបញ្ជាក់ថា «តើសហរដ្ឋអាមេរិកបានស្នើជាបញ្ជីឈ្មោះមករដ្ឋាភិបាលថៃឬទេ?» ។

លោក ឈួន លីកផៃ ដែលជាអ្នកកែទម្រង់ និងជាមេដឹកនាំម្នាក់ក្នុងចំណោមមេដឹកនាំមួយចំនួនតូចដែលគ្មានឯកសារបញ្ជាក់ថាមានការពាក់ព័ន្ធជាមួយខ្មែរក្រហមនោះ បានឆ្លើយតបវិញថា «រដ្ឋាភិបាលសហរដ្ឋអាមេរិកបានទាក់ទងជាផ្លូវការជាមួយប្រទេសថៃរួចហើយពាក់ព័ន្ធនឹងបញ្ហាខ្មែរក្រហម តាំងពីមុន ប៉ុល ពត ស្លាប់ម្ល៉េះ ។ ប៉ុន្តែសហរដ្ឋអាមេរិកមិនទាន់បានដាក់ជូននូវបញ្ជីរាយនាមរបស់ "ជនដែលគេចង់ចាប់ខ្លួន" នោះទេ ។ នាយករដ្ឋមន្ត្រីថៃបានជម្រាបជូនសម្តេច ហ៊ុន សែន ថា ប៉ុល ពត មិនរស់នៅលើទឹកដីថៃទេ ហើយប្រសិនបើ ប៉ុល ពត បានឆ្លងកាត់ព្រំដែន ប៉ុល ពត ប្រហែលជាត្រូវចាប់ខ្លួនរួចទៅហើយក្រោមច្បាប់ប្រឆាំងនឹងការជ្រៀតចូលទឹកដីថៃដោយខុសច្បាប់» ។ នាយករដ្ឋមន្ត្រីថៃ ឈួន លីកផៃ បានជម្រាបសម្តេចនាយករដ្ឋមន្ត្រី ហ៊ុន សែន ថា លោកមិនដែលបានជួបមុខមេដឹកនាំខ្មែរក្រហមណាម្នាក់ឡើយ ហើយលោកតែងតែធ្វើឲ្យមានភាពច្បាស់លាស់ក្នុងទំនាក់ទំនងជាមួយប្រទេសជិតខាង ។ ហេតុដូចនេះ ប្រសិនបើកម្ពុជាមានភស្តុតាងបង្ហាញថាមានមេដឹកនាំខ្មែរក្រហមនិងស្ថានីយ៍វិទ្យុផ្សាយសំឡេងឬអង់តែនរបស់ខ្មែរក្រហមនៅក្នុងប្រទេសថៃ លោកសូមឲ្យសម្តេច ហ៊ុន សែន បង្ហាញភស្តុតាងដើម្បីលោកចាត់វិធានការដាក់ស្តែង ។ លោកនាយករដ្ឋមន្ត្រីថៃ ឈួន លីកផៃ ក៏បានឲ្យជាយោបល់ចំពោះសម្តេច ហ៊ុន សែន ថា សូមចុចទូរស័ព្ទចូលទាក់ទងលោកដោយផ្ទាល់ក្នុងករណីមានបញ្ហានេះកើតឡើង ។

នាយករដ្ឋមន្ត្រីថៃ ឈួន លីកផៃ បានទទួលនូវគំនិតមិនល្អពីសំណាក់សមភាគីរបស់ខ្លួនហើយ ។ លោក ឈួន លីកផៃ គឺជាអ្នកប្រជាធិបតេយ្យពិតៗ ដែលប្រយុទ្ធប្រឆាំងនឹងការប្រើអំពើហិង្សានិងការបំភិតបំភ័យនៅក្នុងឆាកនយោបាយរបស់ថៃ ។ យោងតាមសម្តីរបស់មន្ត្រីជាន់ខ្ពស់ថៃម្នាក់បានឲ្យដឹងថា លោក ឈួន លីកផៃ មិនសូវពេញចិត្តចំពោះសំណើរបស់សម្តេច ហ៊ុន សែន ។ «យើងមិនយល់ច្បាស់ទាល់តែសោះថាតើសំណើនេះមានន័យយ៉ាងដូចម្តេច ។ មានអ្នកខ្លះគិតថា នេះគឺជាសំណើដែលមានលក្ខណៈបិទបាំង ចង់ឲ្យគេនិរទេសមេដឹកនាំខ្មែរក្រហមទៅប្រទេសចិន ប៉ុន្តែយើងគ្មានហេតុផលនឹងជឿជាក់ថាចិនយល់ព្រមលើគំនិតនេះឡើយ ។ អ្នកផ្សេងទៀតយល់ថា នេះគឺជាសំណើមួយចង់ឲ្យគេសម្លាប់មេដឹកនាំទាំងបីនាក់នេះ ដោយហេតុថា យើងច្បាស់ជាមិនអាចឃុំអ្នកទាំងបីទុកនៅក្នុងគុកសម្ងាត់នៅប្រទេសថៃក្នុងរយៈពេលយូរបានឡើយ ។ អាចថា សម្តេច ហ៊ុន សែន អាចធ្វើកិច្ចការនេះ ប៉ុន្តែចំណែកយើងវិញធ្វើទៅមិនរួចទេ ។ ប្រទេសថៃគឺជាប្រទេសកាន់របបប្រជាធិបតេយ្យ» ។

លោក ឈួន លីកផៃ បាននិយាយប្រាប់មកសម្តេច ហ៊ុន សែន វិញ ដោយស្តីបន្ទោសសម្តេចអំពីការធ្វើរដ្ឋប្រហារនៅខែកក្កដា ឆ្នាំ១៩៩៧ និងក្រើនរំឭកដល់សម្តេច ហ៊ុន សែន ថា នៅក្នុងប្រទេសប្រជាធិបតេយ្យ អ្នកកាន់អំណាចត្រូវផ្លាស់ប្តូរទៅតាមពេលវេលាជានិច្ច ។ «នាយករដ្ឋមន្ត្រី ឈួន លីកផៃ ក៏បានជម្រាបទៅសម្តេច ហ៊ុន សែន ថា រូបលោកផ្ទាល់មិនអាចធ្វើជានាយករដ្ឋមន្ត្រីថៃអស់មួយជីវិតទេ ហើយថាគាត់បានស្វាគមន៍សម្តេច ហ៊ុន សែន នេះក៏ដោយសារដំណើរការប្រជាធិបតេយ្យដែរ...។ លោកបានជម្រាបសម្តេចថា ពិតពលោកកំពុងតែពិនិត្យមើលយ៉ាងដិតដល់ទៅនឹងដំណើរការបោះឆ្នោតជាតិនៅកម្ពុជា និងរំពឹងថាការបោះឆ្នោតនឹងមានលក្ខណៈគួរឲ្យជឿទុកចិត្តបាន ។ ពេលនោះកម្ពុជានឹងស្ថិតនៅក្នុងជំហរមួយប្រសើរជាងមុន ដែលអាចឲ្យកម្ពុជារៀបចំខ្លួនជាស្រេចចូលក្នុងអង្គការអាស៊ាន ។ "ដូចដែលខ្ញុំបានជម្រាបជូនខាងលើមកហើយថា ខ្ញុំមិនអាចធ្វើនាយករដ្ឋមន្ត្រីអស់មួយជីវិតទេ ហើយខ្ញុំនឹងឆ្លៀតឱកាសនេះដើម្បីបង្កើនសន្តិភាពនិងវឌ្ឍនភាព ។ វាជាការសំខាន់ណាស់សម្រាប់ប្រវត្តិសាស្ត្ររបស់ប្រទេសមួយ" ។

ថ្ងៃទី៦ ខែឧសភា ឆ្នាំ១៩៩៨ មិនមែនជាលើកទី១ទេ ដែលសម្តេច ហ៊ុន សែន បានប៉ុនប៉ងដោះស្រាយបញ្ហាខ្មែរក្រហមដោយសុំឲ្យប្រទេសថៃធ្វើឲ្យមេដឹកនាំខ្មែរក្រហមបាត់ខ្លួន ។ យោងតាមបន្ទូលរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងមន្ត្រីថៃមួយចំនួន បានឲ្យដឹងថា នៅថ្ងៃទី២១ ខែកក្កដា ឆ្នាំ

១៩៩៧ សម្តេច ហ៊ុន សែន បានសុំឲ្យបុព្វាធិការីរបស់លោក ឈួន លីកផៃ គឺឧត្តមសេនីយ៍ ឆាវលីត យុង ឆៃយុទ្ធ ធ្វើកិច្ចការដូចគ្នានេះដែរ ។

បុគ្គលទាំងឡាយដែលប៉ុនប៉ងបង្កើតតុលាការកាត់ទោសខ្មែរក្រហម នឹងចាត់ទុកថ្ងៃទី ២១ កក្កដា ថាជាថ្ងៃសំខាន់បំផុត ។ គឺថ្ងៃនេះហើយដែលរដ្ឋាភិបាលកម្ពុជាស្នើជាលើកដំបូងឲ្យអង្គការសហប្រជាជាតិបង្កើតនូវតុលាការពិសេសមួយសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ។ នាយករដ្ឋមន្ត្រីទីមួយ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ និងនាយករដ្ឋមន្ត្រីទី២ សម្តេច ហ៊ុន សែន បានផ្ញើលិខិតមួយច្បាប់ទៅលោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ស្នើសុំឲ្យអង្គការសហប្រជាជាតិនាំយកជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ និង/ឬឧក្រិដ្ឋកម្មប្រឆាំងនឹងមនុស្សជាតិ នៅអំឡុងពេលនៃការកាន់កាប់របស់ខ្មែរក្រហមពីឆ្នាំ១៩៧៥ដល់ឆ្នាំ១៩៧៩ ។


CONFIDENTIAL

Working visit to Thailand of
HE Second Prime Minister Hun Sen

MAY 6, 1998

Call on H.E. Prime Minister Chuan Leekpai at the Government House

Cambodian Side: Second PM Hun Sen

Thai Side: Prime Minister Chuan Leekpai

«យើងដឹងហើយអំពីកិច្ចខិតខំប្រឹងប្រែងប្រហាក់ប្រហែលគ្នានេះទាក់ទងនឹងអំពើប្រល័យពូជសាសន៍ និងឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិនៅប្រទេសរវ៉ាន់ដានិងអតីតយូហ្គោស្លាវី ហើយសុំឲ្យមានជំនួយដូចគ្នានេះដែរចំពោះប្រទេសកម្ពុជា» ។ អង្គការសហប្រជាជាតិបានបង្កើតនូវតុលាការអន្តរជាតិសម្រាប់ប្រទេសទាំងពីរនេះ ។ សម្តេចក្រុមព្រះនិងសម្តេច ហ៊ុន សែន សុំឲ្យអង្គការសហប្រជាជាតិធ្វើកិច្ចការដូចគ្នានេះដែរសម្រាប់ប្រទេសកម្ពុជា ។

ប៉ុន្តែនៅថ្ងៃជាមួយគ្នានេះ ដែលសម្តេច ហ៊ុន សែន កំពុងជួបប្រជុំជាមួយតំណាងសិទ្ធិមនុស្សរបស់អង្គការសហប្រជាជាតិ លោក ថមម៉ាស់ ហាម៉ាប៊ឺក ពិភាក្សាអំពីការបង្កើតតុលាការខ្មែរក្រហម សម្តេច ហ៊ុន សែន ក៏បានសុំឲ្យប្រទេសថៃធ្វើឲ្យកិច្ចការនេះមិនអាចសម្រេចទៅបាន ។ តាមបន្ទូលរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ បានឲ្យដឹងថា «សម្តេច ហ៊ុនសែន បានសុំឲ្យនាយករដ្ឋមន្ត្រីថៃ ឆាវលីត យុង ឆៃយុទ្ធ អនុញ្ញាតឲ្យ ប៉ុល ពត, នួន ជា និង ខៀវ សំផន និរទេសខ្លួនទៅក្នុងប្រទេសថៃ ។ ឆាវលីត និយាយថា គាត់ចង់ធ្វើកិច្ចការនេះដែរ ប៉ុន្តែចាំគាត់ពិភាក្សាជាមួយមន្ត្រីរបស់គាត់សិន ហើយថាប្រសិនបើគាត់ធ្វើកិច្ចការនេះក៏ត្រូវតែឲ្យមានការសម្ងាត់ដែរទើបបាន» ។ (សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ក៏បាននិយាយរឿងនេះប្រាប់អ្នកសរសេរប្រវត្តិរូបរបស់សម្តេច គឺលោក ហារីស មេតា ដែលបានបោះពុម្ពចេញជាសៀវភៅរួចហើយ និងប្រហែលជាគ្មាននរណាចាប់អារម្មណ៍ផងក៏មិនដឹង នៅទំព័រទី ១២៣ នៃសៀវភៅដែលមានចំណងជើងថា «ស្តេចសង្គ្រាម») ។

មិនដូចជាលោក ឈួន ទេ លោក ឆាវលីត មានទំនាក់ទំនងយ៉ាងជិតស្និទ្ធទាំងជាមួយខ្មែរក្រហមនិងជាមួយសម្តេច ហ៊ុន សែន ។ នៅពេលស្ថិតក្នុងតំណែងយោធា លោក ឆាវលីត ទទួលខុសត្រូវផ្ទាល់ខ្លួនដើរតួនាទីជាអន្តរការីរវាងប្រទេសចិនជាមួយនឹងថ្នាក់ដឹកនាំខ្មែរក្រហមសំខាន់ៗទទួលបន្ទុកផ្នែកភស្តុភារ

និងហិរញ្ញវត្ថុ ។ ឆាវលិត បានបង្កើតនិងគ្រប់គ្រងអង្គភាពយោធាចំនួនពីរទទួលកិច្ចការដោះស្រាយជាមួយខ្មែរក្រហម ។

មន្ត្រីថៃមួយចំនួនដែលជិតដិតជាមួយលោក ឆាវលិត បញ្ជាក់ដំណើររឿងរបស់សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ។ ជំនួយការផ្ទាល់របស់លោក ឆាវលិត បាននិយាយថា “លោក ឆាវលិត បានយល់ស្រប ប៉ុន្តែគាត់គឺជាមនុស្សដែលមិនធ្លាប់និយាយថាទេជាមួយនរណាម្នាក់ឡើយ ។ គាត់មិនដែលយកគំនិតនេះទៅគិតទេ ។ គ្មានឱកាសនឹងរក្សាការសម្ងាត់នៃផែនការនេះទេ ហើយនៅខែឧសភា ឆ្នាំ១៩៩៨ យើងប្រហែលជាមិនអាចចាប់មេដឹកនាំខ្មែរក្រហមបានទេ ទោះជាយើងចង់ចាប់ក៏ដោយ ។ យើងគួរតែបានចូលទៅក្នុងទឹកដីកម្ពុជា ទើបចាប់បាន ។ យើងគ្មានហេតុផលធ្វើដូច្នេះឡើយ” ។

លោក ឆាវលិត និងប្រទេសថៃ បានសន្និដ្ឋានជាចុងក្រោយថា ប្រទេសថៃគ្មានអ្វីគួរឲ្យភ័យខ្លាចជាមួយនឹងតុលាការអន្តរជាតិខ្មែរក្រហមទេ ។ ជាក់ស្តែង សម្តេច ហ៊ុន សែន មានអារម្មណ៍ផ្សេងពីនេះ ។




ជាផ្លូវការការចរចារវាងអង្គការសហប្រជាជាតិនិងកម្ពុជាក្នុងការបង្កើតតុលាការចម្រុះសម្រាប់កាត់ទោសមេដឹកនាំខ្មែរក្រហម ត្រូវបានកាត់ផ្តាច់នៅខែកុម្ភៈកន្លងទៅ ដោយសារការមិនចុះសម្រុងគ្នាទៅលើបញ្ហាបច្ចេកទេសមួយចំនួន ។

តែតាមការពិត អង្គការសហប្រជាជាតិហាក់សម្រេចចិត្តថា អ្នកដែលខ្លួនកំពុងតែចរចាជាមួយមិនមែនសម្តែងចេញដោយសុទ្ធចិត្តឡើយ ។

បើវិនិច្ឆ័យទៅតាមការទាក់ទងរវាងសម្តេច ហ៊ុន សែន ជាមួយលោក ឈួន លីកផៃ និង ឆាវលិត អង្គការសហប្រជា-ជាតិធ្វើនេះត្រឹមត្រូវ ។ គ្មានភ័ស្តុតាងណាប្រសើរជាងភ័ស្តុតាងនៃកង្វះសុទ្ធចិត្តរបស់សម្តេច ហ៊ុន សែន ដែលប៉ុនប៉ងធ្វើឲ្យមេដឹកនាំខ្មែរក្រហមបាត់ខ្លួន ទោះជាបាត់ខ្លួនមែនទែនឬលេង១ក៏ដោយ ជាជាងបើកសវនាការជំនុំជម្រះឧក្រិដ្ឋកម្មទាំងឡាយដែលសម្តេច ហ៊ុន សែន ខ្លួនឯងធ្លាប់បានប្រៀបធៀបម្តងហើយទៅនឹងឧក្រិដ្ឋកម្មប្រព្រឹត្តដោយពួកណាហ្ស៊ីនោះ ។

រហូតដល់ខែកុម្ភៈ អស់រយៈពេល៤ឆ្នាំហើយដែលសម្តេច ហ៊ុន សែន នាំអង្គការសហប្រជាជាតិជិះលើរ៉ូល័រកូស្ទ័រ (ចូលការពិភាក្សាដែលចេះតែប្រែប្រួលរហូត) ដែលហាក់បីដូចជាធ្វើដំណើរមិនចេះឈប់សោះ ។ ម្តងសម្តេចមានប្រសាសន៍ថាសម្តេចចង់ឲ្យមានតុលាការ ម្តងសម្តេចប្រកាសថាចង់“កប់អតីតកាល” ។ ដូច្នេះហើយបានជា នៅក្នុងការជួបជុំគ្នាចំថ្ងៃបុណ្យណូអែលឆ្នាំ១៩៩៨ ជាមួយ នួន ជា និង ខៀវ សំផន សម្តេចចាត់ទុកអ្នកទាំងពីរនេះដូចជាវីរជន មិនមែនជាឧក្រិដ្ឋជនទេ ។ សម្តេចមានប្រសាសន៍ថា គ្មានមេដឹកនាំខ្មែរក្រហមណាមួយនឹងត្រូវ

រារាំងមិនឲ្យចូលខ្លួននៅក្នុងតុលាការទេ ប៉ុន្តែក្រោយមកទៀត សម្តេចមានប្រសាសន៍ថា មិនត្រូវចាប់ខ្លួន អៀង សារី ទេ ។ សម្តេចមានប្រសាសន៍ថា សម្តេចចង់បាននូវការជំនុំជម្រះក្តីដែលមានកម្រិតអន្តរជាតិ ប៉ុន្តែក្រោយមកបដិសេធមិនព្រមបញ្ចូលនូវបញ្ញត្តិចាំបាច់នានានៅក្នុងច្បាប់ដើម្បីឲ្យមានចៅក្រមព្រះរាជអាជ្ញា និងទីប្រឹក្សាច្បាប់ឯករាជ្យ ។ សម្តេចបានគំរាមម្តងហើយម្តងទៀតថានឹងឈប់ចរចា ប៉ុន្តែបានចូលខ្លួនវិញក្រោយពីទាញបាននូវសម្បទានពីអង្គការសហប្រជាជាតិ ឬអន្តរការីជនជាតិអាមេរិកាំងដូចជាលោក ចន កែរី ជាដើម ។ មានន័យថាសម្តេចតាមរករឿងមិនចេះចប់មិនចេះហើយទាល់តែសោះ ។

មើលទៅប្រហែលជាថា សញ្ញាដ៏ច្បាស់បំផុតនៃការរារាំងគឺការអះអាងជាញឹកញយរបស់សម្តេចដែលថា សង្គ្រាមស៊ីវិលនឹងកើតឡើងសាជាថ្មីប្រសិនបើមេដឹកនាំខ្មែរក្រហមត្រូវចាប់ខ្លួន ។ មន្ត្រីយោធានៅក្នុងជួរកងទ័ពនិងគណបក្សប្រជាជន បដិសេធចោលនូវហេតុផលនេះ ដោយនិយាយថា ខ្មែរក្រហមមិនអាចផ្តុំគ្នាសាជាថ្មីដើម្បីតស៊ូទៀតទេ ។ ខ្មែរក្រហមបានស្លាប់យូរណាស់ហើយ លើកលែងតែមានករណីណាមួយដែលចាំបាច់ត្រូវប្រោះខ្មែរក្រហមឲ្យរស់ឡើងវិញដើម្បីបម្រើគោលបំណងនយោបាយ ។

ចុងបញ្ចប់ហាក់ដូចជាថា យុទ្ធសាស្ត្ររបស់សម្តេច ហ៊ុន សែន ចេះតែបន្តពន្យារពេល ហើយទទួលបានជោគជ័យ (រហូតមកដល់សព្វថ្ងៃនេះ) ប្រហែលជាសង្ឃឹមថា មេដឹកនាំខ្មែរក្រហមនឹងស្លាប់ដោយសារអាយុកាលមុនពេលប្រឈមមុខនឹងការកាត់ទោស ។ ជាក់ស្តែង មេដឹកនាំខ្មែរក្រហមម្នាក់បានស្លាប់បាត់ទៅហើយ គឺ តា ពក ។ ការពន្យារពេលស្ទើរតែមួយឆ្នាំ នៅក្នុងការអនុម័តជាលើកចុងក្រោយនូវច្បាប់ក្នុងស្រុកដែលជាការចាំបាច់ក្នុងការបង្កើតអង្គជំនុំជម្រះនោះ ហាក់ដូចជាផ្នែកមួយនៃយុទ្ធសាស្ត្ររបស់សម្តេច ហ៊ុន សែន ដែរ ។

ឥឡូវនេះទំនងជាថា សម្តេច ហ៊ុន សែន មិនចង់បាន "ការកាត់ទោស" ខ្មែរក្រហមទេ ដែលនេះមិនមែនក្នុងន័យថា ពាក្យ "កាត់ទោស" នេះ ត្រូវបានយល់ពីសំណាក់អ្នកដែលមានធ្លាប់ដឹងច្បាស់អំពីតុលាការឯករាជ្យនិងមិនលម្អៀងនោះទេ ។ ក្រោយពីការតស៊ូស៊ិតស្វាញអស់ជាច្រើនឆ្នាំកន្លងមក សម្តេចក្លាយជាមេដឹកនាំកម្ពុជាដែលគ្មានដម្លោះទៀត ។ ប្រទេសចិនដែលជាមិត្តថ្មីរបស់សម្តេច បានបដិសេធយ៉ាងដាច់អហង្ការទៅលើបញ្ហាបង្កើតតុលាការដែលមិនគ្រប់គ្រងតាមលក្ខណៈនយោបាយ ។ ជាក់ស្តែង សម្តេចបានប្រមើលថា ការជំនុំជម្រះក្តីពិតប្រាកដដែលមិនអាចទស្សន៍ទាយបាននិងមានលក្ខណៈរញ៉េរញ៉ៃនោះមិនមែនជាផលប្រយោជន៍នយោបាយរបស់សម្តេចឡើយ ។

ចុះហេតុអ្វីបានជាសម្តេច ហ៊ុន សែន ចុះហត្ថលេខាលើសំណើទៅកាន់អង្គការសហប្រជាជាតិ ចុះថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ ធ្វើអ្វី? ចម្លើយដែលទំនងជាត្រឹមត្រូវគឺថា សម្តេច ហ៊ុន សែន ចាត់ទុកថាតុលាការគឺជាអាវុធប្រឆាំងនឹងខ្មាំងនយោបាយរបស់សម្តេច ។ នៅថ្ងៃទី២១ ខែមិថុនា ឆ្នាំ១៩៩៧ ប្រហែលជាសម្តេចឆ្ងើយគេចពីអ្វីដែលខ្លួនបានសន្យាពីមុនមកក៏មិនដឹង ។ ជម្រើសទីមួយរបស់សម្តេចគឺឲ្យប្រទេសថៃធ្វើឲ្យមេខ្មែរក្រហមបាត់ខ្លួន ដូច្នេះហើយបានជាសម្តេចស្នើទៅ ឆាវលិត ។ ប្រសិនបើកិច្ចការនេះមិនអាចទៅរួច សម្តេចនឹងប្រើប្រាស់តុលាការដែលរៀបចំដោយអង្គការសហប្រជាជាតិ ជាអាវុធមួយក្នុងចំណោមអាវុធនានាក្នុងការកម្ទេចខ្មែរក្រហមដែលជាចលនានយោបាយ ហើយវាមានគ្រោះថ្នាក់ណាស់ប្រសិនបើសម្តេចមិនបានចុះហត្ថលេខា ។ សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ មានអំណរសាទរណាស់អំពីការចាប់ខ្លួន ប៉ុល ពត ប្រគល់ទៅឲ្យសហគមន៍អន្តរជាតិ ។ ប្រសិនបើសម្តេចក្រុមព្រះបានសម្រេចកិច្ចការនេះក្នុងករណីមានការជំទាស់ពីសម្តេច ហ៊ុន សែន នោះ សម្តេចក្រុមព្រះនឹងប្រាកដជាឈ្នះឆ្នោតនៅអាណត្តិបន្ទាប់ ។ សម្តេចក្រុមព្រះនឹងក្លាយជាមនុស្សដែលទទួលបានការចូលចិត្តជាងគេនៅក្នុងសហគមន៍អន្តរជាតិ ។

ប៉ុន្តែពីរសប្តាហ៍បន្ទាប់មក សម្តេចក្រុមព្រះ នរោត្តម រណឫទ្ធិ ត្រូវនិរទេសខ្លួន ចំណែកគណបក្សហ៊្វុនស៊ិនប៉ិចត្រូវកម្ទេច អាជីពនយោបាយរបស់សម្តេចក្រុមព្រះត្រូវគំរាមកំហែង ។

ក្រោមការដឹកនាំពីសំណាក់ប្រទេសជប៉ុន សហរដ្ឋអាមេរិក បារាំង និងអូស្ត្រាលី អង្គការសហប្រជាជាតិត្រឡប់មកប្រទេសកម្ពុជាម្តងទៀតក្រោមសម្ពាធមួយឲ្យធ្វើយ៉ាងណាបញ្ចប់ឲ្យបាននូវកិច្ចព្រមព្រៀងជាមួយសម្តេច ហ៊ុន សែន ទៅលើការ

បង្កើត "តុលាការចម្រុះ" មួយដើម្បីកាត់ទោសមេដឹកនាំខ្មែរក្រហម ។ ឥឡូវនេះជប៉ុនកំពុងតែរៀបចំដំណោះស្រាយមួយសម្រាប់ចូលរួមនៅក្នុងមហាសន្និបាតអង្គការសហប្រជាជាតិនៅខែតុលា ដែលដំណោះស្រាយនេះនឹងស្នើឲ្យដំរុញឲ្យលោក កូហ្វី អាណាន់ បើកការចរចាសាជាថ្មីជាមួយរដ្ឋាភិបាលកម្ពុជា ។ ប្រសិនបើគ្មានការផ្លាស់ប្តូររូបមន្ត "មតិភាគច្រើនលើសលប់" ដើម្បី ទប់ស្កាត់ការសម្របសម្រួលតាមផ្លូវនយោបាយទេនោះ ឬគ្មានសញ្ញាប្រកបដោយសុទ្ធចិត្តពីសំណាក់សម្តេច ហ៊ុន សែន ទេ ដំណោះស្រាយនេះនឹងមានបញ្ហាមិនខាន ។

សុទ្ធចិត្តគឺជាបញ្ហាដ៏សំខាន់នៅក្នុងកិច្ចខិតខំប្រឹងប្រែងបន្តទៅទៀត ដើម្បីបង្កើតតុលាការមួយ ។ ការយល់ស្របទៅតាមរូបមន្តឲ្យមានចៅក្រមខ្មែរភាគច្រើន និងបោះបង់ចោលនូវការទាមទារសុំឲ្យមានព្រះរាជអាជ្ញាឯករាជ្យនោះ មានន័យថា អង្គការសហប្រជាជាតិបានប្រគល់ការគ្រប់គ្រងរបស់ខ្លួនទៅក្នុងដំណើរការជំនុំជម្រះក្តីទៅតាមប្រព័ន្ធនយោបាយរបស់កម្ពុជារួចស្រេចទៅហើយ ។ ប្រសិនបើតុលាការចម្រុះដូចដែលបានប្រមើលពីមុននោះត្រូវបានបង្កើតឥឡូវនេះមែន អង្គការសហប្រជាជាតិនឹងគ្មានផ្លូវគ្រប់គ្រងទៅលើអន្តរាគមន៍របស់សម្តេច ហ៊ុន សែន ទៅលើចៅក្រមព្រះរាជអាជ្ញានិងមេធាវីការពារចុងចោទឡើយ ។ អង្គការសហប្រជាជាតិដឹងច្បាស់ណាស់ថា គ្មានចៅក្រមឬព្រះរាជអាជ្ញាខ្មែរណាម្នាក់អាចចេញសាលក្រម ឬចេញដីកាចោទប្រកាន់ដោយគ្មានការយល់ព្រមពីសម្តេច ហ៊ុន សែន នោះទេ ។

ឥឡូវនេះ យើងដឹងហើយនូវអន្តរាគមន៍របស់សម្តេច ហ៊ុន សែន ជាមួយនឹងប្រទេសថៃ នៅខែមិថុនា ឆ្នាំ១៩៩៧ និងនៅខែឧសភា ឆ្នាំ១៩៩៨ ។ គ្មានផ្លូវនឹងដឹងថាមានដំណោះស្រាយប៉ុន្មានដែលសម្តេចបានពិភាក្សាជាមួយប្រទេសផ្សេងៗទៀតឡើយ ។ រដ្ឋជាច្រើនដែលបានស្ម័គ្រចិត្តផ្តល់នូវចៅក្រមដែលនឹងត្រូវធ្វើជារបងការពារការប៉ុនប៉ងជ្រៀតជ្រែកចូលបូរណភាពរបស់ដំណើរការជំនុំជម្រះក្តី បានសម្តែងនូវឆន្ទៈកាលពីអតីតកាលក្នុងការដោះស្រាយជាមួយរដ្ឋាភិបាលកម្ពុជា (ដូចជាប្រទេសចិនដែលមានការចាប់អារម្មណ៍ខ្លាំងចំពោះលទ្ធផលចុងក្រោយចេញពីអង្គជំនុំជម្រះ និងដែលបានបញ្ចេញនូវឆន្ទៈចង់ផ្តល់នូវចៅក្រមមកឲ្យតុលាការចម្រុះ) ។

ដោយមិនគាបសង្កត់ឲ្យអង្គការសហប្រជាជាតិផ្តល់នូវសម្បទានថែមទៀត វាដល់ពេលដែលជប៉ុន សហរដ្ឋអាមេរិក បារាំង និងអូស្ត្រាលី ប្រាប់ទៅសម្តេច ហ៊ុន សែន ឲ្យបង្ហាញឲ្យច្បាស់ថាសម្តេចពិតជាប្រាកដប្រជាទៅលើបញ្ហានេះ ។ វិធីល្អបំផុតសម្រាប់ធ្វើកិច្ចការនេះគឺសុំឲ្យសម្តេចអនុញ្ញាតឲ្យតុលាការកម្ពុជាប្រើច្បាប់កម្ពុជាក្នុងការស៊ើបអង្កេត ចោទប្រកាន់ និងចាប់ខ្លួន មេដឹកនាំខ្មែរក្រហមទាំងអស់ដែលទាក់ទិននឹងភ័ស្តុតាងដែលមានស្រាប់ ។ ជាការច្បាស់ណាស់ បុគ្គលដែលនឹងមានឈ្មោះក្នុងបញ្ជីមានដូចជា នួន ជា, អៀង សារី និង ខៀវ សំផន ។

ប្រសិនបើសម្តេច ហ៊ុន សែន ពិតជាចង់បានយុត្តិធម៌សម្រាប់ប្រជាជនកម្ពុជា សម្តេចនឹងធ្វើអ្វីមួយឲ្យឆាប់រហ័សដើម្បីធានាថា មេដឹកនាំកម្ពុជាទាំងបីនាក់ដែលបង្កការឈឺចាប់ទុក្ខវេទនាមកលើប្រជាជនកម្ពុជា ពិតជាត្រូវចូលគុកយ៉ាងពិតប្រាកដ ។ ទង្វើនេះនឹងក្លាយជាសញ្ញាមួយច្បាស់បញ្ជាក់ពីសុទ្ធចិត្តរបស់សម្តេច ដែលអាចធ្វើឲ្យអ្នកដែលចេះតែសង្ស័យមានជំនឿថា ទីបំផុតសម្តេច ហ៊ុន សែន ពិតជាប្រាកដប្រជាក្នុងការបញ្ចប់សុបិនអាក្រក់ដែលញាំញីប្រទេសកម្ពុជារហូតមកដល់បច្ចុប្បន្ន ។ មានតែពេលនោះទេដែលអង្គការសហប្រជាជាតិអាចជឿទុកចិត្តថា ការចូលរួមរបស់ខ្លួននៅក្នុងតុលាការនេះអាចជួយឲ្យប្រជាជនកម្ពុជារកឃើញថា តើសម័យដ៏យង់ឃ្នងនោះកើតឡើងដោយរបៀបណា ហើយមកពីហេតុអ្វី ។

**ប្រេជ អាដាម**

## ពាក្យស្លោកខ្មែរក្រហម

◆ **ប្រយុទ្ធរវាងវណ្ណៈ មានវណ្ណៈខ្លះទទួលជ័យជម្នះ ហើយវណ្ណៈខ្លះទៀតត្រូវវិនាស នេះជាប្រវត្តិសាស្ត្រ។**

◆ **អាវុធជាកត្តាមួយសំខាន់ តែមិនមែនជាកត្តាឱ្យឈ្នះសង្គ្រាមទេ កត្តាសម្រេចធំបង្អស់គឺមនុស្ស មិនមែនជាសំភារៈម្យ៉ាងទេ។**

◆ **បដិវត្តជាសង្គ្រាមប្រជាជន មានតែការបំផុសបំផុលប្រជាជនទេ ទើបអាចធ្វើសង្គ្រាមបាន។**

*(កំណត់ហេតុសិក្សារបស់សមមិត្ត ញ៉ុក សារុន)*

# សុន្ទរកថា
# របស់ឯកឧត្តម សុខ អាន
## ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី
## ក្នុងឱកាសបិទសន្និសីទតាមដានរបស់ជំនាញការស្តីពីតុលាការព្រហ្មទណ្ឌអន្តរជាតិ
## (ភ្នំពេញ ថ្ងៃទី១០ ខែតុលា ឆ្នាំ២០០២)

ឯកឧត្តម លោកជំទាវ លោក លោកស្រី!

ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ខ្ញុំសូមស្វាគមន៍យ៉ាងកក់ក្តៅ ចំពោះវាគ្មិននិងអ្នកចូលរួមទាំងអស់ពីបណ្តាប្រទេសប្រមាណជា ២០លើពិភពលោក ដែលបានជ្រើសរើសប្រទេសកម្ពុជាសម្រាប់ទទួលរៀបចំ ដែលឯកឧត្តម លោកជំទាវ លោក លោកស្រី បានចូលរួមក្នុងការពិភាក្សាយ៉ាងស៊ីជម្រៅរយៈពេលពីរថ្ងៃ ពាក់ព័ន្ធនឹងការបង្កើតនិងកិច្ចដំណើរការតុលាការព្រហ្មទណ្ឌអន្តរជាតិ ។

ឆ្នាំ២០០២គឺជាដំណាក់កាលរបត់ប្រវត្តិសាស្ត្រមួយដែលប្រជាជននៅក្នុងពិភពលោកបានសម្រេចចិត្តជាលើកដំបូង ក្នុងការបង្កើតឲ្យមានតុលាការអចិន្ត្រៃយ៍មួយដើម្បីកាត់ទោស និងផ្តន្ទាទោសទៅលើឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតរបស់មនុស្សជាតិ គឺ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ឧក្រិដ្ឋកម្មប្រឆាំងមនុស្សជាតិ និងឧក្រិដ្ឋកម្មសង្គ្រាម ហើយគេសង្ឃឹមថាតុលាការនេះនឹងអនុវត្តយុត្តាធិការរបស់ខ្លួនលើឧក្រិដ្ឋកម្មឈ្លានពានផងដែរនៅក្នុងពេលអនាគត ។ ឆ្លងកាត់រយៈពេលជាងកន្លះសតវត្សរ៍ទើបប្រជាជាតិលើពិភពលោកបានប្រមូលផ្តុំសេចក្តីក្លាហាន រួបរួមគ្នាដើម្បីប្រែក្លាយសំណើបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិឲ្យទៅជាសន្ធិសញ្ញាមួយនៅឆ្នាំ១៩៩៨ ហើយដែលបួនឆ្នាំក្រោយមកទៀត លក្ខន្តិកៈក្រុងរ៉ូម បានក្លាយជាតថៈភាពនៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២ ។ យើងសូមសម្តែងនូវការគោរពនិងស្ញប់ស្ញែងចំពោះមនុស្សរាប់សែននាក់ដែលឯកឧត្តមអស់លោកមួយចំនួនមានវត្តមាននៅទីនេះ ហើយដែលបានរួមចំណែកក្នុងកិច្ចខិតខំប្រឹងប្រែងរួមគ្នាបង្កើតឲ្យមានតុលាការនេះឡើង ។

ដូចដែលសម្តេចនាយករដ្ឋមន្ត្រីបានមានប្រសាសន៍នៅក្នុងសុន្ទរកថាបើកថា ប្រទេសយើងខ្ញុំដែលមានទំហំតូច និងមានប្រជាជនប្រមាណតែ១៣លាននាក់នោះ មានមោទកភាពដោយបានស្ថិតក្នុងចំណោមប្រទេសដែលបានផ្តល់សច្ចាប័នទាំង៦០ ដើម្បីបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ឆ្លៀតឱកាសនេះ សម្តេច ហ៊ុន សែន មានប្រសាសន៍ថា កម្ពុជាត្រៀមខ្លួនរួចជាស្រេច ដើម្បីដើរតួនាទីយ៉ាងសកម្មនិងទទួលខុសត្រូវក្នុងការបង្កើតនិងដំណើរការតុលាការព្រហ្មទណ្ឌអន្តរជាតិ ដូចដែលយើងបានធ្វើនៅក្នុងយុទ្ធនាការដើម្បីទទួលបាននូវសច្ចាប័នគ្រប់ចំនួនសម្រាប់បង្កើតតុលាការនេះ ។ ជាពិសេស កម្ពុជាបានត្រៀមផ្តល់ធនធានមនុស្សតាមការចាំបាច់ ហើយយើងរីករាយនឹងពិភាក្សាអំពីតំណែងណាមួយដ៏សមស្របបំផុតដែលកម្ពុជាគួរស្នើសុំសម្រាប់បេក្ខជនកម្ពុជា ។

ទន្ទឹមនឹងមានក្តីមោទកនិងកិត្តិយសដែលបានស្ថិតនៅក្នុងចំណោមសមាជិកស្ថាបនិកនៃតុលាការព្រហ្មទណ្ឌអន្តរជាតិ ដែលមានប្រទេសតែបីប៉ុណ្ណោះនៅអាស៊ី ហើយកម្ពុជាគឺជាប្រទេសតែមួយគត់នៅអាស៊ី-អាគ្នេយ៍ និងដែលបានរៀបចំសន្និសីទដ៏សំខាន់នេះ ប្រជាជនកម្ពុជាក៏មានហេតុផលផ្សេងពីនេះមួយចំនួនទៀត ក្នុងការដើរតួនាទីយ៉ាងសកម្មតុលាការព្រហ្មទណ្ឌអន្តរជាតិ ។ ហេតុផលសំខាន់បំផុតមួយគឺ ប្រជាជនកម្ពុជានៅតែទទួលរងនូវមុខរបួសនិងការឈឺចាប់ដែលបណ្តាលមកពីឧក្រិដ្ឋកម្មគ្រប់ប្រភេទ ជាអាទិ៍ ឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ដែលជាកម្មវត្ថុរបស់តុលាការព្រហ្មទណ្ឌអន្តរជាតិ ។ យើងនៅតែដក់ជាប់នូវភាពល្វីងជូរចត់ ហើយសូម្បីតែសង្គមកម្ពុជាក៏នៅតែទទួលរងនូវផលវិបាកទាំងនេះ ក្នុងខណៈដែលយើងប្រឹងប្រែងដើម្បីកសាងនិងស្តារឡើងវិញនូវសង្គមជាតិទាំងមូលអស់

រយៈពេល២៣ឆ្នាំក្រោយនេះ ។

នៅពេលនេះ យើងនៅតែគិតគូរយ៉ាងខ្លាំងចំពោះមរតកឧក្រិដ្ឋកម្មទាំងនេះ ។ ក្នុងរយៈពេលជាងពីរសប្តាហ៍កន្លងទៅនេះ ប្រជាជនកម្ពុជាបានប្រារព្ធពិធីបុណ្យភ្ជុំបិណ្ឌដែលមានអត្ថន័យជាការរំឭកនិងគោរពដល់វិញ្ញាណក្ខ័ន្ធរបស់អ្នកដែលបានចែកឋានទៅ ។ គណៈប្រតិភូអន្តរជាតិខ្លះបានទៅទស្សនាសារមន្ទីរប្រល័យពូជសាសន៍ទួលស្លែង ហេតុនេះពិតជាអាចយល់ដឹងបានកាន់តែច្បាស់ពីប្រវត្តិសាស្ត្រដ៏ជូរចត់របស់កម្ពុជា ។ ថ្ងៃនេះ តាមរយៈវត្តមានរបស់យើងនៅទីនេះ យើងចាត់ទុកថាយើងមិនដែលបំភ្លេចពួកគេឡើយ ហើយយើងនឹងបូជាឲ្យអស់នូវកម្លាំងកាយចិត្ត ដើម្បីធានាថា កូនចៅជំនាន់ក្រោយនឹងមិនទទួលរងទុក្ខដូចអតីតកាលឡើយ ។

ក្រោយពីបានងើបពីរបបប្រល័យពូជសាសន៍នៅឆ្នាំ ១៩៧៩ ប្រទេសកម្ពុជាត្រូវខិតខំប្រឹងប្រែងរកមធ្យោបាយដើម្បីដោះស្រាយជាមួយលទ្ធផលនេះ ។ យើងបានចាប់កសាងប្រទេសរបស់យើងពីបាតដៃទទេ ។ យើងបានធ្វើសមាហរណកម្មកងកម្លាំងនិងភាគីជម្លោះទាំងឡាយ ហើយសម្រេចបាននូវការបង្រួបបង្រួមជាតិ និងនាំមកនូវសន្តិភាពពេញលេញជាលើកដំបូងក្នុងប្រវត្តិសាស្ត្រសហសម័យរបស់យើង ពោលគឺក្នុងរយៈពេលជាង៣០ឆ្នាំក្រោយនេះ ។ នៅពេលជាមួយគ្នានេះដែរ យើងបាននិងកំពុងស្វែងរកការទទួលខុសត្រូវតាមច្បាប់សម្រាប់ឧក្រិដ្ឋកម្មធ្ងន់ធ្ងរបំផុត ។ ក្រោយពីបានផ្តួលរំលំរបបខ្មែរក្រហម រដ្ឋាភិបាលបានចាប់ដំណើរការតុលាការមួយ ដែលបានកាត់ទោសនិងផ្តន្ទាទោសមេដឹកនាំពីររូប ពីបទឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ ។ អ្នកច្បាប់អន្តរជាតិបានសហការជាមួយយើងនៅក្នុងកិច្ចខិតខំប្រឹងប្រែងលើកដំបូងនេះ ដើម្បីកាត់ទោសឧក្រិដ្ឋកម្មប្រល័យពូជសាសន៍តាមផ្លូវច្បាប់ ។ កិច្ចខិតខំប្រឹងប្រែងនេះបានបន្តឥតឈប់ឈរ ។

ទើបតែជាងមួយឆ្នាំប៉ុណ្ណោះ ដែលសភាជាតិបានអនុម័តច្បាប់ស្តីពីការបង្កើតអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងតុលាការកម្ពុជា ដើម្បីកាត់សេចក្តីឧក្រិដ្ឋកម្មដែលបានប្រព្រឹត្តឡើងក្នុងរយៈកាលនៃកម្ពុជាប្រជាធិបតេយ្យ ដើម្បី«វិនិច្ឆ័យទោសមេដឹកនាំជាន់ខ្ពស់កម្ពុជាប្រជាធិបតេយ្យ និងជនទាំងឡាយដែលទទួលខុសត្រូវខ្ពស់បំផុតចំពោះឧក្រិដ្ឋកម្ម ការរំលោភបំពានធ្ងន់ធ្ងរលើច្បាប់ព្រហ្មទណ្ឌកម្ពុជា ច្បាប់មនុស្សធម៌អន្តរជាតិ ច្បាប់និងទំនៀមទម្លាប់អន្តរជាតិ ព្រមទាំងរំលោភទៅលើអនុសញ្ញាអន្តរជាតិដែលកម្ពុជាបានទទួលស្គាល់ ហើយដែលបានប្រព្រឹត្តក្នុងអំឡុងថ្ងៃ ១៧ ខែមេសា ឆ្នាំ១៩៧៥ ដល់ថ្ងៃទី៦ ខែមករា ឆ្នាំ ១៩៧៩» ។ ច្បាប់នេះជាសមិទ្ធផលនៃកិច្ចខិតខំប្រឹងប្រែងរួមរបស់កម្ពុជានិងទីប្រឹក្សាច្បាប់អង្គការសហប្រជាជាតិ និងពីបណ្តាប្រទេសផ្សេងទៀត ដែលរួមមាន ប្រទេសបារាំង អាមេរិក រុស្ស៊ី ឥណ្ឌា និងអូស្ត្រាលី ។ នេះគឺជាលើកទីមួយក្នុងប្រវត្តិសាស្ត្ររបស់ពិភពលោក ដែលបានបង្កើតអង្គជំនុំជម្រះវិសាមញ្ញក្នុងប្រព័ន្ធតុលាការជាតិ ហើយដែលរួមមានចៅក្រម ព្រះរាជអាជ្ញា និងបុគ្គលិក បរទេសនិងកម្ពុជា និងដែលបានចែងយ៉ាងច្បាស់លាស់ពីរូបមន្តដើម្បីធានាឲ្យមានតុល្យភាពរវាងអ្នកទាំងនោះ ដោយឈរលើគោលការណ៍គោរពអធិបតេយ្យភាពជាតិ និងប្រកាន់ខ្ជាប់នូវបទដ្ឋានយុត្តិធម៌ដែលទទួលស្គាល់ជាអន្តរជាតិ ក្នុងក្របខ័ណ្ឌនៃសន្តិភាព ស្ថិរភាពនយោបាយ សណ្តាប់ធ្នាប់សាធារណៈ និងការបង្រួបបង្រួមជាតិ ។

កម្ពុជាជារដ្ឋសមាជិកដែលមានកាតព្វកិច្ចចម្បងក្នុងការផ្តន្ទាទោសឧក្រិដ្ឋកម្មទាំងនេះ ស្របតាមមាត្រាទី៦នៃអនុសញ្ញាប្រឆាំងអំពើប្រល័យពូជសាសន៍ ហើយកម្ពុជាមានបំណងរួមសហការជាមួយសហគមន៍អន្តរជាតិ ដើម្បីធានាថាការកាត់ទោសនេះឆ្លើយតបទៅនឹងបទដ្ឋានដែលទទួលស្គាល់ជាអន្តរជាតិ ។

ក្នុងការបង្កើតអង្គជំនុំជំរះវិសាមញ្ញ យើងបានខិតខំយ៉ាងខ្លាំង ធ្វើយ៉ាងណាឲ្យស្របទៅនឹងគោលការណ៍បំពេញបន្ថែមដែលបានចែងក្នុងបុព្វកថានៃលក្ខន្តិកៈទីក្រុងរ៉ូម ដែលបានបញ្ចូលនូវគោលការណ៍អធិបតេយ្យជាតិនិងសកលភាព ។ គោលការណ៍បំពេញបន្ថែមក៏មានន័យថា តុលាការនេះគួរមានតុល្យភាពរវាងភូមិសាស្ត្រនិងយេនឌ័រ ហើយគួរតំណាងឲ្យប្រព័ន្ធច្បាប់ផ្សេងៗនៅក្នុងពិភពលោកផងដែរ ដោយរួមទាំងប្រព័ន្ធច្បាប់នៅអាស៊ី និងប៉ាស៊ីហ្វិក នៅសម័យបុរាណនិងមុនសម័យអាណានិគម ។

រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជាធានាពីសិទ្ធិមនុស្ស

ហើយមាត្រា៣១ បានចែងយ៉ាងច្បាស់ពីធម្មនុញ្ញរបស់អង្គការសហប្រជាជាតិ និងសេចក្តីថ្លែងការណ៍ជាសាកលនៃសិទ្ធិមនុស្ស និងរាល់សន្ធិសញ្ញានិងអនុសញ្ញាទាំងឡាយដែលពាក់ព័ន្ធនឹងសិទ្ធិមនុស្ស និង សិទ្ធរបស់ស្ត្រីនិងកុមារ ។ ហើយមាត្រា៣២បានចែងយ៉ាងច្បាស់ពីការហាមប្រាមមិនឲ្យមានទោសប្រហារជីវិត ។ ក្នុងរយៈកាល១០ឆ្នាំកន្លងមកនេះ កម្ពុជាកំពុងកែប្រែប្រព័ន្ធច្បាប់និងយុត្តិធម៌របស់ខ្លួន ដោយរួមមានទាំងការកែប្រែក្រមច្បាប់មូលដ្ឋាន និងបង្កើនធនធានមនុស្ស ដោយរួមមានទាំងការបង្កើតសាលាភូមិន្ទចៅក្រម ។

ឯកឧត្តម លោកជំទាវ លោក លោកស្រី!

ដោយបានចូលជាធរមាននៅថ្ងៃទី១ ខែកក្កដា ឆ្នាំ២០០២ តុលាការព្រហ្មទណ្ឌអន្តរជាតិគឺជាតុលាការមួយដែលមានចរិតលក្ខណៈអចិន្ត្រៃយ៍ មិនមានប្រតិសកម្ម ហើយនិងមានទិដ្ឋភាពបង្ការផងដែរ ។ យោងតាមលក្ខណៈសម្បត្តិដូចបានរៀបរាប់ខាងលើ តុលាការព្រហ្មទណ្ឌអន្តរជាតិអចិន្ត្រៃយ៍នេះគឺមានចរិតខុសប្លែកទាំងស្រុងពីតុលាការពិសេសនៅក្រុង Nuremberg និងតូក្យូ ដែលបានបង្កើតឡើងក្រោយសង្គ្រាមលោកលើកទី២ ហើយក៏ខុសប្លែកផងដែរពីតុលាការព្រហ្មទណ្ឌអន្តរជាតិនាទសវត្សរ៍ឆ្នាំ១៩៩០ សម្រាប់អតីតប្រទេសយូហ្គោស្លាវីនិងរ៉ាន់ដា ហើយក៏ខុសប្លែកពីអង្គជំនុំជម្រះវិសាមញ្ញនៅក្នុងប្រព័ន្ធតុលាការកម្ពុជាដែលបានចែងពីការចូលរួមរបស់បរទេស ។

តុលាការទាំងនេះគឺជាតុលាការពិសេសដែលត្រូវបានបង្កើតឡើងតែនៅក្រោយពីមានការសម្លាប់រង្គាលរួចហើយប៉ុណ្ណោះ ។ ក្នុងអំឡុងពេលជាង៥០ឆ្នាំឆ្លងកាត់សង្គ្រាមនិងជម្លោះប្រដាប់អាវុធជាង២៥០ បានធ្វើឲ្យរងគ្រោះប្រជាជនរាប់លាននាក់ ។ ការចូលជាធរមាននៃលក្ខន្តិកៈក្រុងរ៉ូមគឺជាការវិវត្តជាវិជ្ជមានមួយក្នុងការគោរពសិទ្ធិមនុស្ស និងលើកកម្ពស់ការអនុវត្តច្បាប់មនុស្សធម៌អន្តរជាតិ ។ ហេតុនេះ យើងអាចនិយាយបានថា ជាមួយនឹងឧបករណ៍យោធាដែលអាចអនុវត្តតាមរយៈសេចក្តីសម្រេចចិត្តរបស់ក្រុមប្រឹក្សាសន្តិសុខអង្គការសហប្រជាជាតិ សហគមន៍អន្តរជាតិមានឧបករណ៍ច្បាប់ថ្មីមួយទៀត តាមរយៈតុលាការឧក្រិដ្ឋកម្មអន្តរជាតិនេះ ហើយក្នុងពេលអនាគត ឧបករណ៍ថ្មីនេះនឹងក្លាយទៅជាអាវុធយុទ្ធភណ្ឌដ៏មានប្រសិទ្ធភាព ពោលគឺ «អាវុធច្បាប់» ។

តាមការចូលរួមរបស់ព្រះរាជាណាចក្រកម្ពុជាជារដ្ឋសមាជិកចំពោះលក្ខន្តិកៈក្រុងរ៉ូម និងការផ្តល់សច្ចាប័នរបស់កម្ពុជា សម្តែងឲ្យឃើញនូវឆន្ទៈយ៉ាងមុតមាំដើម្បីរួមចំណែកដល់ការគោរពសិទ្ធិមនុស្ស និងលើកកម្ពស់ច្បាប់មនុស្សធម៌អន្តរជាតិ ស្របតាមគោលការណ៍ធំៗដែលមានចែងក្នុងរដ្ឋធម្មនុញ្ញរបស់ប្រទេស ។

ចាប់ពីថ្ងៃនេះតទៅ ក្រោយពេលតុលាការព្រហ្មទណ្ឌអន្តរជាតិដំណើរការបានពេញលេញហើយនោះ អាចឲ្យប្រជាជាតិទាំងអស់បង្ការបាននូវអំពើឃោរឃៅទាំងឡាយប្រកបដោយប្រសិទ្ធភាពដោយផ្តន្ទាទោសអ្នកដែលបានប្រព្រឹត្តឧក្រិដ្ឋកម្មដ៏ធ្ងន់ធ្ងរបំផុតដែលភាគច្រើននៅក្នុងអតីតកាលតែងតែរួចខ្លួន និងរំលោភយ៉ាងខ្លាំងទៅលើច្បាប់មនុស្សធម៌អន្តរជាតិ "ដែលប៉ះពាល់ដល់សហគមន៍អន្តរជាតិទាំងមូល" នៅក្នុងករណីដែលរដ្ឋពាក់ព័ន្ធមិនអាចធ្វើបាន ឬគ្មានឆន្ទៈនឹងធ្វើ ។ លើសពីនេះទៅទៀតការទទួលយកនូវកាតព្វកិច្ចដោយស្ម័គ្រចិត្តរបស់រដ្ឋសមាជិកក្នុងការរួមសហការជាមួយតុលាការ នឹងដើរតួនាទីក្នុងការបង្ការយ៉ាងសំខាន់ ។

យើងរង់ចាំមើលការបកស្រាយលទ្ធផលរបស់ក្រុមអ្នកជំនាញការដ៏ឧត្តុង្គឧត្តម រយៈពេលពីរថ្ងៃខាងមុខនេះ នៅក្នុងតថភាព ។ យើងជឿជាក់ថា សន្និសីទនេះនឹងជំរុញឲ្យប្រទេសទាំងឡាយដែលមិនទាន់បានចុះហត្ថលេខាឬផ្តល់សច្ចាប័នចំពោះលក្ខន្តិកៈក្រុងរ៉ូម នឹងចូលរួមជាមួយយើងជារដ្ឋសមាជិក ហើយនឹងពង្រឹងឲ្យបណ្តាប្រទេសដែលបានរួមបង្កើតតុលាការព្រហ្មទណ្ឌអន្តរជាតិ ឲ្យបន្តបូជាកម្លាំងកាយចិត្ត ដើម្បីដាក់ឲ្យដំណើរការតុលាការនេះឲ្យបានប្រកបដោយភាពត្រឹមត្រូវនិងចីរភាព ។

ខ្ញុំសូមថ្លែងអំណរគុណប្រទេសកាណាដា អាល្លឺម៉ង់ បារាំងហូល្លង់ ណូវែលហ្សេឡង់ ស៊ុយអែដ អង្គការ No Peace Without Justice និងដៃគូរបស់យើង Center for Restorative Justice ដែលបានជួយឧបត្ថម្ភចំពោះការរៀបចំសន្និសីទនេះ ។

សូមអរគុណ ។

# ព្រាត់បងប្អូនម្ភៃប្រាំបីឆ្នាំហើយ


ប៉ាំ សុផា (បច្ចុប្បន្ន)

ខ្ញុំឈ្មោះ ប៉ាំ សុផា កើតនៅថ្ងៃទី១៥ ខែមេសា ឆ្នាំ១៩៧៣ ក្នុងស្រុកកណ្តាលស្ទឹង ខេត្តកណ្តាល ។ ឪពុកឈ្មោះ ប៉ាំ ម៉ុត ម្តាយឈ្មោះ ប៉ុល ហួន ។ នៅខែធ្នូ ឆ្នាំ១៩៧៤ ខ្ញុំមានបងស្រីពីរនាក់ កាលនោះម្នាក់មានអាយុ១៧ឆ្នាំ ម្នាក់ទៀតអាយុ១១ឆ្នាំ និងបងប្រុសម្នាក់អាយុ១៣ឆ្នាំ ។

ឪពុកម្តាយខ្ញុំស្លាប់អស់ហើយ ។ ឪពុកខ្ញុំស្លាប់នៅឆ្នាំ១៩៧៤ ។ ម្តាយខ្ញុំស្លាប់ក្រោយ ។ ខ្ញុំមិនដឹងថាម្តាយខ្ញុំស្លាប់នៅពេលណាហើយដោយមូលហេតុអ្វីឡើយ ។

ខ្ញុំសូមជម្រាបជូនបងស្រីបងប្រុសនិងញាតិសន្តានរបស់ខ្ញុំផងថា ខ្ញុំបានជួបមុខអ្នកទាំងអស់ជាលើកចុងក្រោយនៅខែធ្នូ ឆ្នាំ១៩៧៤ នៅបន្ទាយទាហានតាខ្មៅខេត្តកណ្តាល គិតមកដល់បច្ចុប្បន្នមានរយៈពេលជិតម្ភៃប្រាំបីឆ្នាំហើយ ។ កាលណោះខ្ញុំមានអាយុ២០ខែ ដូច្នេះខ្ញុំមិនអាចចាំមុខបងប្អូនបានទេ ។ ម្តាយចិញ្ចឹមខ្ញុំតែងតែប្រាប់ខ្ញុំឲ្យចេះរក្សាតម្លៃជាបងប្អូនរៀងរហូតមក ។ ខ្ញុំមិនស្គាល់ឈ្មោះបងប្អូនទាំងអស់ ព្រោះឯកសារបាត់បង់អស់ទៅហើយ ។ ខ្ញុំនៅសល់តែសំបុត្រកំណើតរបស់ខ្លួនឯងតែប៉ុណ្ណោះ ។

បច្ចុប្បន្នខ្ញុំរស់នៅប្រទេសអូស្ត្រាលី ។ ខ្ញុំមកដល់ប្រទេសអូស្ត្រាលីនៅខែកុម្ភៈ ឆ្នាំ១៩៧៥ ។ បងស្រីបងប្រុសដឹងទេថាខ្ញុំស្វែងរកអ្នកទាំងអស់គ្នាតាំងពីឆ្នាំ១៩៧៥មកម៉្លេះ ។ តាំងពីពេលដែលជនភៀសខ្លួនខ្មែរបានចាប់ផ្តើមរត់មកប្រទេសថៃម្នាក់ៗនិយាយប្រាប់នូវរឿងរ៉ាវគួរឲ្យព្រឺព្រួចរបស់គេរៀងៗខ្លួនអំពីអ្វីដែលបានកើតឡើងនៅប្រទេសកម្ពុជាក្រោមរបបប៉ុលពត ។ ប៉ុន្តែធ្វើដូចម្តេចទើបបងស្រីបងប្រុសបានដឹងអំពីខ្ញុំ? ឈ្មោះឪពុកម្តាយរបស់យើងមានបិទនៅការិយាល័យភ្នាក់ងារស្វែងរកគ្រួសារនៅតាមព្រំដែនថៃ ។ ខ្ញុំសង្ឃឹមថា បងប្រុសបងស្រីឬបងប្អូនណាម្នាក់ ប្រាកដជាឆ្លងកាត់ព្រំដែនហើយឃើញឈ្មោះខ្លួនឯងជាមិនខាន ។ ប៉ុន្តែជាអកុសល គ្មានបងប្អូនណាម្នាក់មកទេ ។ ទោះជាយ៉ាងណាក៏ខ្ញុំមិនបានបោះបង់ការព្យាយាមនេះដែរ ។

ឈ្មោះឪពុកម្តាយរបស់យើងមានបិទនៅកាកបាទក្រហមភ្នំពេញសព្វថ្ងៃនេះ ។ ម្តាយចិញ្ចឹមរបស់ខ្ញុំនិងរូបខ្ញុំផ្ទាល់បានមកប្រទេសកម្ពុជានៅខែមេសា ឆ្នាំ២០០២ ។ យើងបានឃើញសប្បុរសជនជាច្រើនដែលបានជួយរកក្រុមគ្រួសាររបស់យើង ។

តើបងស្រីបងប្រុសមានស្គាល់ខ្ញុំទេ? ពេលដែលយើងបែកគ្នាគឺនៅរដូវវស្សា ត្រូវនឹងខែធ្នូ ឆ្នាំ១៩៧៤ ។ ឥឡូវនេះខ្ញុំសូមរៀបរាប់ដំណើររឿងរបស់ខ្ញុំតាមរយៈក្រសែភ្នែករបស់ម្តាយចិញ្ចឹមខ្ញុំ ÷

“ម្តាយចិញ្ចឹមរបស់ខ្ញុំបានមកប្រទេសកម្ពុជាដើម្បីសុំក្មេងស្រីម្នាក់យកទៅចិញ្ចឹមនៅប្រទេសអូស្ត្រាលី ។ នៅពេលមកដល់ប្រទេសកម្ពុជា ម្តាយចិញ្ចឹមខ្ញុំរកមិនបានក្មេងស្រីសោះ ។ ប៉ុន្តែគឺរូបខ្ញុំនេះតែម្តងដែលគាត់មករក ។

មនុស្សដែលស្នាក់នៅជាមួយម្តាយធម៌របស់ខ្ញុំបានចេញទៅបន្ទាយទាហាននៅតាខ្មៅដើម្បីថតកុន ។ នៅតាខ្មៅ មេបញ្ជាការយោធាម្នាក់បានដើរសំដៅរថយន្តរបស់អ្នកថតភាពយន្ត ហើយបានប្រាប់អ្នកទាំងនោះថា គាត់មានគ្រួសារកំព្រាមួយ សូមឲ្យពួកគេយកគ្រួសារនោះទៅរស់នៅប្រទេសអូស្ត្រាលីផង ។ មេបញ្ជាការរូបនោះនិយាយថា ជីវិតរបស់គ្រួសារនេះលំបាកណាស់

សឹងតែមិនអាចរស់បានផង ហើយថែមទាំងមានក្មេងដែលកំពុងតែមានជំងឺ ។

គ្រួសារនោះគឺយើងទាំងបួននាក់នេះឯង ។ ខណៈនោះបងស្រីរបស់ខ្ញុំចេញទៅក្រៅ មិនបាននៅស្តាប់ការពិភាក្សានោះទេ នៅសល់តែបងប្រុសនិងរូបនាងខ្ញុំតែប៉ុណ្ណោះ ។

មានការជជែកគ្នាយ៉ាងយូរអំពីអនាគតរបស់បងប្អូនខ្ញុំទាំងអស់គ្នា ។ ពួកគេត្រូវតែបានទទួលការអនុញ្ញាតពីបងស្រីរបស់ខ្ញុំជាមុនសិនទើបអាចយកខ្ញុំទៅចិញ្ចឹមនៅអូស្ត្រាលីបាន ។ ពួកគេនឹងត្រឡប់មកបន្ទាយម្តងទៀតនៅវេលាល្ងាច ដើម្បីសុំការអនុញ្ញាតពីបងស្រីរបស់ខ្ញុំ ។

បងស្រីខ្ញុំមានការស្ទាក់ស្ទើរមិនចង់ឲ្យខ្ញុំទៅគេចិញ្ចឹម ទោះបីជាបុរសម្នាក់ទទួលបន្ទុកក្មេងកំព្រានិងអ្នកដទៃទៀតចេះតែព្យាយាមប្រាប់គាត់ថានេះជាដំណោះស្រាយដ៏ល្អយ៉ាងណាក៏ដោយ ។ គាត់មិនចង់បែកពីខ្ញុំឡើយ ។ ប៉ុន្តែ ក្រោយពីមានការបញ្ចុះបញ្ចូលច្រើនគ្នាថានេះជាផ្លូវដ៏ល្អបំផុតសម្រាប់បងប្អូនទាំងអស់គ្នារួចមក បងស្រីក៏យល់ព្រមប្រគល់ខ្ញុំឲ្យទៅគេ ព្រមទាំងប្រគល់នូវសំបុត្រកំណើតរបស់ខ្ញុំផង ។

អ្នកថតកុនគឺជាអ្នកកាសែតដែលធ្វើការជាមួយស្ថានីយ៍ទូរទស្សន៍មួយនៅសហរដ្ឋអាមេរិក ។ គាត់ក៏បានសុំឲ្យមនុស្សម្នាដែលមកមើលពពាក់ពពូននោះញាកទៅម្ខាង ទើបគាត់អាចថតកុនបាន ។ បងប្រុសខ្ញុំដែលមានការភ័យខ្លាច បានពខ្ញុំទៅឈរនៅទីមួយដែលគេឆ្ការព្រៃរួចហើយ ។ កាលនោះខ្ញុំមានអាយុ២០ខែក៏ពិតមែន ប៉ុន្តែមើលទៅដូចទើបតែមានអាយុ៦ខែតែប៉ុណ្ណោះ ។ ខ្ញុំមានរោគរលាកទងសួត ។ ខ្ញុំដកដង្ហើមថប់ៗដូចមនុស្សកើតហឺតទឹកភ្នែកហូររហាមឥតឈប់ ប្រឡាក់ប្រឡូសពេញផ្ទៃមុខ ។

កាលនោះក្មេងដែលមានអាយុលើសពី៥ឆ្នាំមិនបានទទួលការអនុញ្ញាតឲ្យចេញទៅក្រៅប្រទេសទេ ។ ក្រោយពេលពិភាក្សាគ្នាយ៉ាងយូរមក ក៏សម្រេចថាគេអាចយកខ្ញុំទៅចិញ្ចឹមនៅប្រទេសអូស្ត្រាលីបាន ។ ចំណែកបងប្រុសនិងបងស្រីរបស់ខ្ញុំត្រូវរង់ចាំពីរឬបីសប្តាហ៍ទៀតទើបបានមកភ្នំពេញ ហើយនឹងស្នាក់នៅក្នុងផ្ទះមួយសម្រាប់ក្មេងៗដែលគ្រប់គ្រងដោយជនជាតិអូស្ត្រាលីពីរនាក់ប្តីប្រពន្ធ ។ ខ្ញុំជួយធ្វើកិច្ចការនៅផ្ទះ ចំណែកឯបងប្រុសទៅសាលារៀន ។

ទំនុកបម្រុងបែបនេះចេះតែប្រព្រឹត្តទៅរហូតដល់ពេលមានរបៀបរបបធ្វើទិដ្ឋាការថ្មី ។ ពេលនោះហើយដែលបងប្អូនរបស់ខ្ញុំមានសង្ឃឹមថាអាចធ្វើដំណើរមកប្រទេសអូស្ត្រាលីដើម្បីរស់នៅជាមួយខ្ញុំ ។ ប៉ុន្តែ នៅផ្ទះសម្រាប់កុមារគ្មានកន្លែងទំនេរសម្រាប់ដាក់មនុស្សបន្ថែម ដូច្នេះបងប្អូនរបស់ខ្ញុំត្រូវរង់ចាំពីរ-បីសប្តាហ៍ទៀត ។ នៅទីនោះសុទ្ធតែកូនក្មេងដែលមានអាយុក្រោម៣ឆ្នាំកំពុងរង់ចាំទិដ្ឋាការចេញទៅប្រទេសអូស្ត្រាលី ។ លុះមានការចេញដំណើរជាបណ្តើរៗ ទើបបងស្រីបងប្រុសរបស់ខ្ញុំអាចចូលទៅស្នាក់នៅក្នុងផ្ទះនោះបាន ។ ទម្រាំតែគាត់បានចូលក្នុងផ្ទះនោះ រូបខ្ញុំបានមកដល់ប្រទេសអូស្ត្រាលីស្រេចទៅហើយ ។

ខ្ញុំដឹងថា ប្រមាណមួយសប្តាហ៍ក្រោយមក មនុស្សមកពី“ផ្ទះកុមារ”បានយកអង្ករមួយបាវមកឲ្យបងប្អូនខ្ញុំនៅបន្ទាយទាហានតាខ្មៅ ។ អ្វីៗបានប្រែប្រួលអស់រលីងដោយសារការវាយលុកដោយពួកខ្មែរក្រហមនៅថ្ងៃចូលឆ្នាំថ្មី ។ អ្នកធ្វើការនៅឯផ្ទះកុមារត្រូវតែខំប្រឹងរត់ទិដ្ឋាការឲ្យបានរហ័ស ដើម្បីចេញដំណើរឲ្យបានរួសរាន់ ។ ខ្ញុំនិងក្មេងក្នុងផ្ទះកុមារបានចាកចេញពីទីក្រុងភ្នំពេញឆ្ពោះទៅប្រទេសអូស្ត្រាលីនៅខែកុម្ភៈ ឆ្នាំ១៩៧៥ ។ ពីរសប្តាហ៍ក្រោយមក អ្នកធ្វើការនៅផ្ទះកុមារមានបំណងវិលត្រឡប់ទៅបន្ទាយទាហាននៅតាខ្មៅ និងចង់ទៅយកបងស្រីបងប្រុស

សូមសរសេរលិខិត
ឬអត្ថបទពិភាក្សាជុំវិញបញ្ហាខ្មែរក្រហម ផ្ញើមក
**ទស្សនាវដ្តី «ស្វែងរកការពិត»**
ប្រអប់សំបុត្រលេខ ១១១០ ភ្នំពេញ
ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទលេខៈ (៨៥៥) (២៣) ២១១ ៨៧៥
ទូរសារលេខៈ (៨៥៥) (២៣) ២១០ ៣៥៨
Email: dccam@bigpond.com.kh
Home page: http://welcome.to/dccam

របស់ខ្ញុំមកភ្នំពេញ ។ ជាអកុសលគ្មានថ្ងៃនោះសោះ ។ ចាប់តាំងពីពេលនោះមក ខ្ញុំវង់ចាំបងប្រុសបងស្រីជារៀងរហូត ។

ខ្ញុំគិតថា មូលហេតុមួយដែលយើងរកមិនឃើញបង១គឺថា បង១មិនដឹងថាយើងកំពុងតែស្វែងរកបង១ឡើយ ។ ម្ភៃប្រាំបីឆ្នាំក្រោយមក ខ្ញុំមិនសូវចាំរឿងរ៉ាវទាំងនោះទៀតឡើយ ។ សព្វថ្ងៃខ្ញុំមានក្រុមគ្រួសារហើយ ។ ខ្ញុំរៀបការជាមួយបុរសជនជាតិអូស្ត្រាលី និងមានកូនប្រុស៣នាក់ ។ កូនបងមានអាយុ៧ឆ្នាំ កូនបន្ទាប់អាយុ៤ឆ្នាំ និងកូនក្រោយមានអាយុ៣ឆ្នាំ ។ ខ្ញុំខិតខំចិញ្ចឹមបីបាច់កូន១ទាំងបីឲ្យមានអំនួតដែលខ្លួនជាផ្នែកមួយនៃជាតិខ្មែរ និងមានអំនួតចំពោះវប្បធម៌របស់ខ្មែរ ។

ខ្ញុំសង្ឃឹមថា បងស្រីបងប្រុសទាំងអស់កំពុងតែរស់នៅប្រទេសកម្ពុជា ហើយបានមើលអត្ថបទដែលខ្ញុំសរសេរនេះ បើមិនបានឃើញខ្លួនឯងក៏មិត្តភក្តិប្រាប់ដែរ ។ ធ្វើដូច្នេះទើបខ្ញុំអាចរកឃើញនូវគ្រួសាររបស់ខ្ញុំ អតីតកាលរបស់ខ្ញុំ និងដឹងអំពីដីដូនដីតារបស់ខ្ញុំ ។ ម្តាយចិញ្ចឹមរបស់ខ្ញុំបានដាក់ឈ្មោះឲ្យខ្ញុំទៅតាមខេត្តដែលខ្ញុំកើត គឺខេត្តកណ្តាល ។ ដូច្នេះឈ្មោះខ្ញុំសព្វថ្ងៃគឺ «កណ្តាល រ៉ូប៊ីនសុន សំប្រ៊ុក» ។

**ជាំ សុផា**

# រំពុកឡើងវិញដើម្បីការពារ

សូមថ្លែងអំណរគុណដល់សហការីរបស់ទស្សនាវដ្តីស្វែងរកការពិត ។ ខ្ញុំបាទបានទទួលអំណោយទស្សនាវដ្តីចំនួន២ក្បាល លេខ២៦ លេខ២៩ ខែឧសភា ឆ្នាំ២០០២ ។ ក្រោយពីបានអាន ទស្សនាវដ្តីនេះពិតជាមានខ្លឹមសារដ៏ល្អ ធ្វើឲ្យយើងខ្ញុំក៏ដូចជាប្រជាជនកម្ពុជានៅក្នុងភូមិកំពង់ទ្រា ឃុំទ្រា ដែលឆ្លងក្នុងរបបខ្មែរក្រហម នឹកឡើងវិញដែលឃោរឃៅព្រៃផ្សៃ ។ ខ្ញុំសង្ឃឹមថាតទៅទៀត រដ្ឋាភិបាលពិតជាមិនព្រងើយកន្តើយឲ្យរបបខ្មែរក្រហមវិលមកជាលើកទី២ ។

ខ្ញុំគិតថា ទស្សនាវដ្តីស្វែងរកការពិតរបស់មជ្ឈមណ្ឌលឯកសារកម្ពុជាមានសារសំខាន់សម្រាប់ខ្ញុំផ្ទាល់ក៏ដូចជាការស្រាវជ្រាវឯកសារការពិតក្នុងរបបខ្មែរក្រហម ការរងទុក្ខវេទនារបស់ប្រជាជនកម្ពុជាដែលបានឆ្លងកាត់ក្នុងរបបខ្មែរក្រហម ទុកជាប្រវត្តិសាស្ត្រកម្ពុជា ។ ការពិតមានសារសំខាន់ដូចជា ឈ្មោះ គឹម ទន ហៅ ទុយ ខ្ញុំពុំដឹងថាឈ្មោះនេះធ្វើកងទ័ពខ្មែរក្រហមកាលពីឆ្នាំ ១៩៧៣ ហើយដឹងថាឈ្មោះមានឋានៈជាអ្នកសួរចម្លើយនៅមន្ទីរ ស-២១ ទើបបានដឹងពីទស្សនាវដ្តីស្វែងរកការពិត ព្រមទាំងសហការីរបស់លោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាចុះទៅភូមិខ្ញុំផ្ទាល់ ។ ឈ្មោះ គឹម ទន ហៅ ទុយ ពិតជានៅភូមិកំពង់ទ្រា ឃុំទ្រា ស្រុកសំរោង ខេត្តតាកែវ ពិតមែន ។ ចំពោះប្រជាជនក៏យល់ដូចខ្ញុំដែរ ។

ខ្ញុំសូមបន្ថែមឲ្យលោកប្រធានមជ្ឈមណ្ឌលឯកសារកម្ពុជាស្វែងរកការពិតស្រាវជ្រាវឯភូមិ ឃុំ ស្រុក ខេត្ត ពីការរងទុក្ខវេទនារបស់ប្រជាជននៅតាមសហករណ៍ កងចល័ត ។ សូមចែកទស្សនាវដ្តីមកដល់តាមភូមិ ដើម្បីឲ្យប្រជាជនបានអានបានយល់ពិតពីទស្សនាវដ្តីស្វែងរកការពិត ។



សូមលោកប្រធានទទួលនូវក្តីគោរពពីខ្ញុំបាទដ៏ខ្ពង់ខ្ពស់ ។

មេភូមិកំពង់ទ្រា ថ្ងៃទី១៩-៩-២០០២

**ឈន សែត**

# ពិពណ៌រូបថតនៅសារមន្ទីរឧក្រិដ្ឋកម្មប្រល័យពូជសាសន៍ទួលស្លែង





## ជនរងគ្រោះនៃប្រវត្តិសាស្ត្រ សំឡេងជនរងគ្រោះនិងជនដៃដល់ នៃរបបខ្មែរក្រហម

*ដើម្បីឧបត្ថម្ភការបោះពុម្ពនិងចែកចាយដោយឥតគិតថ្លៃដល់មន្ទីរស្រុកនិងឃុំនៅទូទាំងព្រះរាជាណាចក្រកម្ពុជា*
*ទស្សនាវដ្តីចំនួន១០០០ច្បាប់ជារៀងរាល់លេខនឹងដាក់លក់តែនៅក្នុងរាជធានីភ្នំពេញប៉ុណ្ណោះ មួយច្បាប់ក្នុងតម្លៃ ៧០០០រៀល*

*មជ្ឈមណ្ឌលឯកសារកម្ពុជាអំពាវនាវដល់រដ្ឋាភិបាល មូលនិធិនានា និងសាធារណជនគ្រប់រូប សូមជួយឧបត្ថម្ភការបោះពុម្ពផ្សាយទស្សនាវដ្តីនេះទៅតាមលទ្ធភាពដែលអាចធ្វើបាន។ ព័ត៌មានបន្ថែមចំពោះការបោះពុម្ពផ្សាយទស្សនាវដ្តីស្វែងរកការពិត សូមមេត្តាទាក់ទងមកកាន់នាយកមជ្ឈមណ្ឌលឯកសារកម្ពុជាតាមទូរស័ព្ទលេខ (៨៥៥) ២៣ ២១១ ៨៧៥ ។ សូមអរគុណ!*

The Documentation Center of Cambodia would like to appeal to governments, foundations and individuals for support of the publication of Searching for the Truth!. For contribution, please contact (855) 23 211 875 or By Email: dccam@bigpond.com.kh. Thank you.

A magazine of the Documentation Center of Cambodia: *Searching for the truth*. Number 34, October 2002.
Funded by the Royal Ministry of Foreign Affairs, Oslo, Norway, Section for the Human Rights and Humanitarian Assistance; Canadian International Development Agency (CIDA) through the Civil Society Fund; the Royal Danish Government and the Royal Netherlands Government, *The Hague*.